# ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២១

## រាជរដ្ឋាភិបាលកម្ពុជា សម្រេចកែលម្អលក្ខណសម្បត្តិគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» មាន៧ចំណុច

http://btv.com.kh/ 30/01/2021

ភ្នំពេញ ៖ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។ ដើម្បីឆ្លើយតបទៅ នឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឲ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលំអលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះ ជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

ទី១-បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឲ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

ទី២-កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ដោយបំផុសឲ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

សូមជម្រាបថា លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» មានដូចជា ៖

ទី១-ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

ទី២-គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ទី៣-មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

ទី៤-គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

ទី៥-ដោះស្រាយវិធានការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ទី៦-មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។

និងទី៧-ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៕

## សូមបន្តទប់ស្កាត់ពលករចំណាកស្រុក ដើម្បីបង្ការកូវីដ១៩

https://kohsantepheapdaily.com.kh/ Banteay Meanchey ៣១ ខែ មករា ឆ្នាំ ២០២១ ម៉ោង ២០:៥៧

ខេត្តបន្ទាយមានជ័យ៖ មេបញ្ជាការកងទ័ពជើងគោក បានក្រើនរំលឹកដល់កងកម្លាំង ដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវបង្កើនការយកចិត្តទុកដាក់ ទប់ស្កាត់ពលករចំណាកស្រុក ដើម្បីបង្ការ និងទប់ស្កាត់កូវីដ១៩។ លោកមេបញ្ជាការ បានលើកឡើងដូច្នេះ ក្នុងឱកាស ដែលលោកបំពេញការងារ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ នៅបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនគោក លេខ៥០៣ ក្នុងទិសទីមួយ ខេត្តបន្ទាយមានជ័យ។ លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងមេបញ្ជាការកងទ័ពជើងគោក បានលើកឡើងថា កងកម្លាំង ដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវយកចិត្តទុកដាក់ការពារបូរណភាពទឹកដី និងចូលរួមទប់ស្កាត់អោយបាននូវពលករចំណាកស្រុកខុសច្បាប់ ដែលលួចឆ្លងដែន ដោយល្មើសច្បាប់ ការពារសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋ និងបង្ការ ទប់ស្កាត់កូវីដ១៩ ដើម្បីអនុវត្តអោយបានតាមការណែនាំរបស់ក្រសួងសុខាភិបាល។

លោកបានបញ្ជាក់ថា ជាការខិតខំប្រឹងប្រែងពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសុខាភិបាល បានខិតខំយកចិត្តទុកដាក់បង្ការ ទប់ស្កាត់កូវីដ១៩ ហើយពង្រឹងការត្រួតពិនិត្យ និងធ្វើចត្តាឡីស័កដល់ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ។ លោក ហ៊ុន ម៉ាណែត បានកោតសសើរ ចំពោះការខិតខំប្រឹងប្រែងរបស់អភិបាលខេត្តបន្ទាយមានជ័យ និងមន្ត្រីស្ថាប័នពាក់ព័ន្ធ និងកងកម្លាំង ដែលសហការគ្នាល្អ ដែលទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ និងទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃ។ ពលករមកពីថៃ ត្រូវទទួលយកទៅដាក់នៅមណ្ឌលធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ដែលត្រូវបានអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងឱកាសនោះ លោក ហ៊ុន ម៉ាណែត ក៏បានផ្តល់អគារស្នាក់នៅដល់កងល្បាតទី៣ ចំនួន១ខ្នង ឃ្លាំងអាវុធ ១ខ្នង រថយន្តសង្គ្រោះ ១គ្រឿង និងអគារស្នាក់នៅរបស់កងល្បាតទី២ ចំនួន ១ខ្នង និងវិទ្យុទាក់ទងលើតុចំនួន ៨គ្រឿង វិទ្យុទាក់ទងកាន់ដៃ ២០គ្រឿង ផ្ទាំងសូឡា ៥០ផ្ទាំង និងឧបត្ថម្ភថវិកាដល់បញ្ជាការដ្ឋានកងការពារព្រំដែនគោកលេខ ៥០៣ ចំនួន ១០លានរៀល និងថវិកាកងល្បាតទាំង ៧ ចំនួន ៥០លានរៀល៕ ដោយ៖ ប៊ុន ធឿន

## ឧត្តមសេនីយ៍ត្រី សឿន សេន អញ្ជើញចូលរួមពិធីបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពី "យុត្តិធម៌អនីតិជន និង កិច្ចការពារកុមារ"

http://cambodiapolice.com/policekh/ 5:10 pm 29 មករា 2021

សៀមរាប ៖ នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី សឿន សេន ស្នងការរងទទួលផែនការងារសេនាធិការ តំណាងលោកឧត្តមសេនីយ៍ទោ ទិត្យ ណារ៉ុង ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពី "យុត្តិធម៌អនីតិជន និង កិច្ចការពារកុមារ" នៅសាលាស្រុកពួក ។

ក្នុងពិធីនោះ មានការអញ្ជើញចូលរួមពីលោក ថេង សំណាង ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តសៀមរាប លោក ស៊ីន ចាន់ថុល អភិបាលស្រុកពួក, លោកស្រី ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស, លោក វរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, លោក វរសេនីយ៍ឯក ទុំ សុក្រ៍ នាយការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល និងលោក វរសេនីយ៍ឯក ស្រី យូរ៉ា មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តសៀមរាប និងមានការសម្របសម្រួលពីលោក ផង់ ចិន្តា អង្គការជីវិតនៅកម្ពុជា ព្រមទាំងលោកអធិការ-អធិការរង លោកនាយផ្នែក លោកនាយ-នាយរងប៉ុស្តិ៍ និងមន្ត្រី

នគរបាល មកពីអធិការដ្ឋានស្រុកចំនួន ០៣ ( អធិការដ្ឋាននគរបាលពួក ស្រុកអង្គរធំ និងស្រុកវ៉ារិន សរុបចំនួន ៨៥នាក់ ស្រី ០៣នាក់ និងកងរាជអាវុធហត្ថចំនួន ០៨នាក់ ។

លោកឧត្តមសេនីយ៍ត្រីស្នងការរង បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះ គឺដើម្បីធ្វើបទបង្ហាញ និងពន្យល់ជូនដល់សិក្ខាកាម មានដូចជា៖

១. តួនាទី និងភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់

២. ការអនុវត្ត គោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព"

៣.ការអនុវត្ត គោលការណ៍វាយតម្លៃអំពីចំណាត់ថ្នាក់ប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព"

៤.ការអនុវត្ត គោលការណ៍វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាល

៥.ការអនុវត្ត ការងារនគរបាល និងសហគមន៍

៦.នីតិវិធីសម្ភាសន៍បែបកុមារមេត្រី

៧.ច្បាប់ ស្តីពី យុត្តិធម៌អនីតិជន កិច្ចការពារកុមារ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២១

(សៀមរាប)៖ នៅថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៥នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារា ៤នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ 2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣១នាក់ ស្រី ១២នាក់ កុមារា ២នាក់ កុមារី ២នាក់។ 3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២២នាក់ ស្រី ៩នាក់ កុមារា ២នាក់ កុមារី ១នាក់។ 4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១២នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ 5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៦៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥៣នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យ ចំនួន ១២នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ប្រភព: ក្រុមការងារប្រចាំការរបស់រដ្ឋបាលខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

# ក្រសួងសង្គមកិច្ច ចុះពង្រឹង និងពិនិត្យការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងពលករមកពីប្រទេសថៃ តាមខេត្តជាប់ព្រំដែន

http://m.freshnewsasia.com/ 2021-01-29 02:39pm

**(បន្ទាយមានជ័យ)៖** នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១នេះ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រី និងមានការចូលរួមពីអភិបាលរងខេត្ត ក្រុមការងារការពារ ជនរងគ្រោះ និងអន្តរក្រសួង បានចុះត្រួតពិនិត្យមើលការគ្រប់គ្រងស្ថានភាព ការទទួលជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើរជួញដូរមនុស្ស និងពលករដែលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិ ខេត្តបន្ទាយមានជ័យ។ ទីតាំងច្រកទ្វារអន្តរជាតិដែលសំខាន់ៗ រួមមាន៖ ច្រកប៉ោយប៉ែត, ច្រកអូរបីជាន់, ច្រកបឹងត្រកួន និងច្រកម៉ាឡៃ។

ដើម្បីពង្រឹងការគ្រប់គ្រងស្ថានភាព មេរោគរាតត្បាតកូវីដ១៩ តាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ដែលមានការចូលរួម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងសុខាភិបាល និងអភិបាលរងខេត្តទាំង៣ ព្រមទាំងបានផ្តល់ម៉ាស និងជែល ដល់ក្រុមការងារផងដែរ។

សូមជម្រាបថា គិតត្រឹមម៉ោង៧៖០០នាទីព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១នេះ កម្ពុជារកឃើញអ្នកឆ្លងកូវីដ១៩ សរុបចំនួន ៤៦៣នាក់ ក្នុងនោះអ្នកជំងឺព្យាបាលជាសះស្បើយចំនួន ៤៣៨នាក់ និងអ្នកជំងឺកំពុងសម្រាកនៅមន្ទីរពេទ្យចំនួន ២៥នាក់៕

# អង្គការធ្វើការផ្នែកកុមារ រកឃើញករណីរំលោភផ្លូវភេទលើកុមារាច្រើនជាងកុមារី

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 29 January 2021 | 10:22 ICT

**ភ្នំពេញ៖** អង្គការធ្វើការងារផ្នែកកុមារ រកឃើញករណីរំលោភបំពានផ្លូវភេទលើកុមារាមានការកើតឡើងច្រើនជាងកុមារីនៅក្នុងប្រទេសកម្ពុជា ពិសេសនាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប៉ុន្តែការផ្សព្វផ្សាយការយល់ដឹងរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាលើបញ្ហានេះនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ។

នាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីកុមារ (APLE) លោក សំលៀង សីលា ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ កាលពីថ្ងៃទី ២៧ មករា ថា ករណីរំលោភបំពានផ្លូវភេទលើកុមារា កាលពីប្រមាណ ៤ ឆ្នាំមុន ភាគីពាក់ព័ន្ធមិនសូវបានលើកយកមកពិភាក្សា ផ្សព្វផ្សាយឱ្យបានទូលំទូលាយទេ ហើយការយល់ដឹងក៏មានកម្រិតទាប។ ប៉ុន្តែបច្ចុប្បន្នពិសេសក្នុងពេលថ្មីៗនេះតាមរយៈការផ្សព្វផ្សាយ និងបណ្តុះបណ្តាលរបស់អង្គការ និងក្រសួងពាក់ព័ន្ធចំណេះដឹងអំពីបញ្ហានេះ មានការកើនឡើង។ បើតាមលោក សីលា ការរំលោភបំពានផ្លូវភេទលើកុមារាសម្រាប់ទិន្នន័យដែលអង្គការ APLE ទទួលបានគឺមានច្រើនជាងការរំលោភបំពានលើក្មេងស្រី។ ទិន្នន័យដែលអង្គការទទួលបាននេះ គឺប្រព្រឹត្តឡើងដោយជនដែលធ្វើដំណើរ ឬអ្នកទេសចរ ពិសេសជនបរទេស។ លោកថ្លែងថា៖ «អ្វីដែលជាបញ្ហា គឺការផ្តល់សេវាសម្រាប់កុមារា ព្រោះនៅកម្ពុជាមិនទាន់មានការផ្តល់សេវាដល់កុមារាដូចកុមារីទេ។ វិធីនៃការផ្តល់សេវាដូចជាតើកុមារារងគ្រោះត្រូវការអ្វី ហើយរបៀបនៃការផ្តល់សេវាដល់ក្មេងប្រុសត្រូវមានបែបបទយ៉ាងម៉េចនោះក៏មិនទាន់បានល្អដែរ គឺស្ថិតនៅក្នុងដំណាក់កាលនៃការរៀនសូត្រនៅឡើយ»។

លោកបញ្ជាក់ថា៖ «តួលេខរបស់យើង បើគិតពីឆ្នាំ ២០០៣ រហូតដល់ឆ្នាំ ២០២០ ចំពោះករណីរំលោភបំពានផ្លូវភេទលើកុមារដោយអ្នកទេសចរ ឬអ្នកធ្វើដំណើរដែលភាគច្រើនជាជនបរទេសក្នុងនោះបានកើតឡើងលើកុមារាជាមធ្យមមានចំនួន ៥៦% ចំណែកកុមារីមានតែ ៤៤% ទេ ក្នុងចំណោមករណីរំលោភបំពានផ្លូវភេទលើកុមារជាង ៩៨០ នាក់»។ លោក សីលា អះអាងថាករណីរំលោភផ្លូវភេទលើកុមារាកាលពីប្រមាណ ៥ ឆ្នាំមុនមិនសូវកើត

មានឡើងទេ គឺជាករណីដែលកម្រ។ ប៉ុន្តែនាប៉ុន្មានឆ្នាំចុងក្រោយនេះមានការកើនឡើងហើយជាចំនួនមួយដែលគួរឱ្យព្រួយបារម្ភផងដែរទាក់ទងនឹងជនជាតិខ្មែរ រំលោភទៅលើក្មេងប្រុស។

លោក យួន សារ៉ាត់ ប្រធានគ្រប់គ្រងកម្មវិធីនៃអង្គការជំហានដំបូងកម្ពុជា ប្រាប់ភ្នំពេញប៉ុស្តិ៍ ពីថ្ងៃទី ២៧ មករា ថា តាំងពីចាប់ផ្តើមធ្វើការលើករណីរំលោភបំពានផ្លូវភេទលើកុមារានៅកម្ពុជាពីឆ្នាំ២០១០ ដល់ ២០២០ មានករណីសរុប ៨៣០ ទាំងកុមារា និងកុមារី។ ករណីដែលកើតឡើងលើកុមារាស្ថិតក្នុងវ័យ ចាប់ពី ៨ ដល់ ១៧ ឆ្នាំ។ លោកថ្លែងថា៖ «ជាទូទៅកុមារទាំងអស់សុទ្ធតែប្រឈមក្នុងការទទួលរងការរំលោភបំពានផ្លូវភេទប្រសិនបើមិនមានអ្នកមើលថែជាប់លាប់ និងអ្នកមើលថែមិនមានចំណេះដឹងអំពីការរំលោភបំពានផ្លូវភេទ។ ជាពិសេសកុមារដែលទទួលរងការរំលោភបំពានផ្លូវភេទនោះ គឺកុមារដែលត្រូវបានឳពុកម្តាយ និងអ្នកមើលថែបណ្តោយមិនសូវយកចិត្តទុកដាក់មើលថែកូនៗនិងទុកចិត្តអ្នកដទៃពេកមិនចាប់អារម្មណ៍ចំពោះប្រវត្តិរបស់អ្នកនោះ»។ បើតាមលោក សារ៉ាត់ អង្គការជំហានដំបូងកម្ពុជាកំពុងធ្វើការងារលើការបណ្តុះបណ្តាលតាមរយៈការបើកវគ្គសិក្ខាសាលា ស្តីអំពីការការពារកុមារពីការរំលោភបំពានផ្លូវភេទនៅតាមសហគមន៍ មណ្ឌលរបស់អង្គការនានា។ វគ្គបណ្តុះបណ្តាលដល់បុគ្គលិក រដ្ឋាភិបាល និងអង្គការនានា។ កសាងបណ្តាញជាមួយរដ្ឋាភិបាល អង្គការ និងសាលានានា និងផ្សព្វផ្សាយតាមរយៈវិទ្យុជាដើម។ លោកឱ្យដឹងថា អង្គការជំហានដំបូងកម្ពុជាបាននិងកំពុងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលកម្ពុជាមានដូចជា ក្រសួងសង្គមកិច្ច ក្រសួងមហាផ្ទៃក្រសួងកិច្ចការនារី ក្រសួងអប់រំ ក្នុងការផ្តល់សេវាសម្រាប់អតិថិជន ហើយក៏សហការជាមួយអាជ្ញាធរនៅតាមមូលដ្ឋានជាច្រើនផងដែរ។

លោក គួច ចាន់នី មន្ត្រីនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលស្គាល់ថា ករណីរំលោភបំពានផ្លូវភេទលើកុមារាពិតជាកើតមានឡើងនៅប្រទេសកម្ពុជា ប៉ុន្តែករណីដែលកើតឡើងភាគច្រើន ជាជនបរទេសមកទេសចរណ៍នៅកម្ពុជា។ លោកថ្លែងថា៖ «យើងមិនអាចកំណត់បានថា ករណីរំលោភបំពានផ្លូវភេទលើកុមារានេះ កើតឡើងច្រើននៅក្នុងពេលណាទេ គឺករណីនេះបានកើតឡើងច្រើនឆ្នាំកន្លងមកហើយ ឥឡូវក៏នៅតែមានកើតឡើង»។ ក្រសួងសង្គមកិច្ចមានគោលជំហរ មិនអាចបណ្តែតបណ្តោយឱ្យសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារា កើតមានឡើងទៀតទេ។ បច្ចុប្បន្នក្រសួងមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សកំពុងធ្វើការងារនេះដោយសហការជាមួយអង្គការដៃគូពាក់ព័ន្ធទាំងអស់។ នេះបើតាមការអះអាងរបស់លោក ចាន់នី។

អង្គការជំហានដំបូងកម្ពុជាកាលពីពេលថ្មីៗនេះចេញផ្សាយអត្ថបទមួយក្រោមចំណងជើងថា ការរំលោភបំពានលើកុមារ «វាកើតឡើងលើកុមារាផងដែរ»។ អង្គការនេះថា ប្រសិនបើអ្នកសួរមនុស្ស ១០ នាក់ដោយចៃដន្យពីការគិតរបស់ពួកគេនៅពេលនិយាយអំពីការរំលោភបំពានផ្លូវភេទកុមារ និងជនរងគ្រោះ ស្វ័យប្រវត្តិចម្លើយ គឺប្រាកដជាជនរងគ្រោះដោយការរំលោភបំពាន គឺជាកុមារី។ បើតាមអង្គការនេះកុមារាទទួលរងការរំលោភបំពានផ្លូវភេទដូចកុមារីដែរ (យ៉ាងហោចណាស់ ៥% នៃកុមារនៅក្នុងប្រទេសកម្ពុជា)។ ប៉ុន្តែសម្រាប់ហេតុផលជាច្រើនករណីកុមារនេះស្ទើរតែមិនត្រូវបានរាយការណ៍។ (៦% នៃករណីរំលោភបំពានផ្លូវភេទកុមារាត្រូវបានរាយការណ៍) បើប្រៀបធៀបទៅនឹងការរំលោភបំពានផ្លូវភេទកុមារី ៤០% ត្រូវបានរាយការណ៍។ នេះបើតាមការស្រាវជ្រាវរបស់ UNICEF ឆ្នាំ ២០១២ និង ២០១៤។ អង្គការជំហានដំបូងកម្ពុជាបានអះអាងថា កំពុងធ្វើការនៅតាមមូលដ្ឋានលើបញ្ហានេះដើម្បីស្វែងរកយុត្តិធម៌ឱ្យកុមារចំពោះបញ្ហាដែលកប់ទុកគ្មានគេនិយាយ គ្មានអ្នកណាដឹង និងគ្មានអ្នកស្តាប់។ ប៉ុន្តែវាបានធ្វើឱ្យកុមារជាច្រើនឈឺចាប់ និងរងរបួសផ្លូវចិត្ត ជាពិសេសចំពោះកុមារាតែម្តង៕

## បុរសជនជាតិបារាំងចោទប្រកាន់ពីបទរំលោភផ្លូវភេទលើកុមារខ្មែរ និងនេប៉ាល់

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2021-01-30

តុលាការបារាំងបង្គាប់ឱ្យបើកសវនាការជំនុំជម្រះទណ្ឌិតបារាំងម្នាក់ឡើងវិញ ដែលរងការចោទប្រកាន់ថា បានរំលោភផ្លូវភេទលើកុមារខ្មែរ និងនេប៉ាល់ (Nepal) ជាច្រើននាក់ តាមរយៈសមាគមសាមគ្គី ហ្វីលមី (Philmy) របស់លោក។ ទីភ្នាក់ងារព័ត៌មានបារាំងអា.អេហ្វ.ប៉េ (AFP) កាលពីថ្ងៃទី២៩ ខែមករា ឱ្យដឹងថា ទណ្ឌិត ហ្វីលីព ហ្សឺរ៉ាដ (Philippe Gerard) អាយុ៥១ ឆ្នាំ ត្រូវបានតុលាការបារាំង សម្រេចឱ្យបើកការជំនុំជម្រះសាជាថ្មីទៀត ពីបទចោទប្រកាន់ថា បានរំលោភផ្លូវភេទលើកុមារខ្មែរ៩នាក់ និងកុមារនេប៉ាល់១៥នាក់ ដែលមានអាយុចន្លោះពី ៦ឆ្នាំ ដល់ ១៤ ឆ្នាំ កាលពីអំឡុងឆ្នាំ២០១១ ដល់ ឆ្នាំ២០១៥។ ជនជាប់ចោទរូបនេះ បានបដិសេធចំពោះការចោទប្រកាន់ទាំងនេះ ប៉ុន្តែក្រោយមកក៏បានសារភាពនៅចំពោះមុខចៅក្រមស៊ើបអង្កេតសាកសួរ។ ចំណែកមេធាវីការពារក្តី ទណ្ឌិត ហ្វីលីព ហ្សឺរ៉ាដ បដិសេធមិនឆ្លើយបញ្ជាក់ពីករណីចោទប្រកាន់នេះទេ។ ក៏ប៉ុន្តែប្រសិនបើតុលាការរកឃើញកំហុសពិតមែន ជនល្មើសរូបនេះនឹងប្រឈមការជាប់ពន្ធនាគារចំនួន ២០ឆ្នាំ។ លោក ហ្វីលីព ហ្សឺរ៉ាដ ធ្លាប់ត្រូវបានតុលាការនៅទីក្រុងតុងនុន (Thonon) ស្ថិតនៅតំបន់ភាគខាងកើតប្រទេសបារាំង បានកាត់ទោស ឱ្យជាប់ពន្ធនាគារ៣ឆ្នាំ និងព្យួរទោស១៨ខែ កាលពីឆ្នាំ ២០០៥ ក្រោមបទចោទថា បានរំលោភកុមារបារាំង នៅជំរំវិស្សមកាល។ ក្រោយពីបានដោះលែងមកជនសង្ស័យ រូបនេះ ក៏បានទៅប្រទេសនេប៉ាល់ និងប្រទេសកម្ពុជា ដោយបង្កើតអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានការជួយឧបត្ថម្ភថវិកា ពីក្រុមគ្រួសារនិងមិត្តភក្តិ៕

## មន្ត្រីសិទ្ធិការងារយល់ថា ពលករចំណាកស្រុកនៅតែចាញ់បោកមេខ្យល់ និងប្រថុយប្រថានទៅធ្វើការ

https://www.rfa.org/khmer/ ដោយ ខែ សុណង 2021-01-29

មន្ត្រីសិទ្ធិការងារយល់ថា ពលករចំណាកស្រុកនៅតែចាញ់បោកមេខ្យល់ និងប្រថុយប្រថានទៅធ្វើការខុសច្បាប់នៅប្រទេសម៉ាឡេស៊ី (Malaysia) គឺដោយសាររដ្ឋាភិបាលមិនបានយកបញ្ហានេះជាអាទិភាពក្នុងការដោះស្រាយ។ មន្ត្រីជាន់ខ្ពស់អង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា ថ្លែងថា ដោយសារបញ្ហាអំពើពុករលួយជាប្រព័ន្ធនេះជាប្រភពសំខាន់នាំឱ្យមានការជួញដូរកម្លាំងពលកម្ម និងការលួចលាក់នាំពលរដ្ឋចេញទៅធ្វើការខុសច្បាប់ ចេះតែបន្តកើតមានឡើងដដែលៗ ឥតស្រាកស្រាន្ត។ លោកថា រដ្ឋាភិបាលនឹងស្ថាប័នពាក់ព័ន្ធគួរយកបញ្ហានេះជារឿងអាទិភាព ពីព្រោះជនល្មើសភាគច្រើនជាមុខសញ្ញាដដែលៗ ហើយក៏មិនមែនជាពលរដ្ឋសាមញ្ញដែលហ៊ានរកស៊ីជួញដូរមនុស្សដែរ៖ «ទោះដឹងថា មានមេខ្យល់នៅត្រង់ណាក៏ដោយប្រសិទ្ធភាពនៃការចាត់វិធានការមិនសូវម៉ឺងម៉ាត់ឱ្យមានប្រសិទ្ធភាពនៅតែគិតថា វាដូចជារឿងសាមញ្ញ ជារឿងធម្មតាអ៊ីចឹងទៅ មិនបានគិតថា វាជាកិត្យានុភាពជាតិ វាជាមុខមាត់ជាតិ ជាបញ្ហារបស់ប្រជាពលរដ្ឋនៅស្រុកខ្មែរនេះ ជនអ្នកប្រព្រឹត្តបទល្មើសបើសិនជាគេចង់ចាប់មិនលើសពី២នាទីទេ គេចាប់បានហើយ ចុះមេខ្យល់ច្រងោៗ ដដែលៗ ចេញពីប្រភពដដែលៗម៉េចមិនចាប់»។ ការលើកឡើងនេះ បន្ទាប់ពីអាជ្ញាធរកម្ពុជាបានអន្តរាគមន៍បញ្ជូនពលករខ្មែរចំនួន ៦នាក់ និងទារកម្នាក់ មកកម្ពុជាវិញ។

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង បានឱ្យដឹងថា អ្នកទាំងនេះ ដែលចាញ់បោកមេខ្យល់ឆ្លងដែនទៅធ្វើការខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ស្ថានទូតខ្មែរបានរៀបចំឯកសារទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី ដើម្បីបញ្ជូនពួកគេទៅធ្វើតេស្តរកជំងឺកូវីដ-១៩ និងជូនពួកគេទៅព្រលានយន្ត

ហោះត្រឡប់មកកម្ពុជា នៅល្ងាចថ្ងៃទី២៧ មករា។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី ២៧ ខែមករា ក៏បានអំពាវនាវដល់ពលករខ្មែរ ឱ្យឈប់ចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់តទៅទៀត៕

## ស្ត្រីខ្មែរម្នាក់ដែលត្រូវមេខ្យល់ឆបោកឲ្យទៅរៀបការប្ដីចិន ហើយបង្ខាំងបិទសិទ្ធិសេរីភាពក្នុងការរស់នៅ ត្រូវបានអាជ្ញាធរកម្ពុជា ជួយសង្គ្រោះត្រឡប់មកប្រទេសកម្ពុជាវិញ

https://khmernote.com.kh/ January 29, 2021 srey nuch

រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា ស្ត្រីជនជាតិខ្មែរម្នាក់ដែលបានសរសេរសារបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកថា នាងត្រូវបានមេខ្យល់ឆបោកឲ្យទៅរៀបការជាមួយប្តីជនជាតិចិន ហើយត្រូវបានគេបង្ខាំងបិទសេរីភាពក្នុងការរស់នៅ និងបានទទួចស្នើសុំឲ្យអាជ្ញាធរកម្ពុជាជួយអន្តរាគមន៍នាំមកប្រទេសកម្ពុជានោះ ត្រូវបានត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាវិញហើយ ប៉ុន្តែរូបនាងកំពុងតែអនុវត្តវិធានចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័ករាជធានីភ្នំពេញ។

សូមរំឭកថា នៅរសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០ ឯកឧត្តម ជីវ ផល្លី បានបញ្ជាក់ឲ្យដឹងថា ស្ត្រីជនជាតិខ្មែរម្នាក់ដែលបានសរសេរសារបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកថា នាងត្រូវបានមេខ្យល់ឆបោកឲ្យទៅរៀបការជាមួយប្តីជនជាតិចិន ហើយត្រូវបានគេបង្ខាំងបិទសេរីភាពក្នុងការរស់នៅ និងបានទទួចស្នើសុំឲ្យអាជ្ញាធរកម្ពុជាជួយអន្តរាគមន៍នាំមកប្រទេសកម្ពុជានោះ ត្រូវបានរកឃើញហើយ និងបានបញ្ជូនទៅអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសចិន ដើម្បីអនុវត្តនីតិវិធីធ្វើបត្យាប័នមកកម្ពុជាវិញ។ ឯកឧត្តមបានបញ្ជាក់បន្ថែមថា ការទទួលជោគជ័យក្នុងការស្រាវជ្រាវស្វែងរកអាសយដ្ឋានស្នាក់នៅឯប្រទេសចិនរបស់នារីរងគ្រោះខាងលើ និងបានធ្វើការសង្គ្រោះនោះ គឺបានទទួលកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងអាជ្ញាធរចិន និងអាជ្ញាធរកម្ពុជា។ ឯកឧត្តម ជីវ ផល្លី បានបញ្ជាក់បន្ថែមថា កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានទទួលព័ត៌មានពីក្រុមការងារប្រតិកម្មរហ័សរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធនឹងការចុះផ្សាយលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក របស់គណនីឈ្មោះ វាសនាកូនស្រីទី៤ ដោយបានសរសេរខ្លឹមសារបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមថា ពុំមានសេរីភាពក្នុងការរស់នៅ បន្ទាប់ពីចាញ់បោកមេខ្យល់រៀបការប្តីជនជាតិចិន និងទទួចសំណូមពរឲ្យអាជ្ញាធរកម្ពុជាអន្តរាគមន៍ជួយសង្គ្រោះត្រឡប់មករស់នៅប្រទេសកម្ពុជាវិញ។ ក្នុងខ្លឹមសារសំណេរបញ្ជាក់ថា នាងមានឈ្មោះ ធួក សុភី អាយុ ២០ ឆ្នាំ នៅភូមិឃ្សឹបក្រៅ ឃុំឃ្សឹបក្រៅ ស្រុកស្នួល ខេត្តក្រចេះ។

អនុវត្តតាមមតិចង្អុលដឹកនាំរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម លោកជំទាវ អគ្គស្នងការរងទទួលផែនការងារជំនាញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ កម្លាំងជំនាញរបស់នាយកដ្ឋាន បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តក្រចេះ ធ្វើការស្រាវជ្រាវស្វែងរកឃើញសាច់ញាតិ និងសាកសួរព័ត៌មានលម្អិត ដើម្បីធ្វើការស្រាវជ្រាវ និងកំណត់អត្តសញ្ញាណមេខ្យល់ ព្រមទាំងបានស្របសម្រួលឱ្យម្តាយនារីរងគ្រោះមកដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា នាយកដ្ឋានបានសហការជាមួយក្រុមលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកតម្រុយ និងទីកន្លែងស្នាក់នៅរបស់ជនរងគ្រោះខាងលើ ដើម្បីមានមូលដ្ឋានពិតប្រាកដក្នុងការអនុវត្តនីតិវិធីអន្តរាគមន៍សង្គ្រោះ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ មន្ត្រីជំនាញរបស់នាយកដ្ឋាន បានបញ្ជូនព័ត៌មានបន្ថែម

ទៀត រួមមានគណនីហ្វេសប៊ុក ដែលមានអាសយដ្ឋាន អត្តសញ្ញាណបណ្ណប្តីជនជាតិចិន ឲ្យទៅក្រុមការងារលេខាធិការដ្ឋានមេគង្គឡានឆាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីមានមូលដ្ឋានក្នុងការស្រាវជ្រាវសង្គ្រោះ ទើបនៅរសៀលថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានឆ្លើយតបថា បានរកឃើញនារីរងគ្រោះនៅខេត្តហឺណាន នៃសាធារណរដ្ឋប្រជាមានិតចិន និងបានជួយសង្គ្រោះ ព្រមទាំងបានបញ្ជូនទៅកាន់ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងប៉េកាំង ដើម្បីអនុវត្តន៍នីតិវិធីបន្ត។

ឯកឧត្តម ជីវ ផល្លី សូមឲ្យក្រុមគ្រួសារនារីរងគ្រោះ មេត្តាយោគយល់អធ្យាស្រ័យចំពោះភាពយឺតយ៉ាវនៃការធ្វើបត្យាប័នបញ្ជូននារីរងគ្រោះមកកម្ពុជាវិញ ហើយភាពយឺតយ៉ាវនេះបណ្តាលមកពីអាជ្ញាធរកម្ពុជាត្រូវពេលវេលាស្វែងរកអង្គការសម្ព័ន្ធចាប់ដៃ ដើម្បីជួយគាំទ្រវាប់រងលើការចំណាយផ្សេងៗ( ស្នាក់នៅ អាហាហូបចុក និងថ្លៃសំបុត្រយន្តហោះជាដើម...) រួមជាមួយនឹងការអនុវត្តវិធានចត្តាឡីស័កនៅប្រទេសទាំងពីរចិនផង ។ បន្ទាប់ពីបញ្ចប់ការអនុវត្តវិធានចត្តាឡីស័ក សមត្ថកិច្ចនឹងអញ្ជើញជនរងគ្រោះមកសួរនាំស្វែងរកព័ត៌មានបន្ថែម ដើម្បីឈានដល់អនុវត្តជំនាញធ្វើការស្រាវជ្រាវកំណត់អត្តសញ្ញាណជនសង្ស័យដែលជាមេខ្យល់ ចាត់ការតាមច្បាប់។ ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អាជ្ញាធរចិន និងស្ថាប័នពាក់ព័ន្ធ បានរួមចំណែកលើការងារនេះ ពិសេសសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម ៕

## ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ផ្តល់ជំនួយជាង២.៤ពាន់លានរៀល សម្ភារៈ និងឃីតបន្ថែមទៀត ដល់ខេត្តចំនួន៤ ជាប់ព្រំដែនថៃ ដើម្បីត្រៀមរៀបចំធ្វើចត្តាឡីស័កដល់ពលករ អំឡុងបុណ្យចូលឆ្នាំចិន

http://www.freshnewsasia.com/ 2021-02-02 08:41am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១នេះ បានសម្រេចផ្តល់ជំនួយទឹកប្រាក់ចំនួន ២,៤៧៥,០០០,០០០រៀល សម្ភារៈ និងឃីតមួយចំនួនបន្ថែមទៀត ដល់ខេត្តកម្ពុជាចំនួន៤ ដែលនៅជាប់ព្រំដែនថៃ ដើម្បីត្រៀមរៀបចំធ្វើចត្តាឡីស័កដល់ពលករ ដែលនឹងចូលមកកម្ពុជា អំឡុងបុណ្យចូលឆ្នាំចិន។ នេះបើតាមលោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

**ខេត្តចំនួន៤ ដែលទទួលបានជំនួយនេះ មាន៖**

**១៖** ខេត្តបាត់ដំបង ទទួលបានថវិកា ៣៧៥លានរៀល ឃីត ១៥០០ ទឹកសុទ្ធ២០០០កេស និងមីកញ្ចប់ ១៥០០កេស

**២៖** ខេត្តបន្ទាយមានជ័យ ទទួលបានថវិកា ១,១៧០លានរៀល ឃីតចំនួន៤០០០ ទឹកសុទ្ធ៣០០០កេស និងមីកញ្ចប់ ១០០០កេស

**៣៖** ខេត្តឧត្តរមានជ័យ ទទួលបានថវិកា ៧៨០លានរៀល ឃីតចំនួន៣០០០ ទឹកសុទ្ធចំនួន៦០០០កេស និងមីកញ្ចប់ចំនួន៣០០០កេស

**៤៖** ខេត្តប៉ៃលិន ទទួលបានថវិកា១៥០លានរៀល ទឹកនិង សុទ្ធ៥០០កេស

បើតាមលោកស្រី យក់ សម្បត្តិ, ថវិកាទាំងនេះគឺសម្រាប់ត្រៀមរយៈពេល២សប្តាហ៍ ចាប់ពីថ្ងៃទី០២ ដល់ ១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដោយសារតែអំឡុងពេលបុណ្យចូលឆ្នាំចិន ខាងមុខនេះ អាចនឹងមានការកកស្ទះតាមដងផ្លូវ ហើយក្រុមហ៊ុនមួយចំនួននឹងឈប់សម្រាក។ លោកស្រី បានបន្ថែមថា ពេលនេះអំណោយសម្រាប់ខេត្តឧត្តរមានជ័យ កំពុងដឹកជញ្ជូនទៅកាន់ខេត្តឧត្តរមានជ័យ ដោយឡែកខេត្ត៣ទៀត កំពុងបន្តរៀបចំដឹកទៅប្រគល់ជូន ហើយសម្រាប់ថវិកាក៏កំពុងរៀបចំផ្ទេរទៅកាន់រដ្ឋបាលខេត្តទាំង៤ផងដែរ។ ការផ្តល់ជំនួយដល់បណ្តាខេត្តកម្ពុជា ដែលនៅជាប់ព្រំដែនថៃ បានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីរៀបចំការធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ក្រោយពេលប្រទេសថៃ បានផ្ទុះឡើងនូវការឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍យ៉ាងខ្លាំងក្លា ដែលផ្តើមចេញពីខេត្តសាមុតសាខន ប្រទេសថៃ។

បើតាមក្រសួងសុខាភិបាល, រហូតមកដល់ពេលនេះ មានពលករខ្មែរចំនួនជាង២ម៉ឺននាក់ បានត្រឡប់ពីប្រទេសថៃ ហើយត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក នៅខេត្តជាប់ព្រំដែន ក្នុងប្រទេសកម្ពុជា៕

## នាយកដ្ឋានទីចាត់ការព្រំដែន អគ្គបញ្ជាការ ប្រជុំដាក់ផែនការបន្តទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ នៅខេត្តបន្ទាយមានជ័យ

http://www.freshnewsasia.com/ 2021-02-01 06:09pm

**(បន្ទាយមានជ័យ)៖** លោកឧត្តមសេនីយ៍ទោ ពេជ្រ វណ្ណា នាយករងទីចាត់ការព្រំដែន អគ្គបញ្ជាការ និងប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានដឹកនាំប្រជុំបូកសរុបលទ្ធផលការងារថ្មីៗ ដើម្បីពង្រឹងវិន័យសណ្តាប់ធ្នាប់ ជូនដល់នាយទាហាន ជាពិសេសដាក់ផែនការអនុវត្តការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ នៅព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១។ ក្នុងកិច្ចប្រជុំនោះលោកឧត្តមសេនីយ៍ទោ ពេជ្រ វណ្ណា បានគូសបញ្ជាក់ថា « **បណ្តាកងកម្លាំងឈរជើងនៅតាមច្រកបៀងខ្មែរ-ថៃ ត្រូវចុះត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែនចំណុចក្បាលស្ពានច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីទប់ស្កាត់ការចម្លងរីករាលដាលនៃជម្ងឺកូវីដ១៩ ពីប្រទេសថៃ ដែលកំពុងផ្ទុះក្នុងសហគមន៍យ៉ាងខ្លាំង**»។ លោកបានបញ្ជាក់ឲ្យទៀតថា តាមការណែនាំរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល ពលករដែលវិញមកពីប្រទេសថៃចូលមកស្រុកខ្មែរ តាមច្រករបៀងតាមខេត្តបន្ទាយមានជ័យ ត្រូវចូលទៅក្នុងមណ្ឌល ចត្តាឡីស័ក ដែលរដ្ឋបាលខេត្តរៀបចំទុកជាស្រេច ដើម្បី វាស់កំដៅ និងបង្ខាំងទុក ១៤ថ្ងៃ ពិនិត្យឲ្យបានត្រឹមត្រូវទើបឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញបាន។

លោកថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងតែផ្តល់ការលើកទឹកចិត្តដល់ក្រុមការងារអង្គភាពទាំង៣រួមមាន៖ អាវុធហត្ថ នគរបាល និងយោធា រួមជាមួយក្រុមគ្រូពេទ្យស្ម័គចិត្ត និងគ្រូពេទ្យជាប់កិច្ចសងន្យា ដែលកំពុងឈរជើងប្រចាំទទួលពលករដែលវិលត្រឡប់មកពីប្រទេថៃ តាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ លោកបានបញ្ជាក់ថា «**សព្វថ្ងៃនេះរាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ផ្នែកកំពុងយកចិត្តទុកដាក់ខិតខំបំពេញការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ នេះបានយ៉ាងល្អ និងមានប្រសិទ្ធិភាពខ្ពស់ ក្នុងនោះលោកបានផ្តល់កម្លាំងចិត្ត និងផ្តល់កម្លាំងចិត្តដល់បងប្អូនពលករ ឲ្យគោរពវិន័យ និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបានឆាប់វិលត្រឡប់ទៅផ្ទះសម្បែង ហើយក្លាយជាកម្លាំងពលកម្មដ៏រឹងមាំ មានសុខភាពល្អសម្រាប់កសាងជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិឲ្យរីកចម្រើនថែទៀត**»៕

## អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរជិត ២០នាក់ ក្នុងពេលឆ្លងដែនមកពីប្រទេសម៉ាឡេស៊ីខុសច្បាប់

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2021-02-01

អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរជិត ២០នាក់ ដែលបានឆ្លងដែនត្រឡប់មកពីធ្វើការនៅប្រទេសម៉ាឡេស៊ី (Malaysia) ចូលទៅប្រទេសថៃ កាលពីព្រឹកថ្ងៃទី៣១ មករា។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលករទាំងនោះ អាចនឹងត្រូវអាជ្ញាធរថៃ ពិន័យជាប្រាក់ និងផ្តន្ទាទោស ដាក់ពន្ធនាគារមុននឹងបញ្ជូនពួកគេត្រឡប់ទៅកម្ពុជា។ ពលករខ្មែរប្រមាណ ១៧នាក់ មានអាយុចន្លោះពី ២០ ទៅ ៤០ឆ្នាំ ត្រូវបានទាហានថៃចាប់ខ្លួនក្នុងពេលពួកគាត់ធ្វើដំណើរនៅតំបន់ព្រំដែនក្នុងខេត្តណារ៉ាធិវ៉ាត់ (Narathiwat) ជាប់ព្រំដែនដែនប្រទេសម៉ាឡេស៊ី (Malaysia) នៅព្រឹកថ្ងៃទី៣១ មករា។

ទូរទស្សន៍ថៃ ភីប៊ីអេស (Thai PBS) របស់ថៃ ផ្សាយនៅយប់ថ្ងៃទី៣១ មករាថា ពលករទាំងនោះបានឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ ហើយពួកគេត្រូវបានចាប់ខ្លួន ក្នុងពេលដែលអាជ្ញាធរថៃចុះល្បាតនៅតំបន់ព្រំដែន។ អាជ្ញាធរថៃបានបញ្ជូនពលករទាំងនោះទៅធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ នៅខេត្តណារ៉ាធិវ៉ាត់ (Narathiwat) ហើយប្រសិនបើរកមិនឃើញមានជំងឺកូវីដ១៩ នឹងបញ្ជូនពួកគេទៅតុលាការផ្តន្ទាទោសតាមច្បាប់បន្តទៀត។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង និងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសុំអត្ថាធិប្បាយជុំពីការចាប់ខ្លួនពលករខ្មែរនេះបានទេ នៅថ្ងៃទី១ កុម្ភៈ ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

អាជ្ញាធរថៃបានដាក់ប្រទេសក្នុងគ្រាអាសន្នរហូតដល់ថ្ងៃទី២៨ កុម្ភៈ ដើម្បីទប់ស្កាត់កុំមានការរាតត្បាតជំងឺកូវីដ១៩។ ច្បាប់នេះបានហាមឃាត់មិនឱ្យប្រជាពលរដ្ឋប្រមូលផ្តុំគ្នាជាច្រើននាក់ និងមិនឱ្យពលករបរទេសចល័តទីតាំងពីខេត្តមួយទៅខេត្តមួយទៀតជាដើម។ ពលរដ្ឋណាល្មើសនឹងបម្រាមនេះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ និងពិន័យជាប្រាក់ប្រមាណ ៤ម៉ឺនបាត (៤០.០០០) ស្មើនឹង ១ពាន់ ៣០០ដុល្លារ (១.៣០០)។

ទាក់ទងនឹងការចាប់ខ្លួនពលករខ្មែរនេះ មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា យល់ថា ពលករខ្មែរទាំងនោះអាចនឹងត្រូវអាជ្ញាធរថៃផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់តាមច្បាប់ ដោយសារពួកគេបានល្មើសនឹងបម្រាមរបស់រដ្ឋាភិបាលថៃ។ ចំណែកករណីដែលពលករខ្មែរត្រឡប់មកពីប្រទេសម៉ាឡេស៊ីវិញ លោកប្រាប់ថា ដោយសារពួកគេគ្មានការងារធ្វើ ព្រោះប្រទេសម៉ាឡេស៊ី កំពុងរាតត្បាតដោយជំងឺកូវីដ-១៩ដែរ៖ «អ៊ីចឹងវាមានទាំងពិន័យជាប្រាក់ និងដាក់ពន្ធនាគារ ប៉ុន្តែបើសិនជាពិន័យជាប្រាក់ពួកគាត់មិនមានលុយទេ។ អ៊ីចឹងហើយ ឱកាសដែលពួកគាត់ត្រូវជាប់មន្ទីរឃុំឃាំងវាមានច្រើនភាគរយណាស់។ មូលហេតុដែលគេជ្រើសយកជម្រើសនេះ តាមពិតទៅគេមិនចង់ចាប់ពលករទេ ដោយសារមួយរយៈពេលនេះការចាប់ខ្លួនមានច្រើននាក់ ដើម្បីបង្ហាញនូវវិធានការតឹងតែងមួយ ដើម្បីឱ្យអ្នកដទៃទៀតឱ្យមានការបារម្ភភ័យខ្លាចពីចំណុចហ្នឹងដែរ»។

ពលករខ្មែរធ្វើការនៅប្រទេសម៉ាឡេស៊ី លោក ជុំ សុខវរៈ ប្រាប់អាស៊ីសេរីថា នៅព្រឹកថ្ងៃទី១ កុម្ភៈថា ពលករខ្មែរជាច្រើននាក់ធ្វើការជាមួយលោក ព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ដោយសារជំងឺកូវីដ១៩ កំពុងមានការរាតត្បាតខ្លាំងនៅប្រទេសម៉ាឡេស៊ី។ ពលករវ័យ ៣៩ឆ្នាំរូបនេះ បន្តថា មានពលករខ្មែររាប់ពាន់នាក់អត់ការងារធ្វើ ហើយពួកគេចង់ត្រឡប់ទៅកម្ពុជាវិញ ប៉ុន្តែមិនអាចទៅរួច ដោយសារមួយរយៈនេះអាជ្ញាធរម៉ាឡេស៊ី បានបង្កើនការត្រួតពិនិត្យតឹងតែង និងហាមឃាត់មិនឱ្យពលករបរទេសចល័តទីកន្លែងធ្វើការនោះឡើយ៖ «ទី១ភ័យខ្លាចថាយើងជាជនជាតិក្រៅស្រុកគេឆ្លងច្រើនរហូតដល់មន្ទីរពេទ្យប្រទេសម៉ាឡេស៊ីហ្នឹងគេលែងមានកន្លែងដាក់ហើយ។ អ៊ីចឹងសម្រាប់ជនជាតិគេឆ្លងច្រើនគេយកចិត្តទុកដាក់តែប្រជាពលរដ្ឋគេទេ វាអាចដែរ នេះគ្រាន់តែជាការប៉ាន់ស្មានរបស់

ពួកខ្ញុំទេ។ អ៊ីចឹងយើងភ័យខ្លាចថា បើយើងជាជនជាតិក្រៅស្រុក ខ្លាចគេមិនមើលយើងជិតដល់មិនយកចិត្តទុកដាក់យើង ហើយគេយកយើងទៅដាក់ចោលអ៊ីចឹង។ ឥឡូវឧទាហរណ៍ផ្ទាល់នៅរោងចក្រដែលកំពុងតែកើតឡើងនៅកន្លែងធ្វើការរបស់ខ្ញុំ ពួកជនជាតិភូមា និងនេប៉ាល់ (Nepal) ឆ្លងចំនួន ១០នាក់ហ្នឹង គឺគេអត់ទាន់មានកន្លែងដាក់ទេ គេដាក់ឱ្យនៅផ្ទះនៅឡើយទេ គេអត់ទាន់បញ្ជូនទៅមន្ទីរពេទ្យទេ»។

មន្រ្តីសិទ្ធិការងារលោក ឌី ថេហូយ៉ា ឱ្យដឹងថា ចាប់តាំងពីខែសីហា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី ១ កុម្ភៈ មានពលករខ្មែរជាង១ម៉ឺននាក់ (១០.០០០) ហើយត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ក្នុងពេលដែលពួកគេស្នាក់នៅ និងធ្វើដំណើរក្នុងប្រទេសថៃដោយខុសច្បាប់។ មន្រ្តីសង្គមស៊ីវិលរូបនេះបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហានេះ អាជ្ញាធរកម្ពុជាគួរតែផ្ដល់ស្បៀងអាហារ និងរកទីកន្លែងឱ្យពលករបានស្នាក់នៅក្រៅប្រទេសជាបណ្ដោះអាសន្នមួយរយៈ ដើម្បីជួយសម្រួលដល់ពួកគាត់កុំឱ្យឆ្លងដែនដោយប្រថុយប្រថានអំឡុងពេលនេះ៕

## នគរបាលប៉ុស្តិ៍រដ្ឋបាលរកាកណ្តាល ចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ

http://cambodiapolice.com/policekh/ 4:09 pm 1 កុម្ភៈ 2021

ក្រចេះ ៖ នៅព្រឹកថ្ងទី០១ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលរកាកណ្តាល បានចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព តាមខ្នងផ្ទះប្រជាពលរដ្ឋភូមិទី១ សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ មានដូចខាងក្រោម ៖

-សេចក្តីអំពាវនាវគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

-អំពីគ្រោះ អគ្គីភ័យផ្សេងៗ

-ការលេងល្បែងស៊ីសងគ្រប់ប្រភេទ និង ការប្រើប្រាស់អាវុធខុសច្បាប់

-អំពើអាណាចារ្យ ការជួញដូរមនុស្សស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

-ច្បាប់ចរាចរណ៍ផ្លូវគោកអនុក្រឹត្យលេខ៣៩ អនក្រ.បកចុះថ្ងៃទី១៧ខែមីនាឆ្នាំ២០២០លទ្ធផលអ្នកចូលរួមចំនួន( ៣២នាក់) (ស្រី០៩នាក់) និងចែកលិខិតបណ្ណ័បានចំនួន (៣២សន្លឹក) ៕

## ពលករខ្មែរបន្តគេចចេញពីថៃ ដោយសារកំណើននៃការឆ្លងកូវីដ-១៩ ក្នុងសហគមន៍ប្រទេសនេះ

http://btv.com.kh/ 01/02/2021

បាត់ដំបង ៖ នៅក្នុងសហគមន៍ប្រទេសថៃ ជារៀងរាល់ថ្ងៃ មានមនុស្សរាប់សិបនាក់ បានឆ្លងកូវីដ–១៩ ដែលស្ថាន ភាពនេះ បានធ្វើឱ្យមានផលប៉ះពាល់ដល់ការងារពលករខ្មែរ ក្នុងប្រទេសនេះ ដែលបញ្ហានេះ បានធ្វើឱ្យពលករខ្មែរជាច្រើនរយនាក់ សម្រេចចិត្តវិលមកប្រទេសកម្ពុជាវិញ។

យោងតាមរបាយការណ៍របស់រដ្ឋបាលខេត្តបាត់ដំបង បានឲ្យដឹងថា មកទល់ពេលនេះ ពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ ចំនួនជាង៤ពាន់នាក់ហើយ បានវិលមកវិញ តាមច្រកខេត្តបាត់ដំបង ហើយ អាជ្ញាធរខេត្តបាត់ដំបង បានត្រៀមជានិច្ចនូវមណ្ឌលចត្តាឡីស័ក ចំនួន១១កន្លែង សម្រាប់ធ្វើចត្តាឡីស័ក ពលករ ដែលមណ្ឌលទាំងនោះ មាននៅស្រុកកំរៀង ភ្នំព្រឹក សំពៅលូន បាណន់ សំឡូត ឯកភ្នំ ថ្មគោល បវេល មន្ទីរពេទ្យបង្អែកខេត្ត រតនមណ្ឌល និងស្រុកមោងឫស្សី ។ របាយការណ៍ បានបន្តថា សម្រាប់ពលករបានបញ្ចប់ចត្តាឡីស័ក និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ សរុបចំនួន២៧១៦នាក់ និងកំពុងធ្វើចត្តាឡីស័ក ចំនួន១០៤០នាក់ ។ ចំណែកការយកសំណាកចំនួនជិត ៤០០០នាក់ និងមានពលកររស់នៅខេត្តបាត់ដំបង មានវិជ្ជមានជំងឺកូវីដ១៩ ចំនួន១៧នាក់ បានសម្រាក

ព្យាបាលក្នុងមន្ទីរពេទ្យបង្អែកខេត្ត ហើយបច្ចុប្បន្នពួកគេបានជាសះស្បើយ និងអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះ វិញអស់ហើយ ។

ជាមួយនឹងវិធានការទប់ស្កាត់កុំឲ្យរីករាលដាលក្នុងសហគមន៍ជាថ្មីក្នុងប្រទេសកម្ពុជា នៃជំងឺកូវីដ១៩ អាជ្ញាធរខេត្ត ក៏ដូចជាមន្ត្រីសុខាភិបាល និងកងកម្លាំងទាំង៣ បានត្រៀមជានិច្ចនូវបន្ទាត់ព្រំដែន កម្ពុជា-ថៃ តាមព្រំដែននានា ជាប់ខេត្តបាត់ដំបង ក្នុងការទទួលពលករឆ្លងដែនពីថៃ និងនាំពួកគេទៅពិនិត្យ សុខភាព យកសំណាករកជំងឺកូវីដ១៩ ហើយធ្វើចត្តាឡីស័ក ឲ្យបានគ្រប់គ្នា តាមការណែនាំរបស់រាជ រដ្ឋាភិបាល និងក្រសួងសុខាភិបាល ជាមួយនឹងការផ្តល់នូវអាហារបីពេលក្នុងមួយថ្ងៃ ។

ក្នុងកិច្ចប្រជុំ ឬពិធីសំណេះសំណាលនានាជាមួយពលរដ្ឋ កងកម្លាំងជាដើមនោះ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានអំពាវនាវ និងជំរុញឲ្យមានការយកចិត្តទុកដាក់ ក្នុងការទប់ស្កាត់កុំឲ្យ មានការរីករាលដាលជំងឺកូវីដ១៩។ ចំពោះសមត្ថកិច្ច និងមន្ត្រីជំនាញនៅតាមព្រំដែន ត្រូវក្តាប់ឲ្យបាននូវ ការឆ្លងដែន របស់ពលករមកពីប្រទេសថៃ ក្នុងការអនុវត្តវិធានការសុខាភិបាលលើពួកគាត់៕ អត្ថបទ ៖ បាន សុខរិទ្ធ

## ឯកឧត្តម ខៀវ សុភ័គ៖ អាជ្ញាធរ ត្រូវអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ឱ្យមានប្រសិទ្ធភាព

http://btv.com.kh/ 01/02/2021

ព្រៃវែង៖ ឯកឧត្តម សន្តិបណ្ឌិត ខៀវ សុភ័គ សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានទី១ ក្រុមការងារចុះមូលដ្ឋានស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានអញ្ជើញប្រកាសក្រុមការងារគណបក្សប្រជាជនកម្ពុជា ឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ព្រមទាំងចែកអំណោយដល់ប្រជា ពលរដ្ឋក្រីក្រ ជួបការ លំបាក ចំនួន២៤០គ្រួសារ។ ឯកឧត្តម សន្តិបណ្ឌិត បានសាកសួរសុខទុក្ខ ព្រមទាំងបានរំលឹកនូវប្រវត្តិសាស្ត្រ ដែល រូបឯកឧត្តមផ្ទាល់បានឆ្លងកាត់កន្លងមក រហូតមកដល់បច្ចុប្បន្នក្រោមការខិតខំប្រឹង ប្រែង របស់គណបក្សប្រជាជនកម្ពុជាទើបប្រទេសទទួលបានសុខសន្តិភាព ស្ថិរភាព រួមជាមួយការអភិវឌ្ឍ។ ឆ្លៀតឱកាសនោះផងដែរ ឯកឧត្តម សន្តិបណ្ឌិត ក៏បានលើកឡើង នូវ គោល នយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ដែលមាន ០៧ចំណុច៖

ទី១-ផ្តល់សេ វាសាធារណៈ ប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងទទួលបានជំនឿទុកចិត្ត ដោយឯកឧត្តមលើកទឹកចិត្តឱ្យមេឃុំដាក់ចិត្តដាក់កាយបម្រើពលរដ្ឋដោយស្មោះ ដោយត្រូវចុះ ជួយពលរដ្ឋតាមខ្នងផ្ទះនៅពេលដែលគាត់មានតម្រូវការ ដែលទង្វើបែបនេះទើប ពលរដ្ឋស្រឡាញ់ និងបន្តបោះឆ្នោតដល់គណបក្សប្រជាជនកម្ពុជា។

ទី២-ភូមិ ឃុំ ដែល គ្មាន បទល្មើសគ្រប់ប្រភេទ គ្មានការលួច ឆក់ ប្លន់ គ្មានគ្រឿងញៀន និងធ្វើឱ្យភូមិ ឃុំ គ្មាន បទល្មើស។

ទី៣-ភូមិឃុំ ដែលមានសណ្តាប់ធ្នាប់សាធារណៈល្អ គ្មានគ្រោះថ្នាក់ ចរាចរណ៍ ជាមួយគ្នានេះឯកឧត្តម ក៏បានអំពាវនាវឱ្យអ្នក ប្រើប្រាស់ផ្លូវ ទាំងអស់ត្រូវគោរពច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងពេលបើកបរផងដែរ។

ទី៤-ភូមិ ឃុំដែលគ្មាន អំពើអនា ចារ គ្មានការជួយញដូរមនុស្ស គ្មានការជួញដូរស្ត្រី និងកុមារ ព្រមទាំងគ្មាន អំពើរ ហិង្សា ក្នុងគ្រួសារ។

ទី៥-ដោះស្រាយវិវាទនៅក្នុងមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកប ដោយគុណភាព និងប្រសិទ្ធភាពនិងដោយសន្តិវិធី។

ទី៦-មានអនាម័យល្អ មានសោភ័ណភាពល្អ និងមាន បរិស្ថានល្អ។

ទី៧-ឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងជំងឺកាចសាហាវ ប្រកបដោយប្រសិទ្ធភាព។

លើពីនេះទៀត ឯកឧត្តម សន្តិបណ្ឌិត បានផ្តាំផ្ញើឱ្យពលរដ្ឋថែទាំសុខភាព និងប្រកាន់ខ្ជាប់នូវការពាក់ម៉ាស ការពារខ្លួនពីជំងឺកូវីដ១៩ ព្រោះជំងឺនេះមិនទាន់ទៅណាឆ្ងាយនៅឡើយទេ បើទោះបីជាប្រទេសរបស់យើងគ្រប់គ្រងស្ថានការណ៍នៃជំងឺនេះបានល្អយ៉ាងណាក៏ដោយ។ ក្នុងឱកាសនោះដែរ ឯកឧត្តមសន្តិ បណ្ឌិត ខៀវ សុភ័គ បានប្រគល់ថវិកាសម្រាប់ជួសជុលផ្លូវលំចំនួន ១,៨០០,០០០ រៀល ក្រដាសរ៉ាម ៨០ដុំ ប៊ិច ៨០០ដើម ប្រតិទិន ១០០ក្បាលជូនគណបក្សឃុំ។ ក្នុងនោះ ឯកឧត្តម សន្តិបណ្ឌិត ក៏បានអញ្ជើញបន្តពិនិត្យអគារប៉ុស្តិ៍រដ្ឋបាល សាលាឃុំ មណ្ឌល សុខភាព ព្រមអញ្ជើញប្រគល់ថ្នាំពេទ្យជូនដល់មណ្ឌលសុខភាព ឃុំពាមមន្ទារ និងឃុំគោខ្ចក ចំនួន ១៧មុខ និងឧបត្ថម្ភ ថវិកាដល់ក្រុមគ្រូពេទ្យ ដោយសរុបថវិកាប្រមាណ ២០,០០០,០០០រៀលផងដែរ។

គួរបញ្ជាក់ថា ឃុំពាមមន្ទារ ជាឃុំមួយក្នុងចំណោម ឃុំ ទាំង ១៣ស្ថិតក្នុងស្រុកកំពង់ត្របែក ដែលមានភូមិសាស្រ្តជាប់សាង ខាងជងទន្លេ កំពង់ ត្របែក ចាប់ពីស្ពានកំពង់ត្របែករហូតដល់ទល់នឹងព្រំដែនប្រទេសវៀតណាម និងមាន ភូមិចំនួន១១។ ឃុំពាមមន្ទារ មានសមិទ្ធផលសម្រាប់សម្រើសេវាជូនប្រជាពលរដ្ឋទូទៅ មិនប្រកាន់និន្នាការ រួមមានសាលាឃុំប៉ុស្តិ៍រដ្ឋបាល មណ្ឌលសុខភាព ពិសេសមាន ស្នាក់ ការគណបក្សដែលជាគ្រឹះរឹងមាំសម្រាប់បម្រើគោលនយោបាយរបស់បក្សមូលដ្ឋាន៕ អត្ថបទ៖ ដាវណ្ណ

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃចន្ទ ទី០១ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២១នាក់ ស្រី ៥៤នាក់ ក្នុងនោះកុមារា ១១នាក់ កុមារី ៦នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ 2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤៥នាក់ ស្រី ២២នាក់ កុមារា ៣នាក់ កុមារី ១នាក់។ 3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៩នាក់ ស្រី ៨នាក់ កុមារា ៥នាក់ កុមារី ១នាក់។ 4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៧នាក់ ស្រី ២៤នាក់ កុមារា ៣នាក់ កុមារី ២នាក់។ 5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ១២១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៧៤នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៤៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ប្រភព: ក្រុមការងារប្រចាំការរបស់រដ្ឋបាលខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

# ការរឹតត្បិតដោយសារជំងឺកូវីដ-១៩ នៅក្នុងទីផ្សារអាហារសមុទ្រនៅខេត្តសាមុតសាខុន ប្រទេសថៃបណ្ដាលអោយមានការជម្លៀសពលករចំណាកស្រុកកម្ពុជាយ៉ាងច្រើន

http://khmerinkorea.com/ Kong Arey / Khmer Times February 1, 2021

នៅពេលមានការកើនឡើងភ្លាមៗ នៃករណីជំងឺកូវីដ-១៩ នៅក្នុងទីផ្សារអាហារសមុទ្រ ខេត្តសាមុតសាខុន ប្រទេសថៃពលករចំណាកស្រុកកម្ពុជា ដែលប្រឈមនឹងបញ្ហាការងារធ្ងន់ធ្ងរ ដោយសារការបញ្ឈប់ការងារ និងការលំបាកក្នុងការធានាការងារថ្មីបានរកឃើញថា ពួកគេស្ថិតក្នុងភាពច្របូកច្របល់ថ្មីដែលធ្វើឲ្យពួកគេគ្មានជំរើសក្រៅពីភៀសខ្លួន។ ដោយពលកររាប់ពាន់នាក់បានរត់ភៀសខ្លួនចេញពីប្រទេសថៃ តាមមធ្យោបាយដែលអាចធ្វើទៅបានតាមរយៈចំណុចត្រួតពិនិត្យស្របច្បាប់ ទោះបីជាចំណុចត្រួតពិនិត្យអន្តោប្រវេសន៍ព្រំដែន ត្រូវបានបិទជាផ្លូវការក៏ដោយ។ មនុស្សជាច្រើនបានជិះទូកខ្នាតតូច និងជិះតាក់ស៊ីខុសច្បាប់ទៅព្រំដែនកម្ពុជា-ថៃដោយខ្លួនឯង ខណៈដែលអ្នកផ្សេងទៀតបានទាក់ទងភ្នាក់ងារ ដើម្បីដឹកជញ្ជូនពួកគេនៅជិតព្រំដែនកម្ពុជាតាមដែលអាចធ្វើទៅបាន។ នៅពេលដែលត្រូវបានគេទម្លាក់ចោលនៅតំបន់ដែលមានរាប់ពាន់គីឡូម៉ែត្រពីព្រំដែន ប្រជាជនកម្ពុជាបានធ្វើដំណើរឆ្លងកាត់ព្រៃ និងដីស្រែឆ្ពោះទៅអូរមួយដែលនៅពេលនេះនៃឆ្នាំនេះមានជម្រៅប្រហែល ១ ម៉ែត្រដើម្បីស្វែងផ្លូវត្រឡប់ទៅជម្រកនៅក្នុងប្រទេសកំណើតវិញ។

កិច្ចប្រឹងប្រែងរបស់ខ្មែរថាមស័ក្នុងការស្វែងរកការឆ្លងដែនខុសច្បាប់ បានធ្វើឲ្យមានការលំបាកដោយសារព្រំដែននៅបាត់ដំបងបានអូសបន្លាយចម្ងាយប្រហែល៤០គីឡូម៉ែត្រ ហើយការល្បាតសន្តិសុខក៏ត្រូវបានបង្កើនផងដែរ។ ពលករទាំងនេះ ពួកគេមិនបានព្យាយាមប្រើប្រាស់ចំនុចត្រួតពិនិត្យជាផ្លូវការដែលនៅតែបើកចំហរសម្រាប់ការដឹកទំនិញឡើយ។ ពួកគេប្រើអ្វីដែលលោកខាងលិចហៅថា រណ្ដៅកណ្ដុរ ដើម្បីលួចឆ្លងកាត់ព្រំដែនថៃ ដោយដើរឆ្លងកាត់ទឹកហូរចូលទៅក្នុងប្រទេសកម្ពុជាហើយបន្ទាប់មកដើរកាត់ដីស្រែលើទឹកដីកម្ពុជា ដើម្បីស្វែងរកទាហានល្បាតដើម្បីជួយ។

លោក ត្រៃ រ័ត្ន អភិបាលរងស្រុកសំពៅលូនបាននិយាយថា៖ «ពួកគេមានសំណាងណាស់ដែលជនជាតិថៃបានសហការគ្នាហើយពេលខ្លះបានជូនដំណឹងអំពីការល្បាតពីវត្តមានរបស់ពលករចំណាកស្រុកទាំងនេះនៅតាមព្រំដែន ហើយបានលើកទឹកចិត្តឲ្យយើងទទួល ឬជួយពួកគេឆ្លងកាត់អូរខណៈលើកទឹកចិត្តដល់ពលករឆ្លងកាត់ផ្លូវទឹកដោយគ្មានការភ័យខ្លាច»។ ពលករបានប្រាប់យើងថា នៅពេលខ្លះពួកគេមានសំណាងដែលបានជួបពលករខ្មែរនៅលើដីស្រែថៃដែលបានផ្ដល់ស្បៀងអាហារ និងទឹកហើយណែនាំពួកគេនៅលើផ្លូវឆ្លងកាត់ដែលល្អបំផុតហើយនៅពេលផ្សេងទៀតទាហានថៃផ្ដល់ទិសដៅផងដែរ។ លោកបន្ថែមថាទោះយ៉ាងណា ពលករភាគច្រើនបានឆ្លងកាត់ដីស្រែ បន្លែ និងចូលតាមខ្សែរទឹកមកកម្ពុជា។ លោកនិយាយថា៖ «សូម្បីតែកសិកររបស់យើងដែលនៅជិតព្រំដែនក៏មិនដឹងថាតើពលករមកពីពេលណា ឬទីណាដែរប៉ុន្តែយើងបានជូនដំណឹងដល់ពួកគេអំពីលទ្ធភាពទាំងនេះ និងជូនដំណឹងដល់មន្ត្រីរបស់យើងប្រសិនបើពួកគេបានឃើញពលករចំណាកស្រុក ឬបានដឹងអំពីវត្តមានរបស់ពួកគេនៅក្នុងភូមិ»។

លោកវរសេនីយ៍ទោ រុន ថាវី មេបញ្ជាការកងរាជអាវុធហត្ថស្រុកកំរៀងបានអោយដឹងថាមានពលករខ្លះមានការភ័យខ្លាចក្នុងការជាន់មីន ដែលអាចកើតមានឡើង។ លោកនិយាយថា៖ «ទោះយ៉ាងណា ពួកគេភាគច្រើនដើរតាមគន្លងដែលពួកគេឃើញនៅក្នុងទីងងឹតដោយប្រើខ្សែភ្លើង ឬទូរស័ព្ទ ដោយប្រើវាជាទិសដៅដើម្បីរកអូរ និងកន្លែងដែលត្រូវឆ្លងកាត់។ កាលពីអតីតកាល មានករណីឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃដែលបញ្ចប់ដោយអ្នកស្លាប់ ឬរងរបួសធ្ងន់ធ្ងរនៅពេលពួកគេឈានដល់តំបន់មីន»។ លោកបន្ថែមទៀតថាអាជ្ញាធរមិនច្បាស់ថានៅពេលណាលំហូរចូលនៃជនអន្តោប្រវេសន៍នឹងបញ្ឈប់នោះទេ ប៉ុន្តែបានទទួលស្គាល់ថាវាមានភាពយឺតយ៉ាវ ដោយផ្ដល់

ពេលវេលាដល់មណ្ឌលដើម្បីធ្វើការសម្អាតសម្រាប់មេរោគ និងផ្លាស់ប្តូរកងទ័ពមួយចំនួន។ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## លោក ឡុង ឌីម៉ង់៖ ពលករខ្មែរនៅក្វាងជូជាប់លេខ១ លើការអត់ធ្មត់ តស៊ូ និងគោរពច្បាប់ តែក៏មានបញ្ហាចោទមួយចំនួនលើពលករខុសច្បាប់ដែរ

http://khmerinkorea.com/ February 1, 2021

កូរ៉េខាងត្បូង៖ ពលករខ្មែរដែលបាន និងកំពុងរស់នៅធ្វើការក្នុងទីក្រុងក្វាងជូ ប្រមាណ១២០០នាក់ ត្រូវបានជាប់ចំណាត់ថ្នាក់លេខ១ ជាពលករដែលមានការអត់ធ្មត់ ប្រឹងប្រែង តស៊ូ និងគោរពច្បាប់ ក្នុងបណ្តាពលករជនជាតិផ្សេងទៀត នេះបើតាមការបញ្ជាក់របស់លោកឯកអគ្គរាជទូត ឡុង ឌីម៉ង់ នៅក្នុងទំព័រហ្វេសប៊ុករបស់លោក។ លោកទូត ឡុង ឌីម៉ង់បញ្ជាក់បែបនេះ ក្រោយពីបានជួបពិភាក្សាការងារជាមួយអគ្គនាយកនៃទីភ្នាក់ងារអភិវឌ្ឍន៍ធនធានមនុស្ស HRD Korea ប្រចាំទីក្រុងក្វាងជូ ដែលជាស្ថាប័នគ្រប់គ្រងពលករអន្តោប្រវេសន៍ លោកស្រី Jeong Eun-hee។ ក្នុឱកាសជំនួបនៅតំបន់ក្វាងជូធំ កាលពីចុងសប្តាហ៍កន្លងទៅនេះ លោកស្រីអគ្គនាយកនៃទីភ្នាក់ងារអភិវឌ្ឍន៍ធនធានមនុស្ស HRD Korea បានសម្តែងនូវការអរគុណ និងគាំទ្រជាមួយស្ថានទូតកម្ពុជា ក្នុងកិច្ចការងារដោះស្រាយ-គាំពារ ធ្វើយ៉ាងណាលើកកម្ពស់ស្ថានភាពរស់នៅ ក៏ដូចជាលក្ខខណ្ឌការងារដល់ពលករខ្មែរនៅកូរ៉េ ជាពិសេសនៅតំបន់ក្វាងជូធំនេះ។

យ៉ាងណាមិញ ភាគីទាំងពីរក៏បានពិភាក្សាគ្នាលើបញ្ហាផ្សេងៗពាក់ព័ន្ធនឹងពលករកម្ពុជាយើង ហើយបញ្ហាពលករខុសច្បាប់ ក៏នៅតែជាបញ្ហាប្រឈមមួយដែលភាគីទាំងពីរបានពិភាក្សាគ្នា ដោយឯកភាពថា បញ្ហាបង្កើន ឬផ្អាកកូតាផ្តល់ឲ្យកម្ពុជា គឺអាស្រ័យទៅលើកិច្ចខិតខំប្រឹងប្រែងក៏ដូចជាលទ្ធផលនៃការកាត់បន្ថយចំនួនពលករខុសច្បាប់នៅលើទឹកដីកូរ៉េនេះ។ ម្យ៉ាងវិញទៀតពលករខុសច្បាប់នឹងអាចមានការប្រឈមបញ្ហាផ្លូវច្បាប់ ក៏ដូចជាការរំលោភបំពានសិទ្ធិ ការដែលមិនអាចទទួលបាននូវអត្ថប្រយោជន៍ ឬការគាំពារផ្សេងៗផងដែរ។

# ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២១

## លោក ហ៊ុន សែន បញ្ជាក់ពីការកែលម្អគោលនយោបាយ «ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព»

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 02 February 2021 | 09:15 ICT

**ភ្នំពេញៈ** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគូសបញ្ជាក់អំពីការសម្រេចរបស់រដ្ឋាភិបាលក្នុងការកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ថាធ្វើឡើងដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន ពីព្រោះសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះ ដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតឱ្យមានការរីកចម្រើន។ ការសម្រេចកែលម្អលក្ខណសម្បត្តិ នៃគោលនយោបាយនេះបានធ្វើឡើងបន្ទាប់ពីឆ្លងកាត់បទពិសោធអស់រយៈពេល ១០ ឆ្នាំរបស់ក្រសួងមហាផ្ទៃ ដោយមានការគាំទ្រ និងចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកពាក់ព័ន្ធបានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរីកចម្រើនរបស់សង្គមជាតិ។

លោក ហ៊ុន សែន ថ្លែងបែបនេះតាមរយៈលិខិតស្តីអំពីការលើកកម្រិតលក្ខណសម្បត្តិគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២១។ លោកបញ្ជាក់ថា ទោះបីមានសន្តិភាព ស្ថិរ

ភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានានៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។ លោកថ្លែងថា៖ «ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល»។ លោកបញ្ជាក់ថា៖ «សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតមានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា»។

បើតាមលោកនាយករដ្ឋមន្ត្រី ការលើកកម្រិតលក្ខណសម្បត្តិនៃគោលនយោបាយនេះមានគោលបំណង និងសំណូមពរបន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះ ដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។ លើសពីនេះ ត្រូវកសាងជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុបក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

លោក អំ សំអាត នាយករងអង្គការលីកាដូសង្កេតឃើញថា គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលនេះល្អ ក្នុងគោលបំណងធ្វើឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានអាចរស់នៅប្រកបដោយភាពសុខដុមរមនា មានសន្តិសុខ សុវត្ថិភាព និងបរិស្ថានល្អ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងរបស់មន្ត្រីមូលដ្ឋានមួយចំនួន មិនទាន់ឆ្លើយតបទៅតាមគោលនយោបាយនេះនៅឡើយទេ។ លោកថ្លែងថា៖ «ប្រជាពលរដ្ឋមួយចំនួននៅតែលើកឡើងពីបញ្ហាមួយចំនួន ដូចជាករណីគ្រឿងញៀនដែលបច្ចុប្បន្នគឺរាលដាលដល់ជនបទ ល្បែងស៊ីសងមួយចំនួននៅបន្តកើតមានឡើង ចោរកម្មមួយចំនួននៅតែកើតមានឡើង»។ លោក សំអាត បន្តថា៖ «ដូច្នេះដើម្បីឱ្យគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពមានប្រសិទ្ធភាពទាល់តែមន្ត្រីមូលដ្ឋានត្រូវចូលរួមអនុវត្តឱ្យបានពេញលេញ និងមានការចូលរួមពីប្រជាពលរដ្ឋ និងមានទំនុកចិត្តពីពលរដ្ឋ»។

លក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមមាន ១ ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។ ២ គ្មានបទល្មើស លួច ឆក់ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។ ៣ មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។ ៤ គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។ ៥ ដោះស្រាយវិធានការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ៦ មានអនាម័យ មានសោភណភាពល្អ និងមានបរិស្ថានល្អ។ ៧ ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៕

# កម្ពុជាស្នើសុំចូលជាសមាជិកនៃប្រទេសដែលជោគជ័យ ក្នុងការលុបបំបាត់ផលប៉ះពាល់ជនទេសន្តរប្រវេសន៍

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 02 February 2021 | 18:23 ICT

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការជំរុញពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា (IOM) បានដាក់លិខិតស្នើសុំចូលជាសមាជិកភាព នៃប្រទេសដែលបានអនុវត្ត ដោយជោគជ័យក្នុងការលុបបំបាត់ ឬកាត់បន្ថយផលប៉ះពាល់ទៅលើជនទេសន្តរប្រវេសន៍ និងអនុវត្តបានជោគជ័យ នៃកតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) នៃក្រសួងមហាផ្ទៃ ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២ ខែកុម្ភៈ ថា អង្គការសហប្រជាជាតិដែលមានអង្គការ IOM ជាលេខាធិការដ្ឋានបានទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា។ អង្គការនេះបានលើកទឹកចិត្តឱ្យប្រទេសកម្ពុជា គួរតែត្រូវបានចូលនៅក្នុងបញ្ជីបេក្ខភាព នៃប្រទេសដែលបានអនុវត្តជោគជ័យ (Champion Country) ក្នុងការលុបបំបាត់ឬកាត់បន្ថយផលប៉ះពាល់ទៅលើជនទេសន្តរប្រវេសន៍។ លោកស្រី ជូ ប៊ុនអេង ថ្លែងថា ការលុបបំបាត់ឬកាត់បន្ថយផលប៉ះពាល់ទៅលើជនទេសន្តរប្រវេសន៍ រួមមានទាំងការរំលោភសិទ្ធិ ផលប្រយោជន៍ សេចក្ដីថ្លៃថ្នូរ ការជួញដូរក្រុមទេសន្តរប្រទេសន៍ និងការធ្វើទារុណកម្ម ដែលហៅថា Global Compact for Safe, Orderly and Regular Migration។ លោកស្រីថ្លែងថា៖ «ឥឡូវនេះដោយសារតែយើងត្រូវបានអង្គការធ្វើការជាមួយគ្នា មើលឃើញ និងលើកទឹកចិត្ត ប្រមុខរាជរដ្ឋាភិបាលបានដាក់លិខិតទៅអង្គការសហប្រជាតិ។ យើងបានដាក់លិខិតទៅកាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំនេះរួចហើយ»។

បើតាមលោកស្រី ជូ ប៊ុនអេង ដើម្បីចូលក្នុងបញ្ជីជាបេក្ខភាពនៃប្រទេសដែលបានអនុវត្តជោគជ័យ គឺរាជរដ្ឋាភិបាលបាននិងកំពុងជំរុញការអនុវត្តសកម្មភាពយ៉ាងសកម្មលើការប្រមូលទិន្នន័យពាក់ព័ន្ធទៅនឹងអំពោះការជួញដូរមនុស្ស និងពលករចំណាកស្រុក ទេសន្តរប្រទេសន៍ឱ្យបានល្អ និងការអនុវត្តកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយប្រទេសដែលមានទំនាក់ទំនងផងដែរ។ លោកស្រីបញ្ជាក់ថា៖ «ការចូលជាសមាជិកនេះ គឺជារឿងសកលដែលទាក់ទងទៅនឹងការអនុវត្ត កតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ក្នុងនោះក៏មានករណីជួយដូរមនុស្សផងដែរ។ ប៉ុន្តែអ្វីដែលអង្គការដៃគូជំរុញលើកទឹកចិត្តនេះ បន្ទាប់ពីឃើញកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តកតិកាសញ្ញាជាសកនេះ»។ លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថាឆ្នាំ ២០២០ គ.ជ.ប.ជ. រាជធានី-ខេត្ត បានបន្តសកម្មភាពរបស់ខ្លួនទៅតាមទិសដៅដែលបានគ្រោងទុក ទោះបីមានបញ្ហាជំងឺកូវីដ ១៩ និងបញ្ហាប្រឈមមួយចំនួនទៀតក៏ដោយ។ លោកស្រីថ្លែងថា ដើម្បីឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា មានប្រសិទ្ធភាព ភាគីពាក់ព័ន្ធត្រូវប្រកាន់គោលការណ៍សកម្មភាពមួយចំនួន ដូចជា ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជួយជនរងគ្រោះ និងការអនុវត្តច្បាប់។ លោកស្រីបញ្ជាក់ថា ក្នុងដំណាក់កាលកម្ពុជាកំពុងប្រឈមទៅនឹងជំងឺកូវីដ ១៩ វិបត្តិសេដ្ឋកិច្ច នាំឱ្យពលករអត់ការងារធ្វើ ដោសារការបិទរោងចក្រទាំងនៅប្រទេសកម្ពុជា និងថៃ។ កត្តានេះពលករខ្មែរបានត្រឡប់ពីប្រទេសថៃ មកម្ពុជាវិញកាលពីឆ្នាំ ២០២០ មានជាង ១៣ ម៉ឺននាក់។ លោកស្រីថ្លែងថា៖ «ឱកាសនេះឯង ដែលជនជួញដូរមនុស្សឆ្លៀតឱកាស ដើម្បីយកផលចំណេញពីកម្មករ-កម្មការិនី ដែលអត់ការងារធ្វើ។ ដូច្នេះសមត្ថកិច្ចពាក់ព័ន្ធត្រូវមានវិធានការបន្ថែមទៀត ដើម្បីទប់ស្កាត់ការនាំមនុស្សចេញដោយខុសច្បាប់»។

អង្គការ IOM ប្រចាំកម្ពុជា កោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសជាមួយនឹងលោកស្រី ជូ ប៊ុនអេង តាមរយៈកិច្ចសហប្រតិបត្តិការជាមួយគ្នាកន្លងមក។ អង្គការ

IOM បញ្ជាក់ថា ពិសេសចំណារយល់ព្រមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានគាំទ្រឲ្យកម្ពុជាក្លាយជាប្រទេសសមាជិកនៃប្រទេស ដែលបានអនុវត្តដោយជោគជ័យក្នុងការលុបបំបាត់ ឬកាត់បន្ថយផលប៉ះពាល់ទៅលើជនទេសន្តរប្រវេសន៍សកលនេះ៕

## តំណាង FBI នៅកម្ពុជា៖ ការវាយតម្លៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាកន្លងទៅ មានការភ័ន្តច្រឡំ និងមិនបានស្វែងយល់ការពិតពីកម្ពុជា

http://www.freshnewsasia.com/ 2021-02-02 11:07am

**(ភ្នំពេញ)៖** លោក Steve Stuehser អនុព័ន្ធច្បាប់តំណាង FBI ប្រចាំស្ថានទូតអាមេរិកនៅកម្ពុជា បានលើកឡើងថា ការវាយតម្លៃអំពីការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា នាពេលកន្លងមក អាចមានការភាន់ច្រឡំ ខ្វះមូលដ្ឋានព័ត៌មាន និងមិនទាន់ស្វែងយល់ច្បាស់លាស់អំពីស្ថានភាពពិតរបស់ប្រទេសកម្ពុជា។

ក្នុងឆ្នាំ២០២០កន្លងទៅ សហរដ្ឋអាមេរិក បានដាក់ចំណាត់ថ្នាក់លេខ២ជូនកម្ពុជា ស្ថិតក្រោមការឃ្លាំមើលរឿងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងចាត់ទុកថា ជារឿងអយុត្តិធម៌សម្រាប់កម្ពុជា ដែលកំពុងខិតខំយ៉ាងខ្លាំងដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ចំណាត់ថ្នាក់លេខ២ ជាប្រទេសស្ថិតក្រោមការឃ្លាំមើល ដែលដាក់ផ្តល់ដោយសហរដ្ឋអាមេរិក មកលើប្រទេសកម្ពុជានេះ មានន័យថា ប្រទេសកម្ពុជា បានប្រឹងប្រែងតិចតួចប៉ុណ្ណោះ ក្នុងការប្រយុទ្ធប្រឆាំងជាមួយអំពើជួញដូរមនុស្ស។ ការលើកឡើងបែបនេះរបស់លោក Steve Stuehser ធ្វើឡើងក្នុងជំនួបពិភាក្សាការងារជាមួយ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នៅរសៀលថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងគោលបំណងបន្តពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្តច្បាប់ នៃភាគីអាមេរិក ជាមួយនគរបាលជាតិកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ។

ក្នុងជំនួបនោះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានធ្វើការបំភ្លឺយ៉ាងច្បាស់លាស់អំពីទិដ្ឋភាពច្បាប់ បទពិសោធន៍ និងស្ថានភាពជាក់ស្តែង ដោយបានធ្វើឲ្យតំណាងភាគីអាមេរិក យល់កាន់តែច្បាស់អំពីស្ថានភាពពិត នៃកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពីជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។ តាមរយៈការបកស្រាយរបស់ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានធ្វើឱ្យភាគីអាមេរិកយល់ច្បាស់ពីស្ថានភាពពិត អំពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជា។ តំណាងភាគីអាមេរិក សន្យាថា នឹងធ្វើរបាយការណ៍ច្បាស់លាស់បញ្ជូនទៅទីក្រុងវ៉ាស៊ីនតោន អំពីស្ថានភាពពិតនៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។

ភាគីទាំងពីរ បានបង្ហាញអំពីទស្សនៈឯកភាពគ្នា ដើម្បីបន្តកិច្ចសហការឲ្យកាន់តែល្អប្រសើរថែមទៀតដោយជំរុញកិច្ចសហការផ្លាស់ប្តូរព័ត៌មាន ឲ្យបានច្បាស់លាស់ រួមទាំងការផ្តល់ទិន្នន័យបទល្មើស និងលទ្ធផលបង្ក្រាបអំពើជួញដូរមនុស្ស។ សហការជួយគាំទ្រការលើកកម្ពស់ធនធានមនុស្ស ដោយភាគីអាមេរិកបានរៀបចំកញ្ចប់ថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលលើមុខជំនាញស៊ើបអង្កេត និងការប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

គួរជម្រាបថា ក្នុងឆ្នាំ២០២០កន្លងទៅ សហរដ្ឋអាមេរិក បានដាក់ចំណាត់ថ្នាក់លេខ២ជូនកម្ពុជា ស្ថិតក្រោមការឃ្លាំមើលរឿងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងចាត់ទុកថា ជារឿងអយុត្តិធម៌សម្រាប់កម្ពុជា ដែលកំពុងខិតខំយ៉ាងខ្លាំងដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ចំណាត់ថ្នាក់លេខ២ ជាប្រទេសស្ថិតក្រោមការឃ្លាំមើលដែលដាក់ផ្តល់ដោយសហរដ្ឋអាមេរិក មកលើប្រទេសកម្ពុជានេះ មានន័យថា ប្រទេសកម្ពុជា បានប្រឹងប្រែងតិចតួចប៉ុណ្ណោះ ក្នុងការប្រយុទ្ធប្រឆាំងជាមួយអំពើជួញដូរមនុស្ស៕

## អាមេរិកសន្យា ធ្វើរបាយការណ៍ច្បាស់លាស់ ពីការខិតខំប្រឹងប្រែង ប្រឆាំងអំពើជួញ ដូរមនុស្សនៅកម្ពុជា

https://dap-news.com/national/ ByPH104 Posted on February 2, 2021

ភ្នំពេញ ៖ សហរដ្ឋបានអាមេរិកសន្យាថា នឹងធ្វើរបាយការណ៍ច្បាស់លាស់ បញ្ជូនទៅទីក្រុងវ៉ាស៊ីនតោន អំពីស្ថានភាពពិត នៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ នេះបើយោងតាមការ ចេញផ្សាយអគ្គស្នងការដ្ឋាន នគរបាលជាតិ។

កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានទទួលជួបពិភាក្សាការងារជាមួយ តំណាងភាគីអាមេរិក ក្នុងគោលបំណងបន្តពង្រឹង កិច្ចសហការរវាង មន្ត្រីអនុវត្តច្បាប់ នៃភាគីអាមេរិក ជាមួយនគរបាលជាតិកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ។ នាឱកាសនោះ កម្ពុជា-អាមេរិក បានឯកភាពគ្នាធ្វើការវាយតម្លៃខ្ពស់ ចំពោះលទ្ធផលដ៏ល្អប្រសើរនៃភាគីទាំងពីរ ដែលជាផ្នែកមួយយ៉ាងសំខាន់ ឆ្លុះបញ្ចាំងអំពីចំណង ទំនាក់ទំនងយ៉ាងល្អប្រសើររវាងកម្ពុជា អាមេរិក ។ បន្ថែមពីនេះទៀត ភាគីទាំងពីរ ក៏បានពិភាក្សាគ្នា ចំពោះអនុសាសន៍អាមេរិក ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងនោះ នាយឧត្តមសេនីយ៍ នេត សាវឿន បានធ្វើការបំភ្លឺយ៉ាងច្បាស់លាស់ អំពីទិដ្ឋភាពច្បាប់ បទពិសោធន៍ និងស្ថានភាពជាក់ស្តែង ដោយបានធ្វើឲ្យតំណាងភាគី អាមេរិកយល់កាន់តែច្បាស់ អំពីស្ថានភាពពិត នៃកិច្ចខិតខំប្រឹងប្រែង របស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំង អំពីជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។

ជាការឆ្លើយតប តំណាងភាគីអាមេរិក បានសន្យាថា «នឹងធ្វើរបាយការណ៍ច្បាស់លាស់ បញ្ជូនទៅទីក្រុងវ៉ាស៊ីនតោន អំពីស្ថានភាពពិត នៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សនៅកម្ពុជា»។ ឆ្លៀតឱកាសនោះដែរ កម្ពុជា-អាមេរិក បានបង្ហាញអំពីទស្សនៈឯកភាពគ្នា ដើម្បីបន្តកិច្ចសហការ ឲ្យកាន់តែល្អ ប្រសើរថែមទៀត រួមមាន ៖ ជំរុញកិច្ចសហការផ្លាស់ប្តូរព័ត៌មានឲ្យបានច្បាស់លាស់ រួមទាំង ការផ្តល់ទិន្នន័យបទល្មើស និងលទ្ធផលបង្ក្រាបអំពើជួញដូរមនុស្ស ,សហការជួយគាំទ្រការលើកកម្ពស់ធនធានមនុស្ស ដោយភាគីអាមេរិក បានរៀបចំកញ្ចប់ថវិកា សម្រាប់កម្មវិធីបណ្តុះបណ្តាលលើមុខជំនាញស៊ើបអង្កេត និងការប្រឆាំងអំពើជួញដូរមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

សូមបញ្ជាក់ថា សមាសភាពតំណាងភាគីអាមេរិក ចូលជួបពិភាក្សាការងារជាមួយ នាយឧត្តមសេនីយ៍ នេត សាវឿន រួមមាន ៖ លោក Steve Stuehser អនុព័ន្ធច្បាប់តំណាង FBI ប្រចាំស្ថានទូតអាមេរិកនៅកម្ពុជា ,លោក Russell Bash អនុព័ន្ធច្បាប់តំណាង ICE ប្រចាំស្ថានទូត អាមេរិកនៅកម្ពុជា និងលោក Weldon Montgomery មន្ត្រីផ្នែកនយោបាយ ទទួលបន្ទុករៀបចំរបាយការណ៍ ប្រចាំស្ថានទូតអាមេរិកនៅកម្ពុជា៕

## ចាប់ពីឆ្នាំ២០០៧ មកដល់បច្ចុប្បន្ន កម្ពុជាបញ្ជូនពលករខេិត ៧ម៉ឺននាក់ ទៅកាន់សាធារណរដ្ឋកូរ៉េ

https://dap-news.com/national/ ByVNT108 Posted on February 2, 2021

ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា បានឱ្យដឹងថា គិតចាប់ពីឆ្នាំ២០០៧ មកដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនពលករ សរុបចំនួន ៦៨ ២៩៤នាក់ (ស្រី ១៤ ២៥៥នាក់) ទៅធ្វើការងារនៅកូរ៉េខាងត្បូង ក្នុងវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារ មានរយៈពេល ៤ឆ្នាំ ១០ខែ។ នេះបើយោងតាមហ្វេសប៊ុកផេក របស់លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការអោយដឹងបែបនេះធ្វើឡើងនៅ ក្នុងឱកាស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រ

កម្ពុជា និងក្រសួងការងារ និងមុខរបរ នៃសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខា បន្តអនុស្សរណៈយោគយល់គ្នា ស្តីពីការបញ្ជូនពលករទៅបម្រើការងារ នៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) លើកទី៦។

សូមបញ្ជាក់ ការបញ្ជូនពលករកម្ពុជា ទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) បានចុះអនុស្សរណៈនៃការយោគយល់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម Roh Moo-Hyun អតីតប្រធានាធិបតី នៃសាធារណរដ្ឋកូរ៉េ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលមាន គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងមុខរបរនិងការងារ នៃសាធារណរដ្ឋកូរ៉េ ជាប្រតិបត្តិករ។

ក្រសួងបញ្ជាក់ថា «គិតចាប់ពីឆ្នាំ២០០៧មក កម្ពុជាបានបញ្ជូនពលករ សរុបចំនួន ៦៨ ២៩៤នាក់ (ស្រី ១៤ ២៥៥នាក់) ក្នុងវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារមានរយៈពេល ៤ឆ្នាំ ១០ខែ។ បច្ចុប្បន្ន ពលករកម្ពុជា ដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ មានចំនួនប្រមាណ ៤៥ ៤៦២នាក់ (ស្រី ១០ ១៨៣នាក់)»។ ក្រសួងបញ្ជាក់បន្ថែមថា តាំងពីចាប់ផ្តើមនៃការបញ្ជូនមក កម្ពុជាតែងតែជាប់ចំណាប់ថ្នាក់ល្អ ជាប្រទេសបញ្ជូន និងតាមរយៈការពិភាក្សារវាងភាគីកម្ពុជា-កូរ៉េ បន្ទាប់ពីស្ថានភាពកូវីដ ១៩នៅសាធារណរដ្ឋកូរ៉េ មានភាពធូរស្រាល ដែលអាចទទួលយកកម្លាំង ពលកម្មបរទេស បានកម្ពុជារំពឹងថានឹងក្លាយជា ប្រទេសអាទិភាពក្នុងការបញ្ជូន ដោយសារកម្ពុជា មានស្ថានភាពកូវីដ-១៩ល្អប្រសើរ, មានជើងហោះហើរច្រើន និងអត្រាពលករកម្ពុជាខុសច្បាប់មានកំរិតទាប បើធៀបជាមួយប្រទេស បញ្ជូនផ្សេងទៀត៕

## ឃាត់ខ្លួនមេខ្យល់២នាក់នាំពលករឆ្លងដែនចូលប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 02/02/2021

កម្លាំងសមត្ថកិច្ចចម្រុះ ឈរជើង នៅចំណុចច្រករបៀងស្វាយចេក ក្នុងទឹកដីស្រុកកំរៀង បានធ្វើការឃាត់ខ្លួនមេខ្យល់២នាក់ នាំពលករខ្មែរចូលទៅប្រទេសថៃ អំឡុងដែលប្រទេសថៃផ្ទុះជំងឺឆ្លងកូវីដ-១៩ ។ ការឃាត់ខ្លួនមេខ្យល់ទាំង២នាក់នោះ ធ្វើឡើងតាមការឯកភាពពីព្រះរាជអាជ្ញាខេត្តផងដែរ ។ ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង១២និង៥៥នាទី ថ្ងៃត្រង់ នៅចំណុចភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ដោយសារតែជនសង្ស័យទាំង ២ នាក់នេះ ជាប់ពាក់ព័ន្ធនិងករណីនាំយកពលករចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន។

សមត្ថកិច្ចបញ្ជាក់ថា ជនសង្ស័យទាំងពីរនាក់ដែលត្រូវបានឃាត់ខ្លួនទី១/ ឈ្មោះ កែវ ជ្រឹង ភេទប្រុស អាយុ៥៧ឆ្នាំ រស់នៅភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មុខរបរលក់ដូរ និងទី២/ ឈ្មោះ គឿក ក្រុងប៉ាត់ហៅ(ចាន់) ភេទប្រុស អាយុ៤៤ឆ្នាំ រស់នៅភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មុខរបរកម្មករ ដែលបានធ្វើសកម្មភាពលួចនាំយកពលករខ្មែរចំនួន០៤ នាក់ ( ស្រី ១ នាក់ ) ដើម្បីឆ្លងចូលមកប្រទេសកម្ពុជា ហើយក៏ត្រូវកម្លាំងចម្រុះប្រចាំនៅគោលដៅប៉ុស្តិ៍នគរបាលច្រករបៀងស្វាយចេកឃាត់ខ្លួនបាន។

នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យទាំងពីរនាក់នោះបានឆ្លើយសារភាពថា ពួកខ្លួនពិតជាបាននាំពលករចំនួន០៤នាក់ខាងលើពិតប្រាកដមែន ហើយយកថ្លៃឈ្នួលក្នុងម្នាក់ចំនួន១០០០(មួយពាន់)បាត ដើម្បីឆ្លងដែនចូលមកប្រទេសកម្ពុជា(ស្រុកកំរៀង)។បច្ចុប្បន្នករណីខាងលើនេះជំនាញបានធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២ នាក់ តាមបញ្ជារបស់លោកព្រះរាជអាជ្ញា ដើម្បីកសាងសំណុំរឿងបញ្ជូនទៅការិយាល័យចាត់ការបន្តតាមនីតិវិធី៕

## ចៅក្រម បានសម្រេចឃុំខ្លួន មេខ្យល់ ២ នាក់ ពីបទនាំពលករឆ្លងដែនខុសច្បាប់ ចេញចូលប្រទេសថៃ

https://www.rasmeinews.com/ 2 February, 2021

**ដោយៈ គ្រញូង / បាត់ដំបងៈ** *កាលពីព្រឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ ចៅក្រមនៃសាលាដំបូង ខេត្តបាត់ដំបង បានសម្រេចឃុំខ្លួន ជនសង្ស័យ ចំនួន២នាក់ ដែលជាមុខសញ្ញាមេខ្យល់ នាំពលករខ្មែរឆ្លងដែន ចេញ ចូលទៅកាន់ប្រទេសថៃ ខុសច្បាប់។ ជនទាំង២នាក់នេះ ត្រូវកម្លាំងសមត្ថកិច្ចចម្រុះ ដែលឈរជើងនៅចំណុចច្រករបៀង ស្វាយចេក ឃាត់ខ្លួន បាន តាមការឯកភាពពីលោក គឺ ប៊ុណ្ណារ៉ា ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តកាលពីរសៀល ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ នៅចំណុចភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។*

លោកវរសេនីយ៍ឯក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង បានឲ្យដឹងថាៈ ជនសង្ស័យ ទាំងពីរនាក់នេះ មានឈ្មោះ កែវ ជ្រឹង អាយុ ៥៧ ឆ្នាំ មានមុខរបរ ជាអ្នកលក់ដូរ និងឈ្មោះ តឿក ក្រុងប៉ាត់ ហៅ ចាន់ អាយុ ៤៤ ឆ្នាំ មានមុខរបរ ជាកម្មករ ។ បុរសមេខ្យល់ ២ នាក់នេះ រស់នៅភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ជាមួយគ្នាហើយបានធ្វើ សកម្មភាព លួចនាំយកពលករខ្មែរ ចំនួន ៤ នាក់ (ស្រី១នាក់) ដើម្បីឆ្លងចូលមកប្រទេសកម្ពុជា ហើយក៏ត្រូវកម្លាំងចម្រុះ ប្រចាំនៅគោលដៅប៉ុស្តិ៍នគរបាល ច្រករបៀង ស្វាយចេក ឃាត់ខ្លួនបាន។

នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យទាំងពីរនាក់នោះ បានឆ្លើយសារភាពថាៈ ពួកខ្លួន ពិតជាបាននាំពលករ ចំនួន ៤ នាក់ ពិតប្រាកដមែន ហើយយកថ្លៃឈ្នួល ក្នុងម្នាក់ ចំនួន ១.០០០ បាត (ប្រាក់ថៃ) ដើម្បីឆ្លងដែនចូលមកប្រទេសកម្ពុជា (ស្រុកកំរៀង)។ បច្ចុប្បន្ន ករណីខាងលើនេះ មន្ត្រីជំនាញ បានឃាត់ខ្លួនជនសង្ស័យ ទាំង២នាក់ តាមបញ្ជា របស់លោក ព្រះរាជអាជ្ញា គឺ ប៊ុណ្ណារ៉ា ដើម្បីកសាងសំណុំរឿង បញ្ជូនទៅឃុំខ្លួន បណ្តោះអាសន្ន រង់ចាំកាត់ក្តី នៅពេលក្រោយ៕/V-PC

## តុលាការកំពូលតម្កល់ទោសស្ត្រីម្នាក់ ៧ ឆ្នាំដដែល ពីបទសញ្ញារកម្ម

https://www.postkhmer.com/ គឹម សារុំ | Publication date 02 February 2021 | 17:09 ICT

**ភ្នំពេញៈ** តុលាការកំពូលកាលពីម្សិលមិញបានប្រកាសសាលដីកាតម្កល់ទោស ស្ត្រីម្នាក់ឲ្យជាប់ពន្ធនាគារ ៧ ឆ្នាំដដែល បន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ២៥ មករាពាក់ព័ន្ធបើកហាងម៉ាស្សាបង្កប់សេវាផ្លូវភេទ ប្រព្រឹត្តនៅសង្កាត់ស្ទឹងមានជ័យកាលពីឆ្នាំ ២០១៧។

លោកចៅក្រម សាលី ធារ៉ា បានប្រកាសសាលដីកាមុនស្ត្រីជាប់ចោទចូលមកបង្ហាញមុខក្នុងបន្ទប់សវនាការពីម្សិលមិញថា សំណុំរឿងនេះមានស្ត្រីជាប់ចោទឈ្មោះ សុខា សុថារី អាយុ ៣៨ ឆ្នាំ ជាប់ចោទពីបទសញ្ញារកម្មមានស្ថានទម្ងន់ទោស។ ប៉ុន្តែដោយសារតែជនជាប់ចោទអវត្តមានក្នុងពេលប្រកាសសាលដីកា ដូច្នេះតុលាការមិនលើកពីមូលហេតុនៃការពិភាក្សាមកអានជូនក្នុងអង្គសវនាការទេ ដោយអានតែសេចក្តីសម្រេចប៉ុណ្ណោះ។ លោកថ្លែងថា៖ « តុលាការកំពូល សម្រេចតម្កល់ទោសតាមអំណាចសាលដីការបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី ១២ សីហា ឆ្នាំ ២០២០ ទុកជាបានការដដែល និងបន្តឃុំខ្លួនស្ត្រីជាប់ចោទបន្តទៀត»។

បើតាមកំណត់ហេតុនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញស្ត្រីជាប់ចោទឈ្មោះ សុខា សុថារី បានបើកហាងកាត់សក់បុរស និងកន្លែងម៉ាស្សា តាមបណ្តោយផ្លូវវេងស្រេងក្នុងសង្កាត់ស្ទឹងមានជ័យ។ ស្ត្រីជាប់ចោទត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ ជាមួយក្មេងស្រីមិនទាន់គ្រប់អាយុ ៣ នាក់ និងស្ត្រីពេញវ័យម្នាក់។ ការបង្ក្រាបនេះ សមត្ថកិច្ចបានរំដោះក្មេងស្រីអាយុ ១៥ ឆ្នាំ, ១៦ ឆ្នាំ, ១៧ ឆ្នាំ និងនារីអាយុ ២១ ឆ្នាំម្នាក់។ នៅថ្ងៃឃាត់ខ្លួនពួកគេទាំង ៤ នាក់ឆ្លើយប្រាប់សមត្ថកិច្ចថា ពួកគេពិតជាបានរួមភេទជាមួយភ្ញៀវមែន

ដោយម្តងៗយកកម្រៃពីភ្ញៀវម្នាក់ ៣០ ដុល្លារ ប៉ុន្តែបានដាក់ឱ្យស្ត្រីម្ចាស់ហាង ៥ ដុល្លារ។ សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីនៅថ្ងៃទី ២២ មិថុនា ឆ្នាំ ២០១៨ ផ្តន្ទាទោសស្ត្រីជាប់ចោទ ៧ ឆ្នាំ ដោយចោទពីបទសញ្ជារកម្មមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២៨៤,២៨៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែដោយមិនសុខចិត្តស្ត្រីជាប់ចោទបានប្តឹងឧទ្ធរណ៍តែត្រូវឧទ្ធរណ៍តម្កល់ទោស ៧ ឆ្នាំដដែល៕

## សមត្ថកិច្ចឃាត់ពលករខ្មែរ៣នាក់ កំពុងរៀបលួចឆ្លងដែនចូលទៅប្រទេសថៃ

http://nokorwatnews.com/ 02-02-2021

**ខេត្តបន្ទាយមានជ័យ៖** កម្លាំងនគរបាលការពារព្រំដែនគោក៨៩១ សហការជាមួយកម្លាំងយោធាកងពលលេខ៥១ នៅវេលាម៉ោង២នឹង២៥នាទីទៀបភ្លឺថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ បានឃាត់ប្រជាពលរដ្ឋជាពលករខ្មែរលួចឆ្លងដែនចូលទៅប្រទេសថៃ ចំនួន៣នាក់ រួមមាន៖

១-ឈ្មោះ គឿន ឆែម ភេទប្រុស អាយុ៣៥ឆ្នាំ នៅភូមិប្រជាធម្ម សង្កាត់ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

២-ឈ្មោះ កេត ហំ ភេទប្រុស អាយុ១៧ឆ្នាំ រស់នៅភូមិផ្សារកណ្តាល សង្កាត់ក្រុងប៉ោយប៉ែត ។

៣-ឈ្មោះ ត្រេង ចិត្រា ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

អ្នកទាំង៣ត្រូវកម្លាំងសមត្ថកិច្ចប្រទះឃើញនៅមាត់អូរព្រំដែន ចំណុចរោងម៉ាស៊ីនក្រុមហ៊ុនគ្រែនដាយម៉ន ស៊ុ ធីក្រោយនាគមាស ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនធ្វើការអប់រំ។ បន្ទាប់ពីធ្វើការអប់រំលោកវរសេនីយ៍ឯក ហាំ វណ្ណៈ មេបញ្ជាការវរៈ៨៩១ ចាត់កម្លាំងប៉ុស្តិ៍ក្បាលស្ពានដឹកនាំដោយលោកវរសេនីទោ ឈិន ឈាង មេបញ្ជាការរងទទួលទិសបញ្ជូនពលករខ្មែរទាំង៣នាក់ ទៅធ្វើចត្តាឡីស័កនៅមណ្ឌលសុំចត ស្ថិតនៅសាលាបឋមសិក្សា ហ៊ុន សែន ព្រហ្មនិម្មិត ភូមិក្បាលស្ពាន២ សង្កាត់ក្រុងប៉ោយប៉ែត ៕

## កិច្ចប្រជុំស្តីពីការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងចាត់វិធានការការពារការរីករាលដាលនៃជម្ងឺកូវីដ-១៩

https://gdlf-kh.com/ 2021/02/02/Kao sophy ខេត្តកោះកុង

ខេត្តកោះកុង៖ ថ្ងៃអង្គារ ៥ រោច ខែមាឃ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០២១ លោក សំឃិត វៀន អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង បានអញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងចាត់វិធានការការពារការរីករាលដាលនៃជម្ងឺកូវីដ-១៩ លោកអភិបាលរងខេត្តបានលើកឡើងថា ជំងឺកូវីដ-១៩ កំពុងតែរីករាលដាលខ្លាំង និងបានបំលែងខ្លួនយ៉ាងរហ័ស ជាមួយគ្នានេះដែរប្រទេសកម្ពុជាយើងភាគច្រើនបាននាំចូលមកពីក្រៅប្រទេស ថ្មីៗនេះតាមរយៈពលករ ដែលបានវិលមកពីប្រទេសថៃ ក៏មានការឆ្លងច្រើនដែរ ជាមួយគ្នានេះខេត្តរបស់យើងក៏តែងតែមានពលករចូលជាបន្តបន្ទាប់ តែត្រូវបានអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងខេត្តរបស់យើងសហការបានល្អ បាននាំពួកគាត់មកមណ្ឌលចត្តាឡីស័ក បានត្រឹមត្រូវតាមគោលការណ៍ណែនាំ របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ដើម្បីឱ្យការងារចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ សូមអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់បន្តពង្រឹងការអនុវត្តឱ្យបសនល្អបន្ថែមទៀត ទាំងតាមបន្ទាត់ព្រំដែន និងមណ្ឌលចត្តាឡីស័កនានាទូទាំងខេត្ត៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី០២ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១១៦នាក់ ស្រី ៤៩នាក់ ក្នុងនោះកុមារា ៦នាក់ កុមារី ៥នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ ២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១២នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ១នាក់។ ៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៦នាក់ ស្រី ១១នាក់ កុមារា ១នាក់ កុមារី ០០នាក់។ ៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៧៨នាក់ ស្រី ៣២នាក់ កុមារា ៥នាក់ កុមារី ៤នាក់។ ៥- ច្រកដូង ស្រុកកំរៀង ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ១១៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣៨នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យ ចំនួន ៧៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរខេត្តឧត្តរមានជ័យ បង្កើនការប្រុងប្រយ័ត្ន លើការពិនិត្យសុខភាពពលករមកពីថៃ

http://btv.com.kh/ 02/02/2021

ឧត្តរមានជ័យ ៖ អាជ្ញាធរខេត្តមានជ័យ កាន់តែបង្កើនការប្រុងប្រយ័ត្នលើការត្រួតពិនិត្យសុខភាពពលករមកពីថៃ ខណៈដែលប្រទេសនេះ កំពុងតែរងនូវការរាតត្បាតដោយកូវីដ–១៩ ក្នុងសហគមន៍។ អភិបាលខេត្តឧត្តរមានជ័យ និងជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ឯកឧត្តម ប៉ែន កុសល្យ បានជំរុញអាជ្ញាធរឈរជើងនៅតាមព្រំដែននៃខេត្តនេះ ទាំងអស់ បង្កើនការទប់ស្កាត់យ៉ាងតឹងរ៉ឹង នៅតាម ច្រកព្រំដែនសំខាន់ៗ និងច្រករបៀងនានា ខណៈមានកំណើនរំហូរពលករខ្មែរ មកពីប្រទេសថៃ ចូលមក កម្ពុជា ដោយសារតែមានការបារម្ភឆ្លងកូវីដ–១៩។ ឯកឧត្តម អភិបាលខេត្ត បានបន្តឲ្យដឹងថា មកទល់ពេលនេះ ពលករខ្មែរ នៅតែបន្តការធ្វើដំណើរ ចូលមកកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងច្រកទ្វារព្រំដែនជាំសាងាំ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ដោយក្នុងនោះ មានមកពីបណ្ដាខេត្តផ្សេងៗគ្នា នៃព្រះរាជាណាចក្រថៃ ដែលបានកំពុងផ្ទុះ នូវជំងឺ កូវីដ–១៩ នៅតាមសហគមន៍យ៉ាងខ្លាំងគួរឲ្យបារម្ភនោះ។ ឯកឧត្តម បានបញ្ជាក់ថា បញ្ហាប្រឈមទាំងអស់នេះហើយ ដែលមន្ត្រីចត្តាឡីស័ក ដែលកំពុងឈរ ជើងនៅតាមបណ្ដាច្រកព្រំដែនទាំងអស់ ត្រូវតែរួមគ្នាបំពេញការងារត្រួតពិនិត្យឱ្យបានហ្មត់ចត់ កុំឱ្យពលករ លួចឆ្លងដែនខុសច្បាប់ មិនព្រមចូលមកធ្វើចត្តាឡីស័ក ដើម្បីពិនិត្យរកមេរោគកូវីដ–១៩នោះ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា គិតត្រឹម ថ្ងៃទី២ ខែកុម្ភៈ នេះ មានពលករ ជាង៦ពាន់៣រយនាក់ បានឆ្លងដែនចូលមកតាមច្រកអូរស្មាច់ និងច្រកជាំសាងាំ និងកំពុងត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក ចំនួនជាង២ពាន់នាក់ និងបានចេញជាបន្តបន្ទាប់ផងដែរ។ ហើយអ្វី ដែលជាបញ្ហា

ប្រឈមនោះ គឺបញ្ហាទឹកភ្លើង ដោយសារតែការប្រើប្រាស់ច្រើន នៅតាមមណ្ឌល ចត្តាឡីស័ក ព្រោះរដូវនេះ អាកាសធាតុក្តៅ៕ អត្ថបទ៖ ឃិន សារិទ្ធ

## ក្នុងរយៈពេលតែជាងមួយម៉ោងមានពលករចំណាកស្រុកជាង ២០០ នាក់បានឆ្លងដែនពីថៃចូលកម្ពុជាតាមច្រកអូរស្មាច់

https://www.khmertimeskh.com/ February 2, 2021 Khmer Times

កាសែតខ្មែរថាមស៍បានរកឃើញថា កម្មករចំណាកស្រុកកម្ពុជាជាង ២០០ នាក់បានឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជាតាមច្រកអូរស្មាច់ ខេត្តឧត្តមានជ័យ ត្រឹមតែចន្លោះពីម៉ោង ៩ ដល់ម៉ោង ១០ កន្លះព្រឹកថ្ងៃនេះ។ ពលករកម្ពុជាទាំងនេះបានប្រមូលផ្តុំគ្នានៅទីតាំងមួយក្នុងទឹកដីថៃ ចម្ងាយប្រមាណ ១០ គីឡូម៉ែត្រពីច្រកអូរស្មាច់កាលពីយប់ម្សិលមិញ។ ក្រោយមកពួកគេត្រូវបានដឹកដោយរថយន្តមកពីខាងថៃនាំមកទីតាំងមួយទៀត ស្ថិតនៅចម្ងាយប្រហែល ១០០ ម៉ែត្រពីច្រកព្រំដែន ហើយពួកគេបានដើរឆ្លងកាត់ច្រកព្រំដែន។ ជាមួយនឹងឥវ៉ាន់ជាប់ខ្លួនរណេងរណោង ពលករដែលកំពុងវិលត្រលប់មកកម្ពុជាវិញទាំងនោះ ត្រូវបានវាស់សីតុណ្ហភាព និងក្រោយមកត្រូវបានដឹកដោយរថយន្តយោធាទៅទីតាំងធ្វើចត្តាឡីស័ក ដែលពួកគេនឹងត្រូវទទួលការធ្វើតេស្តរកមេរោគកូវីដ-១៩។

## ក្មេងស្រីខ្មែរឥស្លាម រងគ្រោះដោយម្ចាស់ផ្ទះធ្វើទារុណកម្មកាត់ត្រចៀក បានត្រឡប់មកដល់កម្ពុជា

https://www.cen.com.kh/ February 2, 2021

ភ្នំពេញ ៖ ក្មេងស្រីខ្មែរឥស្លាមបម្រើការងារជាជំនួយការមេផ្ទះ នៅប្រទេសម៉ាឡេស៊ី រងគ្រោះដោយម្ចាស់ផ្ទះធ្វើទារុណកម្មកាត់ត្រចៀក ត្រូវបានអាជ្ញាធរខ្មែរអន្តាគមន៍សង្គ្រោះ និងបានត្រឡប់មកដល់កម្ពុជាវិញហើយ។ នៅរសៀលថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានផ្តល់ព័ត៌មានផ្លូវការឲ្យដឹងថា ក្មេងស្រីខ្មែរឥស្លាមបម្រើការងារជាជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ីរងគ្រោះដោយម្ចាស់ផ្ទះធ្វើទារុណកម្មកាត់ត្រចៀក ត្រូវបានអាជ្ញាធរខ្មែរ សហការជាមួយអាជ្ញាធរម៉ាឡេស៊ី ក្រោមការសម្របសម្រួលពីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជួយអន្តាគមន៍សង្គ្រោះដោយជោគជ័យ និងបានបញ្ជូនត្រឡប់មកដល់កម្ពុជា នាថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង៤៥នាទីរសៀល តាមជើងយន្តហោះអាកាសចរណ៍សិង្ហបុរីលេខSQ5008។ ពលការិនីរងគ្រោះដោយអំពើព្រៃផ្សៃនេះមានឈ្មោះ អូស្មាន ក្រីម៉ះ ភេទស្រី អាយុ១៦ឆ្នាំ ។

សូមរំលឹកថា កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារប្រតិកម្មរហ័ស នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានពិនិត្យឃើញថា មានការចែករំលែកជាបន្តបន្ទាប់លើបណ្តាញសង្គម ពាក់ព័ន្ធនឹងករណីហិង្សាដែលកើតឡើងលើពលការិនីជនជាតិខ្មែរអ៊ីស្លាមម្នាក់នៅប្រទេសម៉ាឡេស៊ី។ ករណីនេះត្រូវបានដាក់ជូននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីអនុវត្តជំនាញ និងជួយអន្តាគមន៍។ នៅរសៀលថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានឲ្យដឹងថា ស្ត្រីជនជាតិខ្មែរអ៊ីស្លាមម្នាក់ដែលត្រូវបានគេសរសេរសារបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកថា "ក្មេងស្រីខ្មែរម្នាក់បម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ីត្រូវម្ចាស់ផ្ទះធ្វើទារុណកម្ម និងកាត់ស្លឹកត្រចៀកយ៉ាងព្រៃផ្សៃ" នោះត្រូវបានជួយសង្គ្រោះដោយជោគជ័យ ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលពីស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី

និងសហការជាមួយសមត្ថកិច្ចម៉ាឡេស៊ីផងដែរ ទើបឈានដល់ការរំដោះនារីរងគ្រោះ និងបានបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ។

ឧត្តមសេនីយ៍ ជីវ ផល្លី បានបញ្ជាក់បន្ថែមថា សមត្ថកិច្ចម៉ាឡេស៊ីកំពុងស៊ើបអង្កេតដើម្បីមានចំណាត់ការបន្តលើជនដៃដល់ រីឯជនរងគ្រោះ បន្ទាប់ពីព្យាបាលជាសះស្បើយពីរបួស ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី នឹងរៀបចំសម្របសម្រួលឲ្យវិលត្រឡប់មកកម្ពុជាវិញ ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានសង្កត់ធ្ងន់ថា ជាទិសដៅនៅពេលដែលនារីរងគ្រោះខាងលើ បានត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាវិញ ជំនាញរបស់នាយកដ្ឋាន សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីធ្វើការស៊ើបអង្កេតស្វែងរកជនសង្ស័យជាមេខ្យល់នាំនារីរងគ្រោះខាងលើទៅបម្រើការងារនៅប្រទេសម៉ាឡេស៊ី ដើម្បីឈានដល់ការអនុវត្តនីតិវិធីនាំខ្លួនជនសង្ស័យមកផ្តន្ទាទោសតាមច្បាប់។ ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អាជ្ញាធរម៉ាឡេស៊ី និងស្ថាប័នពាក់ព័ន្ធ បានរួមចំណែកលើការងារនេះ និងសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ក្រសួងការងារកម្ពុជា និងក្រសួងការងារកូរ៉េ ចុះហត្ថលេខាបន្តអនុស្សរណៈយោគយល់គ្នា ស្តីពី ការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) លើកទី៦

https://www.cen.com.kh/ February 2, 2021

ភ្នំពេញ៖ នៅថ្ងៃទី២ ខែកុម្ភៈ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារ និងមុខរបរ នៃសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខាបន្តអនុស្សរណៈយោគយល់គ្នា ស្តីពីការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) លើកទី៦។

សូមបញ្ជាក់ការបញ្ជូនពលករកម្ពុជាទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) បានចុះអនុស្សរណៈនៃការយោគយល់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម Roh Moo-Hyun អតីតប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលមាន គណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងមុខរបរនិងការងារនៃសាធារណរដ្ឋកូរ៉េ ជាប្រតិបត្តិករ។

គិតចាប់ពីឆ្នាំ២០០៧មក កម្ពុជាបានបញ្ជូនពលករសរុបចំនួន ៦៨ ២៩៤នាក់ (ស្រី ១៤ ២៥៥នាក់) ក្នុងវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារមានរយៈពេល ៤ឆ្នាំ ១០ខែ។ បច្ចុប្បន្ន ពលករកម្ពុជាដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ មានចំនួនប្រមាណ ៤៥ ៤៦២នាក់ (ស្រី ១០ ១៨៣នាក់)។ តាំងពីចាប់ផ្តើមនៃការបញ្ជូនមក កម្ពុជាតែងតែជាប់ចំណាប់ថ្នាក់ល្អជាប្រទេសបញ្ជូន និងតាមរយៈការពិភាក្សាវាងភាគីកម្ពុជា-កូរ៉េ បន្ទាប់ពីស្ថានភាពកូវីដ-១៩នៅសាធារណរដ្ឋកូរ៉េមានភាពធូរស្រាល ដែលអាចទទួលយកកម្លាំងពលកម្មបរទេសបានកម្ពុជារំពឹងថានឹងក្លាយជាប្រទេសអាទិភាពក្នុងការបញ្ជូន ដោយសារកម្ពុជាមានស្ថានភាពកូវីដ-១៩ល្អប្រសើរ, មានជើងហោះហើរច្រើន និងអត្រាពលករកម្ពុជាខុសច្បាប់មានកំរិតទាបបើធៀបជាមួយប្រទេសបញ្ជូនផ្សេងទៀត ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

# មេប៉ូលិសកម្ពុជាជួបជាមួយ FBI អាមេរិកពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ

https://www.cen.com.kh/ February 2, 2021

ភ្នំពេញ: នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជួបពិភាក្សាការងារជាមួយតំណាង FBI និងមន្ត្រីខាងផ្នែកនយោបាយ រួមទាំងមន្ត្រីសរសេររបាយការណ៍ប្រចាំស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា កាលពីរសៀលថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានមានប្រសាសន៍ថា គោលបំណងសំខាន់ នៃជំនួបពិភាក្សានេះ គឺការពិគ្រោះយោបល់ ដើម្បីបន្តពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្តច្បាប់កម្ពុជា និងអាមេរិក ក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ។ ហើយភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលសហប្រតិបត្តិការ ដែលកើតចេញពីសកម្មភាពសហការរបស់មន្ត្រីអនុវត្តច្បាប់ និងអង្គភាពអនុវត្តច្បាប់ នៃភាគីទាំងពីរ ដែលក្នុងនោះមាននគរបាលជាតិកម្ពុជា និងខាងអាមេរិក មាន FBI , HSI , ICE ដែលកន្លងមកបានសហការគ្នាបានយ៉ាងល្អប្រសើរ។ ដោយភាគីអាមេរិកបានវាយតម្លៃថា លទ្ធផលទាំងនេះ គឺជាផ្នែកមួយយ៉ាងសំខាន់ឆ្លុះបញ្ចាំងអំពីទំនាក់ទំនងយ៉ាងល្អប្រសើររវាងកម្ពុជា និងសហរដ្ឋអាមេរិក។ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានបន្តថា ភាគីទាំងពីរក៏បានយកការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សមកពិភាក្សា ដែលកន្លងមកខាងក្រសួងការបរទេសសហរដ្ឋអាមេរិក បានដាក់ចេញនូវអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងស្ថានភាពអំពើជួញដូរមនុស្សនៅកម្ពុជា។ ដោយក្នុងកិច្ចពិភាក្សានេះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានស្រាយបំភ្លឺយ៉ាងច្រើននូវបណ្តាអនុសាសន៍មួយចំនួនពាក់ព័ន្ធដល់ដែនសមត្ថកិច្ចរបស់នគរបាលជាតិ ទាំងទិដ្ឋភាពច្បាប់ ទាំងដែនសមត្ថកិច្ច និងទាំងបទពិសោធន៍ រួមទាំងស្ថានភាពជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

តាមការបកស្រាយនេះ ភាគីអាមេរិកបានទទួលយក និងយល់ច្បាស់អំពីស្ថានភាពប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។ ភាគីអាមេរិកក៏បានឯកភាពថា ការវាយតម្លៃអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជានាពេលកន្លងមកហាក់ដូចជាមានការភ័ន្តច្រឡំ ខ្វះមូលដ្ឋានព័ត៌មានច្បាស់លាស់មិនពិតប្រាកដ ដែលធ្វើឲ្យការវាយតម្លៃពុំច្បាស់លាស់មិនមានតម្លាភាព ជាពិសេសគឺការយល់ដឹងអំពីស្ថានភាពពិតនៅកម្ពុជាមិនទាន់បានច្បាស់លាស់។

អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានបន្តទៀតថា ភាគីទាំងពីរបានឯកភាពគ្នាបន្តកិច្ចសហការរួមមានៈ ជម្រុញការផ្លាស់ប្តូរព័ត៌មានគ្នាឲ្យបានច្បាស់លាស់ជាពិសេសប្រឆាំងអំពើជួញដូរមនុស្ស គឺភាគីអាមេរិកស្នើភាគីកម្ពុជាផ្តល់ទិន្នន័យបទល្មើស សភាពការណ៍បទល្មើស និងលទ្ធផលនៃការបង្ក្រាបអំពើជួញដូរមនុស្សនៅកម្ពុជា។ ចំពោះចំណុចនេះ អគ្គស្នងការនគរបាលជាតិបានបើកជំហហរ និងសន្យាផ្តល់ព័ត៌មានឲ្យបានទាន់ពេល និងច្បាស់លាស់ជូនទៅភាគីអាមេរិក។ ជម្រុញកិច្ចសហប្រតិបត្តិការគាំទ្រលើកកម្ពស់ជួយគ្នាក្នុងការកសាងធនធានមនុស្ស ដោយភាគីអាមេរិកបានសន្យាថា នឹងជួយបណ្តុះបណ្តាលជំនាញស៊ើបអង្កេត ប្រឆាំងការជួញដូរមនុស្សតាមរយៈប្រព័ន្ធបច្ចេកវិទ្យាទំនើប តាមសំណូមពររបស់អគ្គស្នងការនគរបាលជាតិ៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២១

### សហរដ្ឋអាមេរិក និងកម្ពុជាជួបពិភាក្សាគ្នាស្ដីពីការទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា

https://www.rfa.org/khmer/ ហេង វស្ន 2021-02-03

មន្ត្រីស្ថានទូតសហរដ្ឋអាមេរិក និងអគ្គស្នងការនគរបាលជាតិបានជួបពិភាក្សាគ្នា ស្ដីពីការទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា។ ជំនួបនេះធ្វើឡើងក្រោយពីក្រសួងការបរទេសសហរដ្ឋអាមេរិក ចេញរបាយការណ៍មួយ កាលពីចុងឆ្នាំ២០២០ រកឃើញថា កម្ពុជាមិនបានគោរពឱ្យបានពេញលេញ តាមបទដ្ឋានអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្សនៅឡើយទេ។

អ្នកនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា លោក ឆាត រ៉ូតឌីម៉ៃ (Chad Roedemeier) ប្រាប់អាស៊ីសេរី តាមសារអេឡិចត្រូនិកថា កិច្ចប្រជុំរវាងលោក ស្ទីវ ស្ទូស៊ែរ (Steve Stuehser) អនុព័ន្ធច្បាប់តំណាងការិយាល័យស៊ើបអង្កេតសហព័ន្ធរបស់សហរដ្ឋអាមេរិក ហៅកាត់ថា អេហ្វប៊ីអាយ (FBI) ប្រចាំស្ថានទូតអាមេរិកនៅកម្ពុជា ជាមួយអគ្គស្នងការនគរបាលជាតិលោក នេត សាវឿន ពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងការអនុវត្តច្បាប់របស់ប្រទេសកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស។ លោកបន្តថា សហរដ្ឋអាមេរិកកំពុងធ្វើការជាមួយប្រទេសកម្ពុជា ដើម្បីផ្ដន្ទាទោស អ្នករកស៊ីជួញដូរមនុស្ស ដើម្បីការពារជនរងគ្រោះ និងការពារកុំឱ្យមានឧក្រិដ្ឋកម្ម ដែលកើតចេញពីការជួញដូរមនុស្ស។

របាយការណ៍ស្ដីពីការជួញដូរមនុស្សឆ្នាំ២០២០ ក្រសួងការបរទេសអាមេរិករកឃើញថា កម្ពុជាមិនបានគោរពឱ្យបានពេញលេញ តាមបទដ្ឋានអប្បបរមា ដើម្បីលុបបំបាត់ការជួញដូរមនុស្សទេ។ ចំណែកអំពើពុករលួយនៅតែធ្វើឲ្យរាំងស្ទះដល់ការងាររបស់សមត្ថកិច្ច ដំណើរការកាត់ក្ដីជនល្មើស និងការផ្ដល់សេវាដល់ជនរងគ្រោះ។

អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិលោក ឆាយ គឹមឃឿន ប្រាប់អាស៊ីសេរីថា រដ្ឋាភិបាលបានខិតខំប្រយុទ្ធប្រឆាំងនឹងសកម្មភាពជួញដូរមនុស្ស ហើយបើប្រៀបធៀបកាលពីឆ្នាំមុនៗ ការជួញដូរមនុស្សមានការថយចុះចំនួន ១រយ ៣០ដង។ លោកបន្តថា កម្ពុជាត្រៀមខ្លួនធ្វើការងារជាមួយនឹងសហរដ្ឋអាមេរិក ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស៖ «ការជួបពិភាក្សាគ្នានេះ ក្នុងគោលបំណងបន្តកិច្ចសហប្រតិបត្តិការ រវាងមន្ត្រី និងអង្គភាពអនុវត្តច្បាប់ នៃភាគីទាំងពីរ ដែលក្នុងនោះភាគីទាំងពីរបានឯកភាពគ្នាវាយតម្លៃខ្ពស់ ចំពោះលទ្ធផល សហប្រតិបត្តិការ នាពេលកន្លងមក ហើយភាគីទាំងសហរដ្ឋអាមេរិក ក៏បានលើកឡើងផងដែរ ថានេះជាផ្នែកមួយដែលឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការល្អរវាង ភាគីកម្ពុជា និងអាមេរិក»។

កាលពីចុងឆ្នាំ២០២០ សហរដ្ឋអាមេរិកបានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជា នៅបន្តស្ថិតនៅលំដាប់ថ្នាក់ទី២ ក្នុងបញ្ជីតាមដាន រយៈពេល ២ឆ្នាំ ជាប់គ្នាកន្លងមកនេះ ដោយសារតែកម្ពុជា មិនបានបង្កើត និងអនុវត្តប្រព័ន្ធតាមដានផ្នែកយុត្តិធម៌ ឲ្យបានគ្រប់គ្រាន់ ដែលធ្វើឲ្យជនសង្ស័យជាច្រើននាក់គេចខ្លួនមុនសវនាការ ហើយជាហេតុនាំឲ្យមានការកាត់ទោសកំបាំងមុខជាច្រើនករណី៕

### ពលករខ្មែរ និងកុមារ១៧នាក់ នៅម៉ាឡេស៊ី នឹងត្រឡប់មកកម្ពុជាវិញ ក្រោមកិច្ចអន្តរាគមន៍ពីស្ថានទូត

https://thmeythmey.com/ 03, Feb 2021 , 5:34 pm ដោយ: ជឿន បញ្ញាឬទ្ធិ

ភ្នំពេញ៖ បើគ្មានអ្វីប្រែប្រួលទេ! ពលករខ្មែរ១៥នាក់ និងកុមារ២នាក់ នៅម៉ាឡេស៊ី នឹងត្រឡប់មកកម្ពុជានៅល្ងាចថ្ងៃទី៣ កុម្ភៈនេះ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី។ ស្ថានទូតកម្ពុជាប្រចាំម៉ាឡេស៊ី បានបញ្ជាក់ថា ពលករខ្មែរទាំងនេះ នឹងមកកម្ពុជាតាមជើងយន្តហោះលេខSQ5008។ អមជាមួយការជួយសង្គ្រោះនេះ ស្ថានទូតកម្ពុជា បានសង្កត់ធ្ងន់ថា៖«សូមបញ្ឈប់ការធ្វើចំណាកស្រុកដោយខុសច្បាប់»។

កាលពីខែមករា កន្លងមក ស្ថានទូតកម្ពុជា ក៏បានជួយសង្គ្រោះពលករខ្មែរជាង២០នាក់ហើយ នៅម៉ាឡេស៊ី ដើម្បីសម្របសម្រួលឱ្យពួកគេអាចត្រឡប់មកកម្ពុជា។ ពលករដែលស្ថានទូតកម្ពុជា អន្តរាគមន៍សង្គ្រោះនេះ ភាគច្រើនជាពលករឆ្លងដែនខុសច្បាប់ ចូលម៉ាឡេស៊ី៕

## អភិបាលខេត្តកោះកុង ជំរុញឱ្យមន្ត្រីនៅតាមច្រកទ្វារអន្តរជាតិចាំយាម និងបន្ទាត់ព្រំដែន ត្រូវពង្រឹងលើការងារធ្វើចត្តាឡីស័កឱ្យបានម៉ឺងម៉ាត់បំផុត

https://grandnewsasia.com/ 03-02-2021

កោះកុង ៖ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ លោកស្រី មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្តកោះកុង បានអញ្ជើញចុះពិនិត្យច្រកទ្វារអន្តរជាតិចាំយាម និងបន្ទាត់ព្រំដែន ដើម្បីពង្រឹងការទប់ស្កាត់ពលករឆ្លងដែនក្នុងគោលបំណងតម្រូវឱ្យធ្វើចត្តាឡីស័កគ្រប់ៗរូប និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ជាមួយគ្នានេះដែរ លោកស្រីសូមឱ្យសមត្ថកិច្ចគ្រប់រូប មានវិធានការឱ្យបានម៉ឺងម៉ាត់បំផុត ព្រមទាំងសហការជាមួយអាជ្ញាធរភូមិ ឃុំ ស្រុក ធ្វើយ៉ាងណាគ្រប់គ្រងឱ្យបាននូវពលករ ដែលវិលមកស្រុកកំណើតវិញ ស្រមតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប ៖ នៅថ្ងៃពុធ ទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៨៩នាក់ ស្រី ៣៨នាក់ ក្នុងនោះកុមារា ៥នាក់ កុមារី ៥នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥៤នាក់ ស្រី ២២នាក់ កុមារា ៣នាក់ កុមារី ៣នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៩នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ១នាក់។ ៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៨នាក់ ស្រី ១១នាក់ កុមារា ១នាក់ កុមារី ១នាក់។

៥- ច្រកដូង ស្រុកកំរៀង ចំនួន ៨នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ១នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៨៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥៣នាក់, ខេត្តបាត់ដំបង ចំនួន ៨នាក់ និងឧត្តរមានជ័យចំនួន ៣៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរ ខេត្តកោះកុង កំពុងខិតខំទប់ស្កាត់ពលករមកពីថៃ តាមផ្លូវទឹកដែលមានបំណង គេចពីចត្តាឡីស័ក

http://btv.com.kh/ 03/02/2021

កោះកុង ៖ ថ្នាក់ដឹកនាំខេត្តកោះកុង បង្ហាញពីការព្រួយបារម្ភចំពោះរំហូរចូលនៃពលករខ្មែរ មកពីខេត្តត្រាត ប្រទេសថៃ តាមភូមិសាស្ត្រច្រកព្រំដែនទឹក ដែលពួកគេទំនងមានបំណងគេចពីការធ្វើចត្តាឡីស័ក ។ អាជ្ញាធរ មានសមត្ថកិច្ច កំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់សកម្មភាពនេះ។

ច្រកព្រំដែនផ្លូវទឹក រវាងខេត្តកោះកុង និងខេត្តត្រាត ប្រទេសថៃ ជាភូមិសាស្ត្រមួយ ដែលមិនងាយស្រួលក្នុងការគ្រប់គ្រងរំហូរចេញចូល នៃពលករខ្មែរលួចឆ្លងដែន តាមរយៈមេខ្យល់នោះទេ ដែលនេះបញ្ហាបារម្ភចំពោះការឆ្លងរាលដាលកូវីដ–១៩ ទៅក្នុងសហគមន៍ ដោយសារតែពលករ ដែលចេញចូលតាមច្រកនេះ មានបំណងគេចវេស ពីការធ្វើចត្តាឡីស័ក និងការពិនិត្យសុខភាពស្វែងមេរោគកូវីដ–១៩។

លោក សំ ឃិតវៀន អភិបាលរងខេត្តកោះកុង បានលើកឡើងដូច្នេះ កាលពីរសៀលថ្ងៃទី០២ ខែកុម្ភៈ ម្សិលមិញ ក្នុងកិច្ចប្រជុំទប់ស្កាត់រំហូរចូលពលករខ្មែរមកពីប្រទេសថៃ អំឡុងពេលការរីករាលដាលកូវីដ១៩។ ដោយពិនិត្យឃើញពីលទ្ធភាព នៃការអាចគេចវេសធ្វើចត្តាឡីស័កបាន របស់ពលករមកតាមផ្លូវទឹក បែបនេះ លោកអភិបាលរងខេត្ត បានប្រាប់ដល់សមត្ថកិច្ចអាជ្ញាធរមូលដ្ឋាន ឱ្យបន្តបង្កើនតាមដានពិនិត្យ ដោយដាក់ប៉ុស្តិ៍ផ្លូវទឹក ព្រមទាំងចំណតរថយន្ត ឱ្យបានល្អិតល្អន់ថែមទៀត។ លោក សំ ឃិតវៀន បានបញ្ជាក់ថា ចំពោះភូមិសាស្ត្រច្រកព្រំដែនគោកវិញ គឺសមត្ថកិច្ចនគរបាល និងយោធាការពារព្រំដែន កំពុងអនុវត្តវិធានការល្បាតស្វែងរកពលករខ្មែរ ដែលឆ្លងដែនមកពីថៃ ទាំងយប់ ទាំងថ្ងៃ ដូច្នេះអាជ្ញាធរអាចទប់ស្កាត់ និងគ្រប់គ្រងរំហូរពលករ បានស្ទើរតែ១០០ភាគរយហើយ។

គិតត្រឹមថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ មានពលករខ្មែរ ចំនួន៨៣នាក់ បន្តចាកចេញពីមណ្ឌល ចត្តាឡីស័ក ដែលរដ្ឋបាលខេត្ត និងក្រុមការងារជំនាញ បានរៀបចំ ដើម្បីតាមដានពិនិត្យសុខភាព ជូនពួកគេ ១៤ថ្ងៃ ស្វែងរកវីរុសកូវីដ បន្ទាប់ពីការឆ្លងដែនមកពីថៃ។

កន្លងទៅ លោកជំទាវអភិបាលខេត្ត ក៏ធ្លាប់ផ្ញើសារដល់ពលករខ្មែរទាំងអស់ ដែលនៅប្រទេសថៃ បើមានបំណងវិលមកប្រទេសកម្ពុជាវិញ សូមធ្វើដំណើរចូលតាមច្រកព្រំដែនអន្តរជាតិ ខណៈមានក្រុមកងកម្លាំង និងមន្ត្រីជំនាញ ត្រៀមរង់ចាំទទួលយកធ្វើចត្តាឡីស័ក ចៀសវាងការគេចវេសលួចឆ្លងដែនចូលតាម ច្រករបៀង ដែលនាំឱ្យឆ្លងរីករាលដាលកូវីដ១៩ ដល់សហគមន៍ ប្រសិនបើពួកគេបានឆ្លងមេរោគកូវីដ–១៩ មកពីប្រទេសថៃនោះ៕ អត្ថបទ៖ ឈឹម មករា

## ពលករចំណាកស្រុកកម្ពុជារាប់រយនាក់បានដើរឆ្លងព្រំដែនបន្តគ្នាយគ្នា

https://www.khmertimeskh.com/ ទិត្យ គង់នៅ / Khmer Times

**ច្រកព្រំដែនអន្តរជាតិអូរស្មាច់ ឧត្តរមានជ័យ** -សញ្ញាដំបូងនៃការជម្លៀសប្រជាជនកម្ពុជា យ៉ាងច្រើនពីខេត្តសុរិន្ទរបស់ប្រទេសថៃ គឺជាឡានដឹកជញ្ជូនសម្ភារៈផ្ទាល់ខ្លួនចំនួន ៥ របស់ពលករ។ រថយន្តដឹកទំនិញដែលបានចុះបញ្ជីដោយជនជាតិថៃបានឆ្លងកាត់កម្ពុជាតាមច្រកព្រំដែនអូរស្មាច់ខេត្ត ឧត្តរមានជ័យ នៅម៉ោងប្រហែល ៨ ព្រឹកម្សិលមិញដោយដឹកសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ទូទឹកកកខ្នាតតូច ទូរទស្សន៍ ចង្ក្រានបាយ និងកាបូបដាក់ឥវ៉ាន់ផ្ទាល់ខ្លួន។

កងទាហានដែលកំពុងរង់ចាំមានចំនួន ៥៥ នាក់ រួមជាមួយរថយន្តដឹកទាហាន២៥គ្រឿង មន្ត្រីសុខាភិបាល និងសន្តិសុខព្រំដែនបានចាប់ផ្ដើមធ្វើសកម្មភាពយ៉ាងរហ័ស ហើយបានរង់ចាំនៅច្រកទ្វារព្រំដែនចម្ងាយតែប៉ុន្មាន

ម៉ែត្រពីខេត្តសូរិន្ទប្រទេសថៃនៅ។ ពួកគេបានមកដោយថ្មើរជើង មកដោយខ្លួនឯង ឬជាក្រុមមានគ្នាពីនាក់ ប្រាំទៅ ៣០ ក្នុងពេលតែមួយនិងបន្តហូរឥតឈប់ឈរ និងរហ័សក្នុងរយៈពេលជាងមួយម៉ោងកន្លះ។ មុននេះពួកគេបានប្រមូលផ្តុំគ្នានៅចម្ងាយ ១០ គមនៅព្រំដែនថៃ ដែលមានឈ្មោះថា Kab Jerng ដែលពួកគេចាប់ភាគច្រើនបានមកដល់តាំងពីល្ងាចថ្ងៃច័ន្ទនិងខ្លះទៀតនៅព្រឹកព្រលឹម។

លោក ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបាននិយាយថា ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ ចំនួនពលករដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមរយៈច្រកព្រំដែនអូរស្មាច់មានចំនួនចន្លោះពី ១៥០ ទៅ ២០០ នាក់ ប៉ុន្តែកាលពីថ្ងៃច័ន្ទ និងម្សិលមិញគឺមានចំនួនច្រើនលើសលុប។ កាលពីថ្ងៃច័ន្ទ គេបានឃើញប្រជាជនកម្ពុជាឆ្លងកាត់ ៣០០ នាក់ ហើយចំនួននេះបានកើនឡើងដល់ ៣២៤ នាក់ដែលរួមមានបុរស ស្ត្រី កុមារ និងព្រះសង្ឃ។ លោកបន្តថា៖ «ប្រហែល៨០ ភាគរយនៃប្រជាជនដែលត្រលប់មកពីប្រទេសថៃ គឺជាអ្នកវិលត្រឡប់ស្របច្បាប់ក្នុងន័យថា ពួកគេមានឯកសារធ្វើដំណើរត្រឹមត្រូវ និងមានការអនុញ្ញាតឲ្យធ្វើការផងដែរ។ អ្នកដែលនៅសេសសល់គឺបានឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ហើយច្រកទ្វារអន្តរជាតិអូរស្មាច់ គឺជាច្រកឆ្លងកាត់តែមួយប៉ុណ្ណោះនៅក្នុងតំបន់នេះ។ មិនមានស្ទឹង ទឹកហូរ ឬផ្លូវឆ្លងកាត់ផ្សេងទៀតក្រៅពីផ្លូវពីព្រោះច្រកព្រំដែនទាំងពីរគឺជាតំបន់ភ្នំ និងមានតំបន់មីន»។

លោកបន្ថែមថា៖ «ចំនួនដ៏ច្រើននៃការធ្វើមាតុភូមិនិវត្តន៍នេះ ទំនងជាត្រូវការមណ្ឌលចត្តាឡីស័កបន្ថែម ដែលមណ្ឌលដែលមានស្រាប់ចំនួន ១៧ ភាគច្រើនគឺពេញ ឬជិតពេញហើយ។ យើងចាំបាច់ត្រូវសង្កេតអ្នកដែលត្រលប់មកវិញឲ្យធ្វើចត្តាឡីស័ក និងធ្វើតេស្តឲ្យមានប្រសិទ្ធិភាពមុននិងអនុញ្ញាតឲ្យត្រលប់ទៅផ្ទះបន្ទាប់ពីរយៈពេល ១៤ ថ្ងៃហើយមណ្ឌលនិងត្រៀមខ្លួនសម្អាតមេរោគសម្រាប់អ្នកបន្ទាប់»។ លោកនិយាយថាចំនួនពលករដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញចាប់ពីថ្ងៃទី ២១ ខែធ្នូឆ្នាំ ២០២០ ដល់ថ្ងៃច័ន្ទតាមរយៈច្រកទ្វារព្រំដែនអូរស្មាច់មានចំនួនសរុប ៦ ៤៧០ នាក់ និងភាគច្រើនជាពលករចំណាកស្រុក។ ហើយមានមនុស្សប្រមាណជា ២ ៤២៧ កំពុងស្ថិតក្នុងការធ្វើចត្តាឡីស័ក ខណៈពេលដែល ៤ ០៤៣ នាក់ត្រលប់ទៅផ្ទះបន្ទាប់ពីបានបញ្ចប់ការធ្វើចត្តាឡីស័ក។ លោកបន្តថា៖ «យើងមានករណីវិជ្ជមានតែពីរប៉ុណ្ណោះហើយករណីទាំងពីរត្រូវបានព្យាបាល និងអនុញ្ញាតឲ្យត្រលប់ទៅផ្ទះហើយ។ រហូតមកដល់ពេលនេះ ចំនួនអ្នកធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកម្ពុជាមិនបានថយចុះទេហើយផ្ទុយទៅវិញមានតែការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដែលគួរឲ្យព្រួយបារម្ភព្រោះថាប្រសិនបើចំនួនទាំងនេះនៅតែបន្តកើនឡើងទៀតអាជ្ញាធរនឹងត្រូវការពង្រីកមណ្ឌលចត្តាឡីស័ក ឬបន្ថែមមណ្ឌលថ្មី»។

លោកនិយាយថា មូលហេតុចំបងៗ ដែលពលករចំណាកស្រុកប្រញាប់ប្រញាល់វិលត្រឡប់មកស្រុកវិញគឺដោយសារតែការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃដែលនាំឲ្យមានការបិទក្រុមហ៊ុនជាច្រើននៅទីនោះដែលធ្វើឲ្យពលករគ្មានការងារធ្វើ។ ពួកគេក៏មានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួននិងសមាជិកគ្រួសាររបស់ពួកគេដែលនៅជាមួយពួកគេនៅក្នុងប្រទេសថៃផងដែរ។ លោកបន្តថា៖ «យើងកំពុងជួបជាមួយអភិបាលខេត្តដើម្បីស្វែងរកកន្លែងបន្ថែមទៀត ដើម្បីត្រៀមសម្រាប់ពលករ ហើយយើងរំពឹងថានឹងមានការត្រលប់មកវិញកាន់តែច្រើននៅពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខិតជិតមកដល់។ បើគិតទៅ នេះគឺជារយៈពេលដែលពលករចំណាកស្រុកមួយចំនួនធំ និងសមាជិកគ្រួសាររបស់ពួកគេនៅក្នុងប្រទេសថៃចូលមកប្រទេសកម្ពុជាម្តងទៀត។ ដូចនេះអាជ្ញាធរខេត្តត្រូវតែត្រៀមខ្លួនជាមុន»។ លោកបានបន្ថែមទៀតថាសម្រាប់ខេត្តឧត្តរមានជ័យលោកអភិបាលខេត្តបានអនុញ្ញាតតែប៉ុស្តច្រកព្រំដែនអូរស្មាច់ ហើយមិនមានពលករចំណាកស្រុកណាម្នាក់អាចវិលត្រឡប់មកប្រទេសកម្ពុជាវិញតាមរយៈផ្លូវផ្សេងទៀតដូចជាអន្លង់វែងទេ។ នេះក៏ព្រោះតែនៅតាមខ្សែបន្ទាត់ព្រំដែនជាតំបន់ភ្នំ

និងព្រៃឈើរួមទាំងតំបន់ដែលមានមីន ដូច្នេះពលករមានការភិតភ័យយ៉ាងខ្លាំងក្នុងការប្រើប្រាស់ផ្លូវដែលមិនមានកំនត់ ឬផ្លូវក្រៅផ្លូវការដើម្បីត្រលប់មកវិញ។

លោក ជា ពិសិដ្ឋ ប្រធានរដ្ឋបាលសាលាខេត្តឧត្តរមានជ័យ បាននិយាយថាបច្ចុប្បន្ននេះ អាជ្ញាធរកំពុងប្រញាប់ប្រញាល់វាយតម្លៃទីតាំងផ្សេងៗនៅក្នុងខេត្តឧត្តរមានជ័យ ដើម្បីត្រៀមសាងសង់មណ្ឌលចត្តាឡីស័កក្នុងករណីចំនួនពលករដែលវិលត្រឡប់មកវិញនៅតែបន្តកើនឡើង។ លោកបន្តថា៖ «យើងកំពុងកំណត់ទីតាំងបន្ថែមទៀត ដើម្បីធ្វើជាមណ្ឌលចត្តាឡីស័ក ពីព្រោះចំនួនពលករដែលចូលក្នុងមួយថ្ងៃគឺមានចំនួនជាមធ្យម ៣០០ បើប្រៀបធៀបទៅកាលពីមុនមានចន្លោះពី ១៥០ ទៅ ២០០។ មណ្ឌលចត្តាឡីស័កដែលមានស្រាប់ប្រហែលជាមិនគ្រប់គ្រាន់ដើម្បីទទួលយកពលករចំណាកស្រុកទាំងអស់នោះទេ»។ លោកបន្ថែមទៀតថាសម្រាប់ការប្រុងប្រយ័ត្ន គឺមិនត្រឹមតែសម្រាប់ពលករដែលវិលត្រឡប់មកពីប្រទេសថៃប៉ុណ្ណោះទេ តែគឺសម្រាប់អ្នកបើកបរដែលដឹកទំនិញតាមរថយន្តដឹកទំនិញដែលឆ្លងកាត់ព្រំដែនអូរស្មាច់តម្រូវឲ្យមានការធ្វើតេស្តរៀងរាល់ ១៤ ថ្ងៃម្តង។

លោកវរសេនីយ៍ទោ នៅ សារុន មេបញ្ជាការកងពលតូចដឹកជញ្ជូនលេខ ៩៩ បាននិយាយថាលោកបានបញ្ជូនកម្លាំងចំនួន ៥៥ នាក់និងរថយន្តដឹកចំនួន ២៥ គ្រឿងដើម្បីដឹកពលករទៅមណ្ឌលចត្តាឡីស័កចំនួន ១៧ និងកំពុងបំពេញភារកិច្ចរបស់ខ្លួន ២៤ ម៉ោងក្នុងមួយថ្ងៃ។ លោកបន្តថា៖ «យើងមិនគិតពីភាពនឿយហត់ទេ ជាពិសេសនៅពេលដែលពលករមកដល់ចំណុចត្រួតពិនិត្យនៅម៉ោងសេសគឺយើងធ្វើសកម្មភាពភ្លាមៗ ដោយមិនគិតពីពេលវេលាដែលពួកគេមកដល់។ ក្នុងនាមជាកម្លាំងដឹកជញ្ជូនពិសេសនៅក្នុងខេត្តឧត្តរមានជ័យ យើងរីករាយនឹងបំពេញភារកិច្ចរបស់យើងតាមការណែនាំរបស់រដ្ឋាភិបាល ជាពិសេសដោយអភិបាលខេត្តដោយមិនគិតពីពេលវេលា ឬថ្ងៃសម្រាក។ ដរាបណាមានពលករវិលត្រឡប់មកវិញ យើងនឹងបំពេញភារកិច្ចក្នុងការដឹកពួកគេ និងឥវ៉ាន់ទៅកាន់មណ្ឌលចត្តាឡីស័កដែលបានកំណត់»។

អ្នកស្រី សួន នាថ អាយុ ៤១ ឆ្នាំមកពីស្រុកពញាក្រែក ខេត្តត្បូងឃ្មុំបាននិយាយថាអ្នកស្រីបានធ្វើការនៅប្រទេសថៃអស់រយៈពេល ១០ ឆ្នាំជាអ្នកថៃសួននៅប៉ាតាយ៉ាហើយបានរស់នៅទីនោះជាមួយគ្រួសារនិងកូនបីនាក់។ នៅប្រទេសថៃអ្នកស្រីអាចរកប្រាក់បានប្រហែល ១០ ដុល្លារក្នុងមួយថ្ងៃប៉ុន្តែដោយសារតែការផ្ទុះឡើងនៅទីនោះបច្ចុប្បន្នអ្នកស្រីមិនមានការងារធ្វើទេ។ អ្នកស្រីបន្តថា៖ «ឥឡូវនេះពិបាកក្នុងការរកការងារធ្វើណាស់នៅថៃ។ ខេត្តខ្លះជាប់គាំងហើយខ្ញុំមានកូនតូចណាស់។ ខ្ញុំខ្លាចថាជំងឺកូវីដ-១៩ នឹងឆ្លងទៅកូនៗរបស់ខ្ញុំ ដូច្នេះយើងទាំងអស់គ្នាសំរេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញ»។

លោក វេង ស្រឿន អាយុ ៣៨ ឆ្នាំមកពីខេត្តព្រៃវែងបាននិយាយថាគាត់បានធ្វើការនៅប្រទេសថៃអស់រយៈពេល ៤ ឆ្នាំជាជាងជួសជុលគ្រឿងអេឡិចត្រូនិចនៅខេត្តឈុនបុរី។ លោកអាចរកប្រាក់បានប្រហែល ១១ ដុល្លារក្នុងមួយថ្ងៃ។ លោកបន្ថែមទៀតថាបន្ទាប់ពីបានឃើញការរីករាលដាលនៃករណីកូវីដ-១៩ នៅក្នុងប្រទេសថៃលោកបានស្នើសុំឈប់ពីការងារហើយបានវិលត្រឡប់មកប្រទេសកម្ពុជាវិញជាមួយប្រពន្ធនិងកូនប្រុស។ លោកបន្តថា៖ «ខ្ញុំមិនដឹងថាពេលណាខ្ញុំនឹងអាចវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃម្តងទៀតទេ ពីព្រោះនៅក្នុងប្រទេសថៃឥឡូវនេះវាពិបាកក្នុងការរកការងារធ្វើហើយជំងឺរាតត្បាតហាក់ដូចជាមិនធូរស្បើយសោះ។ នៅប្រទេសកម្ពុជា ខ្ញុំនឹងត្រឡប់ទៅធ្វើកសិកម្មមួយរយៈសិន»៕ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

## អាជ្ញាធររៀបចំដំឡើងតង់នៅក្នុងបរិវេណពហុកីឡដ្ឋានខេត្តឧត្តរមានជ័យ ត្រៀមធ្វើជាមណ្ឌលចត្តាឡីស័ក សម្រាប់ទទួលពលករចំណាកស្រុកពីប្រទេសថៃ

http://www.freshnewsasia.com/ 2021-02-04 05:20pm

**(ឧត្តរមានជ័យ)៖** លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១នេះ បានដឹកនាំក្រុមការងារ និងកងកម្លាំងប្រដាប់អាវុធ ចុះពិនិត្យនិងរៀបចំការតម្លើងតង់ ធ្វើជាមណ្ឌលធ្វើចត្តាឡីស័ក នៅក្នុងបរិវេណពហុកីឡដ្ឋានខេត្តដើម្បីត្រៀមទទួលបងប្អូនពលករដែលវិលមកពីប្រទេសថៃ។ លោក ប៉ែន កុសល្យ បានថ្លែងថា សម្រាប់ទីតាំងពហុកីឡដ្ឋានខេត្តនេះ យើងបាននិងកំពុងរៀបចំតម្លើងតង់ចំនួន១០០តង់ និងបង្គន់អនាម័យចំនួន៣៣ ព្រមទាំងបានរៀបចំប្រព័ន្ធទឹក ភ្លើងសម្រាប់សម្រួលដល់ការមកស្នាក់នៅ ធ្វើចត្តាឡីស័ករបស់បងប្អូនពលករយើង។ បន្ទាប់ពីចុះពិនិត្យ និងរៀបចំតម្លើងតង់រួចហើយ លោកអភិបាលខេត្ត បានដឹកនាំក្រុមការងារចុះជួបសំណេះសំណាល សួរសុខទុក្ខបងប្អូនពលករដែលធ្វើចំណាកស្រុកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមរយៈច្រកទ្វារព្រំដែន អន្តរជាតិអូរស្មាច់។

លោកបានលើកឡើងថា «**ការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ចំពោះបងប្អូនពលករនាពេលនេះ ធ្វើឡើងតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងបង្កើនការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីទប់ស្កាត់ ការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ហើយចំពោះការធ្វើចត្តាឡីស័ករយៈពេល១៤ ថ្ងៃនេះដែរ រដ្ឋបាលខេត្ត ក៏បានយកចិត្តទុកដាក់ចំពោះការផ្គត់ផ្គង់នូវការស្នាក់នៅចំណីអាហារ និងសម្ភារប្រើប្រាស់មួយចំនួន ជូនបងប្អូនពលករផងដែរ**»។ លោក ប៉ែន កុសល្យ បានអំពាវនាវឲ្យបងប្អូនពលកររួមគ្នាការពារជំងឺកូវីដ១៩ កុំឱ្យមានការចម្លងដល់បងប្អូនក្រុមគ្រួសារក៏ដូចជាសហគមន៍។ លោកបន្តថា «**ប្រសិនបើបុគ្គលណាមិនគោរពតាមវិធានការរបស់ក្រសួងសុខាភិបាល ដោយចត្តាឡីស័ក១៤ ថ្ងៃ ឬរត់ចេញ ឬគេចវេសពីការធ្វើចត្តាឡីស័ក នឹងត្រូវផាកពិន័យចាប់ពី ២០០,០០០ រៀលទៅ១,០០០,០០០ រៀល និងទោសព្រហ្មទណ្ឌ**»។

សូមបញ្ជាក់ថា គិតត្រឹមម៉ោង១០ និង៣០នាទីព្រឹកថ្ងៃនេះបងប្អូនពលករ ចំណាកស្រុកមកពីប្រទេសថៃ មានចំនួន១៣០នាក់ ខណៈដែលពលករកំពុងធ្វើចត្តាឡីស័កមាន២,៧៨០ នាក់ ដែលកំពុងប្រើប្រាស់មណ្ឌលចត្តាឡីស័ក១៩ មណ្ឌល ទូទាំងខេត្តឧត្តរមានជ័យ៕

## ថៃដោះលែងអ្នកទោសខ្មែរ ៨នាក់ មកស្រុកវិញ!

https://kohsantepheapdaily.com.kh/ Oddar Meanchey ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ១៩:៥៩

ខេត្តឧត្តរមានជ័យ៖ អ្នកទោសខ្មែរ ៨នាក់ ដែលក្រុមអាជ្ញាធរថៃចាប់ និងចោទពីបទឆ្លងដែន ដោយខុសច្បាប់ ចូលទៅកាប់ឈើគ្រញូង ក្នុងទឹកដីថៃ នៅពេលនេះ ត្រូវបានដោះលែងឱ្យ មានសេរីភាពវិញ និងនាំខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា តាមច្រកទ្វារអន្តរជាតិជាំ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីវេលាម៉ោង ១រសៀលថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១។

អ្នកទោសខ្មែរ ដែលក្រុមអាជ្ញាធរថៃដោះលែងនោះ មានឈ្មោះ ស៊ីង សឿន ភេទប្រុស អាយុ ៤៥ឆ្នាំ ថៃចាប់ខ្លួនកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។ យ៉ែម ឡេ ភេទប្រុស អាយុ ៥៧ឆ្នាំ ថៃចាប់ខ្លួន កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨។ ទាំង២នាក់ រស់នៅភូមិត្រពាំងធំ ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ សុខ នី ភេទប្រុស អាយុ ៣៨ឆ្នាំ ចាប់ខ្លួន កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩ រស់នៅភូមិឈើទាលកង ឃុំជាំក្សាន្ត ស្រុកជាំ

ក្សាន្ត ខេត្តព្រះវិហារ។ ឈ្មោះ លូ គឹមលាង ភេទប្រុស ៤១ឆ្នាំ ចាប់ខ្លួន កាលពីថ្ងៃទី២៣មិថុនា ឆ្នាំ២០១៩ រស់នៅភូមិទឹកក្រហម ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ផាន ប៊ុនលី ភេទប្រុស ៣០ឆ្នាំ ចាប់ខ្លួន ថ្ងៃទី២៧ មករា ឆ្នាំ២០១៩ រស់នៅភូមិឈើទាលកង ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ឃឹម សារឿន ភេទប្រុស អាយុ ៤៥ឆ្នាំ ចាប់ខ្លួនថ្ងៃទី៧ឧសភា២០១៩ រស់នៅភូមិឈើទាលកង ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ដន ជឿន ភេទប្រុស អាយុ ៣៤ ឆ្នាំ ចាប់ខ្លួនថ្ងៃទី២៣ធ្នូ ២០១៨រស់នៅភូមិតេជោមរកត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងឈ្មោះ ឌឹម ចន ភេទប្រុស អាយុ ៤៨ឆ្នាំ ចាប់ខ្លួនថ្ងៃទី២០កញ្ញា ឆ្នាំ២០១៨ រស់នៅភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ទាំង ៨នាក់ ត្រូវក្រុមអាជ្ញាធរថៃ ចោទពីបទឆ្លងដែនកាប់ឈើក្រញូង ចូលតាមច្រកមុំបី ជាប់គុកនៅខេត្តអ៊ូប៊ុន ប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅច្រកទ្វារអន្តរជាតិជាំ បានឱ្យដឹង ក្រុមអ្នកទោសខ្មែរ ដែលក្រុមអាជ្ញាធរថៃ បញ្ជូនមកឱ្យកម្ពុជា ពេលនេះ ត្រូវបានខាងសមត្ថកិច្ច សាកសួរ និងអប់រំ ធ្វើកំណត់ហេតុកិច្ចសន្យាបញ្ឈប់ឆ្លងដែនខុសច្បាប់។ បន្ទាប់មក បានប្រគល់ទៅឱ្យគ្រូពេទ្យ ប្រចាំការនៅច្រកជាំ ពិនិត្យវាស់កំដៅ រួចបញ្ជូនបន្តទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សា អន្លង់វែង៕ ដោយៈ ឌិម សារឿន

## អាជ្ញាធរបាត់ដំបងត្រៀមមណ្ឌលចត្តាឡីស័កបន្ថែមខណៈកំណើនពលករមកពីថៃកើនឡើង

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១

បាត់ដំបង៖ អាជ្ញាធរខេត្ត និងមន្ត្រីជំនាញ បានត្រៀមរៀបចំមណ្ឌលចត្តាឡីស័កបន្ថែមទៀត នៅតាមស្រុកជាប់ព្រំដែន ខណៈពលករបានត្រឡប់មកពីប្រទេសថៃតាមច្រកព្រំដែនជាប់ខេត្តបាត់ដំបងកើនឡើងខុសធម្មតាស្របពេលដែល ក្នុងរដូវនេះ សម្បូរទៅដោយបុណ្យទាន ឬពិធីមង្គលការជាដើមនោះ ។

លោក សុខ គឹមខុន អភិបាលស្រុកកំរៀង បានឱ្យដឹងថាក្នុងការដោះស្រាយបញ្ហានេះ មានក្រុមហ៊ុនឯកជនមួយ បាន សម្បទានដីរបស់ខ្លួនប្រមាណ២ហិកតា ក្នុងស្រុកកំរៀង ជិតព្រំដែនថៃ ដើម្បីរៀបចំជាទីតាំងធ្វើមណ្ឌលចត្តាឡីស័កបន្ថែម ត្រៀមទទួលពលករដែលទើបត្រឡប់មកពីប្រទេសថៃ ហើយទីតាំងនេះអាជ្ញាធរក៏បានពិនិត្យរួចរាល់ហើយដែរ ។ លោកអភិបាលស្រុកកំរៀងបានឱ្យដឹងថា ពលករឆ្លងដែនពីប្រទេសថៃតាមច្រកជាប់ស្រុកកំរៀងមានជារៀងរាល់ថ្ងៃ ដោយបច្ចុប្បន្នក្នុងស្រុកមានមណ្ឌលចត្តាឡីស័កចំនួន៣ អាចដាក់ពលករបានជាមធ្យម ៦០០ នាក់ ខណៈមានអ្នកបញ្ចប់ការធ្វើចត្តាឡីស័កបានចេញជាបណ្តើរៗ ប៉ុន្តែកំណើនចូលវិញក៏ច្រើន ។

ក្នុងឱកាសចុះពិនិត្យទីតាំងត្រូវរៀបចំធ្វើមណ្ឌលចត្តាឡីស័ក នៅស្រុកកំរៀង នារសៀលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តម ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិ ប្រចាំភូមិភាគទី៤ និងទី៥ បានមានប្រសាសន៍ថា មណ្ឌលចត្តាឡីស័កត្រៀមថ្មីនេះ គឺសម្រាប់នៅពេលមណ្ឌលចត្តាឡីស័កមានស្រាប់ពេញ ត្រូវបញ្ជូនពលករទើបត្រឡប់មកពីថៃ មកកន្លែងថ្មីដែលត្រៀមទុកនេះ។ ឯកឧត្តម បានជំរុញអាជ្ញាធរខេត្ត និងមន្ត្រីជំនាញ ត្រូវរៀបចំកន្លែងធ្វើចត្តាឡីស័កបន្ថែមនេះឱ្យបានល្អ មានទាំងកន្លែងសម្រាក បង្គន់អនាម័យ និងកន្លែងចម្អិនអាហារជាដើមឱ្យបានសមស្រប ពិសេសឱ្យពួកគាត់ អនុវត្តនូវវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល ។

ជាមួយគ្នានោះ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានណែនាំដល់សមត្ថកិច្ចការពារព្រំដែនទាំងអស់ ត្រូវសហការជាមួយមន្ត្រីសុខាភិបាល បន្តរឹតបន្តឹងក្នុងការពិនិត្យទប់ស្កាត់កុំឲ្យពលករណាម្នាក់ អាចគេចវេសពីការ ពិនិត្យសុខភាព ការយកសំណាក និងការធ្វើចត្តាឡីស័កគឺមិនអាចលើកលែងក្នុងករណីអ្នកណាម្នាក់បាននោះទេ ។

គួរបញ្ជាក់ថា រយៈពេលប៉ុន្មានថ្ងៃ ដើមខែកុម្ភៈនេះ ចំនួនពលករឆ្លងដែនពីប្រទេសថៃ ក្នុងអំឡុងមានការរីករាលដាល នៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ខេត្តសាមុតសាខនប្រទេសថៃ បានធ្វើដំណើរតាមច្រកនានាជាប់ខេត្តបាត់ដំបង មានចំនួនលើស ១០០នាក់ និងមានបន្តមកទៀតជាហូរហែរាល់ថ្ងៃ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូងស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៨៩នាក់ ស្រី ៣០នាក់ ក្នុងនោះកុមារា ៥នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២១នាក់ ស្រី ៩នាក់ កុមារា ២នាក់ កុមារី ១នាក់។ ២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៦នាក់ ស្រី ៩នាក់ កុមារា ៣នាក់ កុមារី ១នាក់។ ៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១១នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២០នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ ៥- ច្រកដូងស្រុកកំរៀង÷ ចំនួន ៣នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៨១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥៨នាក់, ខេត្តបាត់ដំបង ចំនួន ៣នាក់ និងឧត្តរមានជ័យចំនួន ២០នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឱកាសការងារកាន់តែច្រើនសម្រាប់ប្រជាជនកម្ពុជានៅធ្វើការប្រទេសកូរ៉េខាងត្បូង

https://www.khmertimeskh.com/ February 4, 2021 សែន ដេវីត / Khmer Times

ប្រទេសកម្ពុជា និងកូរ៉េខាងត្បូងដឹកនាំក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) កាលពីថ្ងៃអង្គារបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាមួយ ដើម្បីបញ្ជូនពលករកម្ពុជាបន្ថែមទៀតទៅកាន់ប្រទេសកូរ៉េខាងត្បូង។កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា តំណាងក្រសួងការងារ និងការងារនៅប្រទេសកូរ៉េខាងត្បូង។ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃប្រទេសកូរ៉េខាងត្បូងនឹងទទួលបន្ទុកបណ្តុះបណ្តាលនិងបញ្ជូនពលករ។ ប្រទេសកម្ពុជាបានបញ្ជូនពលករទៅប្រទេសកូរ៉េខាងត្បូងចាប់តាំងពី EPS ដំបូងដែលត្រូវបានបង្កើតឡើងនៅពេលដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក Roh Moo-Hyun អតីតប្រធានាធិបតីកូរ៉េខាងត្បូងបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានៅថ្ងៃទី ២០ ខែវិច្ឆិកាឆ្នាំ ២០០៦ ។

លោក សំហេង បាននិយាយថា ចាប់តាំងពីឆ្នាំ២០០៧ មកប្រទេសកម្ពុជាបានបញ្ជូនពលករសរុបចំនួន ៦៨ ២៩៤ នាក់ (ស្រី១៤២៥៥ នាក់) ទៅធ្វើការក្នុងវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់នៅក្នុងប្រទេសកូរ៉េខាងត្បូង។ លោកបន្តថា បច្ចុប្បន្នមានពលករខ្មែរប្រមាណ ៤៥ ៤៦២ នាក់ (ក្នុងនោះមានស្ត្រី ១០ ១៨៣ នាក់) ដែលកំពុងធ្វើការនៅទីនោះ។ លោកនិយាយថា៖«ពលករកម្ពុជាត្រូវបានគេទទួលស្គាល់សម្រាប់ការងារល្អរបស់ពួកគេនៅកូរ៉េខាងត្បូង»។

លោកនិយាយថាប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងក្លាយជាប្រទេសអាទិភាពមួយបន្ថែមទៀតសម្រាប់ការស្វែងរកពលករចំណាកស្រុកនៅប្រទេសកូរ៉េខាងត្បូង ព្រោះប្រទេសនេះមានស្ថានភាពល្អប្រសើរទាក់ទងនិងជំងឺកូវីដ-១៩ មានជើងហោះហើរប្រតិបត្តិការកាន់តែច្រើន ហើយមានចំនួនពលករកម្ពុជាខុសច្បាប់នៅទីនោះតិចបើប្រៀបធៀបនឹងបណ្ដាប្រទេសដទៃទៀត។

លោកឯកអគ្គរដ្ឋទូត ឡុង ឌីម៉ង់ បាននិយាយថាថ្មីៗនេះក្នុងដំណើរបំពេញទស្សនកិច្ចនៅទីក្រុងក្វាងជូ លោក Jeong Eun-hee អគ្គនាយកអភិវឌ្ឍន៍ធនធានមនុស្សបានសម្ដែងការដឹងគុណនិងគាំទ្រដល់ស្ថានទូតកម្ពុជាក្នុងការងាររបស់ខ្លួនលើការតស៊ូមតិ ស្ថានភាពរស់នៅ និងលក្ខខណ្ឌការងារសម្រាប់ប្រជាជនកម្ពុជាដែលកំពុងធ្វើការនៅប្រទេសកូរ៉េខាងត្បូង។ ។ លោកបន្តថា៖ «ពលករកម្ពុជាប្រមាណ ១២០០ នាក់ដែលកំពុងរស់នៅនិងធ្វើការនៅក្នុងប្រទេសក្វាងជូជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងចំណោមពលករចំណាកស្រុកដទៃទៀតដោយសារពួកគេអត់ធ្មត់អត់ធ្មត់ និងគោរពច្បាប់ការងារ»៕ ប្រែសម្រួលដោយ សៀវ គួយអ៊ី

## ដំណើររឿងរបស់ស្ត្រីខ្មែរ ៥ នាក់ដែលបានពីឆ្លងជំងឺកូវីដ-១៩ បន្ទាប់ពីការឆ្លងចូលប្រទេសថៃដោយខុសច្បាប់

https://www.khmertimeskh.com/ February 4, 2021 ទិត្យ គង់នៅ និង Brian Badzmierowski / Khmer Times

អំឡុងពេលនៃជំងឺកូវីដ-១៩ ស្ត្រីកម្ពុជា៥ នាក់បានប្រថុយប្រថានហើយបានចាកចេញទៅខេត្តឈុនបុរី ប្រទេសថៃនៅពាក់កណ្ដាលខែវិច្ឆិកា ដោយខុសច្បាប់ហើយបានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី ៥ ខែមករា ហើយបានធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺកូវីដ-១៩។ ក្នុងចំណោម ៥ នាក់មាន ២ នាក់កំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពព្រះនេត្រ ព្រះខេត្តបន្ទាយមានជ័យ។ នៅពេលនិយាយជាមួយកាសែតខ្មែរថាមស៍ ស្ត្រីទាំងនោះបានសារភាពថាពួកគេបានចូលទៅក្នុងខេត្តឈុនបុរី ដោយខុសច្បាប់តាមរយៈមេខ្យល់ដែលពួកគេបានបង់ប្រាក់ប្រហែល ១១៦ ដុល្លារក្នុងម្នាក់សម្រាប់ការដឹកជញ្ជូននិងជួយពួកគេឲ្យរកការងារធ្វើនៅក្នុងប្រទេសថៃ។

កញ្ញា ពេជ្រ លក្ខិណា អាយុ២៦ឆ្នាំ មកពីស្រុកថ្មគោលបាននិយាយកាលពីម្សិលមិញថានៅពេលទៅដល់គោលដៅ ពួកគេចាប់ផ្ដើមស្វែងរកការងារធ្វើប៉ុន្តែអំឡុងពេលជិតមួយខែរកមិនបានអ្វីនោះទេ។ បន្ទាប់មក កញ្ញាបន្ថែមទៀតថាការប៉ុនប៉ងរកការងារធ្វើបានប្រែក្លាយជាការភ័យខ្លាចនៅពេលដែលកន្លែងដែលពួកគេស្នាក់នៅ បានចាប់ផ្ដើមកត់ត្រានូវចំនួនករណីឆ្លងខ្ពស់។ កញ្ញាបានសំរេចចិត្តវិលត្រឡប់ទៅផ្ទះវិញជាមួយមិត្តភក្តិដែលមានការភ័យខ្លាចដូចគ្នានឹងការឆ្លងជំងឺនេះ ហើយថែមទាំងនៅក្នុងទឹកដីបរទេសទៀត។ កញ្ញានិយាយថា៖ «នៅពេលនោះយើងបានសម្រេចចិត្តចាកចេញហើយពេលកំពុងធ្វើដំណើរ ខ្ញុំចាប់ផ្ដើមភ័យខ្លាចដោយខ្ញុំមានគ្រុនក្ដៅ ក្អក ហៀរសំបោរ និងពិបាកដកដង្ហើម។ ខ្ញុំ និងមិត្តភក្តិបានសម្រេចចិត្តធ្វើដំណើរត្រឡប់មកផ្ទះវិញតាមច្រកទ្វារបឹងបេង»។ ជាអកុសល ការភ័យខ្លាចបានក្លាយជាការពិត នៅពេលមិត្តភក្តិរបស់កញ្ញា យិន សុផានី ត្រូវបានគេធ្វើតេស្តវិជ្ជមាននៅពេលសីតុណ្ហភាពឡើងខ្ពស់ហើយការធ្វើតេស្តលើសំណាកបញ្ជាក់ថាបានឆ្លងជំងឺ។ បន្ទាប់មកកញ្ញា និងមិត្តភក្តិ ៣ នាក់ទៀតដែលបានវិលត្រឡប់មកជុំគ្នាវិញក៏ត្រូវបានគេធ្វើតេស្តវិជ្ជមានកូវីដ-១៩ ដូចគ្នា និងបានសម្រាប់នៅក្នុងបន្ទប់មន្ទីរពេទ្យមង្គលបូរីមុនពេលត្រូវបានបញ្ជូនទៅមណ្ឌលសុខភាពព្រះនេត្រព្រះ។

ជនរងគ្រោះម្នាក់ទៀតឈ្មោះ ហេង សម្ផស្ស អាយុ ២៩ ឆ្នាំមកពីក្រុងប៉ោយប៉ែតបាននិយាយថាកញ្ញាមានរោគសញ្ញានៃជំងឺនេះកាលពីថ្ងៃទី ៣១ ខែវិច្ឆិកានៅពេលដែលនាងចាប់ផ្ដើមមានអាការៈឈឺខ្លួន ពិបាកដកដង្ហើម និងមានហូរឈាមច្រមុះ។ កញ្ញាបន្ថែមថា៖ «ខ្ញុំដឹងថាខ្ញុំឆ្លងកូវីដ-១៩ នៅពេលដែលមិត្តខ្ញុំ និងខ្ញុំបានទៅខេត្តឈុនបុរីហើយត្រូវបានធ្វើតេស្តវិជ្ជមានពេលទៅដល់ច្រកព្រំដែនខេត្តបន្ទាយមានជ័យ»។កញ្ញានិយាយថាកញ្ញាមិនបានស្វែងរកជំនួយផ្នែក

វេជ្ជសាស្ត្រនៅក្នុងប្រទេសថៃទេ ប៉ុន្តែបានសម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញហើយបានជូនដំណឹងដល់អាជ្ញាធរសុខាភិបាលជាបន្តទៀតព្រោះនាងមិនចង់ឲ្យមានការឆ្លងរាលដាលជំងឺនេះដល់ពលករចំណាកស្រុកដទៃទៀតទេ។ កញ្ញាបន្តថា៖ «នៅពេលដែលខ្ញុំឆ្លងកាត់ច្រកទ្វារបឹងត្រកួន ខ្ញុំបានឃើញទាហានម្នាក់កំពុងរង់ចាំដឹកពលករចំណាកស្រុក ហើយខ្ញុំបានប្រាប់គាត់កុំអោយមកជិតខ្ញុំដោយសារខ្ញុំបានឆ្លងជំងឺកូវីដ-១៩ ហើយ។ ខ្ញុំបានប្រាប់គាត់ឲ្យយកខ្ញុំទៅធ្វើតេស្តនិងព្យាបាល»។

កញ្ញា សុផានី អាយុ ៣៣ ឆ្នាំមកពីខេត្តបាត់ដំបង ស្រុកបវេលបាននិយាយថាកញ្ញាបានត្រឡប់មកផ្ទះវិញបន្ទាប់ពីមិនអាចរកការងារធ្វើបានក្នុងរយៈពេល ៣ ខែហើយមិត្តភក្តិរបស់កញ្ញាបានចាប់ផ្តើមជូនដំណឹងថាពួកគេបានឆ្លងជំងឺកូវីដ-១៩។ កញ្ញាបាននិយាយថា៖ «ខ្ញុំមានការភ័យខ្លាច ប៉ុន្តែខ្ញុំត្រូវតែប្រឈមមុខនឹងការពិត។ ប្រសិនបើខ្ញុំព្យាយាមរត់គេចខ្ញុំចម្លងដល់គ្រួសារនិងសហគមន៍របស់ខ្ញុំ។ ខ្ញុំត្រូវទុកភាពភ័យខ្លាចមួយឡែក ដើម្បី គ្រួសារខ្ញុំ។ ពលករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃមិនគួររត់គេចពីការធ្វើចត្តាឡីស័កនោះទេ ព្រោះពួកគេមិនដឹងថាពួកគេជាអ្នកផ្ទុកវីរុស ឬក៏ជាអ្នកឆ្លងនោះទេ»។

កញ្ញា យុត ហេង អាយុ ២៩ ឆ្នាំមកពីសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យបាននិយាយថាពួកគេទាំងអស់មានលិខិតឆ្លងដែនដែលមានសុពលភាពហើយចាប់តាំងពីព្រំដែនត្រូវបានបិទពួកគេបានទៅរកការងារធ្វើ និងបានទៅទស្សនាតំបន់ទេសចរណ៍ដែលនៅក្បែរនោះមុនពេលទៅស្នាក់នៅផ្ទះមិត្តភក្តិប្រុសដែលជាជនជាតិថៃ។ កញ្ញាបន្តថា ពួកគេបានសម្រេសចិត្តវិលត្រឡប់នៅពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ នៅខេត្តសាមុតសាខនកាលពីពាក់កណ្តាលខែធ្នូនិងបានឆ្លងកាត់ព្រំដែនអូរបីជាន់។ កញ្ញាក៏ដូចអ្នកដទៃទៀតបានធ្វើតេស្តវិជ្ជមាននៅពេលដែលបុរសម្នាក់បានទូរស័ព្ទមកប្រាប់ថាគាត់បានឆ្លងជំងឺកូវីដ-១៩។ ប្រែសម្រួលដោយ សៀវ គួយអ៊ី

## ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២១

## កិច្ចជំនួបស្តីពី កិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ជាមួយអង្គការសង្គ្រោះជោគវាសនា

https://www.facebook.com/deputygovernoryousophear/ 05-02-2021

នៅរសៀលថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) ដឹកនាំដោយ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការសង្គ្រោះជោគវាសនា ដើម្បីពិភាក្សាលើកិច្ចសហការរួមគ្នា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញចូលរួមពីលោកស្រី ឧត្តមសេនីយ៍ត្រី ស្នងការរងនគរបាលខេត្ត តំណាងទីចាត់ការអន្តរវិស័យ តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងមន្ទីរកិច្ចការនារី និងតំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តផងដែរ។

នៅក្នុងកិច្ចជំនួបនេះផងដែរ អង្គការសង្គ្រោះជោគវាសនា បានជម្រាបជូនអំពីចក្ខុវិស័យនៃប្រត្តិការរបស់អង្គការ ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការអនុវត្តសកម្មភាពមនុស្សធម៌ និងផលប្រយោជសាធារណៈ ដោយធ្វើកិច្ចសហការជាមួយរាជរដ្ឋាភិបាល កម្ពុជា ក្នុងគោលដៅដើម្បីសង្គ្រោះជនរងគ្រោះដោយអំពីធ្វើអាជីវកម្ម និងទាសកផ្លូវភេទ ដើម្បីធ្វើការស្តារ ការពារពង្រឹងសិទ្ធអំណាចដល់ជនរងគ្រោះ នៅក្នុងប្រទេសចំនួន១០។ ដើម្បីចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរ

មនុស្សក្នុងប្រទេសកម្ពុជា  អង្គការស្នើសុំធ្វើកិច្ចសហការជាមួយគណៈកម្មាធិការតាមរយៈក្រុមការងារបច្ចេកទេសរបស់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

នៅក្នុងកិច្ចជំនួបនេះផងដែរបានធ្វើការពិភាក្សាជាច្រើនពាក់ព័ន្ធនឹងនីតិវិធី ក្នុងកិច្ចសហការ បន្ថែមពីនោះ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជម្រាបជូនអំពីរចនាសម្ព័ន្ធ និងយន្តការនៃការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការ ព្រមទាំងកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ និងអង្គការដៃគូ។ ឆ្លៀតក្នុងឱកាសនេះ លោកស្រីក៏បានស្នើឱ្យអង្គការពិនិត្យលើទ្វភាព ក្នុងការសហការលើការពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលយុត្តិធម៌ និងការជួយគាំទ្រផ្តល់សេវាជូនជនរងគ្រោះដោយអំពើពើជួញដូរមនុស្ស។

## ពលករខ្មែរបីនាក់ត្រូវកម្លាំងនគរបាលការពារព្រំដែនគោក៨៩១ទទួលពីទាហានឈុតខ្មៅថៃដឹកបញ្ជូនទៅមណ្ឌលចត្តាឡីស័ក

http://nokorwatnews.com/ 06-02-2021

ខេត្តបន្ទាយមានជ័យ៖ កម្លាំងនគរបាលវរៈសេនាតូចការពារព្រំដែនគោកលេខ៨៩១ សហការជាមួយកងកម្លាំងយោធាកងពលលេខ៥១ នៅវេលាម៉ោង៦ និង១៥នាទីព្រឹកថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១នេះបានទទួលពលករខ្មែរចំនួន ៣នាក់ពីទាហានឈុតខ្មៅថៃ នៃកងអនុសេនាធំ១២០១ បានបញ្ជូនមកពីផ្សាររោងគ្លឿ (ប្រទេសថៃ ) ដើម្បីមកធ្វើចត្តាឡីស័ករកមេរោគcovid-19។ ពលករខ្មែរដែលភាគីថៃបញ្ជូនមកនោះមាន ឈ្មោះដូចខាងក្រោម៖

១/ឈ្មោះ សៀង ផុល ភេទប្រុស អាយុ៥៥ឆ្នាំ នៅភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត

២/ឈ្មោះ សាមុន បេងលាប ភេទប្រុស អាយុ២៨ឆ្នាំ រស់នៅភូមិម្កោ ឃុំតាល្អង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

៣/ឈ្មោះ សុប បន ភេទប្រុសអាយុ២១ឆ្នាំ រស់នៅភូមិកោកកាណាំង ឃុំគុតតាសត ស្រុកអូរជ្រៅ ។

ពលករទាំង៣ត្រូវបានបញ្ជូនមកតាមអូរព្រំដែន កម្ពុជា ថៃចំណុចរោងម៉ាស៊ីនក្រុមហ៊ុនកាស៊ីណូគ្រេនដាយម៉ន់ស៊ីធីក្រោយនាគមាស ត្រូវបានសមត្ថកិច្ចយើងធ្វើការអប់រំរួចបញ្ជូនមកធ្វើចត្តាឡីស័ក ។

លោក ហាំ វណ្ណៈ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨៩១បានចាត់កម្លាំងប៉ុស្តិ៍ក្បាលស្ពាននៃវរៈ៨៩១ដឹកនាំដោយ លោក សែម សាមឿន នាយប៉ុស្តិ៍ក្បាលស្ពាន នៃវរៈ៨៩១បានដឹកបញ្ជូនពលករទាំង៣នាក់ទៅកាន់មណ្ឌលចត្តាឡីស័កនៅមណ្ឌលសុំចត ស្ថិតនៅក្នុងសាលាបឋមសិក្សាហ៊ុនសែន ព្រហ្មនិម្មិត (ហៅសាលាព្រហ្មនិមិត្ត)ស្ថិតនៅក្នុង ភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។ លោកមេបញ្ជាការបញ្ជាក់ថាចំពោះករណីខាងលើនេះប៉ុស្តិ៍ក្បាលស្ពាននៃវរៈលេខ៨៩១បានបញ្ជូនពលករទៅកាន់ចត្តាឡីស័កចំនួន ៥ លើក ហើយក្នុងនោះលោកក៏អំពាវនាវដល់បងប្អូនប្រជាពលរដ្ឋយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារប្រឆាំងជំងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## អភិបាលខេត្តឧត្តរមានជ័យព្រមានចាត់វិធានការដល់ពលករណាមិនព្រមធ្វើចត្តាឡីស័ក

https://www.kampucheathmey.com/ on February 5, 2021 By Sokhom Khon

លោក ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យបានធ្វើការព្រមានផាកពិន័យនិងដាក់ទោសព្រហ្មទណ្ឌដល់ពលករទាំងឡាយណាដែលរត់គេចវេសមិនព្រមធ្វើចត្តាឡីស័ក។ ថ្លែងក្នុងឱកាសចុះសំណេះសំណាលជាមួយបងប្អូនពលករមកពីថៃតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ លោកបានមានប្រសាសន៍ថា ការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា  មានសារៈសំខាន់ណាស់ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ចូលក្នុងសហគមន៍។ លោកបានបន្តទៀតថា ចំពោះការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ

នេះដែរ រដ្ឋបាលខេត្ត ក៏បានយកចិត្តទុកដាក់ចំពោះការផ្គត់ផ្គង់នូវការស្នាក់នៅ ចំណីអាហារ និងសម្ភារៈប្រើប្រាស់មួយចំនួនជូនបងប្អូនពលករផងដែរ។ លោកអភិបាលខេត្តបានបន្ថែមថា «ប្រសិនបើបុគ្គលណាមិនគោរពតាមវិធានការ របស់ក្រសួងសុខាភិបាល ដោយធ្វើចត្តាឡីស័ក១៤ថ្ងៃ ឬរត់ចេញ ឬគេចវេសពីការធ្វើចត្តាឡីស័ក នឹងត្រូវផាកពិន័យចាប់ពី២០០,០០០រៀល ទៅ១,០០០,០០០ រៀល និងត្រូវមានទោសព្រហ្មទណ្ឌផងដែរ»។ លោកអភិបាលខេត្តបានអំពាវនាវឲ្យបងប្អូនពលករ រួមគ្នាការពារជំងឺកូវីដ១៩កុំឱ្យមានការចម្លងដល់បងប្អូនក្រុមគ្រួសារ ក៏ដូចជាសហគមន៍។ ដោយសារចំនួនពលករមកពីថៃចូលតាមច្រកអូរស្មាច់មានការកើនឡើងនោះ អាជ្ញាធរខេត្តឧត្តរមានជ័យបានសម្រេចយកទីតាំងពហុកីឡដ្ឋានខេត្តធ្វើជាមណ្ឌលចត្តាឡីស័កមួយទៀត ដោយរៀបចំដំឡើងតង់ចំនួន ១០០ និងបង្គន់ចំនួន៣៣ និងបានរៀបចំប្រព័ន្ធទឹកភ្លើងខណៈបច្ចុប្បន្នខេត្តមានមណ្ឌលចត្តាឡីស័កប្រមាណជិត ២០កន្លែង។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះមានពលករកំពុងធ្វើចត្តាឡីស័កសរុបចំនួន២,៧៨០នាក់ ដែលកំពុងប្រើប្រាស់មណ្ឌលចត្តាឡីស័កចំនួន១៩មណ្ឌលនៅទូទាំងខេត្តឧត្តរមានជ័យ៕ អត្ថបទ ៖ សំអឿន

## ឯកអគ្គរាជទូតកម្ពុជា ជួយសង្គ្រោះពលរដ្ឋខ្មែរចំនួន៣នាក់ រងគ្រោះដោយអំពើជួញដូរមនុស្ស ចាញ់បោកក្រុមឧក្រិដ្ឋជន នៅប្រទេសវៀតណាម

https://www.cen.com.kh/ February 7, 2021

ហាណូយ ៖ ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃសៅរ៍ ទី៦ ខែកុម្ភៈ ឆ្នាំ ២០២១ បានចេញសេចក្តីជូនដំណឹងការជួយសង្គ្រោះពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស។ ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា កាលពីឆ្នាំ២០២០ ក្រោមកិច្ចសហការយ៉ាង ជិតស្និទ្ធរវាងស្ថានទូត ជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់វៀតណាម ស្ថានទូតបានអន្តរាគមន៍ និងជួយសង្គ្រោះស្ត្រីខ្មែរ ចំនួន ៣៥នាក់ រងគ្រោះដោយអំពើជួញដូរមនុស្សឱ្យបានវិលត្រឡប់ទៅកម្ពុជាវិញ។ ស្ត្រីរងគ្រោះភាគច្រើនមានអាយុចន្លោះពី១៦-៣០ឆ្នាំ ពុំមានលិខិតឆ្លងដែន និងត្រូវបានក្រុមឧក្រិដ្ឋជន ជួញដូរមនុស្សនាំលួចឆ្លងដែន ចូលប្រទេសវៀតណាមដោយខុសច្បាប់ រួចធ្វើដំណើរបន្តទៅកាន់ប្រទេសទី៣។ ភារកិច្ចរបស់ស្ថានទូតក្នុងការជួយសង្គ្រោះពលរដ្ឋខ្មែរនៅបរទេស គឺជាការងារអាទិភាពបំផុត។

ដោយឡែកនៅឆ្នាំ២០២១នេះ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ អាជ្ញាធរខេត្តកាវបាងរបស់វៀតណាម (ជាប់ព្រំដែនប្រទេសចិន និងមានចម្ងាយ ៣៧០គីឡូម៉ែត្រ ពីទីក្រុងហាណូយ) បានជួយសង្គ្រោះស្ត្រីខ្មែរចំនួន ៣ នាក់ ដែលបានចាញ់បោកក្រុមឧក្រិដ្ឋជន៖

១- ស្ត្រីរងគ្រោះទី១ កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៤ មានអាសយដ្ឋាននៅខេត្តបាត់ដំបង

២- ស្ត្រីរងគ្រោះទី២ កើតថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩១ មានអាសយដ្ឋាននៅខេត្តកំពង់ចាម

៣- ស្ត្រីរងគ្រោះទី៣ កើតថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩០ មានអាសយដ្ឋាននៅខេត្តត្បូងឃ្មុំ។

បន្ទាប់ពីអនុវត្តវិធានការធ្វើចត្តាឡីស័កចប់ ស្ថានទូតបានទទួលស្ត្រីរងគ្រោះទាំង ៣នាក់នៅខេត្តកាវបាង ហើយបញ្ជូនត្រឡប់ទៅកម្ពុជាវិញ តាមរថភ្លើងពីទីក្រុងហាណូយ នៅល្ងាចថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០២១ និងទៅដល់ទីក្រុងហូជីមិញ នៅព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ហើយស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ នឹងជូនដំណើរបន្តទៅព្រំដែនអន្តរជាតិបាវិត ដើម្បីប្រគល់ស្ត្រីរងគ្រោះជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារខេត្តស្វាយរៀង ដើម្បីមានវិធានការបន្ត៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## ពលករខ្មែរ៨នាក់ ត្រូវទាហានឈុតខ្មៅថៃឃាត់ខ្លួន ខណៈដែលពួកគាត់ព្យាយាមលួចធ្វើដំណើរវិលត្រឡប់មកប្រទេសកម្ពុជាវិញ

https://gntimes.com/ ថ្ងៃ ៦ ខែ កុម្ភៈ , ឆ្នាំ ២០២១,

ប៉ោយប៉ែត៖ ពលករខ្មែរ៨នាក់ ត្រូវទាហានឈុតខ្មៅកងរយលេខ ១២០៥ ឃាត់ខ្លួន ខណៈដែលពួកគាត់លួចធ្វើដំណើរមកពីខេត្តនគស្រ៊ីធម្មរាជ និងសុរាត ថានី ព្យាយាមវិលមកប្រទេសកម្ពុជាវិញ នៅបរិវេណបន្ទាត់ព្រំដែនកម្ពុជា-ថៃ ស្រុកអរញ្ញ ខេត្តស្រះកែវ។

បើតាមអ្នកសារព័ត៍មានថៃ បានរាយការណ៍ថា កាលពីថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០២១ សមត្ថកិច្ចប្រចាំព្រំដែនក្នុងទឹកដីខេត្តស្រះកែវ បានធ្វើការរិតបន្តឹង ក្នុងការត្រួតពិនិត្យបញ្ហាការលួចឆ្លងដែនរបស់ពលករខ្មែរ ក្នុងអំឡុងស្ថានការណ៍រាត្បាតរបស់កូវីដ-១៩ ដោយសមត្ថកិច្ចទាហានប្រាណទី១២ ចំណុះអង្គភាពកងរយទី១២០៥ ល្បាតនិងឃ្លាំមើលក្នុងភូមិសាស្ត្រទទួលខុសត្រូវ រហូតបានប្រទះឃើញក្រុមបុគ្គលគួរឲ្យសង្ស័យចំនួន៨នាក់ ប្រុសទាំងអស់ ខណៈកំពង់ដើរ ព្រមទាំងសម្ភារៈ នៅបរិវេណ ភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកអរញ្ញ ខេត្តស្រះកែវ ក្រោយពីធ្វើការសួរនាំ ទើបដឹងថា ពួកគេជាពលករខ្មែរ ដែលទើបធ្វើដំណើរមកពីធ្វើការនៅរោងចក្រកៅស៊ូ ក្នុងខេត្ត នគស្រ៊ី ធម្មរាជ និងខេត្ត សុរាត ថានី ហើយព្យាយាមលួចឆ្លងដែនចូលទៅប្រទេសកម្ពុជា ដើម្បីធ្វើដំណើរត្រឡប់ទៅភូមិលំនៅដ្ឋានរបស់ពួកគាត់វិញ ទើបឃុំខ្លួនមកសាកសួរនៅទីបញ្ជារការកងរយទាហានប្រាណទី១២០៥។

សូមជំបថា ក្រោយពីសមត្ថកិច្ចសួរនាំពលករខ្មែរទាំងអស់ ដែលលួចចេញពីប្រទេសថៃ ក្នុងនោះមានពលករមកពីខេត្តនគស្រ៊ី ធម្មរាជ ចំនួន៤នាក់ រួមមានទី១-ឈ្មោះ ឌុក ផូល អាយុ៤៧ឆ្នាំ, ទី២-ឈ្មោះ ហេង ស្រេះ អាយុ៤៥ឆ្នាំ, ទី៣-ឈ្មោះ វើន សំបូរ អាយុ៣២ឆ្នាំ និងទី៤-ឈ្មោះ បូ ថង អាយុ២៤ឆ្នាំ។ ដោយឡែកពលករខ្មែរដែលមកពីខេត្ត សុរាត ថានី ចំនួន៤នាក់ ទី១-ឈ្មោះ ជួយ លីន អាយុ២២ឆ្នាំ, ទី២-ឈ្មោះ ធីម អន អាយុ២១ឆ្នាំ, ទី៣-ឈ្មោះ ចា ភូ អាយុ៤៨ឆ្នាំ និងទី៤-ឈ្មោះ កែវ នី អាយុ២៣ឆ្នាំ ដែលអ្នកទាំងអស់មានស្រុកកំណើតនៅឯខេត្តព្រៃវែង ប្រទេសកម្ពុជា ។ ក្រោយពីសមត្ថកិច្ចសួរនាំ និងធ្វើកំណត់ហេតុរួច និងធ្វើចត្តាឡីស័កកូវិដ-១៩ មានកម្តៅធម្មតា ទើបសមត្ថកិច្ចនាំខ្លួនពលករទាំងនោះ បញ្ជូនទៅឲ្យទាហានកងរយ១២៧ ភូមិណូន ម៉ាកមុន ស្រុកគោកឃ្សូង ដើម្បីបញ្ជូនឲ្យត្រឡប់ចូលមកកម្ពុជា តាមប្រកត្រួតពិនិត្យអូរបើជាន់បន្ត។

យោងតាមការឲ្យដឹងពីសមត្ថកិច្ចថា ពួកគេបានជិះរថយន្តដឹកអ្នកដំណើរពីខេត្ត សុរាត ថានី និងនគស្រ៊ីធម្មរាជ អស់ថ្លៃជិះរថយន្តក្នុងម្នាក់៤,០០០បាត ដើម្បីមកចុះនៅស្ថានីយ៍ដឹកជញ្ជូន សាយ តៃម៉ី តឹ្លង ធន់ ក្រុងបេបមហានគរ និងម៉ៅរថយន្តតាក់ស៊ីមកចំនួន២គ្រឿង ដើម្បីឲ្យជូនមកស្រុកអរញ្ញ ខេត្តស្រះកែវ អស់ថ្លៃរថយន្តក្នុងម្នាក់៣,០០០បាត មុនហ្នឹងត្រូវទាហានចាប់ឃុំខ្លួនបាន នៅបរិវេណបន្ទាត់ព្រំដែនកម្ពុជា-ថៃ ខាងលើ៕

## ពលករខ្មែរនៅថៃ ប្រឈមការចាប់ខ្លួនព្រោះគ្មានប្រាក់ចុះឈ្មោះសុំសិទ្ធិធ្វើការស្របច្បាប់

https://www.rfa.org/ ដោយ មួង ណារ៉េត 2021-02-07

ពលករខ្មែរធ្វើការនៅប្រទេសថៃជាច្រើននាក់ នៅតែពុំមានលទ្ធភាពចុះឈ្មោះសុំសិទ្ធិធ្វើការងារស្របច្បាប់បាននៅឡើយ ស្របពេលដែលថ្ងៃផុតកំណត់ចុះឈ្មោះនៅចុងសប្តាហ៍នេះ។ ពលករខ្លះមានជីវភាពខ្វះខាត និងខ្លះទៀត ពុំដឹងព័ត៌មាន អំពីអាជ្ញាធរថៃបើកឱ្យពលករបរទេសសុំសិទ្ធិធ្វើការស្របច្បាប់នៅឡើយ។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលករទាំងនោះអាចនឹងត្រូវអាជ្ញាធរថៃចាត់វិធានការតាមច្បាប់នៅពេលខាងមុខ។ ក្រុមពលករខ្មែរ ដែលធ្វើការខុសច្បាប់នៅប្រទេសថៃ កំពុងព្រួយបារម្ភខ្លាចអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ទៅកម្ពុជាវិញ ឬចាប់ដាក់គុក នៅពេលខាងមុខ ដោយសារតែពួកគាត់ ពុំមានលទ្ធភាពចុះឈ្មោះសុំសិទ្ធិការងារស្របច្បាប់។

ប្រជាពលរដ្ឋ ដែលមានស្រុកកំណើត នៅខេត្តប៉ៃលិនលោកស្រី ហែម មុំ រៀបរាប់ប្រាប់អាស៊ីសេរីថា លោកស្រីនិងកូនស្រីរបស់លោកស្រី ២នាក់ មិនទាន់បានចុះឈ្មោះសុំសិទ្ធិធ្វើការងារស្របច្បាប់នៅឡើយទេ ព្រោះទើបតែដឹងព័ត៌មាន ដែលថាអាជ្ញាធរថៃ បើកឱ្យសុំសិទ្ធិធ្វើការងារស្របច្បាប់ ឬបើកឲ្យសុំកាតធ្វើការពណ៌ស៊ីជម្ពូ។ ពលការិនីធ្វើការសំណង់រូបនេះ បន្ថែមថា លោកស្រីគ្មានប្រាក់ចុះឈ្មោះធ្វើកាតស៊ីជម្ពូ ដើម្បីបានសិទ្ធិធ្វើការងារស្របច្បាប់នោះទេ ដ្បិតមួយរយៈនេះ ពួកគាត់ធ្វើការមិនទៀងទាត់ ហើយបានប្រាក់ឈ្នួលតិចតួចសម្រាប់តែដោះស្រាយជីវភាពប្រចាំថ្ងៃប៉ុណ្ណោះ។ ស្ត្រីមេម៉ាយរូបនេះ បញ្ជាក់ថា លោកស្រីមិនចង់ត្រឡប់ទៅកម្ពុជាអំឡុងពេលនេះទេ ព្រោះនៅស្រុកកំណើតគ្មានដីដាំដុះ និងគ្មានរបររកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារឡើយ៖ «ខ្ញុំចាញ់តែបោកគេមិនដែលបានលុយផង ភូមិជីន (Jin)ក៏មិនបានលុយនៅឯប៉ាតាយ៉ាក៏មិនបានលុយ ខ្ញុំដើរឡើង៦ ប្រាំពីរខែហើយមិនដែលបានលុយទេ គេឱ្យតែថ្លៃម្ហូបហូប។ ខ្ញុំមកនេះប៉ុន្មានខែហើយក៏មិនមានលុយណាទៅធ្វើកាត ។ខ្ញុំធ្វើការមកនេះមិនរួចថ្លៃម្ហូបហើយគេកាត់៥០០ៗ ខ្ញុំស្រីបានប្រាក់៥ពាន់អស់ច្រើនហើយ ហើយគេកាត់៥០០ទៀត ខ្ញុំមានអីសល់។ វាពិបាកណាស់និយាយថា អត់ត្រូវ វាពិបាករកនិយាយអីអត់កើត គេឱ្យធ្វើយើងធ្វើទៅ បើគេចាបគេចងគេមិនឱ្យធ្វើមានតែទៅខ្មែរវិញហ្នឹងហើយ»។

ស្រដៀងគ្នានេះដែរ ពលការិនីធ្វើការសំណង់នៅប្រទេសថៃម្នាក់ទៀត លោកស្រី ហៃ សុខន ថ្លែងថា គ្រួសាររបស់លោកស្រី មានសមាជិក៣នាក់ បានឆ្លងដែនទាំងប្រថុយប្រថានមករកការងារធ្វើនៅប្រទេសថៃ កាលពីខែ មេសា ឆ្នាំ ២០២០។ ស្ត្រីវ័យ៣៥ឆ្នាំរូបនេះ ប្រាប់ថា ចាប់តាំងពីពួកលោកស្រី និងកូន២នាក់ មកដល់ប្រទេសថៃមកគឺធ្វើការមិនបានប្រាក់ឈ្នួលគ្រប់ចំនួនតាមកម្លាំងពលកម្មនោះទេ ដោយថៅកែថៃបើកប្រាក់ឱ្យបន្តិចបន្តួច ដើម្បីទិញស្បៀងអាហារហូបចុកប្រចាំថ្ងៃប៉ុណ្ណោះ។ លោកស្រីបន្ថែមថា អំឡុងពេលរាតត្បាតជំងឺកូវីដ១៩នេះ លោកស្រីនិងកូនៗរបស់លោកស្រីបានប្តូរទីកន្លែងធ្វើការចំនួន២លើករួចមកហើយ នៅតែសន្សំប្រាក់មិនបានផ្ញើទៅឱ្យបងប្អូននៅកម្ពុជាដដែល។ លោកស្រីថា ពួកគាត់មិនទាន់បានចុះឈ្មោះ សុំសិទ្ធិធ្វើការងារស្របច្បាប់នៅឡើយទេ ពីព្រោះគ្មានប្រាក់បង់ថ្លៃធ្វើកាតពណ៌ស៊ីជម្ពូរបស់អាជ្ញាធរថៃនោះ៖ «ខ្ញុំព្រួយបារម្ភខ្លាចគេចុះចាប់ចុះអីដែរ ព្រោះអីខ្ញុំមានបញ្ហាដូចថាម៉ែគាត់ឈឺនៅផ្ទះ ខ្ញុំមករកយកទៅមើលម៉ែ។ ដល់ពេលមកអីចឹងយើងអត់មានប៉ាស្ព័រអីចឹងយើងចេះតែព្រួយបារម្ភដែរហ្នឹង មើលដូចកាលពីចូលឆ្នាំសាកលខ្ញុំរត់បែកទឹកបែកដីហើយ កាលណាមិនឱ្យគេអាហ្នឹងឱ្យទេខ្ញុំធ្វើការអត់សល់លុយទៅស្រុកទេ។ ក៏ចង់ធ្វើអាហ្នឹងឯង ព្រោះអីខ្ញុំធ្វើការអត់មានសល់លុយទេ»។

ចំណែកពលរដ្ឋមានស្រុកកំណើតនៅ ខេត្តបន្ទាយមានជ័យវិញ គឺលោកស្រី ឡឿន ថេត លោកស្រី ឱ្យដឹងថា លោកស្រីបានមកស្នាក់នៅជាមួយមិត្តភ័ក្តិជាង ១ខែហើយ ដោយសារមួយរយៈនេះលោកស្រីអត់ការងារធ្វើ ហើយគ្មានប្រាក់ទិញអាហារហូបចុក និងប្រាក់បង់ថ្លៃបន្ទប់ជួល។ ស្ត្រីវ័យ៣៣ឆ្នាំរូបនេះ ប្រាប់ថា លោកស្រីក៏មិនទាន់បានចុះឈ្មោះធ្វើកាតពណ៌ស៊ីជម្ពូនោះដែរ ដោយសារគ្មានប្រាក់បង់ថ្លៃធ្វើឯកសាររបស់អាជ្ញាធរថៃ។ លោកស្រីបញ្ជាក់ថា លោកស្រី ចង់ត្រឡប់ទៅកម្ពុជាវិញដែរ ប៉ុន្តែមិនអាចធ្វើដំណើរទៅបាន ព្រោះអាជ្ញាធរថៃបានហាមឃាត់មិនឱ្យពលករបរទេសចល័តពីខេត្តមួយទៅខេត្តទៀត៖ «ចៃដន្យអីយើងនៅជាមួយគេអីចឹងវាប្រយ័តលុយផង យើងចេះធ្វើបាយធ្វើទឹកអីចឹងទៅវាប្រយ័តលុយ បើសិនទៅញាំខាងក្រៅវិញវាអស់ច្រើន។ សំខាន់គឺការងារវាអត់បានលុយ មកធ្វើការអីចឹងវាមានបញ្ហាហ្នឹងកន្លែងធ្វើការ ជួនកាលយើងមកធ្វើការជាមួយមិត្តភ័ក្តិអីចឹងគេនិយាយកិច្ចសន្យាការងារអត់ដឹងរឿង យើងអត់ដឹងដែរ ដល់មកធ្វើគ្នាអីចឹងវាត្រូវនេះ កាលហ្នឹងធ្វើការប្រហែលជា៣ខែគ្នាបានលុយទេ ទៅកន្លែងថ្មីទៀតក៏មិនសូវបានលុយដែរ។ ២ឆ្នាំនេះខ្ញុំអត់មានចំណូលទេ ខ្ញុំមានតែចាយលុយអ្នកផ្ទះទៀត»។

អាស៊ីសេរីមិនទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញក្តីកង្វល់របស់ពលករនេះបានទេ នៅថ្ងៃទី៧ ខែកុម្ភៈ ដោយទូរស័ព្ទចូលជាច្រើនដងពុំ

មានអ្នកទទួល។ ប៉ុន្តែមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកធ្លាប់ឱ្យដឹងថា ស្ថានទូតមិនអាចជួយដោះស្រាយជូនពលករតាមការស្នើសុំបានទេ ព្រោះអាជ្ញាធរថៃ បានបើកឱ្យពលករចុះឈ្មោះសុំសិទ្ធិធ្វើការងារស្របច្បាប់ហើយ។

ក្រសួងការងារថៃ បើកឱ្យពលករបរទេសចុះឈ្មោះតាមទូរស័ព្ទ ដើម្បីធ្វើកាតធ្វើការពណ៌ស៊ីជម្ពូចាប់ពីថ្ងៃទី ១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ ខាងមុខដើម្បីមានសិទ្ធិធ្វើការងារស្របច្បាប់រយៈពេល២ឆ្នាំនៅក្នុងប្រទេសថៃ។ វិធានការរបស់អាជ្ញាធរថៃនេះ ធ្វើឡើងជាករណីពិសេសដើម្បីទប់ស្កាត់កុំឱ្យមានការរាតត្បាតជំងឺកូវីដ-១៩។ ទោះជាយ៉ាងណា ក្រសួងការងារថៃព្រមានថា អាជ្ញាធរថៃនឹងចាត់វិធានការតាមផ្លូវច្បាប់ លើពលករបរទេសណា ដែលធ្វើការងារខុសច្បាប់ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ តទៅ។

ទោះជាយ៉ាងនេះក្តីមន្ត្រីអង្គការសង់ត្រាល់(Central) ទទួលបន្ទុកសិទ្ធិការងារ លោក ឌី ថេហូយ៉ា យល់ថា ការបើកឱ្យពលករចុះឈ្មោះរយៈពេល ១ ខែនេះ មិនគ្រប់គ្រាន់សម្រាប់ពលករបំពេញបែបបទសុំសិទ្ធិនោះឡើយ។ លោកថា ពលករខ្មែរមានរាប់សែននាក់ កំពុងធ្វើការងារខុសច្បាប់នៅប្រទេសថៃ ហើយពួកគាត់ភាគច្រើន មិនចេះចុះឈ្មោះតាមទូរស័ព្ទនោះទេ។ ម្យ៉ាងទៀត ការធ្វើកាតពណ៌ស៊ីជម្ពូនេះ តម្រូវឲ្យពលករបង់ប្រាក់ជាង៩ពាន់បាត(៩ ០០០) ឬប្រមាណ៣០០ដុល្លារក្នុងម្នាក់ឯណោះ ដែលជាបន្ទុកធ្ងន់សម្រាប់ពលករ។ លោកបន្ថែមថា ពលករមួយចំនួនអត់ការងារធ្វើជាច្រើនខែមកហើយ ដូច្នេះពួកគាត់មិនមានប្រាក់ធ្វើកាតពណ៌ស៊ីជម្ពូនោះឡើយ៖ «ហើយអាបញ្ហាមួយទៀតហ្នឹងគឺគាត់ត្រូវប្រឈមនឹងអត់មានប្រាក់ចំណូលការចិញ្ចឹមជីវភាពការបង់ធនាគារអីជាដើមអីចឹង។ អីចឹងយើងឃើញថា បញ្ហាប្រឈម៤ហ្នឹងវារឹតតែឱ្យគាត់រងគ្រោះ គេហៅថាជនរងគ្រោះនៃសង្គម។ សង្គមហ្នឹងគឺមិនបង្កើតបរិយាកាសមួយអាចឱ្យគាត់អាចរស់បានស្រួលហើយ សង្គមមិនមានការទទួលខុសត្រូវសំដៅទៅការដឹកនាំរដ្ឋមិនមានការទទួលខុសត្រូវចំពោះពលរដ្ឋខ្លួន ដែលដឹងហើយថាបញ្ហានឹងកើតឡើងចំពោះពលរដ្ឋក៏ប៉ុន្តែមិនមានចំណាត់ការសមស្របណាមួយដើម្បីឆ្លើយតបចំពោះបញ្ហាទាំងអស់ហ្នឹង»។

របាយការណ៍ក្រសួងការងារថៃឱ្យដឹងថា គិតត្រឹមថ្ងៃទី៦ ខែ កុម្ភៈ មានពលករខ្មែរជិត ១សែន ២ម៉ឺននាក់ហើយ(១១៩.៨១១) ដែលបានចុះឈ្មោះសុំសិទ្ធិធ្វើការស្របច្បាប់រួចរាល់។

មន្ត្រីសិទ្ធិការងារលោក ឌី ថេហូយ៉ា ឱ្យដឹងដែរថា ពលករខ្មែរធ្វើការងារនៅប្រទេសថៃមាន ១លាន ៨សែននាក់ ក្នុងនោះពលករធ្វើការខុសច្បាប់មានជាង ៤សែន(៤០០.០០០)នាក់។ មន្ត្រីសង្គមស៊ីវិលរូបនេះ ជឿថា ពលករខ្មែរជាង ២សែននាក់ នឹងក្លាយទៅជាពលករខុសច្បាប់ ហើយអាជ្ញាធរថៃ អាចនឹងចាប់បញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ ឬចាប់ដាក់ពន្ធនាគារនៅពេលខាងមុខ។ លោកថា ដើម្បីដោះស្រាយបញ្ហានេះអាជ្ញាធរថៃគួរតែពន្យារពេលចុះឈ្មោះសុំសិទ្ធិធ្វើការទៅមុខមួយរយៈទៀត ហើយបញ្ចុះតម្លៃធ្វើកាតឱ្យបានទាបជាងពេលបច្ចុប្បន្ន។ បន្ថែមពីនេះ លោកជំរុញឲ្យរដ្ឋាភិបាលកម្ពុជានិងថៃ ត្រូវចាត់វិធានលើក្រុមមេខ្យល់ ដែលរត់ការចុះឈ្មោះឱ្យពលករក្នុងតម្លៃថ្លៃលើសការកំណត់របស់អាជ្ញាធរថៃ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រក

ដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៥៥នាក់ ស្រី ៧០នាក់ ក្នុងនោះកុមារា ៩នាក់ កុមារី ១១នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥៤នាក់ ស្រី ២៣នាក់ កុមារា ២នាក់ កុមារី ៤នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៥នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ២នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់ ចំនួន ៦៨នាក់ ស្រី ៣៥នាក់ កុមារា ៧នាក់ កុមារី ៥នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ៨នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៥៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៧៩នាក់, ខេត្តបាត់ដំបង ចំនួន ៨នាក់ និងឧត្តរមានជ័យចំនួន ៦៨ នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ពលករខ្មែរ១៨នាក់ ដែលត្រូវបានជួយសង្គ្រោះហើយ នឹងមកដល់កម្ពុជាវិញ នៅថ្ងៃទី៦ កុម្ភៈ

https://thmeythmey.com/ 06, Feb 2021 , 2:40 pm ដោយ: ធឿន បញ្ញាឬទ្ធិ

ភ្នំពេញ៖ ពលករខ្មែរ១៨នាក់ ដែលខុសច្បាប់នៅម៉ាឡេស៊ី នឹងមកដល់កម្ពុជា នៅម៉ោងជាង៥ល្ងាច ទី០៦ ខែកុម្ភៈនេះ ។ នេះបើតាមស្ថានទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី។ ពលករខ្មែរទាំង១៨នាក់នេះ ត្រូវបានអាជ្ញាធរម៉ាឡេស៊ីឃាត់ខ្លួន ដោយសារតែពួកគេស្នាក់នៅខុសច្បាប់។ ក្រោយដឹងព័ត៌មាននេះ ស្ថានទូតកម្ពុជា ក៏បានអន្តរាគមន៍ជួយសង្គ្រោះ ដោយសម្របសម្រួលជាមួយអាជ្ញាធរម៉ាឡេស៊ី ដោះស្រាយបញ្ហាពួកគេឱ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតកម្ពុជា បានបញ្ជាក់ដូច្នេះថា៖«ការវិលត្រឡប់របស់ពលករពលការិនីខាងលើ គឺធ្វើឡើងតាមរយៈកម្មវិធី Undocumented Migrant Recalibration Plan របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី។ សូមបញ្ឈប់ការធ្វើចំណាកស្រុកដោយខុសច្បាប់។

បើតាមស្ថានទូតខ្មែរ ពលករទាំងនោះនឹងទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះលេខSQ5008 ។ កាលពីថ្ងៃទី៣ កុម្ភៈ ស្ថានទូតកម្ពុជា ក៏បានជួយសង្គ្រោះពលករខ្មែរ១៧នាក់ដែរ។ ស្ថានទូតកម្ពុជា ក៏បានជួយសង្គ្រោះពលករខ្មែរជាង២០នាក់ហើយ នៅម៉ាឡេស៊ី កាលពីខែមករា កន្លងមក ។ ពលករដែលស្ថានទូតកម្ពុជា អន្តរាគមន៍សង្គ្រោះនេះ ភាគច្រើនជាពលករឆ្លងដែនខុសច្បាប់ ចូលម៉ាឡេស៊ី៕

## អាជ្ញាធរម៉ាឡេស៊ី តាមចាប់ស្ត្រីម្ចាស់ផ្ទះ ដែលធ្វើទារុណកម្មលើយុវតីខ្មែរ-អ៊ិស្លាម

https://www.thmeythmey.com/ 05, Feb 2021 , 1:26 pm

ភ្នំពេញ៖ អាជ្ញាធរម៉ាឡេស៊ី កំពុងបន្តស្វែងរកចាប់ស្ត្រីខ្មែរ-អ៊ិស្លាម ដែលវាយធ្វើបាបយុវតីខ្មែរ-អ៊ិស្លាមអាយុ ១៦ឆ្នាំ ដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់។ នេះបើតាមការអះអាងរបស់ស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ី នៅលើទំព័រហ្វេសប៊ុករបស់ខ្លួន។ យុវតីជាជនរងគ្រោះ បានត្រឡប់មកដល់កម្ពុជាវិញហើយ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី។ ជាមួយគ្នាដែរ ស្ថានទូតបានបញ្ជាក់ថា យុវតីជាជនរងគ្រោះ គឺឆ្លងដែនទៅម៉ាឡេស៊ីខុសច្បាប់។ ស្ថានទូតបញ្ជាក់ថាយ៉ាងដូច្នេះថា៖«យុវតីរូបនោះ បានចូលមកប្រទេសម៉ាឡេស៊ីដោយខុសច្បាប់ ហើយត្រូវស្ត្រីជនជាតិខ្មែរ-អ៊ិស្លាមឈ្មោះទីចៅ វាយធ្វើបាប»។ អាជ្ញាពាក់ព័ន្ធ បានទទួលព័ត៌មានអំពីយុវតីខាងលើ រងការធ្វើបាប តាមរយៈការចែករំលែកតៗគ្នាលើបណ្ដាញសង្គម។ អ្នកប្រើ

ប្រាស់បណ្ដាញសង្គម ផ្សាយតៗគ្នាថា យុវតីរូបនោះ ត្រូវបានស្ត្រីម្ចាស់ផ្ទះវាយធ្វើបាបធ្ងន់ធ្ងរហូតដល់កាត់ស្លឹកត្រចៀក ហើយអំពាវនាវឲ្យអាជ្ញាធរកម្ពុជា ជួយសង្គ្រោះនាង។

យ៉ាងណាក៏ដោយ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស អះអាងថា នាង ពិតជាត្រូវបានស្ត្រីម្ចាស់ផ្ទះជាខ្មែរ-អិស្លាមដូចគ្នា ធ្វើទារុណកម្មត្រូវចំស្លឹកត្រចៀកមែន តែមិនដាច់នោះទេ។ ក្នុងកិច្ចសម្ភាសជាមួយសារព័ត៌មានថ្មីៗ តាមទូរស័ព្ទ នៅព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ អ្នកនាំពាក្យរូបនេះ បញ្ជាក់ថា៖«អត់ [ដាច់] ទេ គ្រាន់តែរយះតិចតួចដែរទេ ហើយគេ ព្យាបាលបានទាំងអស់វិញតើ»។ លោក បន្តថា មកដល់នេះ លោក មិនទាន់ដឹងព័ត៌មាននៅឡើយទេថា អាជ្ញាធរម៉ាឡេស៊ី ចាប់ស្ត្រីជាជនល្មើសនោះបានហើយឬនៅ។ ម្យ៉ាងទៀត ស្ថានទូតកម្ពុជាប្រចាំនៅម៉ាឡេស៊ី ក៏មិនទាន់ឃើញផ្សាយអំពីព័ត៌មាននេះដែរ។

ជុំវិញករណីនេះ លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានឲ្យដឹងថា ក្រុមការងាររបស់លោក និងក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន កំពុងប្រជុំពិភាក្សាគ្នាដើម្បីផ្តល់ជំនួយគាំទ្រដល់យុវតីជាជនរងគ្រោះ។ លោក មានប្រសាសន៍ជាមួយសារព័ត៌មានថ្មីៗថា៖«ខាងខ្ញុំកំពុងប្រជុំជាមួយក្រសួងសង្គមកិច្ច អំពីការផ្តល់ការគាំទ្រផ្សេងៗ ដល់គាត់(ជនរងគ្រោះ)។ លោក បន្តថា រាល់ព័ត៌មានលម្អិត លោក មិនអាចផ្តល់ជូននៅពេលនេះបានឡើយ គឺរង់ចាំក្រុមការងារស្រាវជ្រាវបន្ថែម។

បើតាមការផ្សាយរបស់គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ យុវតីខ្មែរ-អ៊ិស្លាមនោះ បម្រើការងារជាជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ី។ នគរបាលជាតិ បានឲ្យដឹងថា បច្ចុប្បន្ន នាង កំពុងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កព្រែកព្នៅ រាជធានីភ្នំពេញ។ នគរបាលជាតិ បានផ្សាយទៀតថា ពេលនាង ធ្វើវិធានចត្តាឡីស័ករួចហើយ អាជ្ញាធរពាក់ព័ន្ធ ស៊ើបអង្កេតស្វែងរកជនសង្ស័យជាមេខ្យល់ ដែលនាំនាង ទៅបម្រើការងារនៅម៉ាឡេស៊ី ដើម្បីឈានដល់ការចាប់មេខ្យល់នោះ យកទៅកផ្តន្ទាទោសតាមច្បាប់។

ទន្ទឹមនឹងនេះ ស្ថានទូតកម្ពុជាប្រចាំម៉ាឡេស៊ី បានអំពាវនាវឲ្យពលរដ្ឋកម្ពុជា បញ្ឈប់ធ្វើការចំណាកស្រុកដោយខុសច្បាប់ ដើម្បីសុវត្ថិភាពផងដែរ៕

## ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១

### កម្ពុជាទទួលជោគជ័យ ក្នុងគ្រប់គ្រងទេសន្តប្រវេសន៍ លើប្រជាពលរដ្ឋដែលចេញទៅធ្វើការនៅក្រៅប្រទេស

https://dap-news.com/national/ ByKD102 Posted on February 9, 2021

**ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា ប្រទេសកម្ពុជាគឺជាប្រទេសដែលទទួលបានជោគជ័យ ក្នុងការងារគ្រប់គ្រងទេសន្តប្រវេសន៍ លើប្រជាពលរដ្ឋរបស់ខ្លួន ដែលធ្វើចំណាកស្រុកទៅធ្វើការ នៅក្រៅប្រទេសតាមរយៈការវាយតម្លៃ របស់អង្គការសហប្រជាជាតិ (UN) កាលពីពេលថ្មីៗកន្លងទៅនេះ។**

ក្នុងពិធីប្រកាសចូលកាន់មុខតំណែង ជាប្រធានលេខាធិការដ្ឋាន អនុប្រធាន សមាជិក និងក្រុមជំនួយការនៃលេខាធិការដ្ឋានគ្រប់គ្រង គ្រោះមហន្តរាយក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ នៅទីស្តីក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម ស ខេង បានណែនាំទៅដល់សមត្ថកិច្ចទូទាំងប្រទេស ត្រូវបន្តរួបរួមគ្នាទប់ស្កាត់ អំពើជួញដូរមនុស្សនៅទូទាំងប្រទេសកម្ពុជា ដើម្បីកិច្ចការនេះឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀត។ សម្តេចក្រឡាហោម ស ខេ បញ្ជាក់ថា «នាពេលថ្មីៗតាមព័ត៌មានថា អង្គការសហប្រជាជាតិ បានចាត់ទុកកម្ពុជាទទួលបានជោគជ័យ

ក្នុងការងារទេសន្តប្រវេសន៍។ នេះជាជោគជ័យមួយ ការគ្រប់គ្រងទេសន្តរប្រវេសន៍ប្រជាពលរដ្ឋយើង ចេញទៅរកការងារនៅក្រៅប្រទេស»។ សម្ដេចក្រឡាហោម បន្តថា តាមរយៈការងារនេះមានន័យថា កម្ពុជាបានការពារប្រជាពលរដ្ឋ បានរួចផុតពីការជួញដូរមនុស្ស។ ប៉ុន្តែដោយឡែកតាមការវាយតម្លៃ របស់ក្រសួងការបរទេស សហរដ្ឋអាមេរិកវិញអោយដឹងថា ការជួញដូរមនុស្សនៅកម្ពុជា នៅតែជាប់ចំណាត់ថ្នាក់លេខ២ ដែលស្ថិតក្រោមការឃ្លាំមើលរបស់គេ។ សម្ដេចក្រឡាហោម ក៏បានសន្និដ្ឋានថា កម្ពុជានៅតែជាប់ចំណាត់ថ្នាក់លេខ២ នេះគឺមានមូលហេតុមួយចំនួនដែលកម្ពុជាមិនទាន់បានអនុវត្តតាមសំណើរ និងសំណូមពររបស់ភាគីដៃគូ ហើយបញ្ហាអំពើជួញដូរមនុស្ស ក៏នាំឲ្យគេបានចាត់ទុកកម្ពុជា ជាប់ចំណាត់ថ្នាក់លេខ២ ផងដែរ។ ជាងនេះទៅទៀត សម្ដេចក្រឡាហោម ស ខេង ក៏បានលើកឡើងថា ទោះបីកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ ក៏ដោយ សមត្ថកិច្ចនិងភាគីពាក់ព័ន្ធមួយចំនួនទៀត ត្រូវបន្តអនុវត្តការងារអំពើ ជួញដូរមនុស្សតាមគោលការណ៍ ច្បាប់របស់ប្រទេសកម្ពុជា ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ជាបន្តទៀត។

ឆ្លៀតឱកាសនោះ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានឲ្យដឹងទៀតថា សម្ដេចធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ទៅលើមូលហេតុគ្រឿងញៀន មានការចរាចរណ៍កាន់តែច្រើននៅក្នុងប្រទេសកម្ពុជា ក្នុងនោះ សមត្ថកិច្ចក៏បានឃាត់ខ្លួនអ្នកជួញដូរ គ្រឿងញៀនកាន់តែច្រើនផងដែរ។ សម្ដេចក្រឡាហោម បានបញ្ជាក់យ៉ាងដូច្នេះថា «ឥឡូវនេះយើងឃើញថា គ្រឿងញៀន ហាក់បីដូចជា មានចរាចរណ៍កាន់តែច្រើន យើងចាប់បានកាន់តែច្រើន ហើយឥឡូវនេះ យើងបន្តសិក្សាបន្តទៀត តើមូលហេតុអ្វីខ្លះ?។ ប៉ុន្មានថ្ងៃមុននេះចាប់បានគ្រឿងញៀនជាង ៥០០គីឡូក្រាម យកទៅលាក់ទុកនៅលើកោះ ក្នុងខេត្តព្រះសីហនុ ឥឡូវសមត្ថកិច្ច បានប្រមូលទុកអស់ហើយ»។ សម្ដេចក្រឡាហោម បន្តថា គ្រឿងញៀនជាង ៥០០គីឡូក្រាម ដែលរឹបអូសយកមកបាន នៅខេត្តព្រះសីហនុ មិនមែនប្រើប្រាស់នៅកម្ពុជាទាំងអស់នោះទេ យកទៅបន្តបែងចែកតាមបណ្ដាប្រទេសផ្សេងៗ ដូចជា វៀតណាម ថៃ ជាដើម ដែលធ្វើឡើងតាមផ្លូវសមុទ្រ។ ជាងនេះទៅទៀត សម្ដេចក្រឡាហោម ស ខេង ក៏បានផ្ដាំផ្ញើទៅដល់សមត្ថកិច្ចទូទាំងប្រទេស ត្រូវបន្តប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅប្រទេសកម្ពុជាឲ្យកាន់តែមាន ប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ៕

## អ្នកលួចលាក់ ឬផ្សំគំនិតជាមួយពលករ គេចវេសពីការធ្វើចត្តាឡីស័ក ត្រូវមានទោស មិនអាចលើកលែង

https://www.kampucheathmey.com/ on February 8, 2021 By Kang Tola

នេះជាការលើកឡើងរបស់លោក ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ខណៈចុះពិនិត្យស្ថានភាពតាមដងអូរ ដែលជាខ្សែបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុកកំរៀង ដែលធ្លាប់មានពលករខ្មែរចូលមកពីប្រទេសថៃតាមច្រកព្រំដែនកាលពីព្រឹកថ្ងៃច័ន្ទទី០៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ។ នៅក្នុងឱកាសនោះលោក ងួន រតនៈ ក៏បានណែនាំដល់ប្រជាពលរដ្ឋរស់នៅតាមដងអូរជាប់ព្រំដែនប្រទេសថៃ កុំលួចលាក់ពលករ ឬផ្សំគំនិតជាមួយពលករដើម្បីគេចវេសពីមណ្ឌលចត្តាឡីស័ក ហើយប្រសិនបើកម្លាំងសមត្ថកិច្ចរកឃើញមានការលួចលាក់ផ្ដល់មធ្យោបាយ និងផ្សំគំនិតដើម្បីធ្វើការគេចវេសពីមណ្ឌលចត្តាឡីស័កត្រូវមានទោសក្នុងការនាំពលករលួចឆ្លងដែនដោយខុសច្បាប់។ លោកអភិបាលបញ្ជាក់ថា ចំពោះមេខ្យល់ណា ដែលលលួចនាំពលករឆ្លងដែន និងនាំពលករគេចវេសពីមណ្ឌលចត្តាឡីស័ក នឹងបានចាត់វិធានការជាបន្ទាន់ ដោយគ្មានលើកលែងឡើយ។ ជាមួយគ្នានោះ លោកអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង បានជំរុញឲ្យសមត្ថកិច្ចការពារព្រំដែន សហការជាមួយមន្ត្រីសុខាភិបាល ក្នុងការពិនិត្យសុខ

ភាព ការធ្វើសំណាក និងរឹងបន្តឹងការធ្វើចត្តាឡីស័កចំពោះពលករ ឲ្យបានម៉ឺងម៉ាត់ ចៀសវាងមានការលួចរត់ចេញពីមណ្ឌលផងដែរ។

សូមបញ្ជាក់ថា ចាប់ពីមានការឆ្លងរីករាលដាល នៃជំងឺកូវីដ១៩ នៅក្នុងសហគមន៍ ខេត្តសាមុទសាខន ប្រទេសថៃ មានពលករខ្មែរបានចូលតាមច្រកជាប់ខេត្តបាត់ដំបងនេះជាង៥០០០នាក់ ក្នុងនោះ ក៏បានធ្វើធ្វើចត្តាឡីស័ក និងយកសំណាក ដើម្បីពិនិត្យរកមេរោគកូវីដ១៩ផងដែរ ហើយក្នុងចំណោមពលករខ្មែរជាង៥០០០នាក់នោះ មានអ្នកបញ្ចប់ការធ្វើចត្តាឡីស័ក និងអនុញ្ញាតិឲ្យទៅផ្ទះវិញជាង៣០០០នាក់ និងកំពុងធ្វើចត្តាឡីស័កជាង១៧០០នាក់៕ *ដោយ ៖ កោះកែវ*

## ពលករខ្មែរនៅថៃនឹងប្រឈមបញ្ហាផ្លូវច្បាប់ ខណៈដែលការចុះបញ្ជីពលករស្របច្បាប់ជិតផុតកំណត់

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 09/02/2021 - 09:03 ដោយ៖ជួប នរក្សា

ពលករខ្មែរនៅថៃប្រមាណ១៣ពាន់នាក់ អាចនឹងប្រឈមនឹងបញ្ហាផ្លូវច្បាប់ ពីអាជ្ញាធរថៃតាមរយៈការចាប់ឃុំឃាំង ឬអាចនឹងបញ្ជូនមកកម្ពុជាវិញ ប្រសិនបើពួកគេមិនបានចុះឈ្មោះធ្វើប័ណ្ណស្របច្បាប់តាមការកំណត់របស់រដ្ឋាភិបាលថៃ។ មន្ត្រីទទួលបន្ទុកផ្នែកអន្តោប្រវេសន៍ Central ឲ្យដឹងថា ពលករខ្មែរនឹងត្រូវប្រឈមបញ្ហាទាំងនោះ បន្ទាប់ពីរដ្ឋាភិបាលថៃអនុវត្តគោលការណ៍លើពលករខុសច្បាប់ក្រោយថ្ងៃទី១៣កុម្ភៈខាងមុខ។ គិតមកដល់ថ្ងៃទី៩កុម្ភៈនេះ ការកំណត់នៃការចុះឈ្មោះធ្វើប័ណ្ណបញ្ជីស្របច្បាប់នៅសល់តែចំនួន៥ថ្ងៃទៀតប៉ុណ្ណោះ ដែលកាលនោះអាជ្ញាធរបានកំណត់ពេលឲ្យពលករទាំងអស់ធ្វើការចុះឈ្មោះពីថ្ងៃទី១៥មករា ដល់ត្រឹមថ្ងៃទី១៣កុម្ភៈ។ លោកលឹង សុផុន មន្ត្រីទទួលបន្ទុកកិច្ចការអន្តោប្រវេសន៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) បានប្រាប់វិទ្យុបារាំងអន្តរជាតិពីខេត្តធុនបុរីប្រទេសថៃថា ក្នុងរយៈពេលជាងមួយខែមកនេះ មានពលករខ្មែរប្រមាណជិត១១ម៉ឺននាក់ (១០,៩៣៩២) បានចុះឈ្មោះស្នើសុំប័ណ្ណស្របច្បាប់ពីអាជ្ញាធរថៃ។ ក៏ប៉ុន្តែនៅមានពលករខ្មែរប្រមាណជាង១៣ពាន់នាក់ (១៣៤៣៤) នៅមិនទាន់បានធ្វើការចុះឈ្មោះធ្វើប័ណ្ណស្របច្បាប់នេះនៅឡើយទេ។

ពលករប្រមាណជាង១៣ពាន់នាក់នោះ នឹងអាចប្រឈមបញ្ហាផ្លូវច្បាប់ មានដូចជាការចាប់ខ្លួន ការឃុំឃាំង និងការបញ្ជូនត្រលប់មកកម្ពុជាវិញ ប្រសិនបើអាជ្ញាធរថៃរកឃើញថា ពួកគេជាពលករខុសច្បាប់។ បើតាមលោកលឹង សុផុន អាជ្ញាធរថៃនឹងចាត់វិធានការទៅតាមគោលការណ៍របស់រដ្ឋាភិបាលថៃ ក្រោយតែរយៈពេល១ខែនៃការចុះបញ្ជីស្របច្បាប់ដល់ពេលកំណត់។ យ៉ាងណាក្តីទោះជាមានការចុះបញ្ជីស្របច្បាប់ ក៏ពលករខ្មែរមួយចំនួនទៀតនៅបន្តមានបញ្ហាគ្មានការងារធ្វើនៅឡើយ។ មន្ត្រីផ្នែកអន្តោប្រវេសន៍ដដែរ បានបញ្ជាក់ថា ពលករខ្មែរប្រមាណជិត១១ម៉ឺននាក់ដែលបានចុះឈ្មោះរួចរាល់ គឺពួកគេក៏មានថៅកែចាំទទួលយកទៅធ្វើការវិញដែរ។ តែពលករប្រមាណជាង១៥ពាន់នាក់ផ្សេងទៀត នៅមិនទាន់មានថៅកែទទួលពួកគេចូលធ្វើការ បើទោះពួកគេបានចុះបញ្ជីស្របច្បាប់នោះរួចហើយក្តី។

នៅថ្ងៃនេះដែរ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFI ឲ្យដឹងថា ក្រសួងការងារកំពុងបន្តតាមដានយន្តការរបស់អាជ្ញាធរថៃនៅពេលនេះ តែយ៉ាងណាក្រសួងនៅតែបន្តអំពាវនាវឲ្យពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ គោរពទៅតាមគោលការណ៍របស់រដ្ឋាភិបាលថៃ និងធ្វើយ៉ាងណាចុះឈ្មោះស្នើសុំបញ្ជីស្របច្បាប់ឲ្យទាន់ពេលវេលាដែលភាគីថៃកំណត់ ដើម្បីចៀសវាងពីបញ្ហាប្រឈមណាមួយ។

សូមជម្រាបជូនថា រដ្ឋាភិបាលថៃបានដាក់ចេញនូវគោលការណ៍ផ្តល់ប័ណ្ណស្របច្បាប់ចំនួន២ឆ្នាំ កាលពីថ្ងៃទី២៩ធ្នូកន្លងទៅ ដល់ពលករទាំងអស់ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ រួមមានពលករខ្មែរផងដែរ។ នេះក៏ដោយសារ បញ្ហាផ្ទុះជំងឺកូវីដ១៩ជាសហគមន៍នៅខេត្តសាមុតសាខន នៅថ្ងៃទី១៧ធ្នូ ហើយរដ្ឋាភិបាលថៃបានកំណត់អត្តសញ្ញាណខ្ពស់នៃការឆ្លងទៅលើពលករបរទេសដែលកំពុងធ្វើការក្នុងប្រទេសខ្លួន៕

## ពលករខ្មែរ២៩នាក់ បានទៅដល់កូរ៉េសម្រាប់ដើមឆ្នាំនេះ ជាការស្វាគមន៍របស់ប្រទេសទាំង២ ក្នុងសម័យកូវីដ

https://dap-news.com/national/ ByVNT108 Posted on February 9, 2021

**ភ្នំពេញ ៖ ពលករខ្មែរថ្មី ចំនួន២៩នាក់ បានធ្វើដំណើរមកដល់ប្រទេសកូរ៉េខាងត្បូង សម្រាប់ដើមឆ្នាំ២០២១ នេះ ដើម្បីធ្វើការងារ ក្នុងសម័យកាលកូវីដ១៩ ដែលជាការស្វាគមន៍ សម្រាប់ប្រទេសទាំង២។ នេះបើតាមហ្វេសប៊ុក លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតខ្មែរប្រចាំកូរ៉េ បានបង្ហាញនៅថ្ងៃ៩ កុម្ភៈ។** បើតាមលោក ឡុង ឌីម៉ង់ ពលករឡើងមកថ្មីនេះ ត្រូវបានស្ថានទូតកម្ពុជា រួមគ្នាជាមួយទីភ្នាក់ងារ អភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ ហៅកាត់ថា HRDK ដែលជាស្ថាប័ន គ្រប់គ្រងពលករអន្តោប្រវេសន៍ និងក្រុមហ៊ុនឧស្សាហកម្ម ផលិតយន្តហោះ-អាវកាសកូរ៉េ Korea Aerospace Industry ទៅទទួលស្វាគមន៍ ដល់ខាងក្នុងព្រលានយន្តហោះ នៅពេលពួកគាត់ បានមកដល់កូរ៉េជាលើកដំបូង។ លោកថា នេះជាការស្វាគមន៍ជានិមិត្តរូប សម្រាប់ពលករឡើងមកថ្មី របស់កម្ពុជាប្រចាំឆ្នាំនេះ ដោយសារកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំង២លើវិស័យការងារ មានលក្ខណៈល្អប្រសើរជារៀងរាល់ឆ្នាំ គួបផ្សំហ្នឹងការគ្រប់គ្រងជំងឺរាតត្បាតកូវីដ១៩ នៅកម្ពុជាល្អជាងគេ ក្នុងចំណោមប្រទេសដែលបញ្ជូនពលករ។ លោកទូតថា ឆ្លៀតឱកាសនោះ គណៈគ្រប់គ្រងព្រលានយន្តហោះ Incheon ក៏បានបង្ហាញនូវនីតិវិធីផ្សេងៗ ដែលកូរ៉េមានបទពិសោធន៍ ក្នុងការគ្រប់គ្រងព្រលាន នៅអំឡុងស្ថានភាពនៃជំងឺរាតត្បាតកូវីដ១៩ ជាពិសេសគ្រប់គ្រង លើអ្នកដំណើរចូល-ចេញ ទាំងអ្នកមានអាការៈជំងឺ ក៏ដូចជាអ្នកគ្មានអាការៈ។ ជាមួយគ្នានេះ ស្ថាប័នទាំង៣ក៏បានជជែកពិភាក្សាគ្នា ដោះស្រាយបញ្ហាប្រឈមដូចជា កង្វល់ផ្សេងៗ ក្នុងការលើកម្ពស់ដល់លក្ខខណ្ឌការងារ លក្ខខណ្ឌរស់នៅប្រចាំថ្ងៃរបស់ពលករខ្មែរ ឲ្យមានលក្ខណៈល្អប្រសើរថែមទៀត៕

## នគរបាលប៉ុស្តិ៍ចក្រី ស្រុកសំពៅលូន សហការទទួលពលរដ្ឋខ្មែរ៣នាក់មកពីប្រទេស បញ្ជូនទៅធ្វើចត្តាឡីស័កនៅវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 2:04 pm   9 កុម្ភៈ 2021

ខេត្តបាត់ដំបង ៖ នាថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនចក្រី នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ស្រុកសំពៅលូន បានសហការជាមួយកម្លាំងយោធាវសេនាតូចលេខ១ និងកងអនុសេនាធំទី២ ទទួលប្រជាពលរដ្ឋវិលត្រឡប់មកពីប្រទេសថៃវិញ ត្រង់ចំណុច និងភូមិសាស្រ្ត ភូមិក្បាលហុង ឃុំអង្គរបាន ស្រុកសំពៅលូនចំនួន៣នាក់ ក្នុងនោះ ក្មេងប្រុស ១នាក់ និងក្មេងស្រី១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះ រួមទាំងធ្វើការអប់រំណែនាំរួចកម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅធ្វើការចត្តាឡីស័ក នៅអនុវិទ្យាល័យកូនភ្នំ៣២ ៕

# ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រក ដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៤នាក់ ស្រី ២២នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២១នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៤នាក់ ស្រី ៦នាក់ កុមារា ២នាក់ កុមារី ១នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៧នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ៨នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣៧នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ១៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ផ្សាយដោយ៖ ធូ កុសល

# មណ្ឌលចត្តាឡីស័កចំនួន ១៧ នៅខេត្តឧត្តរមានជ័យមានសភាពណែនដោយសារពលករវិលត្រលប់ច្រើនពេក

https://www.khmertimeskh.com/ គង់ អារី និង ទិត្យ គង់នៅ / Khmer Times

**ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ឧត្តរមានជ័យ-** ខេត្តឧត្តរមានជ័យ ជាខេត្តដែលមានចំណុចឆ្លងកាត់ផ្លូវការមួយសម្រាប់ពលករចំណាកស្រុកដែលឆ្លងកាត់ពីខេត្តសុរិន្ទ ព្រំដែនប្រទេសថៃ ឥឡូវនេះកំពុងតែមានសភាពណែនយ៉ាងខ្លាំង ខណៈដែលមនុស្សរាប់រយនាក់បានបន្តត្រលប់មកវិញជារៀងរាល់ថ្ងៃចាប់តាំងពីពេលចាប់ផ្តើមកាលពីខែធ្នូ ថ្ងៃទី២១ ឆ្នាំ២០២០។ ខេត្តនេះមានមណ្ឌលចត្តាឡីស័កចំនួន ១៧ ដែលភាគច្រើនគឺជាសាលារៀន។ ដំណើរទស្សនកិច្ចទៅកាន់មណ្ឌលជាច្រើនបានបង្ហាញថាមណ្ឌលត្រូវបានបំពេញដោយពលករចំណាកស្រុក និងប្រជាជនជាច្រើនដែលបានវិលត្រលប់មកពីប្រទេសថៃ។

យោងតាមលោក ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានឲ្យដឹងថាចំនួនប្រជាជនកម្ពុជាដែលវិលត្រឡប់មកវិញតាមព្រំដែនអូរស្មាច់ដែលមានព្រំប្រទល់ជាប់នឹង Chong Chom ប្រទេសថៃជាមធ្យមមានចន្លោះពី ១៥០ ទៅជាង ៣២០ នាក់ក្នុងមួយថ្ងៃ។ លោកបន្តថា៖ «ដើម្បីឆ្លើយតបទៅនឹងការហូរចូលនៃពលករចំណាកស្រុក កងកម្លាំងបានផ្តល់រថយន្តចំនួន ២៥ គ្រឿងនិងចាត់តាំងកងយោធពលខេមរភូមិន្ទចំនួន ៥៥ នាក់ដែលប្រចាំការ ២៤ ម៉ោងក្នុងមួយថ្ងៃរួមជាមួយបុគ្គលិកសុខាភិបាល និងមន្ត្រីផ្សេងទៀតដើម្បីផ្តល់ជំនួយជាបន្ទាន់ដល់ប្រជាជនកម្ពុជាដែលរងគ្រោះដោយជំងឺកូវីដ-១៩ ហើយបានគៀសខ្លួនចេញពីប្រទេសថៃ »។ លោកបន្ថែមថា៖ «យើងកំពុងព្យាយាម និងធ្វើឲ្យអស់ពីសមត្ថភាពដើម្បីទប់ស្កាត់ការផ្ទុះឡើងស្រដៀងគ្នានេះនៅក្នុងខេត្ត ក៏ដូចជានៅក្នុងប្រទេសកម្ពុជា ប៉ុន្តែជាក់ស្តែងមណ្ឌលចត្តាឡីស័ករបស់យើងស្ទើរតែពេញអស់ទៅហើយ។ យើងអាចទទួល

ពលករថ្មីៗដែលត្រលប់មកវិញបាន លុះត្រាតែនៅពេលដែលអ្នកនៅក្នុងមណ្ឌលត្រូវបានអនុញ្ញាតឲ្យត្រលប់ទៅផ្ទះវិញនៅចន្លោះ ១៤ ថ្ងៃ។ ពីការមកដល់រហូតដល់ពេលត្រលប់ទៅវិញ ប្រសិនបើគ្មានករណីវិជ្ជមាននោះទេ»។ គិតត្រឹមថ្ងៃព្រហស្បតិ៍មានពលករសរុបចំនួន ៧ ៣៦៦ នាក់ត្រូវបានចុះឈ្មោះនៅតាមមណ្ឌលផ្សេងៗ ហើយប្រជាជនចំនួន ២ ៤២៧ កំពុងបន្តស្ថិតក្នុងការធ្វើចត្តាឡីស័ក។ ចន្លោះពីថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍មានពលករសរុបចំនួន ៦៥៣ នាក់បានឆ្លងកាត់ច្រកព្រំដែនអូរស្មាច់។ មណ្ឌលចត្តាឡីស័កធំជាងគេនៅខេត្តឧត្តរមានជ័យគឺមណ្ឌលហ៊ុនសែន សំរោង ដែលជាវិទ្យាល័យដោយគិតត្រឹមថ្ងៃព្រហស្បតិ៍មានពលករកម្ពុជាត្រលប់មកវិញខ្ពស់បំផុតចំនួន ៩៨០ នាក់ក្នុងនោះមានស្ត្រី ២៤៣ នាក់និងកុមារគ្រប់វ័យ។

លោក ឈួន ស៊ីធ្យា ប្រធានមណ្ឌលហ៊ុនសែន សំរោង បានប្រាប់កាសែតខ្មែរថាមស៍ថា បុគ្គលិកសិក្សារបស់លោកកំពុងប្រឈមមុខនឹងពេលវេលាដ៏លំបាក ដោយសារមណ្ឌលនេះពេញហើយអ្នកដែលត្រលប់មកថ្មីកំពុងត្រូវបានបញ្ជូនទៅមណ្ឌលផ្សេងទៀត ប៉ុន្តែមិនយូរមណ្ឌលផ្សេងទៀតក៏បានពេញដូចគ្នា។

យោងតាមការឲ្យដឹងលោក ឃ្លោក ហួត ពលករកម្ពុជាជាច្រើននាក់បានត្រលប់មកពីប្រទេសថៃតាមរយៈច្រកព្រំដែនអូរស្មាច់ ព្រោះវាប្រហែលជាច្រកត្រួតពិនិត្យតែមួយគត់ដែលពួកគេអាចវិលត្រឡប់ដោយគ្មានការភ័យខ្លាច ឬត្រូវប្រើប្រាស់ច្រកត្រួតពិនិត្យខុសច្បាប់នៅកន្លែងផ្សេងទៀត។ លោកបន្តថា៖ «ពួកគេគ្រាន់តែត្រូវធ្វើដំណើរទៅដល់ច្រក Chong Chom ហើយដើរឆ្លងព្រំដែនដែលមន្ត្រីសុខាភិបាលនិងសន្តិសុខត្រៀមខ្លួនរួចជាស្រេចក្នុងការរង់ចាំ»។ ច្រកត្រួតពិនិត្យព្រំដែនផ្លូវការចំនួនពីរនៅឧត្តរមានជ័យគឺ Chong Sa Ngam ប្រទេសថៃ – អន្លង់វែងនិង Chong Chom ច្រកព្រំដែនអូរស្មាច់ មានតែច្រកទ្វារអន្តរជាតិអូស្មាច់ទេដែលបើកឲ្យពលករចំណាកស្រុកដែលវិលត្រឡប់មកពីប្រទេសថៃចូល៕ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## ពលរដ្ឋនៅតែបន្តត្រឡប់ពីថៃ និងត្រូវថៃចាប់បញ្ជូន១ថ្ងៃជិត២០០នាក់

https://kohsantepheapdaily.com.kh/ ១០ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ០៩:៥០

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋនៅតែបន្តត្រឡប់ពីប្រទេសថៃ និងត្រូវភាគីថៃចាប់បញ្ជូនមកវិញក្នុង១ថ្ងៃជិត២០០នាក់ រហូតពេលនេះបានធ្វើចត្តាឡីស័កជាង១៥.០០០នាក់ ក្នុងខេត្តបន្ទាយមានជ័យ រហូតដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានប្រាប់ថា នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ប្រជាពលរដ្ឋដែលត្រឡប់ពីប្រទេសថៃ និងភាគីថៃចាប់បញ្ជូនមានចំនួន១៦០នាក់ ស្រី៨៨នាក់ បើប្រៀបធៀបកាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១ មានចំនួន១១៧នាក់ ស្រី៤៧នាក់ក្រោយពេល ដែលក្រុមការងារធ្វើការពិនិត្យ និងធ្វើចត្តាឡីស័កនៅច្រកព្រំដែនអូរបីជាន់ស្រុកអូរជ្រៅហើយត្រូវបានដឹកតាមរថយន្តក្រសួងការពារជាតិដាក់តាមមណ្ឌលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃក្នុងខេត្តបន្ទាយមានជ័យ។

លោកវេជ្ជបណ្ឌិត រឿន សុធី អនុប្រធានមន្ទីសុខាភិបាលខេត្តបន្ទាយមានជ័យបានប្រាប់ថា នៅពេលប្រតិបត្តិការឆ្លងជំងឺកូវីដ១៩ ជាសហគមន៍នៅប្រទេសថៃ និងជាសារណែនាំពីប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុន សែន បានពង្រឹងការត្រួតពិនិត្យនិងធ្វើចត្តាឡីស័កដល់ប្រជាពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃចូលតាមច្រកភូមិសាស្ត្រខេត្តបន្ទាយមានជ័យនៅច្រកក្នុងស្រុកម៉ាឡៃ និងនៅច្រកបឹងត្រកួន ស្រុកថ្មពួក និងច្រកអូរបីជាន់ស្រុកអូរជ្រៅចាប់ពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ មានមណ្ឌលចត្តាឡីស័កចំនួន១៧កន្លែងមានប្រជាពលរដ្ឋចំនួន១៥.១៦៩នាក់ស្រី៦,៧៩១នាក់ ហើយត្រូវបានធ្វើតេស្តយកសំណាកវិភាគមានចំនួន

១៥,៦៦៤នាក់ស្រី៧.០១០នាក់ និងត្រូវបញ្ចប់ធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃអនុញ្ញាតិអោយត្រឡប់ទៅមូលដ្ឋានវិញមានចំនួន១១,៣៨២នាក់ស្រី៥.១៥៤នាក់ និងកំពុងធ្វើចត្តាឡីស័កមានចំនួន៨,៥៦១នាក់ស្រី៣,៨៩៨នាក់៕

## ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២១

### លោក ស ខេង បានអំពាវនាវឲ្យមានពង្រឹងការការពារការជួញដូរមនុស្ស

https://www.khmertimeskh.com/ សែន ដេវីត / Khmer Times February 10, 2021

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានអំពាវនាវដល់អាជ្ញាធរទាំងអស់ឲ្យពង្រឹងបន្ថែមទៀត នូវការការពារការជួញដូរមនុស្ស ទោះបីអង្គការសហប្រជាជាតិថ្មីៗ នេះវាយតម្លៃថា ប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងការគ្រប់គ្រងពលករចំណាកស្រុករបស់ខ្លួនក៏ដោយ។

ថ្លែងនៅក្នុងកិច្ចប្រជុំមួយនៅឯក្រសួងមហាផ្ទៃកាលពីម្សិលមិញលោកបាននិយាយថា យោងតាមព័ត៌មានអង្គការសហប្រជាជាតិបានចាត់ទុកប្រទេសកម្ពុជាថា ទទួលបានជោគជ័យទាក់ទងនឹងការគ្រប់គ្រងការចំណាកស្រុករបស់ប្រជាជន និងការស្វែងរកការងារនៅក្រៅប្រទេស។ លោកបន្តថាការវាយតម្លៃរបស់អង្គការសហប្រជាជាតិបង្ហាញថាកម្ពុជាបានការពារប្រជាជនរបស់ខ្លួនពីការជួញដូរមនុស្ស។ ទោះយ៉ាងណាលោកបន្ថែមថា៖ «យើងត្រូវតែបន្តធ្វើការការពារប្រជាជនរបស់យើងពីការជួញដូរមនុស្សឲ្យទៅធ្វើការនៅបរទេស»។

យោងតាមក្រសួងការបរទេសសហរដ្ឋអាមេរិក ការជួញដូរមនុស្សនៅកម្ពុជានៅតែស្ថិតក្នុងបញ្ជីតាមដានលំដាប់ លេខ ២ ដូចនៅក្នុងរបាយការណ៍ដដែលគឺរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០២០ ។

លោកនិយាយថាលោកគិតថាប្រទេសកម្ពុជានៅតែស្ថិតក្នុងបញ្ជីតាមដានលំដាប់ លេខ ២ ពីព្រោះប្រទេសមិនទាន់បានអនុវត្តនូវអនុសាសន៍ និងសំណើពេញលេញដូចដែលបានស្នើដោយដៃគូរបស់ខ្លួនទាក់ទងនឹងការជួញដូរមនុស្សទេ។ ទោះយ៉ាងណា លោកថាអាជ្ញាធរនិងអ្នកពាក់ព័ន្ធដទៃទៀតត្រូវតែបន្តការពារការជួញដូរមនុស្សស្របតាមគោលការណ៍នៃច្បាប់កម្ពុជាក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

យោងតាមរបាយការណ៍នេះ រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមបទដ្ឋានអប្បបរមាសម្រាប់ការលុបបំបាត់ការជួញដូរទេ ប៉ុន្តែកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធ្វើដូច្នោះ។ របាយការណ៍ដែលបានចេញផ្សាយនៅថ្ងៃទី ១៦ ខែកក្កដាឆ្នាំមុនបានសរសើរប្រទេសកម្ពុជាថា ការបង្កើតផែនការសកម្មភាពថ្មីរយៈពេល៥ ឆ្នាំក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការអភិវឌ្ឍ និងប្រើប្រាស់អត្តសញ្ញាណថ្មី និងបច្ចេកវិទ្យាប្រមូលទិន្នន័យជនរងគ្រោះ។ ទោះយ៉ាងណារបាយការណ៍បន្ថែមទៀតថា រដ្ឋាភិបាលមិនបានបង្ហាញពីការខិតខំប្រឹងប្រែងដែលបានកើនឡើងជាទូទៅបើប្រៀបធៀបទៅនឹងរយៈពេលមុនធ្វើរបាយការណ៍នោះទេ។

កាលពីខែមុន អង្គការអន្តរជាតិអន្តោប្រវេសន៍ (IOM) បានស្នើឲ្យប្រទេសកម្ពុជាតែងតាំងបេក្ខជនសម្រាប់ពានរង្វាន់ប្រឆាំងការជួញដូរមនុស្សដោយលើកឡើងថា ប្រទេសកម្ពុជាបានចាប់ផ្តើមគំនិតផ្តួចផ្តើមដ៏អស្ចារ្យក្នុងចំណោមប្រទេសនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

លោកស្រី ជូ ប៊ុនអេង អនុប្រធានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សបាននិយាយថា៖ « IOM បានកត់សម្គាល់ឃើញការខិតខំរបស់ប្រទេសកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងសមិទ្ធិផលល្អរបស់ខ្លួន។ នេះបានធ្វើឲ្យ IOM លើកទឹកចិត្តយើងឲ្យតែងតាំងបេក្ខជនសម្រាប់ពានរង្វាន់នេះ»។ លោកស្រីបាននិយាយថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមក្នុងការតែងតាំងបេក្ខជនសម្រាប់ពានរង្វាន់នេះ ប៉ុន្តែថាតើគួឲ្យអ្នកណា និងនៅពេលណាគិតត្រឹមពេលនេះ មិនទាន់ត្រូវបានកំណត់នៅឡើយទេ។ ទាក់ទងនឹងការងារប្រឆាំងការជួញដូរមនុស្សកាលពីឆ្នាំមុន លោកស្រីបាននិយាយថា គណៈកម្មាធិការនៅតាមខេត្ត និងរាជធានីបាន

ខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបំពេញភារកិច្ចរបស់ខ្លួនដែលបានគ្រោងទុកកាលពីឆ្នាំមុន ទោះបីជាបានរងនូវវិបត្តិជំងឺរាតត្បាតក៏ដោយ៕ *ប្រែសម្រួលដោយ សៀវ គួយអ៊ី*

## អាជ្ញាធរខេត្តតាកែវ អំពាវនាវ ឲ្យមានការរួបរួមគ្នាដើម្បីទប់ស្កាត់អំពើហិង្សា និងការរំលោភបំពានលើកុមារ

http://btv.com.kh/ 10/02/2021

តាកែវ ៖ លោកអភិបាលរងខេត្តតាកែវ បានធ្វើការអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងបងប្អូនប្រជាពលរដ្ឋ ក៏ដូចជាផ្នែកឯកជន សង្គមស៊ីវិលទាំងអស់ ត្រូវរួមគ្នាជាធ្លុងមួយ ធ្វើយ៉ាងណាដើម្បីធ្វើការទប់ស្កាត់អំពើហិង្សា និងការរំលោភបំពានគ្រប់រូបភាពទៅលើកុមារ ។

លោក ម៉ឹង វុធី អភិបាលរងខេត្តតាកែវ និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត ថ្លែងក្នុងឱកាសអញ្ជើញចូលរួមបើកកិច្ចប្រជុំ បូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០២០ និងទិសដៅបន្តរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តតាកែវ នៅព្រឹកថ្ងៃពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ។ លោក អភិបាលរងខេត្តតាកែវ បានបន្តថា រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងតែយកចិត្តទុកដាក់ និងធ្វើកិច្ចការជាច្រើនដើម្បីឲ្យស្ថានភាពកុមារ នៅក្នុងប្រទេសកម្ពុជា កាន់តែមានលក្ខណៈមួយល្អប្រសើរ សុវត្ថិភាព និងការយកចិត្តទុកដាក់មើលថែទាំបានខ្ពស់ ពិសេសបានផ្តល់ឱកាស និងលើកទឹកចិត្តដល់កុមារទទួលបានការអប់រំ និងបណ្តុះបណ្តាលដើម្បីក្លាយជាសសរទ្រូង ដ៏រឹងមាំសម្រាប់ចូលរួមអភិវឌ្ឍន៍ ប្រទេសជាតិទៅថ្ងៃអនាគត។ ក៏ប៉ុន្តែបើទោះបីជារាជរដ្ឋាភិបាលបានប្រឹងប្រែងទទួលបានជោគជ័យយ៉ាងណាក៏ដោយ ក៏កុមារយើងមួយខ្លះនៅតែប្រឈមមុខបញ្ហាមួយចំនួន។

លោកអភិបាលរងខេត្ត ម៉ឹង វុធី ក៏បានបន្ថែមទៀតថា ប៉ុន្តែទន្ទឹមនឹងការទទួលបាននូវសិទ្ធិរបស់កុមាររបស់យើង កុមារមួយចំនួនទៀតនៅតែបន្តរងនូវឥទ្ធិពលនៃការប្រើប្រាស់គ្រឿងញៀន ការជួញដូ ការរំលោភបំពាន ការប្រើអំពើហិង្សា និងការចូលរួមរបស់កុមារនៅមានកម្រិតនៅឡើយ។ ស្ថានភាពនេះបានធ្វើអោយកុមារទទួលរងផលប៉ះពាល់មួយចំនួន ដូច្នោះគប្បីយើងទាំងអស់គ្នាជាអ្នកពាក់ព័ន្ធទាំងវិស័យរដ្ឋ និងផ្នែកឯកជន សង្គមស៊ីវិល លើកយកបញ្ហាកុមារគឺជាបញ្ហារបស់យើងទាំងអស់គ្នា មិនមែនពឹងផ្អែកតែលើរាជរដ្ឋាភិបាល ឬអាជ្ញាធរតែម្នាក់នោះទេ ។ បើតាមលោកអភិបាលរងខេត្ត ការយកចិត្តទុកដាក់ មើលថែទាំកុមារ និងការលើកកម្ពស់គ្រប់សកម្មភាពរបស់កុមារទាំងនៅក្នុងសង្គម និងគ្រួសារ វាពិតមានសារៈសំខាន់ ព្រោះវានឹងអាចជំរុញដល់កុមារប្រែក្លាយជាមនុស្សដែលមានលក្ខណៈល្អប្រសើរ មានសីលធម៌ល្អ ហើយទទួលបាននូវការអប់រំខ្ពស់ នឹងក្លាយជាធនធានមនុស្សដ៏ ចាំបាច់សម្រាប់សង្គមជាតិទៅថ្ងៃអនាគត ៕ ដោយៈគុជ វិភាគ

## អង្គការសង់ត្រាល់ បានរៀបចំវេទិកាសហគមន៍ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/hashtag/central ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ អង្គការសង់ត្រាល់ បានរៀបចំវេទិកាសហគមន៍ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅភូមិត្បូងក្រពើ ឃុំកកោះ និងភូមិ ស្តុកស្គម ឃុំជ្រាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ ដោយមានកិច្ចសហការជាមួយអង្គការការីតាស់កម្ពុជា ប្រចាំខេត្តកំពង់ធំ។ យោងតាមបទពិសោធន៍របស់អង្គការមជ្ឈមណ្ឌលសម្ព័ន្ធការងារនិងសិទ្ធិមនុស្ស (CENTRAL) កន្លងមកយើងជួបប្រទះបញ្ហាជាច្រើនកើតឡើងចំពោះពលករចំណាកស្រុកខ្មែរយើងបើទោះបីជាពួកគេចំណាកស្រុកតាមរយៈក្រុមហ៊ុនជ្រើរើសពលករស្របច្បាប់ ក្តីមិនស្របច្បាប់ក្តី។

ពួកគេត្រូវឈមនឹងការនាំយកទៅលក់ក្នុងទូកនេសាទធ្វើជាទាសករដាច់ថ្លៃធ្វើការពី១៩ ម៉ោងដល់ ២៤ម៉ោង។ ៧ថ្ងៃក្នុងមួយសប្តាហ៍គ្មានពេលថ្ងៃឈប់សំរាកលើកលែងតែគ្មានការងារទើបបានសំរាក។ អ្នកខ្លះត្រូវស្លាប់បាត់បង់ជីវិតដោយមិនអាចការងារធ្ងន់ស្របពេលមានជម្ងឺមិនអាចបំពេញការងារអោយថៅកែបាន។ ខ្លះធ្វើការមិនបើកប្រាក់ខែអោយហើយថែមទាំងប្តឹងប៉ូលីសចាប់ដាក់គុកទៀតផង។ល។ បញ្ហាទាំងនេះមិនត្រឹមតែជះឥទ្ធិពលមិនល្អដល់ក្រុមគ្រួសារជនរងគ្រោះទេតែវាថែមទាំងជះឥទ្ធិពលដល់សង្គមកម្ពុជាទាំងមូលដូចគ្នាដែរ ព្រោះនៅពេលពលរដ្ឋយើងត្រូវចំណាកច្រើនកំលាំងពលកម្មក្នុងស្រុកបាត់បង់។ លំហែទាំកុមារក្នុងបន្ទុកដែលបន្សល់ទុកកុមារតូចៗនៅជាមួយជីដូនជីតាចាស់ៗជរាមិនអាចមើលថែជិតដល់បានដូច្នេះក្មេងខ្លះត្រូវបោះបង់ចោលសាលាមិនទទួលបានការអប់រំរៀនសូត្រ។

ដោយមើលឃើញបញ្ហាទាំងនេះទើបអង្គការយើងខ្ញុំបង្កើតអោយមានវេទិកាសហគមន៍ឡើងក្នុងគោបំណងផ្តល់ការយល់ដល់ពលរដ្ឋខ្មែរយើងនៅតាមទីជនបទ ដើម្បីអាចទទួលបានការយល់ដឹងពីចំណាកស្រុកដោយសុវត្ថិភាពប្រាស់បញ្ហាចាញ់បោកមេខ្យល់ និងទទួលរងការរំលោភបំពានសិទ្ធិផ្សេងពីការធ្វើចំណាកស្រុកទៅបរទេស។ វេទិកានេះ មានពលរដ្ឋសកម្មចូលរួម១១០នាក់ (ស្ត្រី៦០% យុវជនប្រមាណ១៥%) ដែលមាន គោលបំណងផ្សព្វផ្សាយសំខាន់ៗដូចខាងក្រោម។

១/លើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពជៀងវាងចាញ់បោកមេខ្យល់និងជាកម្មវត្ថុនៃការជួញដូរ និងរំលោភបំពានសិទ្ធិផ្សេងៗ។

២/ដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋកាត់បន្ថយការធ្វើចំណាកស្រុ កដោយគ្មានឯកសារហើយតាត់បន្ថយការធ្វើចំណាកស្រុកទៅបរទេសហើយស្វែងរកការងារសុវត្ថិភាពក្នុងស្រុក។

៣/លើកកំពស់ការចូលរួមរបស់ពលរដ្ឋនិងអាជ្ញាធរមូលដ្ឋានបានសហការទប់ស្កាត់ការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចគ្រប់រូបភាព។

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៣នាក់ ស្រី ២៤នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៩នាក់ ស្រី ១០នាក់ កុមារា ០០នាក់ កុមារី ២នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១២នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ៣នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៨នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ៤នាក់ ស្រីចំនួន ២នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៥៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣១នាក់, ខេត្តបាត់ដំបង ចំនួន ៤នាក់ និងឧត្តរមានជ័យចំនួន ១៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប

## ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងការងារ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

http://nokorwatnews.com/ 11-02-2021

ភ្នំពេញៈ លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នារសៀលថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២១នេះ បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីពិភាក្សានីតិវិធីនៃការបន្តលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងការដាក់ចេញនូវវិធានការ និងរៀបចំផែនការសកម្មភាពមួយចំនួន ដើម្បីឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀតដល់ការផ្តល់កិច្ចគាំពារ និងសេវាគ្រាំទ្រចាំបាច់នានា ដល់បងប្អូនពលករ អាចបន្តស្នាក់នៅ និងធ្វើការដោយស្របច្បាប់ នៅប្រទេសថៃ ជាពិសេសក្នុងដំណាក់កាលនៃវិបត្តិកូវីដ-១៩នេះ។

ដោយមានការរីករាលដាលជំងឺកូវីដ-១៩នៅក្នុងសហគមន៍ពលករទេសន្តរប្រវេសន៍ (ខេត្តសាមុតសាខន) រដ្ឋាភិបាលថៃ បានអនុញ្ញាតឱ្យពលករបរទេសគ្មានឯកសារ មកចុះឈ្មោះក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីបានសិទ្ធិស្នាក់នៅ និងធ្វើការនៅប្រទេសថៃបណ្តោះអាសន្ន ដែលការចុះឈ្មោះនេះ ចាប់ពីថ្ងៃ១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១។ ក៏ប៉ុន្តែរាជរដ្ឋាភិបាលថៃ នឹងដាក់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះពលករបរទេសដែលឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលថៃក៏មិនទាន់បញ្ជាក់ពីវិធានការនេះថាយ៉ាងណានោះឡើយ។ បើយោងតាមរបាយការណ៍នៃការធ្វើការជំរឿនរបស់អាជ្ញាធរថៃ គិតត្រឹមថ្ងៃថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករកម្ពុជាចំនួន ១២៦,១៧២ នាក់ (ក្នុងនោះពលករមាននិយោជក មានចំនួន ១១០,៧៥៦ នាក់ និងពលករមិនមាននិយោជក មានចំនួន១៥,៤១៦នាក់) ដែលត្រូវរៀបចំបន្តឱ្យមានឯកសារសម្រាប់ធ្វើការដោយស្របច្បាប់នៅប្រទេសថៃ។

គួរបញ្ជាក់ថា បើតាមរយៈលទ្ធផលនៃកិច្ចប្រជុំថ្ងៃនេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់នូវឯកសារ និងសេវាគាំទ្រចាំបាច់នានាជូនដល់បងប្អូនពលករកម្ពុជាយើង ដែលមិនមានឯកសារគ្រប់គ្រាន់ ឬបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស នៅពេលដែលភាគីថៃបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន ។ ជាមួយគ្នានេះ គណៈកម្មការនឹងសហការជាមួយភាគីថៃក្នុងការអនុវត្តនូវកិច្ចការងារនេះ ជូនបងប្អូនពលកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ៕**ដោយៈស តារា**

## ពលករសំណាកស្រុកខ្មែរ មកពីប្រទេសថៃ ២០នាក់ឲ្យវិលទៅ លំនៅដ្ឋានវិញក្រោយ លទ្ធផលធ្វើតេស្តអវិជ្ជមាន

https://dap-news.com/national/ BySS107 Posted on February 11, 2021

កោះកុង : លោកវេជ្ជបណ្ឌិត ទៅ ម៉ឹង ប្រធានមន្ទីរសុខាភិបាល ខេត្តកោះកុងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១បានឲ្យដឹងថា ពលករសំណាកស្រុកខ្មែរដែលធ្វើសំណាក់ស្រុកមកពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិ ចាំយាមច្រករបៀង និងតាមផ្ទៃសមុទ្រទឹកត្រូវបានសមត្ថកិច្ចឃាត់ខ្លួនធ្វើតេស្តចក្តាឡីស័ក មានចំនួនសរុប១១៩នាក់ដែលមន្ត្រីសុខាភិបាលបានយកសំណាកទៅធ្វើតេស្តចក្តាឡីស័ក នៅមន្ទីរវិទ្យាស្ថានប៉ាស្ទ័រក្រសួងសុខាភិបាល ជាលទ្ធផលបានបញ្ជាក់ថា ពលករខ្មែរធ្វើសំណាក់ស្រុកមកពីប្រទេសថៃទាំងថ្មីទាំងចាស់សរុប២០នាក់ដែលធ្វើតេស្តចក្តាឡីស័កលទ្ធផលអវិជ្ជមាននេះជាលទ្ធផលចេញពីមន្ទីរវិទ្យាស្ថានប៉ាស្ទ័រក្រសួងសុខាភិបាលហើយ១០៣នៅបន្តធ្វើចក្តាឡីស័កនៅឡើយ។ លោកវេជ្ជបណ្ឌិត ទៅ ម៉ឹង បានឲ្យដឹងបន្តថា ពលករសំណាក់ស្រុកឆ្លងដែនពីប្រទេសថៃវិលចូលស្រុកកំណើតវិញតាមច្រកទ្វារអន្តរជាតិ ច្រករបៀងនិងតាមផ្ទៃសមុទ្រនេះបើមន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រក្រសួងសុខាភិបាលធ្វើតេស្ត អវិជ្ជមានមន្ត្រីសុខាភិបាលអនុញ្ញាតិឲ្យពួកគាត់វិលទៅលំនៅដ្ឋានជួបជុំក្រុមគ្រួសារគាត់វិញ ។

លោកវេជ្ជបណ្ឌិតបានបន្តថា ចំពោះបញ្ហាការរីករាលដាលជំងឺកូវិដ១៩នេះអាជ្ញាធរខេត្តកោះកុងមន្ត្រីប្រចាំការណ៍តាមព្រំដែនមន្ត្រីសុខាភិបាលអាជ្ញាធរគ្រប់មូលដ្ឋានឲ្យមានការរឹតបន្តឹងជាប់ជានិច្ច តាមមាត់ច្រកអន្តរជាតិចាំយាមច្រករបៀង លើផ្ទៃទឹកទាំងអស់ដែលមានព្រំទល់ជាប់ជាមួយប្រទេសថៃគឺឲ្យមានការប្រុងប្រយ័ត្នខ្ពស់នៃការរីករាលដាលនៃជំងឺកូវិដ១៩កុំឲ្យមានការឆ្លងចូលក្នុងសហគមន៍ក្នុងប្រទេសយើង។ ដូច្នេះអ្វីដែលសំខាន់ពលរដ្ឋត្រូវមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ចេះថែរក្សាអនាម័យបរិស្ថានចេះការពារសុខភាពខ្លួនឯង នឹងអនុវត្តន៍តាមការផ្សព្វផ្សាយណែនាំអប់រំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលដែលចាក់ផ្សព្វផ្សាយគ្រប់ម៉ោងគ្រប់មូលដ្ឋាន។ លោកវេជ្ជបណ្ឌិត សូមធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានគ្រប់មូលដ្ឋានត្រូវមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ដើម្បីការពារជំងឺឆ្លងកូវិដ១៩ កុំមានការរីករាលដាលឆ្លងចូលក្នុងសហគមន៍ ពីព្រោះជំងឺកូវិដ១៩ ជាជំងឺឆ្លងសកលដែលគួរឲ្យភ័យខ្លាច៕

## រុះរើស្ពានឈើ ឆ្លងព្រំដែនចេញ ដើម្បីពង្រឹងទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់

https://kohsantepheapdaily.com.kh/ Banteay Meanchey ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ២០:៥១

បន្ទាយមានជ័យ៖ ដើម្បីពង្រឹងនូវវិធានការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ គឺកងកម្លាំងឈរជើងតាមព្រំដែន បានរុះរើស្ពានឈើ ដែលឆ្លងដែនខុសច្បាប់ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី៥ បានប្រាប់ថា ជាការណែនាំពីឯកឧត្តម ហ៊ុន ម៉ាណែត អគ្គបញ្ជាការរង កងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក គឺដើម្បីពង្រឹងការទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ កងកម្លាំងកងពលតូចថ្មើរជើងលេខ៥១ បានចុះរុះរើស្ពានឈើមួយកន្លែង ដែលជាកន្លែងឆ្លងព្រំដែនដោយខុសច្បាប់ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ លោកបានបញ្ជាក់ថា កងកម្លាំងគ្រប់ស្ថាប័ន ត្រូវតែពង្រឹង និងទប់ស្កាត់ពលករចំណាកស្រុក ដោយខុសច្បាប់ ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាលដាកូវិដ១៩ និងការពារសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋ នៅពេលដែលប្រទេសជិតខាង កំពុងរាតត្បាតដោយកូវីដ១៩។ លោកឧត្តមសេនីយ៍ទោ សេង ធារិន បានកោតសសើរចំពោះកង

កម្លាំង ដែលកំពុងឈរជើងតាមបន្ទាត់ព្រំដែន ក្នុងឃោធភូមិភាគទី៥ ដែលខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីការពារបូរណភាពទឹកដី និងបទល្មើសឆ្លងដែន និងពង្រឹងការទប់ស្កាត់កូវីដ១៩ ត្រូវអនុវត្តន៍ អោយបានតាមការណែនាំរបស់ក្រសួងសុខាភិបាល៕ ដោយៈ ប៊ុន ធឿន

## គណៈកម្មការផ្តល់ភាព ស្របច្បាប់ត្រៀមខ្លួនជាស្រេច ក្នុងការផ្តល់ឯកសារ និងសេវាគាំទ្រចាំបាច់ជូនពលករកម្ពុជា ដែលមិនមានឯកសារគ្រប់គ្រាន់

https://dap-news.com/ ByKD102 Posted on February 12, 2021

**ភ្នំពេញ៖ គណៈកម្មការផ្តល់ភាព ស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់នូវឯកសារ និងសេវាគាំទ្រចាំបាច់នានា ជូនដល់ពលករកម្ពុជា ដែលមិនមានឯកសារគ្រប់គ្រាន់។ នេះបើយោងតាមគេហទំព័រហ្វេសប៊ុករបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។**

សូមជម្រាបថា យោងតាមរបាយការណ៍នៃ ការធ្វើការជំរឿនរបស់អាជ្ញាធរថៃ គិតត្រឹមថ្ងៃថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០២១ មានពលករកម្ពុជា ចំនួន ១២៦,១៧២ នាក់ ក្នុងនោះ ពលករមាននិយោជក ចំនួន ១១០,៧៥៦នាក់ និងពលករ មិនមាននិយោជក ចំនួន១៥,៤១៦នាក់ ដែលត្រូវរៀបចំបន្តឲ្យមានឯកសារ សម្រាប់ធ្វើការដោយស្រប ច្បាប់នៅថៃ។ ក្នុងកិច្ចប្រជុំ គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅ ប្រទេសថៃ កាលពី ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងជាប្រធាន គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅ ប្រទេសថៃ បានឲ្យដឹងថា គណៈកម្មការ នឹងសហការជាមួយភាគីថៃ ក្នុងការអនុវត្តនូវកិច្ចការងារនេះ ជូនពលកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ លោកបញ្ជាក់ថា «គណៈកម្មការផ្តល់ភាព ស្របច្បាប់ដល់ពលករ កម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់នូវឯកសារ និងសេវាគាំទ្រចាំបាច់នានាជូន ដល់បងប្អូនពលករកម្ពុជាយើង ដែលមិនមានឯកសារគ្រប់គ្រាន់ ឬបន្តសុពលភាពលិខិតធ្វើដំណើរ ពលករកម្ពុជាធ្វើការនៅបរទេស នៅពេលដែលភាគីថៃ បញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន»។

ជាមួយគ្នានេះដែរ ដោយមានការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ពលករទេសន្តរប្រវេសន៍ នៅខេត្តសាមុតសាខន រដ្ឋាភិបាលថៃ បានអនុញ្ញាតឲ្យពលករបរទេសគ្មានឯកសារ មកចុះឈ្មោះក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីបានសិទ្ធិស្នាក់នៅ និងធ្វើការនៅប្រទេសថៃបណ្តោះអាសន្ន ដែលការចុះឈ្មោះនេះ ចាប់ពីថ្ងៃ១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១។ក៏ប៉ុន្តែរាជរដ្ឋាភិបាលថៃ នឹងដាក់វិធានការយ៉ាងម៉ឺងម៉ាត់ ចំពោះពលករបរទេស ដែល ឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ។ ទោះបីជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលថៃ ក៏មិនទាន់បញ្ជាក់ពីវិធានការនេះថា យ៉ាងណានោះឡើយ៕

# ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២១

## ដាក់បញ្ជាឲ្យរកមេខ្លោង ក្រោយមានពលករមកពីថៃ ឆ្លាយធ្វើដំណើរមកដល់ខេត្តតាកែវ

https://www.kampucheathmey.com/ on February 14, 2021By Dy Bunnara

តាមសារតេឡេក្រាមនៅរសៀលនេះ សម្តេចតេជោ ហ៊ុន សែនបានចេញបទបញ្ជាជាថ្មីឲ្យរឹតបន្តឹងច្រកតាមព្រំដែន ក្រោយមានពលករខ្មែរមកពីថៃ ត្រូវបានឃាត់ខ្លួនបានជាបន្តបន្ទាប់នៅខេត្តតាកែវ ដោយមិនបានធ្វើចត្តាឡីស័កនៅនឹងកន្លែងតាមការណែនាំរបស់រដ្ឋាភិបាល។ អាជ្ញាធរត្រូវរកមេខ្លោង ឬមូលហេតុយ៉ាងណា ទើបពលករទាំងនោះអាចធ្វើដំណើររាប់សិបគីឡូម៉ែត្រឆ្លាយមកដល់ខេត្តតាកែវ ដោយមិនបានធ្វើចត្តាឡីស័កបានត្រឹមត្រូវ ជាហានិ

ក័យអាចបង្កការឆ្លងរាលដាលចូលសហគមន៍សារជាថ្មី។ "ហេតុអីឲ្យឆ្ងាយរបៀបនេះ ត្រូវសួរចម្លើយ អ្នកណានាំផ្លូវ ដើម្បីចាត់ការមេខ្លោងទៀត បើមិនចឹងមិនទេ អន្តរាយជាមិនខាន"។

សម្តេចតេជោក៏ឲ្យកម្លាំងតាមបណ្តាខេត្តជាប់ព្រំដែនថៃ ត្រួតពិនិត្យច្រកចេញចូល រៀបចំកម្លាំងល្បាតឲ្យបានម៉ឺងម៉ាត់បំផុត។ កន្លងទៅនេះប្រមុខរដ្ឋាភិបាល បានចេញបទបញ្ជាមិនឲ្យដឹកជញ្ជូនពលករខ្មែរមកពីថៃចល័តទៅតាមខេត្តខាងក្រោមទៀតឡើយ ដោយតម្រូវឲ្យធ្វើចត្តាឡីស័កនៅតាមព្រំដែនតែម្តង ដើម្បីទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ចូលសហគមន៍ជាថ្មីម្តងទៀត។ ក្រោយរឹតបន្តឹងការធ្វើចត្តាឡីស័កលើពលករឆ្លងចេញចូល ក្រសួងសុខាភិបាលកម្ពុជា បានរកឃើញពលករជាបន្តបន្ទាប់បានឆ្លងកូវីដ ១៩ ពេលធ្វើដំណើរចូលប្រទេសវិញ ស្របពេលដែលថៃកំពុងផ្ទុះការឆ្លងចូលសហគមន៍ នាំឲ្យការបិទខេត្តមួយចំនួន៕ អត្ថបទ៖ ប៊ុណ្ណារ៉ា

## ទីបញ្ជាការសឹករងឧត្តរមានជ័យ មាន ពលករសរុបចំនួន១០៤នាក់បានឆ្លងដែនពីប្រទេសថៃចូល មកកម្ពុជា

https://www.facebook.com/cphnnews/ ថ្ងៃទី កុម្ភៈ 12 នៅម៉ោង 4:34 PM

ឧត្តរមានជ័យ: តាមបទបញ្ជារបស់ ឯកឧត្តម មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៤ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី និងវិធានការរបស់ក្រសួងសុខាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នាថ្ងៃទី១០ កុម្ភៈ ឆ្នាំ២០២១នេះ លោក ឧត្តមសេនីយ៍ទោ តន់ ញ៉ាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ បានដាក់ចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់បណ្តាកងឯកភាពចំណុះទាំងអស់ ឲ្យបន្តអនុវត្តការរឹតបន្តឹងការការពារ អនាម័យ ការរក្សាគម្លាត ដោយវាស់កម្តៅ មុនពេលចូលបម្រើការងារក្នុងអង្គភាព និងសម្អាតដៃជាមួយអាល់កុលជាប្រចាំ។ ក្រៅពីនេះ លោក មេបញ្ជាការ បានណែនាំឲ្យបន្តយកចិត្តទុកដាក់ក្នុងការងារកសាង ពិសេសពង្រឹងប្រព័ន្ធការពារជាតិនិងបង្កបង្កើនផលជាប្រចាំ ដើម្បីអភិវឌ្ឍអង្គភាពឲ្យមានការរីកចម្រើនទៅមុខជាលំដាប់។

ដោយឡែកនៅថ្ងៃនេះដែរ ក្រៅពីភារកិច្ចស្នូលរបស់អង្គភាព លោក មេបញ្ជាការ បានបន្តចាត់តាំងកម្លាំងប្រមាណ៥០នាក់ សហការជាមួយក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជាប្រចាំច្រកទាំង៣ (អូរស្មាច់ ថ្មដូន និងជប់គគី) កងពលតូចដឹកជញ្ជូនលេខ៩៩ កងកម្លាំងចម្រុះ មន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋាន ក្នុងការដឹកជញ្ជូនប្រជាពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ និងត្រៀមស្នាក់ទប់ស្កាត់មិនឲ្យប្រជាពលករឆ្លងដែនខុសច្បាប់នៅតាមច្រករបៀងផ្សេងៗ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ក្នុងនោះដែរ កម្លាំងមួយផ្នែកទៀតបានធ្វើការសហការជាមួយកម្លាំងសមត្ថកិច្ចទាំង៣ប្រភេទក្នុងខេត្ត ប្រចាំការការពារពលករខ្មែរនៅតាមទីតាំងមណ្ឌលចត្តាឡីស័កទាំង៨ ក្នុងខេត្តឧត្តរមានជ័យ មិនឲ្យចេញក្រៅមណ្ឌលក្នុងពេលអនុវត្តចត្តាឡីស័កតាមការណែនាំកំណត់របស់ក្រសួងសុខាភិបាលគួរជម្រាបជូនផងដែរថា គិតត្រឹមម៉ោង១៩:០០នាទីថ្ងៃនេះ មានបងប្អូនប្រជាពលរដ្ឋសរុបចំនួន១០៤នាក់ ក្នុងនោះស្រីចំនួន៣៨នាក់ ដែលបានឆ្លងដែនពីប្រទេសថៃមកដល់ទឹកដីកម្ពុជាតាមច្រកអន្តរជាតិអូរស្មាច់ ហើយកងកម្លាំងទាំង៣ប្រភេទក្នុងខេត្ត សហការជាមួយ កងពលតូចដឹកជញ្ជូនលេខ៩៩ និងក្រុមការងារពាក់ព័ន្ធទាំងអស់ បានសម្របសម្រួល ដោយដឹកជញ្ជូនពួកគាត់មកកាន់ទីតាំងធ្វើចត្តាឡីស័កទាំង៧ ដែលបានកំណត់ទុកក្នុងខេត្តឧត្តរមានជ័យ៕

# ពលករខ្មែរធ្វើការនៅថៃមិនសូវសម្បូរការងារធ្វើក្នុងពេលប្រទេសនេះជួបវិបត្តិជំងឺកូវីដ១៩

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2021-02-12

ពលករខ្មែរធ្វើការនៅប្រទេសថៃ មិនសូវសម្បូរការងារធ្វើហើយពេលខ្លះថៅកែ បើកលុយយឺតទៀតផងក្នុងពេលប្រទេសថៃជួបវិបត្តិជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលដែលធ្វើការងារនេះជំរុញទៅរដ្ឋាភិបាលគួរមានគោលនយោបាយជួយអន្តរាគមន៍ដល់ពលករខ្មែររាប់ម៉ឺននាក់ដែលកំពុងរងផលប៉ះពាល់ដោយវិបត្តិនេះ។ ជាសំឡេងត្អូញត្អែររបស់ពលករខ្មែរមួយក្រុមធ្វើសំណង់នៅប្រទេសថៃ។ ការត្អូញត្អែរនេះក៏ព្រោះតែពួកគាត់ត្រូវក្បិតក្បៀតក្នុងការហូបចុកប្រចាំថៃ ក្នុងពេលប្រទេសថៃកំពុងជួបវិបត្តិជំងឺកូវីដ១៩។ ត្រីអណ្តែងអាំង ពងទាចៀន ត្រីកាម៉ុងចំហុយ ជ្រលក់ស្វាយខ្ចីទាំងនេះជាម្ហូបរបស់ពលករខ្មែរមួយក្រុម កំពុងទទួលបាយថ្ងៃត្រង់យ៉ាងឆ្ងាញ់ពិសាក្នុងការដ្ឋានសំណង់មួយកន្លែងក្នុងទីក្រុងបាងកក(Bangkok)ប្រទេសថៃ។

សម្បុរស្រអែម សក់រួញអង្កាញ់ លោក ធៃ ង៉ុក ជាកម្មករផ្នែកកាត់ក្តារ។ យុវជនវ័យ២១ឆ្នាំរូបនេះត្អូញត្អែរថា ចាប់តាំងពីមានវិបត្តិជំងឺកូវីដ១៩មកលោកមិនសូវមានការងារធ្វើជាប់លាប់នោះទេ។ លោកឱ្យដឹងទៀតថា លោកត្រូវដើររកការងារធ្វើពីកន្លែងមួយទៅកន្លែងមួយ។ កន្លែងការងារថ្មីដែលទើបធ្វើក្នុងទីក្រុងបាងកកនេះ លោកអាចទទួលបានប្រាក់កម្រៃ៣៥០បាត ឬជាង១០ដុល្លារក្នុងមួយថ្ងៃ។ «» មិនឆ្ងាយប៉ុន្មានពីលោក ធៃ ង៉ុក ស្ត្រីម្នាក់កំពុងលើកឥដ្ឋដាក់លើរទេះ។ លោកស្រី ភ័ណ្ឌ សុផា ឱ្យដឹងស្រដៀងគ្នានេះដែរថា សព្វថ្ងៃលែងមានការងារថែមម៉ោងទៀតហើយ គឺបានត្រឹមការងារប្រចាំថ្ងៃប៉ុណ្ណោះ។ លោកស្រីឱ្យដឹងទៀតថា ពេលនេះមិនមានការងារថែមម៉ោងដូចនេះមុននោះទេ ហើយមានពេលខ្លះបើកលុយយឺតថែមទៀតផង ប៉ុន្តែនៅកន្លែងលោកស្រីធ្វើការមិនដែលជួបបញ្ហាថៅកែមិនបើកលុយឱ្យនោះទេ។ «» ពលករខ្មែរកំពុងធ្វើការងារនៅប្រទេសថៃពេលនេះកំពុងជួបបញ្ហាជាច្រើន គ្រាដែលវិបត្តិជំងឺកូវីដ១៩កំពុងរាតត្បាតនៅប្រទេសនេះ អ្នកខ្លះបាត់បង់ការងារ មិនសូវសម្បូរការងារ ពិបាករកការងារធ្វើ ថៅកែបើកលុយយឺត និងលែងមានការងារថែមម៉ោងដូចមុនជាដើម។ ចំណោមពលករខ្មែរប្រមាណ២លាននាក់ (២.០០០.០០០) កំពុងធ្វើការងារនៅប្រទេសថៃមានពលកររាប់ម៉ឺននាក់ជួបបញ្ហា។

ទោះនៅប្រទេសថៃកំពុងជួបវិបត្តិបែបនេះក្តី ពលករម្នាក់ យុវជន ស្រ៊ាង គឹមស្រ៊ង យល់ថា ទីផ្សារការងារនៅទីនេះមានភាពល្អប្រសើរជាងនៅកម្ពុជា។ លោករម្លឹកថា កាលពីលោកមិនទាន់បានការងារធ្វើនៅប្រទេសថៃ លោកបានព្យាយាមរកការងារធ្វើនៅខ្មែរប៉ុន្តែរកមិនទទួល ពេលខ្លះទៀតរកការងារបានហើយដាច់ខែថៅកែមិនបើកលុយឱ្យទៀត។ ពលកររូបនេះលើកឡើងថា ពេលនេះទាំងរូបលោកនិងពលករខ្មែរផ្សេងទៀតខិតខំសន្សំសំចៃក្នុងការចាយវាយប្រចាំថ្ងៃទើបអាចសល់លុយផ្ញើទៅឪពុកម្តាយនៅស្រុកកំណើត ដែលកំពុងជំពាក់លុយធនាគារ។ «» ក្នុងការដ្ឋានសំណង់នេះ ក្រៅពីមានពលករខ្មែរធ្វើការក៏មានពលករជនជាតិផ្សេងទៀតដែរដូចជា ជនជាតិថៃ (Thailand) ភូមា(Burma) និងឡាវ(Laos)។ កម្មករធ្វើការងារតាមជំនាញរៀងៗខ្លួនដោយមានមេការចាំត្រួតពិនិត្យ។

សម្បុរខ្មៅ ពាក់មួកសរដើរចុះឡើងតាមកន្លែងកម្មករធ្វើការងារជាមេការជនជាតិខ្មែរគ្រប់គ្រងកម្មករជាង៦០នាក់ ក្នុងនោះមានពលករខ្មែរជាង២០នាក់។ លោក ម៉ិច សំណាង និយាយថា ការផ្តល់ប្រាក់ឈ្នួលកម្មករគឺអាស្រ័យលើការឧស្សាហ៍ និងសមត្ថភាពរបស់កម្មករដោយចាប់ផ្តើមពីតម្លៃ៣៥០បាតក្នុងមួយថ្ងៃឡើងទៅ ។ លោកលើកឡើងទៀតថា ទម្រាំរកការងារបានមួយកន្លែងៗមិនមែនជារឿងស្រួលទេ។ លោកថា ពេលនេះទាំងកម្មករ មេការ និងថៅកែគឺសុទ្ធតែជួបបញ្ហាធំគឺកង្វះសាច់លុយ។ លោកឱ្យដឹងថា ខែខ្លះថៅកែទម្លាក់លុយមកយឺតលោកត្រូវបង្ខំចិត្តយកលុយផ្ទាល់ខ្លួន ឬយកគ្រឿងអលង្ការរបស់ប្រពន្ធទៅបញ្ចាំងយកលុយមកបើកឱ្យកម្មករសិន។ «» មេការរូបនេះបន្តថា ទោះមានឧបសគ្គខ្លះៗក្តី ប៉ុន្តែលោកសប្បាយចិត្តដែលលោកអាចរកការងារឱ្យកម្មករធ្វើបាន។

ទាក់ទងបញ្ហានេះដែរ មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកសិទ្ធិការងារ លោក ឌី ថេហូយ៉ា សង្កេតឃើញថា វិបត្តិពលករខ្មែរមានដូចជា ការបាត់បង់ការងារ មានការងារធ្វើតិចជាងមុន បើកលុយយឺត ប្រឈមឆ្លងជំងឺកូវីដ១៩ ហើយបញ្ហាចុងក្រោយនេះគឺប្រឈមការចាប់ខ្លួនព្រោះគ្មានប្រាក់ចុះឈ្មោះសុំសិទ្ធិធ្វើការស្របច្បាប់ ចំពោះពលករខុសច្បាប់។ លោកយល់ថា បញ្ហាទាំងនោះរដ្ឋាភិបាល ឬស្ថានទូតកម្ពុជាត្រូវចេញមុខជួយពលករដោយមានយន្តការច្បាស់លាស់។ «» អាស៊ីសេរីមិនទាន់អាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករ និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំការអត្ថាធិប្បាយជុំវិញក្តីកង្វល់នេះបានទេ នៅថ្ងៃទី១១ ខែកុម្ភៈ ដោយទូរស័ព្ទចូលជាច្រើនដងគ្មានអ្នកទទួល។

ទោះយ៉ាងណា ខណៈពលករខ្មែរកំពុងជួបវិបត្តិនេះហ្វេសប៊ុករបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃក៏មានបង្ហោះសកម្មភាពរបស់អគ្គរាជទូត ឬមន្ត្រីទូតចុះចែកអំណោយដល់ពលករនៅតាមតំបន់ខ្លះដែរ។ លោក ឌី ថេហូយ៉ា លើកឡើងថា សកម្មភាពរបស់អគ្គរាជទូត ឬមន្ត្រីទូតចែកអំណោយឱ្យពលករដែលស្ថានទូតបានធ្វើនោះមិនមែនជាដំណោះស្រាយល្អ និងយូរអង្វែងនោះទេ។ លោកយល់ថា ដំណោះស្រាយល្អគឺរដ្ឋាភិបាលត្រូវមានយន្តការគាំទ្រសង្គមដោយត្រូវមានស្ថិតិពលករប្រឈមច្បាស់លាស់ ដឹងពីតម្រូវការរបស់ពលករ និងឆ្លើយតបឱ្យបានត្រឹមត្រូវទៅពលករ៕

## ក្មេងស្រីរងគ្រោះជនជាតិខ្មែរម្នាក់ អាយុ ១៤ឆ្នាំ ដែលត្រូវបានមេខ្យល់ឆបោកទៅប្រទេសចិន ត្រូវបានសមត្ថកិច្ចជួយសង្គ្រោះត្រឡប់មកដល់ប្រទេសកម្ពុជាវិញហើយ!

http://cambodiapolice.com/policekh/ 11:52 am 12 កុម្ភៈ 2021

ភ្នំពេញ ៖ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានថ្លែងឲ្យដឹងថា ក្មេងស្រីរងគ្រោះជនជាតិខ្មែរម្នាក់ អាយុ ១៤ ឆ្នាំ ដែលត្រូវបានមេខ្យល់ឆបោកទៅប្រទេសចិន បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ក្មេងស្រីរងគ្រោះមានឈ្មោះ យឿង សុជាវីន អាយុ១៤ឆ្នាំ មានទីលំនៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ បន្ទាប់ពីអនុវត្តវិធានចត្តាឡីស័ករយៈពេល ១៤ថ្ងៃរួចមក នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារួមជាមួយអង្គការសម្ព័ន្ធចាប់ដៃ បាននាំយកជនរងគ្រោះមកនាយកដ្ឋានដើម្បីធ្វើការសម្ភាសន៍ ស្រាវជ្រាវរកមេខ្យល់ និងអ្នកពាក់ព័ន្ធ ដើម្បីឈានដល់ការនាំខ្លួនជនសង្ស័យមកផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ក្មេងស្រីខាងលើត្រូវបានប្រគល់ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា និងបញ្ជូនទៅឲ្យក្រុមគ្រួសារសាច់ញាតិនៅសហគមន៍វិញ។

សូមរំលឹកថា កាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២០ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានទទួលព័ត៌មានពីស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពាក់ព័ន្ធនឹងគណនីហ្វេសប៊ុកឈ្មោះ អូនវីនស្រឡាញ់ ម៉ាក់ប៉ា ដែលត្រូវបានជនសង្ស័យជាមេខ្យល់ឆបោកនាំទៅប្រទេសចិនរយៈពេល ៤ ខែកន្លងមកហើយ។ បន្ទាប់ពីទទួលបានព័ត៌មាននេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានដាក់បទបញ្ជាឱ្យកម្លាំងការិយាល័យជំនាញធ្វើការស្រាវជ្រាវ និងបានរកឃើញសាច់ញាតិម្ចាស់គណនីហ្វេសប៊ុកខាងលើមានឈ្មោះ ឯលណារី ភេទប្រុស អាយុ៤១ ឆ្នាំ មុខរបរជាសន្តិសុខក្រុមហ៊ុនឯកជន កំពុងបម្រើការងារនៅកាស៊ីណូមួយកន្លែង នៅទីក្រុងប៉ោយប៉ែត និងមានទីលំនៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែល

ត្រូវជាឪពុកម្ចាស់គណនីហ្វេសប៊ុកខាងលើនោះ ។ តាមរយៈការទំនាក់ទំនងតាមទូរសព្ទ បុរសជាឪពុកបានបញ្ជាក់ថា កូនស្រីរបស់គាត់មានឈ្មោះ យឿង សុជារីន អាយុ១៤ឆ្នាំ បានចាញ់បោកមេខ្យល់មិនស្គាល់អត្តសញ្ញាណ នាំយកទៅប្រទេសចិន រយៈពេល៤ខែកន្លងមកហើយ រូបគាត់បានទៅដាក់ពាក្យបណ្តឹងនៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្នើសុំឲ្យសមត្ថកិច្ចនគរបាលជួយអន្តរាគមន៍ដោះស្រាយ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បញ្ជាក់ថា នៅរសៀលថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០២០ ក្រោមកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរចិន និងសមត្ថកិច្ចពាក់ព័ន្ធរបស់កម្ពុជា បានស្រាវជ្រាវស្វែងរកឃើញកន្លែងស្នាក់នៅរបស់ក្មេងស្រីរងគ្រោះខាងលើ និងបានជួយសង្គ្រោះបញ្ជូនមកស្នាក់ការនគរបាលនៅខេត្តហឺណាន ប្រទេសចិន ដើម្បីចាត់ការបន្ត ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់ឲ្យដឹងទៀតថា មន្ត្រីជំនាញរបស់នាយកដ្ឋានបាននិងកំពុងធ្វើការទំនាក់ទំនងសម្របសម្រួលផ្តល់ព័ត៌មានខាងលើទៅឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារលេខាធិការដ្ឋានមេគង្គឡានចាង ដើម្បីធ្វើការបន្តជាមួយស្ថានអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសចិន ដើម្បីឈានដល់ការសម្របសម្រួលជាមួយអាជ្ញាធរចិនរៀបចំបែបបទបញ្ជូនក្មេងស្រីរងគ្រោះខាងលើឲ្យវិលត្រឡប់មកកម្ពុជាវិញ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ថ្លែងថា សូមឲ្យក្រុមគ្រួសារនារីរងគ្រោះ មេត្តាយោគយល់អធ្យាស្រ័យចំពោះភាពយឺតយ៉ាវក្នុងការបញ្ជូននារីរងគ្រោះមកកម្ពុជាវិញ ហើយភាពយឺតយ៉ាវនេះបណ្តាលមកពីតម្រូវការអនុវត្តនីតិវិធីក្នុងការចាត់បញ្ជូនជនរងគ្រោះ រួមជាមួយនឹងការអនុវត្តវិធានចត្តាឡីស័កនៅប្រទេសចិនផងដែរ។

ឯកឧត្តម ឧត្តមសេនីយ៍ ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ជាទិសដៅ សមត្ថកិច្ចនឹងអញ្ជើញជនរងគ្រោះមកសួរនាំស្វែងរកព័ត៌មានបន្ថែម ដើម្បីឈានដល់អនុវត្តជំនាញធ្វើការស្រាវជ្រាវកំណត់អត្តសញ្ញាណជនសង្ស័យដែលជាមេខ្យល់ ចាត់ការតាមច្បាប់។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាអាជ្ញាធរចិន ដែលតែងតែយកចិត្តទុកដាក់ និងគាំទ្រដោះស្រាយគ្រប់សំណូមពររបស់នាយកដ្ឋានជំនាញ ទទួលបានជោគជ័យជាបន្តបន្ទាប់ និងពិសេសសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម៕

## ពលករកម្ពុជាជាង១២ម៉ឺននាក់ ទទួលបានឯកសារស្របច្បាប់ធ្វើការ នៅប្រទេសថៃ

https://www.kampucheathmey.com/ On February 12, 2021By Sorn Phanith

យោងតាមរបាយការណ៍នៃការធ្វើការជំរឿនរបស់អាជ្ញាធរថៃ បានឲ្យដឹងថា គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករកម្ពុជាចំនួន ១២៦,១៧២នាក់ ក្នុងនោះពលករមាននិយោជក មានចំនួន ១១០,៧៥៦នាក់ និងពលករមិនមាននិយោជក មានចំនួន១៥,៤១៦នាក់ ដែលត្រូវរៀបចំបន្តឲ្យមានឯកសារសម្រាប់ធ្វើការ ដោយស្របច្បាប់នៅប្រទេសថៃ។ របាយការណ៍នេះ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃកាលពីរសៀលថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ នៅទីស្តីការក្រសួងការងារ។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានឲ្យដឹងថាកិច្ចប្រជុំនេះរៀបចំឡើង ដើម្បីពិភាក្សានីតិវិធីនៃការបន្តលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងការដាក់ចេញនូវ

វិធានការ និងរៀបចំផែនការសកម្មភាពមួយចំនួនដើម្បីឆ្លើយតបឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ដល់ការផ្តល់កិច្ចគាំពារ និងសេវាគាំទ្រចាំបាច់នានា ដល់បងប្អូនពលករ អាចបន្តស្នាក់នៅ និងធ្វើការដោយស្របច្បាប់ នៅប្រទេសថៃ ជាពិសេស ក្នុងដំណាក់កាលនៃវិបត្តិកូវីដ ១៩នេះ។ លោករដ្ឋមន្ត្រីបានបន្តទៀតថា ដោយមានការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ពលករទេសន្តរប្រវេសន៍នៅខេត្តសាមុតសាខនរដ្ឋាភិបាលថៃ បានអនុញ្ញាតឲ្យពលករបរទេសគ្មានឯកសារ មកចុះឈ្មោះក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីបានសិទ្ធិស្នាក់នៅ និងធ្វើការនៅប្រទេសថៃបណ្តោះអាសន្ន ដែលការចុះឈ្មោះនេះ ចាប់ពីថ្ងៃ១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១។ លើសពីនេះ រាជរដ្ឋាភិបាលថៃ នឹងដាក់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះពលករបរទេសដែលឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលថៃក៏មិនទាន់បញ្ជាក់ពីវិធានការនេះថាយ៉ាងណានោះឡើយ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ជាមួយគ្នាដែរគណៈកម្មការនឹងសហការជាមួយភាគីថៃ ក្នុងការអនុវត្តនូវកិច្ចការងារនេះ ជូនបងប្អូនពលកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។

គួរបញ្ជាក់ថា តាមរយៈលទ្ធផលនៃកិច្ចប្រជុំនេះដែរ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់នូវឯកសារ និងសេវាគាំទ្រចាំបាច់នានាជូនដល់បងប្អូនពលករកម្ពុជាយើង ដែលមិនមានឯកសារគ្រប់គ្រាន់ ឬបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស នៅពេលដែលភាគីថៃបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ ជាមួយគ្នាដែរគណៈកម្មការនឹងសហការជាមួយភាគីថៃ ក្នុងការអនុវត្តនូវកិច្ចការងារនេះ ជូនបងប្អូនពលកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ៕ **អត្ថបទ៖ សំអឿន**

## អាជ្ញាធរខេត្តបាត់ដំបង ផ្អាកមិនឲ្យរថយន្តដឹកទំនិញប្រភេទធុនតូច ឆ្លងកាត់ព្រំដែន

http://btv.com.kh/ 14/02/2021

បាត់ដំបង ៖ ខណៈមានរថយន្តដឹកទំនិញធុនតូចមួយចំនួន មិនសហការជាមួយសមត្ថកិច្ចការពារព្រំដែន ក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ ហើយឃុបឃិតជាមួយមេខ្យល់ លួចនាំពលករពីប្រទេសថៃ ឆ្លងដែនមកស្រុកកំណើត និងបានគេចវេសពីការធ្វើចត្តាឡីស័កនោះ អាជ្ញាធរខេត្តបាត់ដំបង បានសម្រេចប្រកាសផ្អាកមិនឲ្យរថយន្តប្រភេទនេះ ដឹកទំនិញឆ្លងកាត់ព្រំដែនច្រកអន្តរជាតិដូង (ឡែម) ទៀតនោះទេ ។

ក្នុងកិច្ចប្រជុំបន្ទាន់មួយ ពាក់ព័ន្ធបញ្ហាពលករឆ្លងដែនមកពីថៃ គេចវេសមិនចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ជាមួយរាជរដ្ឋាភិបាល កាលពីរសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម សឿម ប៊ុនរិទ្ធិ អភិបាលរងខេត្តបាត់ដំបង បានលើកឡើងថា សមត្ថកិច្ចប្រចាំនៅច្រកអន្តរជាតិ និងច្រកតំបន់ តាមស្រុកជាប់ព្រំដែន មានស្រុកកំរៀង ភ្នំព្រឹក និងសំពៅលូន ត្រូវតែបង្កើនការប្រុងប្រយ័ត្ន ធ្វើការត្រួតពិនិត្យដោយរឹតបន្តឹងឲ្យបានម៉ឺងម៉ាត់បំផុត ពាក់ព័ន្ធលំហូរ ការវិលត្រឡប់របស់ពលករ មកពីប្រទេសថៃ តាមច្រកនានា និងឆ្លងអូរព្រំដែន ក្នុងដែនសមត្ថកិច្ចកំពុងទទួលខុសត្រូវ ដោយមិនត្រូវឲ្យមានពលករគេចវេសពីការធ្វើចត្តាឡីស័កបាននោះទេ។ លោកបានបន្តថា ក្នុងនោះដែរ ក៏មានពលរដ្ឋរស់នៅតាមបន្ទាត់ព្រំដែនបានផ្សំរួមគំនិត និងឃុបឃិតជាមួយពលករមួយចំនួន ក្នុងការបិទបាំងលាក់បំពួន បន្លែបន្លំ ដើម្បីឲ្យគេចវេសពីការត្រួតពិនិត្យនូវវិធានសុខាភិបាល ការដាក់ឲ្យធ្វើចត្តាឡីស័ក នៅតាមមណ្ឌល ។

លោកអភិបាលខេត្តរង ក៏បានព្រមានដល់គ្រប់កម្លាំងសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងការឃុបឃិត និងបន្តឲ្យមានពលករនៅតែបន្តគេចវេស ដោយប្រើមធ្យោបាយក្នុងការឃុបឃិតបង្វែងដាន លួចដឹកពលករមិនបានធ្វើចត្តាឡីស័ក ត្រូវទទួលខុសត្រូវ និងប្រឈមចំពោះមុខច្បាប់ ។ តាមរយៈកិច្ចប្រជុំនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត

បាត់ដំបង បានកំណត់ និងដាក់ចេញនូវវិធានការក្នុងការបិទការធ្វើចរាចរណ៍របស់រថយន្តធុនតូច ដែលបានចូលទៅដឹកទំនិញ ឆ្លងចេញចូលទៅមក ពីប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិដូង ស្ថិតក្នុងស្រុកកំរៀង ដោយ បញ្ឈប់ជាបន្ទាន់ក្នុងការអនុញ្ញាតឲ្យរថយន្តតូចៗខាងលើទាំងនោះ បន្តចេញចូល និងឆ្លងកាត់ចូលទៅដឹកទំនិញ នៅក្នុងផ្សារថៃ ចាប់ពីការចេញបទបញ្ជា មួយរយៈសិន ៕ អត្ថបទ ៖ សុខរិទ្ធ

## យុវតីខ្មែរម្នាក់ស្នើឲ្យពលរដ្ឋខ្មែរកុំទៅធ្វើការនៅស្រុកគេទាំងប្រថុយប្រថាន

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 14/02/2021 - 12:09 ដោយ៖អោ ស្រីពេជ្រ

ភាពក្រីក្របានរុញច្រានយុវតីខ្មែរម្នាក់ឲ្យសាត់អណ្តែតទៅដល់ប្រទេសចិន តាមរយៈការចាញ់បោកមេខ្យល់ ដែលសន្យាថា នឹងរកការងារឲ្យធ្វើនៅទីនោះ។ ជាអកុល បន្ទាប់ពីទៅដល់ប្រទេសចិន នាងបានរងគ្រោះដោយទទួលរងការរំលោភបំពានផ្លូវភេទ ដែលបង្កឡើងដោយមេខ្យល់ និងប្តីជនជាតិចិន។ តាមរយៈបទពិសោធន៍នេះ យុវតីខ្មែរម្នាក់ស្នើឲ្យពលរដ្ឋខ្មែរកុំទៅធ្វើការនៅស្រុកគេទាំងប្រថុយប្រថាន។ តទៅនេះ សូមស្តាប់ការរៀបរាប់ពីដំណើរជីវិតរបស់យុវតីរូបនេះ ដែលទើបត្រលប់ពីប្រទេសចិនមកដល់កម្ពុជា និងទើបបានមកបញ្ចប់ការធ្វើចត្តាឡីស័កនៅថ្ងៃសៅរ៍នេះតាមរយៈបទយកការណ៍របស់ អោ ស្រីពេជ្រ៖

ជីវិតថ្មី ជាឈ្មោះរបស់យុវតីម្នាក់វ័យ២០ឆ្នាំ ដែលត្រូវបានវិទ្យុបារាំងអន្តរជាតិដាក់ឲ្យដើម្បីរក្សាឯកជនភាពរបស់នាង។ ជីវិតថ្មី សម្រេចចិត្តជឿតាមមេខ្យល់ទៅធ្វើការនៅប្រទេសចិន ព្រោះសង្ឃឹមអាចរកប្រាក់កម្រៃសម្រាប់ដោះស្រាយបញ្ហាជីវភាពគ្រួសារ ក៏ប៉ុន្តែនៅទីបំផុត នាងបែរជាត្រូវបានរំលោភបំពានសេពសន្ថវៈយ៉ាងព្រៃផ្សៃទៅវិញ។ «**និយាយរួមទៅមិនមានសេរីភាពទេ គេឃុំឲ្យនៅតែក្នុងផ្ទះ។ មេខ្យល់ដែលយកយើងទៅលក់ គេវាយធ្វើបាបយើង និងបង្ខំឲ្យយើងដេកនៅជាមួយគេ។ ក្រោយពេលដែលគេដេកនៅជាមួយយើងបានសម្រេចហើយ ប្រហែលជា១អាទិត្យ គេយកយើងទៅលក់បន្តឲ្យប្តី។ បើសិនជាយើងព្រមតាមគេ គេឲ្យយើងទៅតែប្តីមួយទេ ក៏ប៉ុន្តែបើសិនជាយើងមិនព្រម គេនឹងលក់យើងបន្តពីប្តីមួយទៅប្តីមួយទៀត។**» រយៈពេល៣ឆ្នាំរស់នៅជាមួយប្តីជនជាតិចិន ជីវិតថ្មី រងការធ្វើទុក្ខបុកម្នេញរាងកាយផង និងផ្លូវចិត្តផង។ «**ឪពុកម្តាយក្មេក គាត់បង្ខំអោយខ្ញុំមានកូនឲ្យគេ។ គេវាយខ្ញុំពេលដែលខ្ញុំមិនទៅពេទ្យជាមួយគេ។ គេបង្ខំឲ្យខ្ញុំទៅពេទ្យទៅយកកូន ហើយប្រសិនបើយើងមិនស្តាប់គេ គេហៅបងប្អូនគេមកវាយដំច្រំជាក់ធ្វើបាបយើង។ បើយើងស្តាប់ យើងព្រមតាម យើងមិនឈឺខ្លួនទេ តែបើយើងរឹង នោះយើងនឹងឈឺខ្លួន**»។ «**គេមិនអោយទំនាក់ទំនង ម៉ែឪបងប្អូន។ ធម្មតាម៉ាក់ខ្ញុំគាត់ឈឺ ខ្ញុំទៅចិនដើម្បីរកលុយព្យាបាលជំងឺគាត់។ ម៉ាក់ខ្ញុំមានជំងឺដុះដុំសាច់ក្នុងស្បូន។ ខ្ញុំបានសុំគេទៅធ្វើការ គេមិនឲ្យយើងទៅធ្វើការទេ។ គេមិនឲ្យយើងគិត និងទំនាក់ទំនងម៉ែឪយើងនៅខ្មែរទេ បើគាត់មានអី គាត់ហូបនឹងទៅ កុំបាច់ទៅគិតអី ធ្វើអីគិតតែគ្រួសារគេហ្នឹងទៅបានហើយ**»

ជីវិតថ្មី ធំធាត់ឡើងនៅខេត្តក្រចេះ។ ដោយសារបញ្ហាជីវភាព នាងត្រូវបញ្ឈប់ការសិក្សាត្រឹមថ្នាក់ទី៤ ដើម្បីរកប្រាក់ចំណូលខ្លះផ្គត់ផ្គង់គ្រួសារ។ នៅឆ្នាំ២០១៨ កាលនោះនាងមានអាយុ១៨ឆ្នាំ នាងសម្រេចចាកចេញពីស្រុកកំណើតមកធ្វើការរោងចក្រនៅភ្នំពេញ។ ធ្វើការមិនបាន១ខែផង នាងស្រាប់តែធ្លាក់ចូលក្នុងសំណាញ់មេខ្យល់ បោកឲ្យទៅធ្វើការនៅប្រទេសចិន។ «**គ្រួសារខ្ញុំអត់មានផ្ទះនៅផង បងក៏ទើបនឹងស្លាប់ និងម៉ែគាត់ឈឺធ្ងន់ ហើយអត់មានលុយព្យាបាល។ ខ្ញុំអត់មានពុកទេ ពួកគាត់លែងលះគ្នា។ ពេលឡើងមកភ្នំពេញ ធ្វើការងារកាត់ព្រុយខោអាវតាមរោងចក្រពីរោងចក្រមួយទៅរោងចក្រមួយ ក៏បានស្គាល់មនុស្សម្នាក់បបួលខ្ញុំទៅចិនហ្នឹង។ ស្គាល់គាត់ប្រមាណ៣ទៅ៤ថ្ងៃ។ ខ្ញុំនិយាយរឿងគ្រួសារប្រាប់គាត់ គាត់ថាមិនអីទេ បងស្លូតទេ បងនាំអូន**

**ទៅធ្វើការល្អ បានលុយច្រើនទៅជួយម៉ែ។ គាត់ថា ថៅកែគាត់នៅចិនកំពុងរកមនុស្សធ្វើការ និងអាចមានប្រាក់ខែច្រើនអាចជួយគ្រួសារបាន។»**

ជីវិតថ្មី រៀបរាប់ពីដំណើរជីវិតសាត់អណ្តែតទៅប្រទេសចិន ក្រោយពេលចាកចេញពីប្រទេសខ្មែរយ៉ាងដូច្នេះថា៖ **«ដល់ពេលទៅដល់ត្រឹមព្រំដែនវៀតណាម គាត់និយាយថា អូនទៅមុនទៅ បងនៅចាំយកគេ២នាក់ទៀតសិន ចាំទៅជួបគ្នានៅចិន។ នៅពេលខ្ញុំនៅប្រទេសចិន អត់មានឃើញគាត់ផង គាត់អត់មកផង។ ពេលនោះបានជួបគាត់ដែរតាមទូរស័ព្ទ គាត់ថា ឲ្យទៅតាមគេសិនទៅ គេយកអូនឯងទៅកន្លែងហើយ។ ពេលហ្នឹងខ្ញុំក៏អត់ដឹងថាកន្លែងអី គិតថាជាកន្លែងធ្វើការ ព្រោះនិយាយពីខ្មែរមកថាធ្វើការ។ ក្រោយមកមេខ្យល់ប្រុសបើកឡានមកយក ក៏ទៅតាមគេ។ ទម្រាំទៅដល់ចិន គឺអស់ពេល២ទៅ៣ថ្ងៃដែរ។ ហើយណាមួយអត់មានបាយអីហូបផង ជិះតាមឡានហ្នឹង គ្មានកម្លាំងអីទៅតតាំងជាមួយគេ មានតែព្រមទៅ។»** ចេញពីប្រទេសខ្មែរទៅវៀតណាមតាមរថយន្ត ទៅដល់វៀតណាមហើយ ជីវិតថ្មី ត្រូវបន្តឡើងយន្តហោះទៅប្រទេសចិន ដោយប្រើប្រាស់លិខិតឆ្លងដែនខុសច្បាប់ដែលមេខ្យល់ប្រគល់ឲ្យនាង។

**«លិខិតឆ្លងដែនទិញឈ្មោះគេទៅ គឺវៀតណាម អ៊ីចឹងត្រូវចុះនៅព្រំដែនវៀតណាម។ គ្រប់យ៉ាង (ឯកសារ) គឺនៅលើមេខ្យល់ទាំងអស់។ ពេលហ្នឹងអត់មានលុយផង មេខ្យល់ថា គេជាអ្នកចេញឲ្យគ្រប់យ៉ាង។ នៅពេលទៅដល់ចិន គេដកទាំងអស់ពេលទៅដល់ចិន សូម្បីតែទូរស័ព្ទ។»** ១ឆ្នាំក្រោយមក ការរស់នៅកាត់ផ្តាច់ទំនាក់ទំនងជាមួយគ្រួសារត្រូវបានផ្សារភ្ជាប់វិញ ដោយនាងបានលួងលោមប្តីជនជាតិចិន ឲ្យនាងអាចប្រើប្រាស់ទូរស័ព្ទដៃបាន។ **«ខ្ញុំសរសេរជាអក្សរ លួងលោមគេ។ តាំងពីឆ្នាំ២០១៨ គេដកទូរស័ព្ទ។ ដល់ឆ្នាំ២០១៩ ទើបខ្ញុំអាចលេងទូរស័ព្ទ ទំនាក់ទំនងមកម៉ែនៅខ្មែរបាន។ ខ្ញុំអាចលេងបាន តែនិយាយមិនបានទេ ព្រោះទូរស័ព្ទត្រូវកាត់ផ្តាច់សំឡេងហើយ។ ខ្ញុំលេងបានតែពេលយប់ទេ គឺពេលដែលគេដេក។ ខ្ញុំកុហកគេថា ខ្ញុំយកមកមើលរឿងទេ ព្រោះអីទូរស័ព្ទនោះគ្មានស៊ីមទេ។»** ទីបំផុត ជីវិតថ្មី អាចគេចចេញពីសំណាញ់ប្តីជនជាតិចិនបាន តាមរយៈការដង្ហោយស្វែងរកជំនួយតាមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក៖ **«ហ្វេសប៊ុកដែលខ្ញុំលេងនឹង គឺខ្ញុំសុំគេដែលជាខ្មែរដែរ។ ម៉ាក់ខ្ញុំដឹងខែតុលាឆ្នាំ២០១៩ ពេលនឹងកូវីដផ្ទុះ អត់មានអ្នកណាមកយក។ ឆ្នាំ២០២០ ខែ១១ ថ្ងៃទី៣០ ខ្ញុំផុស (បង្ហោះ) រូបភាពនៅផ្ទះហ្នឹងឲ្យគេមើលទៅ បានមានគេជួយ។ គេទំនាក់ទំនងស្រាវជ្រាវរកណាំបង។ កាលនោះ បង្ហោះជារូបភាព ព្រោះផុសជាវីឌីអូអត់ឮដដែល អ៊ីចឹងទៅក៏ផុសជារូបភាព ហើយសរសេរអក្សរនៅលើហ្នឹងតែម្តង។ ណាមួយអង្គការ គេបានជួយផ្សព្វផ្សាយ ជួយច្រើនដែរហើយ។ »**

ជីវិតថ្មី បានមកដល់ប្រទេសខ្មែរនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ និងបានបញ្ចប់ការធ្វើចត្តាឡីស័កនៅថ្ងៃសៅរ៍ទី១២កុម្ភៈម្សិលមិញ។ យ៉ាងណាមិញ បើទោះបីជាជីវិតថ្មី បានមកដល់ស្រុកកំណើតក៏ពិតមែន តែនាងនៅតែមិនទាន់អាចភ្លេចរឿងរ៉ាវដែលបានកើតឡើងនៅឡើយទេ។ អំពើឃោរឃៅទាំងនោះ នៅតែបន្តលងបន្លាចរូបនាងនៅឡើយ។ **«យូរដែរ អ៊ីចឹងរៀងធូរ ព្រោះបានមកដល់ស្រុកហើយ។ ក៏ប៉ុន្តែនិយាយអីនៅភ្លេងភ្លាំងៗខ្លះៗ។»** ចេញពីជីវិតខ្មៅងងឹត ជីវិតថ្មី ចង់រៀនផ្នែកសម្អាង ជាជំនាញសម្រាប់ចិញ្ចឹមជីវិត និងគិតលែងចាកចេញទៅប្រទេសក្រៅទៀត។ នាងថា សុបិនរបស់នាងហាក់នៅឆ្ងាយណាស់ ព្រោះនាងគ្មានសល់អ្វីទេនៅពេលនេះ។ តាមរយៈក្បាលមេក្រូរបស់វិទ្យុបារាំងអន្តរជាតិ ជីវិតថ្មីផ្តល់យោបល់ទៅកាន់ស្ត្រីខ្មែរដទៃទៀត ធ្វើយ៉ាងណាគិតគូរឲ្យបានច្បាស់លាស់ជាមុនសិន មុនពេលសម្រេចចិត្តចាកចេញពីប្រទេស មិនថាទៅធ្វើការឬរៀបការនោះទេ។ **«ចង់ឲ្យគាត់កុំឆាប់ជឿគេ ព្រោះមនុស្សយើងស្គាល់មុខ តែមិនស្គាល់ចិត្ត។ យើងលំបាកក្រអី នៅជាមួយម៉ែឪយើងទៅ។ ទោះបីក្រមានអី យើងនៅស្រុកយើង។**

## ពលករ ម្នាក់ជាន់មីនរបួសដាច់ជើង ក្រោយលួចឆ្លងពីប្រទេសថៃមកកម្ពុជា តាមព្រៃភ្នំ, រាជរដ្ឋាភិបាលអំពាវនាវឱ្យពលករទាំងអស់ចូលកម្ពុជាតាមច្រកស្របច្បាប់ និងធ្វើចត្តាឡីស័ក

http://www.freshnewsasia.com/ 2021-02-14 10:32pm

**(ភ្នំពេញ)៖** ពលករខ្មែរម្នាក់ បានជាន់មីនរងរបួសធ្ងន់ដាច់ជើង នៅវេលាម៉ោង៧៖១០នាទីយប់ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១នេះ បន្ទាប់ពីបានលួចឆ្លងដែនពីប្រទេសថៃ ចូលមកកម្ពុជា តាមតំបន់ព្រៃភ្នំ ជាយក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីគេចចេញពីការធ្វើ ចត្តាឡីស័ក។ នេះបើតាមការបញ្ជាក់របស់សមត្ថកិច្ចមូលដ្ឋាន។ សមត្ថកិច្ចបានអះអាងថា ពលករខ្មែរម្នាក់នេះ មានឈ្មោះ យឿន រ៉ន អាយុ៣២ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រៃគុក សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត។ រូបគេបានលួចឆ្លងដែនពីប្រទេសថៃចូលកម្ពុជា នៅក្នុងភូមិសាស្ត្រអូរលៀង ភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយបានជាន់មីនបណ្តាលឱ្យដាច់ជើង ខាងស្តាំរបួសធ្ងន់ ហើយពេលនេះរូបគេត្រូវបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យក្រុងប៉ោយប៉ែត។ អាជ្ញាធរបានបញ្ជាក់ថា តំបន់ដែលពលករខាងលើឆ្លងដែននេះ ជាតំបន់គ្រោះថ្នាក់ ដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ បន្សល់ទុកតាំងពីសម័យសង្គ្រាម មិនទាន់បោសសម្អាតអស់នៅឡើយ។

ពាក់ព័ន្ធនឹងករណីនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអង្គភាពព័ត៌មាន Fresh News បានអំពាវនាវដល់ពលករទាំងអស់ ឱ្យបញ្ឈប់ការឆ្លងដែនតាមព្រៃភ្នំ ឬច្រកណាមួយដែលគ្រោះថ្នាក់ ហើយត្រូវចូលរួមសហការ ក្នុងការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ១៩៕

## កងយោធាទៅត្រួតពិនិត្យបន្ថែមលើសមត្ថកិច្ចនគរបាលច្រកទ្វារព្រំដែនកម្ពុជា ថៃ រឹតបន្តឹងការឆ្លងដែនរបស់ពលករ, រុះរើកូនស្ពានឆ្លងច្រករបៀង

https://www.rasmeinews.com/ 14 February, 2021

**ដោយ: ប.ជ័យ / បន្ទាយមានជ័យ:** *កងយោធារបស់កងពលតូចចំណុះយោធាភូមិភាគទី៥ ចំណុះកងទ័ពជើងគោក ត្រូវបានចាត់បញ្ជារទៅបំពេញបេសកកម្មត្រួតពិនិត្យបន្ថែម លើភារកិច្ចរបស់សមត្ថកិច្ចជំនាញ នៃនគរបាលអន្តោប្រវេសន៍នៅច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ដើម្បីរឹតបន្តឹងការលួចជ្រៀត ឬបង្កប់ការឆ្លងដែនវិលពីប្រទេសថៃរបស់ពលករខ្មែរ។*

នេះបើយោងលោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជការយោធភូមិភាគគទី៥និងជានាយសេនាធិការ អោយដឹងក្នុងផេករបស់លោកកាលពីថ្ងៃទី១៣ ខែកុម្ភ ឆ្នាំ២០២១។ លោកឧត្តមសេនីយ៍ទោអោយដឹងថា ៖ នៅថ្ងៃទី១៣ខែកុម្ភៈ សកម្មភាពកម្លាំងកងពលតូចថ្មើរជើងលេខ៥៣ បានទៅសហការត្រួតពិនិត្យបន្ថែមនៅលើច្រកព្រំដែនអន្តរជាតិដូងស្រុកកំរៀងខេត្តបាត់ដំបង។ ចំណែកកម្លាំងកងពលតូចថ្មើរជើងលេខ៥១ បានកំពុងបំពេញបេសកកម្មនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ។

ប្រភពពីសមត្ថកិច្ចនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិខាងលើ បានឲ្យកាសែតរស្មីកម្ពុជាដឹងថ្ងៃទី១៤ ខែកុម្ភៈថា៖ ប្រតិបត្តិការនេះរបស់កងទ័ព គឺបានត្រួតពិនិត្យបន្ថែមពីលើភារកិច្ចប្រចាំថ្ងៃរបស់សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ នៃច្រកទ្វារដើម្បីរឹតបន្តឹងការជ្រៀត ឬបង្កប់មនុស្ស ឬពលករខ្មែរឆ្លងដែនតាមយានយន្ត ឬថយន្តដឹកទំនិញចេញពីប្រទេសថៃ ជាទីដែលផ្ទុះការរីករាលដាលខ្លាំងក្នុងសហគមន៍នូវជម្ងឺកូវីត១៩ ចូលមកប្រទេសកម្ពុជា ដោយមិនបានត្រួតពិនិត្យ សុខភាព យកវត្ថុសំណាករកមេរោគកូវីត១៩និងដាក់អោយធ្វើចត្តាឡីស័ក ។

លោកឧត្តមសេនីយ៍ សេង ធារិន ក៏បានឲ្យដឹងដែរថា៖ ដើម្បីទប់ស្កាត់ ឬកាត់ផ្តាច់នូវការលួចចេញ ចូលនូវពលករខ្មែរឆ្លងកាត់ច្រករបៀងនៃព្រំដែនកម្ពុជា ថៃ (មាននៅភូមិសាស្ត្រក្រុងប៉ោយប៉ែត និងស្រុកខ្លះទៀតនៅខេត្តបន្ទាយមានជ័យ) កម្លាំងកងពលតូចថ្មើរជើងលេខ៥១ បានរុះរើ កូនស្ពានឆ្លងអូរព្រំដែន។ នៅតាមបណ្តោយខ្សែ

បន្ទាត់ព្រំដែននសខេត្តឯទៀត ក៏ត្រូវធ្វើដែរនូវការលួចធ្វើស្ពាន ,ខ្សែរ៉ក ,ក្បួន,ឬរូបភាពផ្សេងៗដែលបង្កលក្ខណៈអោយពលករលួចឆ្លងដែន។ គឺនៅស្រុកកំរៀង ភ្នំព្រឹក សំឡូត សំពៅលូនខេត្តបាត់ដំបង ស្រុកសាលាក្រៅខេត្តប៉ៃលិន ស្រុកវាលវែងខេត្តពោធិ៍សាត់ ជាដើម។ ប៉ុន្តែនៅបណ្តោយព្រំដែនកម្ពុជា ថៃដែរនាភូមិសាស្ត្រខេត្តកោះកុងនៃយោធាភូមិភាគទី៣, ភូមិសាស្ត្រខេត្តឧត្តរមានជ័យនិងខេត្តព្រះវិហារនៃយោធាភូមិភាគទី៤ ក៏មានការរឹតបន្តឹងលំហូរពលករខ្មែរឆ្លងដែលខុសច្បាប់វិលពីប្រទេសថៃនេះដែរ។ ប៉ុន្តែនៅមិនទាន់មានព័ត៌មានពីប្រតិបត្តិនៃការបិទខ្ទប់ច្រករបៀង ការរុះរើកាត់ផ្តាច់កូនស្ពាន ឬមធ្យោបាយដែលនាំអោយពលករអាចលួចឆ្លងដែននៅឡើយ៕

## កងកម្លាំងនៅព្រំដែនកម្ពុជា ថៃ ទប់ស្កាត់ពលករខ្មែរ ឆ្លងដែន ដែលមិនបានធ្វើចត្តាឡីស័ក បង្ការជំងឺកូវីដ១៩

https://www.cen.com.kh/ February 14, 2021

បន្ទាយមានជ័យ ៖ កងកម្លាំងនគរបាល កងរាជអាវុធហត្ថ និងកងទ័ព ដែលឈរជើងក្នុងភូមិសាស្ត្រខេត្តនានាចំណុះភូមិភាគ៥ និងតាមបណ្តោយព្រំដែនកម្ពុជា ថៃ បាននិងកំពុងបង្កើនល្បាតទប់ស្កាត់លំហូរពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលមិនបានត្រួតពិនិត្យ និងធ្វើចត្តាឡីស័កក្នុងបំណងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ។ សម្រាប់ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ ស្នងការនគរបាលខេត្តនេះ ឲ្យដឹងកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ថា៖ នគរបាលវរៈព្រំដែនគោគទាំង៤ វរៈបានសហការនឹងកម្លាំងប្រដាប់អាវុធជួរមុខ (កងទ័ព កងរាជអាវុធហត្ថ) រួមគ្នាការពារទប់ស្កាត់ពលករចំណូលស្រុក និងចំណាកស្រុកនិងអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល ។

រីឯលោកឧត្តមសេនីយ៍ទោ សេង ជារិន មេបញ្ជាការរងយោធភូមិភាគទី៥ និងជានាយសេនាធិការបានឲ្យដឹងថ្ងៃទី១៣ខែកុម្ភៈថា ៖ កងកម្លាំងចម្រុះបានសហការគ្នាបង្កើនល្បាត ត្រួតពិនិត្យ រឹតបន្តឹងសន្តិសុខតាមបណ្តោយព្រំដែន ទប់ស្កាត់ការជ្រៀតចេញ ចូលពលករខុសច្បាប់ ក្នុងបំណងបង្ការទប់ស្កាត់ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩។ ក្នុងនោះត្រូវត្រួតពិនិត្យ រឹតបន្តឹងមិនឲ្យមានពលករឆ្លងដែន ដែលមិនបានធ្វើចត្តាឡីស័ក និងយកវត្ថុសំណាករកមេរោគកូវីដ ១៩ ។ ជាក់ស្តែង កម្លាំងកងពលតូចថ្មើរជើងលេខ៥២ ក៏ដូចតំបន់ប្រតិបត្តិការសិករងប៉ៃលិន និងនគរបាលព្រំដែនបានបំពេញបេសកកម្ម ការពារល្បាតតាមខ្សែបន្ទាត់ព្រំដែនខេត្តប៉ៃលិន ទប់ស្កាត់ពលករខ្មែរឆ្លងដែនខុសច្បាប់ ដើម្បីពង្រឹងទប់ស្កាត់ជំងឺកូវីដ ១៩ ពោលគឺមិនត្រូវឲ្យមានការឆ្លងដែនណាដែលមិនបានធ្វើការត្រួតពិនិត្យនិងធ្វើចត្តាឡីស័កឡើយ។ ដូចគ្នាដែរ កងការពារព្រំដែនលេខ៥០១ ចាត់តាំងកម្លាំងល្បាត តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រទទួលខុសត្រូវ ។

រីឯលោកវរសេនីយ៍ឯក ចាន់ ប៊ុនឌី មេបញ្ជាការ កងការពារព្រំដែនលេខ៥០១ កាលពីថ្ងៃទី១២ -១៣ខែកុម្ភៈ ឆ្នាំ២០២១ (ចំឱកាសបុណ្យចូលឆ្នាំចិនតាមច័ន្ទគតិ ) បានចាត់តាំងកម្លាំងល្បាតព្រំដែនចាប់ពីអូររំដេង ព្រំប្រទល់ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង ដល់ភ្នំធំ ព្រំប្រទល់ស្រុកសំឡូត ខេត្តបាត់ដំបង ដើម្បីត្រួតពិនិត្យ រក្សាការពារបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទប់ស្កាត់រាល់បទល្មើសនានា ដែលអាចកើតមានក្នុងភូមិសាស្ត្ររបស់ខ្លួនឈរជើង។ ជាការកត់សម្គាល់ របាយការណ៍កងយោធាខាងលើឲ្យដឹងថា ៖ ក្នុងភូមិសាស្ត្រនេះគ្មានបទល្មើសឆ្លងដែន ពលករឆ្លងដែនឬគ្មានបញ្ហាអសន្តិសុខឡើយ។ លោកបន្តថា ក្រៅពីភារកិច្ចស្នូលរបស់អង្គភាព និងការងារល្បាត ក៏បានចាត់តាំងកម្លាំងមួយចំនួន ប្រចាំការត្រៀមត្រួតពិនិត្យ ទប់ស្កាត់ពលករឆ្លងដែនតាមច្រករបៀងពីប្រទេសថៃ នៅតាមបណ្តាគោលដៅច្រករបៀងនានា ដែលមិនបានត្រួតពិនិត្យនិងធ្វើចត្តាឡីស័ក ៕
ដោយ ៖ បន្ទាយ

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃសៅរ៍ ទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៨២នាក់ ស្រី ៣៨នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៨នាក់ ស្រី ១១នាក់ កុមារា ១នាក់ កុមារី ២នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១០នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣០នាក់ ស្រី ១៤នាក់ កុមារា ០០នាក់ កុមារី ២នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ២៤នាក់ ស្រីចំនួន ៩នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៨២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ២៨នាក់, ខេត្តបាត់ដំបង ចំនួន ២៤នាក់ និងឧត្តរមានជ័យចំនួន ៣០នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ផ្សាយដោយ៖ ធូ កុសល

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៥នាក់ ស្រី ៣១នាក់ ក្នុងនោះកុមារា ៣នាក់ កុមារី ៨នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៤នាក់ ស្រី ១២នាក់ កុមារា ១នាក់ កុមារី ២នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២១នាក់ ស្រី ១០នាក់ កុមារា ២នាក់ កុមារី ២នាក់។

សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២០នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ៤នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៤៥នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ២០នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ផ្សាយដោយ៖ ធូ កុសល

## មន្ត្រីស្ថានទូតកម្ពុជា នៅម៉ាឡេស៊ី ជួយពលករខ្មែរ១១នាក់ ធ្វើការខារខុសច្បាប់បានត្រឡប់មកកម្ពុជាវិញ

https://www.cen.com.kh/ February 13, 2021

ភ្នំពេញ ៖ លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់នៅថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០២១ថា ពលករខ្មែរចំនួន១១នាក់ មានស្រីម្នាក់បានមកដល់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីហើយ។ លោកកុយ គួង លើកឡើងថា ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករ ពលការិនីខ្មែរចំនួន១១នាក់ និង ទារិកា១នាក់ ដែលបានមកធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី នឹងទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះលេខ SQ5008 នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០២១ វេលាម៉ោង ០៥និង៣៥នាទីល្ងាច ។ លោកបានបញ្ជាក់តាមប្រព័ន្ធតេឡេក្រាមនៅថ្ងៃនេះថា មន្ត្រីស្ថានទូតបានជួយសម្របសម្រួលឯកសារ នាំទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី ជូនទៅធ្វើតេស្តកូវីដ១៩ ព្រមទាំងជូនពលករ ពលការិនី ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ៕ រក្សាសិទ្ធិដោយ៖CEN

## ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

## ប្រមុខរាជរដ្ឋាភិបាលចេញបញ្ជាឲ្យកងទ័ពពង្រាយកម្លាំងអនុវត្តន៍វិធានការទាំងឡាយប្រឆាំងកូវីដ ១៩

https://www.rasmeinews.com/ 15 February, 2021

**ដោយ៖តារាវិទូ/ភ្នំពេញ៖** *ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នៅយប់ថ្ងៃទី ១៥ ខែកុម្ភៈ បានចេញបទបញ្ជាទៅកាន់កងយោធពលខេមរ ភូមិន្ទឲ្យពង្រាយកម្លាំងកងទ័ពទៅតាមព្រំដែនដើម្បីអនុវត្តន៍វិធានការទាំងឡាយរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងកូវីដ១៩ ។*

នៅក្នុងសារជាសម្លេងនៅក្នុងបណ្ដាញសង្គមតេឡេក្រាម ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានថ្លែងដែលមានខ្លឹមសារថា៖«វង្ស ពិសេស,សៅ សុខា ,ហ៊ុន ម៉ាណែត ពង្រាយកងទ័ព ដាក់ដើម្បីអនុវត្តន៍នូវវិធានការទាំងឡាយហើយមើលអាមេប៉ូលីសៗដែលពុករលួយ លេងវាអាហ្នឹង នេត សារឿន មើលឲ្យច្បាប់អាហ្នឹង ហើយតាមបណ្ដាច្រក់អភិបាលខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី រឿងនេះអត់បានទេគ្រោះថ្នាក់ » ។ ការចេញបទបញ្ជាទាំងយប់របស់សម្តេចតេជោ ហ៊ុន សែន ធ្វើឡើងក្រោយមានរឿងមិនប្រក្រតីមួយចំនួនពាក់ព័ន្ធការលួចនាំមនុស្សឆ្លងដែនខុសច្បាប់តាមច្រកព្រំដែនមួយចំនួនក្នុងខេត្តបាត់ដំបងដែលមានមេខ្លោងនាំពលករចំណាកស្រុកពីប្រទេសថៃចូលមកកម្ពុជាដោយគេចវេះពីការធ្វើចត្តាឡីស័កនៅតាមព្រំដែន។ ជាមួយនេះគេរបានរកឃើញថាមានជាប់ពាក់ព័ន្ធជាមួយមន្ត្រីប៉ូលីសផងដែរ ។ ជាក់ស្ដែងនៅថ្ងៃ១៥ កុម្ភៈនេះ រាជរដ្ឋាភិបាលបានចេញអនុ ក្រឹត្យដកស័ក្តិនិងបណ្ដេញចេញពីក្របខណ្ឌមន្ត្រីប៉ូលីសជាតិនូវអធិការនគរបាលស្រុកកំរៀងលោកគឹមពន្លកដោយ សារតែប្រព្រឹត្តិអំពើពុករលួយលួចដោះលែងមេខ្លោងនាំពលករឆ្លងដែនខុសច្បាស់ ។ នៅថ្ងៃនេះផងដែរមន្ត្រីប៉ូលីសខេត្តបាត់ដំបងក៏បានឃាត់រថយន្តតាក់ស៊ីមួយគ្រឿងដឹកពលករចំណាកស្រុកមកពីប្រទេសថៃរហូតដល់ទៅ៧នាក់ ដែលគេចវេះពីការធ្វើចត្តាឡីស័កនិងកម្លាំងចម្រុះនៅច្រកទ្វារ អន្តរជាតិដូងខេត្តបាត់ដំបងបានឆែកក្នុងរថយន្តដឹកស្វាយ ១គ្រឿងដោយមានបង្កប់ពលករមកពីប្រទេសថៃចំនួន៥នាក់ ។ ក្នុងចំណោមពលករទាំង៥ មានខ្មែរ ៤នាក់និងនារី វៀតណាមម្នាក់ ៕

## សម្តេចតេជោ ប្រាប់ទៅកងកម្លាំង និងអាជ្ញាធរជាប់ព្រំដែនថៃទប់ស្កាត់ដាច់ណាត់កុំឲ្យពលករឆ្លងចេញ-ចូលខុសច្បាប់

https://www.kampucheathmey.com/local-news/ on February 15, 2021By deth leng

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងប្រាប់ទៅដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលខេត្ត ដែលមានព្រំដែនជាប់ប្រទេសថៃ ព្រមទាំងថ្នាក់ដឹកនាំកងកម្លាំងប្រដាប់អាវុធ ត្រូវរកវិធីទប់ស្កាត់ប្រជាជន ពលករខ្មែរឆ្លងដែនចេញ-ចូលខុសច្បាប់ ដើម្បីការពារគ្រោះថ្នាក់នឹងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ ការថ្លែងបែបនេះរបស់សម្តេចតេជោ ហ៊ុន កើតមានឡើងបន្ទាប់ពី មានករណីពលករខ្មែរម្នាក់ ឈ្មោះយឿន រ៉ន មានអាយុ ២៣ ឆ្នាំបានជួបគ្រោះថ្នាក់ជាន់មីនដាច់ជើងក្នុងពេលលួចឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជា កាលពីម៉ោង ៧៖០០ ល្ងាចថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០២០ ស្ថិតនៅតំបន់ព្រៃភ្នំ ដាយក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីគេចចេញពីការធ្វើ ចត្តាឡីស័ក។ តាមរយៈ សារអេឡិចត្រូនិកតេឡេក្រាម សម្តេចតេជោថ្លែងប្រាប់ឲ្យលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលខេត្តដែលនៅជាប់ព្រំដែនថៃ ព្រមទាំងកងកម្លាំងប្រដាប់អាវុធចម្រុះ មានថ្នាក់ដឹកនាំកងទ័ពផងដែរ ត្រូវធ្វើការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋធ្វើដំណើរចូលមកតាមច្រកត្រឹមត្រូវ ជៀសវាងមានគ្រោះថ្នាក់ ដោយសារគ្រាប់មីន ដែលមានមួយករណីកើតឡើងនៅបន្ទាយមានជ័យជាន់មីនដាច់ជើងជាគំរូ។ សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ប្រសិនបើទុកបន្ត រឿងនេះ មិនចប់ទេ ការធ្វើដំណើរចេញ គឺមិនឲ្យចេញដាច់ខាត ដែលកន្លងទៅមានការទំនាក់ទំនងឲ្យចេញ។

សម្តេចតេជោ ហ៊ុន សែន បានប្រាប់ទៅ លោកនេត សាវឿន ត្រូវចងក្រងមនុស្ស គឺរាជរដ្ឋាភិបាលគួតែ យកមុខសញ្ញារត់ពន្ធមនុស្ស ឆ្លងដែន យកមកគ្រប់គ្រងសិន ព្រោះកាលៈទេសៈនេះ ជាកាលៈទេសៈចាំបាច់ ត្រូវរកគ្រប់វិធីដើម្បីយកពួកក្រុមនេះឃុំគ្រង។ សម្តេចសម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា "ឥឡូវប្រសិនបើទុកបន្តគ្រោះថ្នាក់កាន់តែធំ វាទាក់ទិនទៅនឹងគ្រោះថ្នាក់ មីនកន្លែងខ្លះដោះមិនទាន់អស់នោះទេ ដើរចុះឡើង ទៅកន្លែងមិនទាន់ដោះមីន មានគ្រោះថ្នាក់ដាច់ជើង ឬស្លាប់ ដោយសារតែគ្រាប់មីនតែម្តង"។ បើតាមសម្តេចតេជោ ហ៊ុន សែន កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរខេត្ត ត្រូវរកវិធីទប់ស្កាត់ការឆ្លងដែន ខុសច្បាប់ដែលមិនបានធ្វើចត្តាឡីស័ក បូកនឹងការការពារប្រជាជន កុំឲ្យស្លាប់ឬរបួស ដោយសារត្រូវគ្រាប់មីនដូចករណីខាងលើ៕ **អត្ថបទ៖ ឡេង ដេត**

## សម្តេចតេជោ បញ្ជាឲ្យវាយខ្នោះប៉ូលិសសក្តិ៤ម្នាក់ នៅច្រកឡែម បើរកឃើញកំហុសដោះលែងមេខ្យល់

https://www.kampucheathmey.com/ on February 15, 2021By deth leng

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចេញបញ្ជាដាច់ណាត់ឲ្យវាយខ្នោះលោកប៉ូលិសស័ក្តិ៤ម្នាក់នៅច្រកឡែម ប្រសិនបើរកឃើញថា លោកស័ក៤ នោះបានដោះលែងមេខ្យល់នាំពលករខុសច្បាប់ចេញចូលប្រទេសថៃនិងគេចចេញពីការធ្វើចត្តាឡីស័ករបស់សមត្ថកិច្ចនៅតាមព្រំដែន។ ការចេញបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាលនេះ បានធ្វើឡើងតាមរយៈសារជាសំឡេងដែលត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធ តេឡេក្រាម នាព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នេះ។ សម្តេចតេជោ បានបញ្ជាក់ថា សម្តេចបានទទួលរបាយការណ៍ជាច្រើនអំពីការចេញ ចូលរបស់ពលករនៅច្រកឡែម ដោយមានការសហការគ្នារ ហើយសម្តេច ក៏ទទួលបានឯកសារខ្លះអំពីការស្រាវជ្រាវលើករណីនេះ ដែលលោកស័ក្តិ៤ម្នាក់ បានដោះលែងមេខ្យល់ នាំពលករខ្មែរចេញពីប្រទេសថៃ ក្រោយពីទាហានចាប់បាន។

សម្តេចបញ្ជាក់ថា ត្រូវធ្វើការស្រាវ ជ្រាវជាបន្ទាន់លើករណីនេះ។ ចាប់បានមេខ្យល់ហើយ បែរមិនព្រមផ្តន្ទាទោសខណៈដែលទាហានជាអ្នកចាប់ ហើយប៉ូលីសអ្នកដោះលេង។ សម្តេចតេជោបានបញ្ជាក់យ៉ាងដូច្នេះថា "បើ

សិនរឿងនេះជារឿងពិត ត្រូវតែដាក់វិន័យ ឬផ្តន្ទាទោសអាមេប៉ូលីសនេះតែម្តង អាហ្នឹងសុំធ្វើសុំឲ្យធ្វើការស្រាវជ្រាវក្រ សួងមហាផ្ទៃ អគ្គនគរបាលជាតិ សហការគ្នាជាមួយខេត្ត ចុះធ្វើការស្រាវជ្រាវឲ្យខ្ញុំ ហើយរាយការណ៍មកឲ្យខ្ញុំវិញ។ ឯកឧត្តម នេត សាវឿន ឯកឧត្តម ងួន រតនៈ ធ្វើការស្រាវជ្រាវករណីនេះ នៅមាត់ច្រកឡែម"។ សម្តេចតេជោ ហ៊ុន សែន បន្តថា"កុំសួរថាឯកសានេះបានមកពីណាខ្ញុំធ្វើមេដឹកនាំមិនមែនចេះតែលួង់នោះទេ ឥឡូវសុំធ្វើការស្រាវជ្រាវឲ្យខ្ញុំ ហើយខ្ញុំបញ្ចូលទៅក្នុងគ្រុបតែម្តង ដើម្បីឲ្យឃើញទាំងអស់គ្នាតែម្តងអំពីរូបភាព ដាក់ទាំងមេខ្យល់ ដាក់ទាំងស្ទី ហើយមានរូបភាពទាក់ទិនជាមួយនឹងការដោះលែង ខាងទាហានអ្នកចាប់ ខាងប៉ូលីសអ្នកដោះលែង"។

សម្តេចបញ្ជាក់ថា ប្រសិនបើរឿងនេះពិត គឺត្រូវតែវាយខ្ទោះតែម្តងទៅដើម្បីយកជាគំរូ កុំឲ្យករណីមេខ្យល់ចេះតែកើតឡើងដដែលៗ។ សម្តេចតេជោ លើកឡើបញ្ជាក់ថា "ករណីនេះគឺត្រូវតែដាច់ខាតតែម្តង ពីព្រោះរឿងនេះខ្ញុំត្រូវតែធ្វើការស្រាវជ្រាវហើយ ហើយឯកឧត្តម វង្ស ពិសេន ហ៊ុន ម៉ាណែត ធ្វើកិច្ចការងារនេះ ពង្រឹងសមត្ថភាពកងទ័ព ហើយប្រសិនបើប៉ូលិសដោះលែង កងទ័ពត្រូវតែចាប់មកវិញភ្លាម មើលលេងឲ្យណាណីទៅមើល កងទ័ពត្រូវចាប់មកឲ្យប៉ូលីស ប៉ូលិសដោះលែង យើងចាប់មកវិញទៀតមើល ហើយបញ្ជូនមកឲ្យខាងលើ លេងអីចឹងម្តងមើលទាំងអាវុធហត្ថ"។

សម្តេចតេជោ ហ៊ុន សែន ក៏បង្គាប់ឲ្យ លោក វង្ស ពិសេន អគ្គមេបញ្ជាការនៃកងយុទ្ធពលខេមរភូមិន្ទ លោក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ កងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ លោក សៅ សុខា ត្រូវពង្រឹងកងទ័ព ដើម្បីអនុវត្តវត្តវិធានការទាំងឡាយ ហើយមើលមេប៉ូលិស ដែលពុករលួយនោះ នេត សាវឿន មើលឱ្យច្បាស់ អាហ្នឹងតាមបណ្តាច្រក។ សម្តេចតេជោ ក៏បង្គាប់ឲ្យ អភិបាលខេត្តទាំងឡាយត្រូវទទួល ខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី ហើយថារឿងនេះ មិនបានទេ គ្រោះថ្នាក់ វាជាឯកសារមួយច្បាស់ ហើយមានរូបថត ហើយមានថ្ងៃខែលើរូបថតទៀត អំពីការដែលចាប់បានមេរត់ពន្ធនាំមនុស្សឆ្លងដែន ហើយបែរជាដោះលែងត្រឡប់ទៅវិញនេះគឺមានភស្តុតាងនៅក្នុងហ្នឹង៕ **អត្ថបទ៖ កោះកែវ**

## សម្តេចតេជោ ហ៊ុន សែន បញ្ជាឲ្យបកស័ក្តិអធិការនគរបាលស្រុកកំរៀងនិងចាត់ការតាមផ្លូវច្បាប់រឿងដោះលែងមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់

https://www.rasmeinews.com/ 15 February, 2021

ដោយៈ មុនីវ័ត្ន/ភ្នំពេញៈសម្តេចនាយករដ្ឋមន្ត្រីបានចេញបទបញ្ជាឲ្យបកស័ក្តិ និងបណ្តាញលោក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង ខេត្តបាត់ដំបង ចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ និងចាត់ការតាមផ្លូវច្បាប់ដើម្បីផ្តន្ទាទោសជនពុករលួយរូបនេះ ដាក់ពន្ធនាគារឲ្យខានតែបាន ដើម្បីជាការព្រមានដល់ជនទាំងឡាយផ្សេងទៀត កុំឲ្យប្រព្រឹត្តទង្វើបែបនេះ។ ការបញ្ជារបស់សម្តេចតេជោ ហ៊ុន សែន បានធ្វើឡើងនៅរសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២១ នេះ។ លោក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង ពាក់ព័ន្ធករណីដោះលែងមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់ពីប្រទេសថៃ ចូលទឹកដីកម្ពុជា។

នេះបើយោងតាមប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ថ្លែងប្រាប់លោក លឹម ជាវុត្ថា អគ្គនាយកបណ្តាញព័ត៌មាន Fresh News នៅមុននេះបន្តិច នារសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នា២០២១។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ថា ក្រៅពីបកស័ក្តិ និងបណ្តេញចេញពីក្របខណ្ឌ បានបញ្ជាឲ្យអភិបាលខេត្ត និងអគ្គស្នងការនគរបាលជាតិ ត្រូវបន្តចាត់ការអនុវត្តតាមផ្លូវច្បាប់ទៀត ដើម្បីផ្តន្ទាទោសជនពុករលួយរូបនេះ ដាក់ពន្ធនាគារឲ្យខានតែបាន ដើម្បីជាការព្រមានដល់ជនទាំងឡាយផ្សេងទៀត កុំឲ្យប្រព្រឹត្តទង្វើបែបនេះ។ សម្តេចតេជោបានបញ្ជាឲ្យអគ្គស្នងការនគរបាលជាតិ ស្រាវជ្រាវជាបន្ទាន់រឿងមន្ត្រីប៉ូលិសនៅច្រកឡែម ដែលចាប់បានមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ ដែលមេខ្យល់នោះត្រូវបានទាហានចាប់ខ្លួនបាន

ប្រគល់ឲ្យខាងប៉ូលិស ហើយខាងប៉ូលិសជាអ្នកដោះលែងមេខ្យល់នោះ ដោយមិនបញ្ជូនទៅតុលាការ ដើម្បីអនុវត្តច្បាប់។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំបានទទួលបានឯកសារស្រាវជ្រាវខ្លះ គឺលោកស័ក្តិ ៥ ម្នាក់ គឺដោះលែង (មេខ្យល់) មានរូបថតមួយចំនួននៅទីនេះ ស្រាវជ្រាវបន្ទាន់ជាមួយកិច្ចការដែលបានកើតឡើងនៅក្នុងខែមករា ចាប់បានមេខ្យល់ហើយ គឺអត់ទាន់ផ្តន្ទាទោសទេ ទាហានអ្នកចាប់ ប៉ូលិសអ្នកដោះលែង អីចឹងបើរឿងនឹងវាជារឿងពិត ចាំបាច់ត្រូវតែដាក់ពិន័យ ឬក៏ផ្តន្ទាទោសតែម្តង សូមឲ្យធ្វើការស្រាវជ្រាវក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិចុះទៅរួមជាមួយនឹងខេត្ត ដើម្បីធ្វើការស្រាវជ្រាវករណីមួយនេះឲ្យខ្ញុំ ហើយរាយការណ៍ឲ្យខ្ញុំវិញ ឯកឧត្តម នេត សាវឿន ឯកឧត្តម ង៉ួន រតនៈ ធ្វើការងារស្រាវជ្រាវរឿងនេះនៅមាត់ច្រកឡែម ទាក់ទងជាមួយនិងការដោះលែងមេខ្យល់ ខាងទាហានអ្នកចាប់ ខាងប៉ូលិសដោះលែង ចឹងបានជាមេខ្យល់វាមិនអស់ មនុស្សចេះតែធ្លាយមក ចឹងទេមើលប៉ូលិសមួយនឹងមើល បើត្រូវរ៉ៃខ្មោះ រ៉ៃខ្មោះតែម្តង ឲ្យតែរឿងនឹងពិតដាក់ជាគំរូ ត្រូវធ្វើរឿងនឹងឲ្យបានដាច់ខាតព្រោះរឿងនេះត្រូវតែស្រាវជ្រាវហើយ"។

ជាមួយគ្នានេះ សម្តេចតេជោ ហ៊ុន សែន សូមឲ្យនាយឧត្តមសេនីយ៍ វង្ស ពិសេស អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត ធ្វើកិច្ចការងារនេះពង្រឹងសមត្ថភាពកងទ័ពដោយសម្តេចបានលើកឡើងថា បើករណីប៉ូលិសដោះលែង កងទ័ពត្រូវតែចាប់ភ្លាម។ "គេចាប់យកមកឲ្យប៉ូលិស ប៉ូលិសដោះលែងចាប់យកវិញទៀត។ វង្ស ពិសេស សៅ សុខា ម៉ាណែត ពង្រាយកងទ័ពដាក់ដើម្បីអនុវត្តនូវវិធានការទាំងឡាយ ហើយមើលមេប៉ូលិសៗ ដែលពុករលួយ នេត សាវឿន មើលឲ្យច្បាស់អាហ្នឹង ហើយតាមបណ្តាច្រកអភិបាលខេត្តទាំងឡាយ ត្រូវទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី រឿងនឹងអត់បានទេគ្រោះថ្នាក់"។

ទាក់ទងករណីនេះ លោកកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានសម្រេចផ្អាកការងារជាបណ្តោះអាសន្ន ចំពោះលោកវរសេនីយ៍ឯក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង ដោយមូលហេតុ «អនុវត្តការងារខុសនីតិវិធី»៕សរន

## រាជរដ្ឋាភិបាលចេញអនុក្រឹត្យ ដកស័ក្តិ និងបណ្តេញអធិការស្រុកកំរៀង ខេត្តបាត់ដំបង ចេញពីក្របខណ្ឌនគរបាល រឿងដោះលែងមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2021-02-15 09:17pm

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា នៅយប់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ បានចេញអនុក្រឹត្យសម្រេចដកស័ក្តិ និងបណ្តេញលោកវរសេនីយ៍ឯក គឹម ពន្លក អធិការស្រុកកំរៀង ខេត្តបាត់ដំបង ចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ។ នេះបើយោងតាមអនុក្រឹត្យដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅមុនបន្តិច។ ការចេញអនុក្រឹត្យសម្រេចដកស័ក្តិ និងបណ្តេញលោកវរសេនីយ៍ឯក គឹម ពន្លក អធិការស្រុកកំរៀង ខេត្តបាត់ដំបង ចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ធ្វើឡើងបន្ទាប់ពីមានបញ្ជារបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅរសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ បន្ទាប់ពីក្រុមស្រាវជ្រាវរកឃើញថា អធិការស្រុករូបនេះ ពិតជាបានដោះលែងមេខ្យល់នាំមនុស្សឆ្លងដែនខុសច្បាប់ ពីប្រទេសថៃចូលទឹកដីកម្ពុជា។

បើយោងតាមប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ថ្លែងប្រាប់លោក លឹម ជាវុត្ថា អគ្គនាយកបណ្តាញព័ត៌មាន Fresh News នារសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១, ក្រៅពីបកស័ក្តិ និងបណ្តេញចេញពីក្របខណ្ឌសម្តេចបានបញ្ជាឲ្យអភិបាលខេត្ត និងអគ្គស្នងការនគរបាលជាតិ ត្រូវបន្តចាត់ការអនុវត្តតាមផ្លូវច្បាប់ទៀត ដើម្បីផ្តន្ទាទោសជនពុករលួយរូបនេះ ដាក់ពន្ធនាគារឲ្យខាងតែបាន ដើម្បីជាការព្រមានដល់ជនទាំងឡាយផ្សេងទៀត កុំឲ្យប្រព្រឹត្តទង្វើបែបនេះ។ ព័ត៌មានដែលបណ្តាញព័ត៌មាន Fresh News ទទួលបានឲ្យដឹងថា លោកវរសេនីយ៍ឯក គឹម

ពន្លក បានទទួលស្គាល់ថា ខ្លួនពិតជាបានទទួលមុខសញ្ញាមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់ពីកម្លាំងវរៈការពារព្រំដែន-៨១៩ ករណីទីមួយគឺមុខសញ្ញាផ្តល់ជំរកស្នាក់នៅដល់ពលករ ដើម្បីត្រៀមឆ្លងដែនខុសច្បាប់ពីកម្ពុជាទៅថៃ និងករណីទីពីរគឺមុខសញ្ញាពាក់ព័ន្ធនាំពលករឆ្លងដែនខុសច្បាប់ពីថៃចូលកម្ពុជាគេចពីការធ្វើចត្តាឡីស័កប្រាកដមែន។ សូមជំរាបថា នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានចេញសេចក្តីសម្រេចផ្អាកការងារបណ្តោះអាសន្នចំពោះ លោកវរសេនីយ៍ឯក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង៕

## ឃាត់ខ្លួន ពលករខ្មែរ ៧នាក់ លួចឆ្លងដែនខុសច្បាប់ ពីប្រទេសថៃ និងប្រុងគេចខ្លួន ពីការធ្វើចត្តាឡីស័ក

https://dap-news.com/national/ ByPH104Posted on February 15, 2021

**ភ្នំពេញ ៖ កម្លាំងការិយាល័យ នគរបាលចរាចរណ៍ផ្លូវគោក ខេត្តបាត់ដំបង សហការជាមួយកម្លាំងជំនាញពាក់ព័ន្ធក្នុងស្រុកសំពៅលូន បានធ្វើការស្ទាក់ចាប់បាន រថយន្តហាយឡេនឌ័រ មួយគ្រឿង ដឹកពលករខ្មែរ៧នាក់ ដែលទើបលួចធ្វើដំណើរកាត់ព្រៃ ឆ្លងដែនពីប្រទេថៃ និងប្រុងគេចខ្លួន ពីការធ្វើចត្តាឡីស័ក ។**

សេចក្តីរាយការណ៍បានឲ្យដឹងថា កិច្ចប្រតិបត្តិការខាងលើនេះ ធ្វើឡើងកាលពីព្រឹកនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅចំណុចភូមិ តាស្តា ឃុំតាស្តា ស្រុកសំពៅលូន ខណៈដែល កម្លាំងសមត្ថកិច្ច កំពុងឈរជើងល្បាត និងដាក់ការត្រួតពិនិត្យ នៅក្នុងភូមិសាស្រ្តខាងលើ ។ ហើយរថយន្ត មួយគ្រឿង ដែលត្រូវបានសមត្ថកិច្ច ឃាត់បាន ម៉ាកហាយលែនឌ័រ ពណ៌ ទឹកប្រាក់ ពាក់ស្លាកលេខ ភ្នំពេញ 2AC 3654 ជាមួយនឹងពលករខ្មែរ ចំនួន៧នាក់ និង អ្នកបើកបរ១នាក់ក្រោយពីពួកគេលួចធ្វើដំណើរកាត់ព្រៃឆ្លងដែនមកពីប្រទេសថៃទាំងអស់ដោយពុំបានធ្វើចិត្តាឡីស័ក។ បន្ទាប់ពីឃាត់សួរនាំរួច ពលករខ្មែរ ទាំង៧នាក់ និងតៃកុងឡានម្នាក់ ត្រូវបានបញ្ជូនទៅទីតាំងធ្វើចត្តាឡីស័ក ៕

## ល្បិចថ្មី ! ចាប់រថយន្តដឹកផ្លែឈើ លួចបង្កប់ពលករពីខាងក្នុង គេចមិនព្រមធ្វើចត្តាឡីស័ក

https://www.rasmeinews.com/ 15 February, 2021

**ដោយៈ មុនីរ័ត្ន / ភ្នំពេញៈ** *សមត្ថកិច្ច បានឃាត់ត្រួតពិនិត្យរថយន្តយីឌុប ដឹកផ្លែឈើ ពីប្រទេសថៃ ចូលមកកម្ពុជា ដោយបានលួចបង្កប់ពលករខ្មែរ ចំនួន ៣ នាក់។ ការបង្កប់ពលករ នៅក្នុងរថយន្តដឹកផ្លែឈើនេះ គឺដើម្បីគេចវេះ មិនធ្វើចត្តាឡីស័ក។ ការត្រួតពិនិត្យ លើរថយន្តដឹកផ្លែឈើនេះ បានធ្វើឡើង នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នេះ។*

យោងសេចក្តីរាយការណ៍ ពីសមត្ថកិច្ច បានប្រាប់គេហទំព័រ រស្មីកម្ពុជា ឲ្យដឹងថាៈ នៅថ្ងៃទី១៥ ខែកុម្ភៈ នេះ កម្លាំងយោធភូមិភាគទី៥ កងពលតូចថ្មើរជើងលេខ ៥៣ ប្រចាំនៅច្រកទ្វារព្រំដែនអន្តរជាតិដូង ស្ថិតក្នុងស្រុកកំរៀង ខេត្តបាត់ដំបង បានធ្វើការត្រួតពិនិត្យ រថយន្តយីឌុបមួយគ្រឿង ដែលដឹកផ្លែឈើ ចូលទៅថៃ នៅពេលត្រឡប់ចូលកម្ពុជាវិញ បានលួចបង្កប់ពលករ ចំនួន ៣ នាក់ ហើយត្រូវបានឃាត់ខ្លួន យកទៅធ្វើចត្តាឡីស័ក។ ចំណែកអ្នកបើករថយន្ត បាននាំខ្លួនយកទៅអនុវត្ត តាមនីតិវិធីច្បាប់។ រថយន្តដឹកផ្លែឈើ ដែលលួចបង្កប់ពលករ ពាក់ស្លាកលេខត្បូងឃ្មុំ ៣A-០៥៤៩ ។ ប្រភពដដែល បានបន្តថាៈ សរុបនៅថ្ងៃទី១៥ ខែកុម្ភៈ នេះ សមត្ថកិច្ច បានត្រួតពិនិត្យរកឃើញពលករ ចំនួន ១០ នាក់ ឆ្លងដែនមកពីថៃ ដោយក្នុងនោះ ឃាត់ខ្លួនមេខ្យល់ បានម្នាក់ផងដែរ។

ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នេះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងមួយ ស្តីពីការផាកពិន័យ លើពលករខ្មែរ ដែលគេចវេះ មិនធ្វើចត្តាឡីស័កត្រឹមត្រូវ តាមវិធានការសុខាភិបាល ថានឹងត្រូវទទួលរងការផាកពិន័យ ចំនួន ១.០០០.០០០ រៀល ឬច្រើនជាងនេះ និងទទួលទោសព្រហ្មទណ្ឌ ដូចមានចែង នៅក្នុងច្បាប់ និងបទប្បញ្ញត្តិ ព្រហ្មទណ្ឌ ជាធរមាន៕/V

## ផែកផេរថយន្តដឹកទំនិញគ្រប់ប្រភេទ ចៀសវាងការបន្លំលាក់ខ្លួនពលករចេញពីប្រទេសថៃ ដោយសហការជាមួយប៉ូលិសចរាចរណ៍

https://www.rasmeinews.com/ 15 February, 2021

**ដោយ: គ្រញូង / បាត់ដំបង:** *នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី អូន សុខសិលា នាយសេនាធិការរងទទួលបន្ទុកការងារព្រំដែន និងសហការី បានចុះត្រួតពិនិត្យច្រកអន្តរជាតិដូង, ច្រកចាន់គីរី និងច្រកតំបន់ អូរអន្លក់ស្ថិតក្នុងភូមិសាស្ត្រស្រុកកំរៀង ខេត្តបាត់ដំបង។* លោកឧត្តមសេនីយ៍ត្រី អូន សុខសិលាបានធ្វើការណែនាំដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជាថៃត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ ដោយសហការអនុវត្តឱ្យបានម៉ឺងម៉ាត់ទប់ស្កាត់ការលបលួចចូលតាមច្រកព្រំដែន ចំពោះពលករខ្មែរឆ្លងពីប្រទេថៃ ចូលមកប្រទេសកម្ពុជាដោយអនុវត្តតាមវិធានការសុខាភិបាល គឺត្រូវតែបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ករយៈពេល និងជាពិសេសត្រូវថែរក្សាសុខភាពកងកម្លាំង ព្រមទាំងត្រូវរឹតបន្តឹងការឆែកឆេរថយន្តដឹកទំនិញគ្រប់ប្រភេទ ចៀសវាងការបន្លំលួចលាក់ខ្លួនពលករចេញពីប្រទេសថៃនូវគ្រប់រូបភាព ដោយសហការជាមួយប៉ូលិសចរាចរណ៍ផ្លូវគោកគ្រប់ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ ដើម្បីធ្វើការឆែកឆេរកពលករដែលធ្វើដំណើរចូលពីប្រទេសថៃមកស្រុកកំណើតមុនបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរនាពេលខាងមុខនេះ៕

## ក្រសួងការងារនិងស្ថានទូតខ្មែរព្រមានពលករមកថៃថានឹងត្រូវអស់លុយ១លានរៀល បើហ៊ានគេចវេះពីការធ្វើចត្តាឡីស័ក

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 15/02/2021 - 12:22

ក្រសួងការងារ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃនៅរសៀលថ្ងៃចន្ទនេះ បានចេញមកព្រមានដល់ពលករខ្មែរដែលធ្វើដំណើរមកពីប្រទេសថៃថា មិនត្រូវលួចឆ្លងដែនដោយខុសច្បាប់ និង គេចវេះពីការធ្វើចត្តាឡីស័កតាមការណែនាំរបស់ក្រសួងសុខាភិបាលកម្ពុជាឡើយ។ ក្រសួងការងារ និងស្ថានទូតកម្ពុជាព្រមានទៀតថា បើសិនពួកគេហ៊ានបំពាន នោះនឹងត្រូវរងការពិន័យ១លានរៀលតាមច្បាប់របស់កម្ពុជា។ ការព្រមានទាំងនេះ ធ្វើឡើងភ្លាមៗបន្ទាប់ពីលោកនាយករដ្ឋមន្ត្រីហ៊ុន សែន នៅព្រឹកមិញនេះ បានបង្ហាញពីបំណងចង់ឱ្យមានចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានតឹងរឹងបន្ថែមទៀតលើអ្នកដែលគេចវេសមិនព្រមធ្វើចត្តាឡីស័ក។

តាមរយៈសេចក្តីប្រកាសព័ត៌មានពីរដាច់ដោយឡែកពីគ្នាប៉ុន្តែក្នុងន័យតែមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ បានអះអាងប្រាប់ដល់ក្រុមពលករខ្មែរថា មិនត្រូវលួចឆ្លងដែនខុសច្បាប់ចូលមកប្រទេសកម្ពុជាដែលអាចមានហានិភ័យខ្ពស់ចំពោះ អាយុជីវិតផ្ទាល់ខ្លួន និងការនាំជំងឺឆ្លងចូលមកប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះ ពួកគេត្រូវអនុវត្តការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវតាមវិធានសុខាភិបាលដោយមិនត្រូវគេចវេះជាដាច់ខាត។ ក្រសួងការងារ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃបានព្រមានថា ក្នុងករណីដែលពួកគេហ៊ានគេចវេះមិនធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវទេនោះ នឹងត្រូវទទួលរងការផាកពិន័យ១លានរៀល ឬច្រើនជាងនេះនិងទទួលទោសព្រហ្មទណ្ឌថែមទៀត។

ជាមួយគ្នានេះ ក្រសួងការងារ និងស្ថានទូតកម្ពុជាក៏បានប្រាប់ពលករខ្មែរនៅថៃដែរថា ត្រូវសហការផ្តល់ព័ត៌មានដល់ស្ថានទូត ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងមេខ្យល់ដែលសន្យានាំពួកគេឆ្លងដែនចេញ-ចូលដោយខុសច្បាប់មកកាន់ប្រទេសកម្ពុជា។ ចំណែកស្ថានទូតកម្ពុជាបានប្រាប់បន្ថែមថា ពលករខ្មែរត្រូវគោរពអនុវត្ត និងចូលរួមសហការឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានារបស់រដ្ឋាភិបាលថៃដែលបានដាក់ចេញ ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩។ ដោយឡែក ក្រសួងសុខាភិបាលកម្ពុជាវិញ ក៏បានក្រើនរំលឹកពីបញ្ហាផាកពិន័យនេះដល់អភិបាលរាជធានី-ខេត្តទាំង

អស់នៅកម្ពុជា។ ក្រសួងសុខាភិបាលបានប្រាប់ដល់អភិបាលរាជធានី-ខេត្តទាំងអស់ឱ្យអនុវត្តនូវការផាកពិន័យនេះ ដែលតាមច្បាប់ គឺចន្លោះពី២០ម៉ឺនរៀល ទៅ១លានរៀលចំពោះអ្នកដែលគេសវេះពីការធ្វើចត្តាឡីស័ក។ ក៏ប៉ុន្តែ ការផាកពិន័យនេះ បើប្រៀបធៀបទៅនឹងប្រទេសក្បែរខាងកម្ពុជាវិញ គឺនៅកម្រិតមួយទាបខ្លាំងណាស់។

ជាក់ស្តែង នៅប្រទេសវៀតណាម រដ្ឋាភិបាលវៀតណាមបានកំណត់ថា ប្រសិនបើអ្នករត់ចេញ ឬខកខានមិនបានធ្វើចត្តាឡីស័ក គឺនឹងត្រូវពិន័យជាទឹកប្រាក់២០លានដុងឬប្រហែលជាង៨០០ដុល្លារអាមេរិក និងអនុវត្តទោសព្រហ្មទណ្ឌបើសិនបានចម្លងមេរោគកូវីដ១៩ទៅអ្នកដទៃ។ នេះបើតាមការបញ្ជាក់ឱ្យដឹងរបស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសវៀតណាម។ បើតាមស្ថានទូតកម្ពុជា នៅវៀតណាម អ្នករំលោភវិធានការពារជំងឺកូវីដ១៩ អាចប្រឈមការជាប់គុក១២ឆ្នាំ ឯអ្នកមិនធ្វើសេចក្តីប្រកាសសុខភាព ឬប្រកាសក្លែងក្លាយនឹងត្រូវពិន័យដល់ទៅ១០០លានដុងឬប្រមាណជាង៤ពាន់ដុល្លារអាមេរិក ខណៈអ្នកមិនពាក់ម៉ាសនៅកន្លែងសាធារណៈនឹងត្រូវពិន័យ៣លានដុងឬ១៣០ដុល្លារអាមេរិក៕

## ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

## ហាមមន្ត្រីនគរបាលទាំងអស់ យកតម្រាប់តាមគំរូអធិការស្រុកកំរៀង រឿងដោះលែងមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ឥឡូវនេះអធិការស្រុកកំរៀងរូបនោះ ត្រូវបានដកហូតឋានន្តរស័ក្តិ និងបណ្តេញចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

http://www.arey-news.com/ (ថ្ងៃទី 16 February 2021 ម៉ោង 2:09 pm)

**ភ្នំពេញ:** ប្រសាសន៍របស់ សម្តេចក្រឡាហោម ស ខេង បានធ្វើឡើងក្នុងពិធីប្រគល់រថយន្តជូនស្នងការដ្ឋាននគរបាលខេត្ត ចំនួន ១៩ ខេត្ត នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ នៅទីស្តីការក្រសួងមហាផ្ទៃ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បានប្រាប់ទៅស្នងការនគរបាល រាជធានី ខេត្ត រួមទាំង មន្ត្រីនគរបាលដែលពាក់ព័ន្ធ ដោយហាមយកតម្រាប់តាមគំរូ អធិការស្រុកកំរៀង ខេត្តបាត់ដំបងដែលពាក់ព័ន្ធ ក្នុងរឿងដោះលែងមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ដែលឥឡូវនេះអធិការស្រុកកំរៀង រូបនោះ ត្រូវបានដកហូតឋានន្តរស័ក្តិ និងបណ្តេញចេញពីក្របខណ្ឌមន្ត្រីនគរបាល ជាតិកម្ពុជា។ បទពិសោធន៍ អធិការស្រុកកំរៀង ខេត្តបាត់ដំបង គឺជាបទពិសោធន៍មួយ ធ្វើការរំលោភវិជ្ជាជីវៈ រំលោភលើ ឋានានុក្រម ដោយមិនខ្វីរាយការណ៍ ឲ្យថ្នាក់លើបានដឹង គឺខុស។ នេះជាបទពិសោធន៍ដែលត្រូវសិក្សា រៀនសូត្រ ហើយក៏ដូចជា កញ្ចក់សម្រាប់យើង ទាំងអស់គ្នាផងដែរ។ " បទពិសោធន៍អធិការស្រុកកំរៀង ជាបទពិសោធន៍មួយ យើងឃើញថា គាត់ធ្វើការរំលោភវិជ្ជាជីវៈ រំលោភលើឋានានុក្រម ដោយគាត់មិនខ្វីរាយការណ៍ ឲ្យអ្នកណាទេ គាត់សប្បាយខ្លួនគាត់ អាហ្នឹងខុសជាបទពិសោធន៍មួយដែលយើងទាំងអស់គ្នា ត្រូវសិក្សារៀនសូត្រ ហើយក៏ដូចជាកញ្ចក់ សម្រាប់យើងទាំងអស់គ្នាទេ"។

ទាក់ទងករណីអធិការនគរបាលស្រុកកំរៀង ដែលបានដោះលែង មេខ្លោងនាំពលករឆ្លងដែន ដោយខុសច្បាប់ គឺសមត្ថកិច្ចកំពុងតែធ្វើការស្រាវជ្រាវបន្ថែមទៀត ដើម្បីរកអ្នកដែលពាក់ព័ន្ធ ហើយករណីនេះមិនទាន់រកឃើញមានភស្តុតាង ណាមួយ ដែលត្រូវបញ្ជូនទៅតុលាការ នៅឡើយទេ។ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា ក្រសួងមហាផ្ទៃ បន្តធ្វើកំណែទម្រង់ នគរបាល ដោយនាពេលកន្លងមកនេះ បានធ្វើកំណែទម្រង់ ជាបន្តបន្ទាប់ រួចមកហើយ ប៉ុន្តែការកែទម្រង់មិនចេះចប់ទេ ដោយត្រូវធ្វើសារចុះ សារឡើង ហើយការកែទម្រង់ គឺអត់មានទីបញ្ចប់ទេ។ សម្តេចក្រឡាហោម បានបន្តថា ការធ្វើការរបស់មន្ត្រីនគរបាល គឺក្នុងវិជ្ជាជីវៈដោយមិន លំអៀង មនោសញ្ចេតនា ឬមួយក៏ រំលោភលើតួនាទី សិទ្ធិអំណាចរបស់ខ្លួនវាជាការ សំខាន់ណាស់ ដើម្បីតម្រង់ទិសឲ្យនគរបាលឲ្យធ្វើការដោយវិជ្ជាជីវៈវៈ ច្បាស់លាស់ ស្មោះត្រង់នឹងការងារ ដើម្បីមានយុត្តិធម៌សង្គម កសាងយុត្តិធម៌សង្គម។

សូមជម្រាបថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ បានចេញអនុក្រឹត្យ ដកហ៊ានន្តរស័ក្តិ និងបណ្តេញចេញ ពីក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ចំពោះវរសេនីយ៍ឯក គឹម ពន្លក នគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។ ទាក់ទងករណីនេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញអនុក្រឹត្យបកស័ក្តិ និងបណ្តាញលោក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង ខេត្តបាត់ដំបងចេញពីក្របខណ្ឌ មន្ត្រីនគរបាលជាតិ និងចាត់ការតាមផ្លូវច្បាប់ ដើម្បីផ្តន្ទាទោស ជនពុករលួយរូបនេះ ដាក់ពន្ធនាគារ ឲ្យខានតែបាន ដើម្បីជាការព្រមាន ដល់ជនទាំងឡាយ ផ្សេងទៀត កុំឲ្យប្រព្រឹត្តទង្វើបែបនេះ។ ការបញ្ជារបស់ សម្តេចតេជោ ហ៊ុន សែន បានធ្វើឡើង នៅរសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២១ នេះ។ លោក គឹម ពន្លក អធិការនគរបាលស្រុកកំរៀង ពាក់ព័ន្ធករណីដោះលែងមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់ពីប្រទេសថៃ ចូលទឹកដីកម្ពុជា។ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឲ្យអគ្គស្នងការនគរបាលជាតិ ស្រាវជ្រាវជាបន្ទាន់ រឿងមន្ត្រីប៉ូលិសនៅច្រកឡែម ដែលចាប់បានមេខ្យល់ នាំពលករឆ្លងដែន ខុសច្បាប់ ចូលក្នុងប្រទេសថៃ ដែលមេខ្យល់នោះ ត្រូវបានទាហាន ចាប់ខ្លួនបានប្រគល់ឲ្យ ខាងប៉ូលិស ហើយខាងប៉ូលិស ជាអ្នកដោះលែងមេខ្យល់នោះ ដោយមិនបញ្ជូនទៅតុលាការ ដើម្បីអនុវត្តច្បាប់៕

## រដ្ឋមន្ត្រីសុខាភិបាល បានអំពាវនាវពលករធ្វើការនៅប្រទេសថៃ កុំទាន់សម្រុកមកស្រុក ដើម្បីចូលរួមទប់ស្កាត់ ការឆ្លងកូវីដ-១៩ចូលសហគមន៍

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១

បាត់ដំបង ៖ ក្នុងឱកាសចុះពិនិត្យស្ថានភាព និងផ្សព្វផ្សាយពីបញ្ហាកូវីដ-១៩ ដល់ពលករកំពុងធ្វើចត្តាឡីស័ក តាមបណ្តាខេត្ត ជាប់ព្រំដែនភាគពាយ័ព្យនៃប្រទេសកម្ពុជា នៅរសៀលថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួង សុខាភិបាល បានអំពាវនាវដល់ពលករខ្មែរទាំងអស់ដែលធ្វើការនៅប្រទេសថៃ សូមកុំទាន់អាលវិល មកស្រុកកំណើតវិញ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ។ ឯកឧត្តមបញ្ជាក់ថា បងប្អូនពលករគួរតែនៅបន្តធ្វើការនៅទីនោះសិន ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលសហគមន៍ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ឯកឧត្តមរដ្ឋមន្ត្រីមានប្រសាសន៍បន្តថា ក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩ ពលរដ្ឋគួរស្វែងរកការងារធ្វើក្នុងស្រុកយើងឲ្យអស់ លទ្ធភាពសិន មុននឹងធ្វើការចំណាកស្រុកទៅក្រៅប្រទេស ដើម្បីចៀសវាងការឆ្លងរីករាលដាលនៃជំងឺនេះ ព្រោះរាជរដ្ឋាភិបាល តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានរៀបចំនូវការងារនិងបង្រៀនជំនាញខ្លីៗ ដល់ពលករ ដែលបាន បាត់បង់ការងារធ្វើផងដែរ។

ឯកឧត្តម បានបន្តថា ចំពោះអ្នកមានជីស្រែចម្ការ គួរបង្កបង្កើនផលតាមលទ្ធភាពរបស់ខ្លួន កុំចេញចូលឆ្លងដែនទៅប្រទេសថៃ ព្រោះប្រទេសមួយនេះ កំពុងឆ្លងខ្លាំងនៅក្នុងសហគមន៍ តាមខេត្តមួយចំនួន នៃជំងឺកូវីដ-១៩ ហើយសម្រាប់អ្នកចង់មកលេង ស្រុកកំណើត នាឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខាងមុខ បើគ្រាន់ចង់លេងសប្បាយជួបជុំគ្រួសារក្នុងពិធីបុណ្យប៉ុណ្ណោះទេ គួរតែកុំទាន់មកលេងអី ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនូវជំងឺកូវីដ-១៩នេះ ។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រី បានស្នើដល់អាជ្ញាធរខេត្តជាប់ព្រំដែន បន្តជួយចាត់វិធានការឲ្យបានតឹងរ៉ឹង នូវពួកមេខ្យល់ ដែលលួចនាំពលករឆ្លងដែនខុសច្បាប់ ហើយគេចវេះពីការធ្វើចត្តាឡីស័ក ដោយឯកឧត្តម បានអំពាវនាវដល់ពលរដ្ឋ បន្តអនុវត្តវិធានការអនាម័យ តាមការណែនាំរបស់ក្រសួងសុខាភិបាល ខណៈកម្ពុជាមានអ្នកឆ្លងជំងឺកូវីដ-១៩ នៅសល់តិចតួច និងកំពុងគ្រប់គ្រងបាន ។ ចាប់ពីមានការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ខេត្តសាមុតសាខនប្រទេសថៃ មានពលករឆ្លងដែនតាមច្រក នានាជាប់ខេត្តបាត់ដំបង មានជាង ៧០០០នាក់ និង

បានបញ្ចប់ការធ្វើចត្តាឡីស័កជិត ៤០០០នាក់ កំពុងធ្វើចត្តាឡីស័កជាង ៣០០០នាក់ ខណៈនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករឆ្លងដែនពីថៃ មានជាង ៣០០នាក់ ៕

## សមត្ថកិច្ចខេត្តកោះកុង បើកប្រតិបត្តិការល្បាតលើផ្ទៃសមុទ្រ ស្វែងរកពលករដែលមកពីថៃ តាមផ្លូវទឹក

http://btv.com.kh/ 16/02/2021

កោះកុង ៖ លោក សំ ឃិតវៀន អភិបាលរងខេត្តកោះកុង និងលោក សុវណ្ណ ប៊ុនធឿន ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាមបានដឹកនាំកម្លាំងសមត្ថកិច្ចជំនាញបើកប្រតិបត្តិការស្បាតលើផ្ទៃសមុទ្រ កាលពីយប់ថ្ងៃទី១៥ ខែកុម្ភៈ ដើម្បីស្វែងរកមេខ្យល់ ដែលលួចដឹកពលករខ្មែរមកពីប្រទេសថៃ តាមផ្លូវទឹក។ ការប្រតិបត្តិការល្បាតលើផ្ទៃសមុទ្រ ពេញមួយយប់នេះ ពុំទាន់ប្រទះឃើញមុខសញ្ញាសង្ស័យណា មួយនោះទេ។ ត្បិតមិនទាន់ប្រទះឃើញពលករ ឬមេខ្យល់ ក៏ដោយ ក៏ប្រតិបត្តិការទប់ស្កាត់ពលករមកពីប្រទេសថៃ ដោយខុសច្បាប់នៅតែបន្តជានិច្ច តបតាមបទបញ្ជារបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន ក្រុមមេខ្យល់ បានប្រើប្រាស់ផ្លូវទឹក ដើម្បីដឹកជញ្ជូនពលករមកពីប្រទេសថៃ ដែលមានបំណងចង់គេសវេសការធ្វើចាត្តាឡីស័ក ។ រីឯច្រកព្រំដែនគោក គឺសមត្ថកិច្ចអាចគ្រប់គ្រងបានស្ទើរ តែ១០០ភាគរយហើយ ដោយប្រទះឃើញពលករខុសច្បាប់ ជាបន្តបន្ទាប់ និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក៕ អត្ថបទ៖ ឈឹម មករា

## អភិបាលខេត្តបាត់ដំបង មិនលើកលែង ឲ្យចំពោះបុគ្គលណា ពាក់ព័ន្ធជាមួយអធិការ ស្រុកកំរៀង

https://dap-news.com/ ByPH104 Posted on February 16, 2021

**ភ្នំពេញ ៖ លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានប្រកាសមិនលើកលែង ឲ្យអ្នកឃុបឃិត ជាមួយអធិការស្រុកកំរៀង ក្នុងករណីដោះលែងមេខ្យល់ នាំពលករខ្មែរ គេចវេះពីការធ្វើចត្តាឡីស័ក ។ នេះបើតាមការផ្សព្វផ្សាយ របស់រដ្ឋបាលខេត្តបាត់ដំបង ។** ក្នុងឱកាសដឹកនាំកិច្ចប្រជុំបន្ទាន់ ស្តីពីការទប់ស្កាត់ការគេចវេះ ធ្វើចត្តាឡីស័ករបស់ពលករ និងពិនិត្យសភាពការ នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង នៅរសៀលថ្ងៃ១៥ កុម្ភៈ លោក ងួន រតនៈ បានលើកឡើងថា នឹងមិនលើកលែង ចំពោះអ្នកពាក់ព័ន្ធឃុបឃិត នឹងអធិការស្រុកកំរៀង ដែលបានប្រព្រឹត្តខុសនីតិវិធី ដែលនាំពលករគេចវេសពីការធ្វើចត្តាឡីស័ក ។ ជាមួយគ្នានេះ អភិបាលខេត្ត ក៏បានចាត់វិធានការបន្ទាន់ ដើម្បីទប់ស្កាត់កុំឲ្យពលករគេចវេស ពីការធ្វើចត្តាឡីស័ក ហើយអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តវិធានការមួយចំនួនភ្លាមៗ ក្នុងនោះការរឹតបន្តឹង តាមចាប់ពួកមេខ្យល់នាំពលករ ឆ្លងដែនខុសច្បាប់ ការអប់រំផ្សព្វផ្សាយពីសារសំឡេង របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ពាក់ព័ន្ធនឹងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅតាមមូលដ្ឋាន នៅតាមមណ្ឌលចត្តាឡីស័កជាដើម ។

សូមបញ្ជាក់ថា នៅថ្ងៃ១៥ កុម្ភៈ បន្ទាប់ពីរកឃើញកំហុស របស់លោក គឹម ពន្លក អធិការស្រុកកំរៀង ប្រព្រឹត្តខុសនីតិវិធី ហ៊ានដោះលែងមេខ្យល់ដោយចិត្តឯង ដែលនាំពលករគេចវេស ពីការធ្វើចត្តាឡីស័ក តាមវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង បានផ្អាកការងារបណ្តោះអាសន្ន នូវអធិការស្រុកកំរៀងរូបនេះ ។ ក្រោយឃើញករណីនេះ សម្តេចតេជោបានប្រកាសដកតំណែង លោកអធិការស្រុករូបនេះភ្លាម ហើយសម្តេចក៏បានចេញ អនុក្រឹត្យបញ្ចប់មុខតំណែងផងដែរ។

គួររំលឹកថា ចាប់តាំងពីមានការផ្ទុះឆ្លងរីករាលដាលជំងឺកូវីដ១៩ ក្នុងសហគមន៍ខេត្តសាមុទសាខន ប្រទេសថៃ មានពលករឆ្លងដែនពីថៃ តាមច្រកនានាជាប់ខេត្តបាត់ដំបងជាង ៦០០០នាក់ ហើយបានបញ្ចប់ការធ្វើចត្តាឡី

ស័កជាង ៣០០០នាក់ និងកំពុងធ្វើចត្តាឡីស័កជាង ២០០០នាក់ ខណៈអាជ្ញាធរក៏បានឃាត់ខ្លួនមេខ្យល់ ដែលនាំពលករឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់ និងបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធីច្បាប់ និងបន្តស្វែងរកពួកមេខ្យល់មួយចំនួនទៀត ៕

## អាជ្ញាធរ និងសមត្ថកិច្ច ចុះពិនិត្យស្ថានភាពនៅច្រករបៀងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2021-02-16 03:41pm

**(បន្ទាយមានជ័យ)៖** សមត្ថកិច្ចចម្រុះ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ បានចុះពិនិត្យស្ថានភាពនៅច្រករបៀងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ និងរក្សាសន្តិសុខសណ្តាប់ធ្នាប់ផ្សេងៗ។ ប្រតិបត្តិការនេះដឹកនាំដោយលោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ និងលោក គាត ហ៊ុល អភិបាលក្រុងប៉ោយប៉ែត ព្រមទាំងកងកម្លាំងសមត្ថកិច្ចផងដែរ។ លោក ង៉ោ ម៉េងជ្រួន បានលើកឡើងថា អាជ្ញាធរខេត្ត បានដឹកនាំកងកម្លាំងសមត្ថកិច្ចចម្រុះថ្ងៃនេះ ក្នុងគោលបំណងរឹតបន្តឹងការងារសន្តិសុខ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាពិសេសនោះ គឺដើម្បីទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់ពីប្រទេសថៃ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានបញ្ជាឱ្យក្រសួងសុខាភិបាល និងមន្ត្រីពាក់ព័ន្ធទាំងអស់ ចាប់ផ្តើមអនុវត្តន៍វិធានការច្បាប់តាម «អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល» ឱ្យបានតឹងរឹងបំផុតចំពោះអ្នកព្យាយាមគេចវេសពីការធ្វើចត្តាឡីស័ក។ បទបញ្ជា និងការណែនាំដ៏ម៉ឺងម៉ាត់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានធ្វើឡើងតាមរយៈសារសំឡេងនៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១នេះ។ បទបញ្ជា និងការណែនាំនេះ បានធ្វើឡើងបន្ទាប់ពីពលករខ្មែរឆ្លង មកពីប្រទេសថៃមួយចំនួន បានព្យាយាមគេចវេសពីការធ្វើចត្តាឡីស័ក ដែលជាហានិភ័យដ៏ធ្ងន់ធ្ងរក្នុងការនាំជំងឺកូវីដ១៩ ចូលក្នុងសហគមន៍។ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ពលករឆ្លងពីថៃ ហើយចូលធ្វើចត្តាឡីស័កគិតត្រឹមយប់ថ្ងៃទី១៤ ខែកុម្ភៈ មានចំនួន ៣៥,៦៦៥នាក់។ ក្នុងនោះអ្នកកំពុងធ្វើចត្តាឡីស័កនៅតាមខេត្តជាប់ព្រំដែនទាំង ៧ មានចំនួន ១១,៨៥៧នាក់។ក្នុងចំណោមអ្នកឆ្លងដែនពីប្រទេសថៃនេះ រកឃើញអ្នកកើតជំងឺកូវីដ១៩ សរុប ៨៩ នាក់។ សម្រាប់អ្នកធ្វើចត្តាឡីស័កនេះ ក្នុងមួយថ្ងៃទទួលបានការឧបត្ថម្ភថវិកា ២ម៉ឺនរៀល ដោយមិនគិតពីការឧបត្ថម្ភទឹកបរិសុទ្ធ ឬមី ក៏ដូចជាសម្ភារប្រើប្រាស់ផ្សេងទៀតនោះឡើយ៕

## អភិបាលខេត្តបាត់ដំបង ព្រមានអ្នករត់តាក់ស៊ី កុំឲ្យលួចដឹក ពលករគេចវេះ ធ្វើចត្តាឡីស័ក

https://dap-news.com/ ByPH104 Posted on February 16, 2021

**ភ្នំពេញ ៖ លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានព្រមានដល់ ក្រុមអ្នករត់តាក់ស៊ី ទាំងអស់កុំលួចលាក់ ដឹកពលករគេចវេះ ពីមណ្ឌលចត្តាឡីស័ក ហើយប្រសិនរកឃើញ នឹងអនុវត្តតាមនីតិវិធីច្បាប់ ដោយមិនលើកលែងឡើយ ។ នេះបើតាមការចុះផ្សាយ របស់រដ្ឋបាលខេត្ត។** លោក ងួន រតនៈបានថ្លែងបែបនេះ ក្នុងឱកាសជួបសំណេះសំណាល ជាក្រុមអ្នករត់តាក់ស៊ី នៅច្រកអន្តរជាតិដូង ស្រុកកំរៀងនៅព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ។ លោកបន្តថា ប្រសិនបើសមត្ថកិច្ចឃើញក្រុមអ្នករត់តាក់ស៊ី លួចដឹកពលករមិនឲ្យធ្វើចត្តាឡីស័ក នឹងត្រូវផ្តន្ទាទោសដោយមិនលើកលែងឡើយ ពីបទជួញដូរមនុស្សខុសច្បាប់។ អភិបាលបន្តទៀតថា ការដឹកជញ្ជូនពលករ ដើម្បីគេចវេះមណ្ឌលចត្តាឡីស័ក គឺជាហានិភ័យខ្ពស់មួយប្រសិនបើពលករនោះមានផ្ទុះជំងឺកូវីដ១៩ នឹងមានការរីករាលដល់បងប្អូនក្រុមគ្រួសារ និងឈានទៅដល់ការផ្ទុះ ក្នុងសហគមន៍ណាមួយជាមិនខាន។ ទន្ទឹមនឹងនេះដែរលោក ងួន

រតនៈ បានសង្កត់ធ្ងន់ៗថា បើសមត្ថកិច្ចណាម្នាក់ ហ៊ានដោះលែង អ្នកដឹកជញ្ជូនពលករ ដើម្បីគេចវេះពីមណ្ឌលចត្តាឡីស័ក ដោយមនោសញ្ចេតនាក្តី ឬដោយការសូកប៉ាន់ក្តី នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដូចគ្នា ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៧៧នាក់ ស្រី ៣៩នាក់ ក្នុងនោះកុមារា ៣នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៦នាក់ ស្រី ៧នាក់ កុមារា ១នាក់ កុមារី ០០នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១២នាក់ ស្រី ៥នាក់ កុមារា ២នាក់ កុមារី ២នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣២នាក់ ស្រី ១៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ១៤នាក់ ស្រីចំនួន ៩នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៧៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣១នាក់, ខេត្តបាត់ដំបង ចំនួន ១៤នាក់ និងឧត្តរមានជ័យចំនួន ៣២នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ផ្សាយដោយ៖ ធូ កុសល

## អភិបាលខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរត្រូវតែធានាឱ្យបានថា ពលករមកពីថៃ ត្រូវបានធ្វើចត្តាឡីស័ក

http://btv.com.kh/ 16/02/2021

ឧត្តរមានជ័យ ៖ អភិបាលខេត្តឧត្តរមានជ័យ បានដាក់បទបញ្ជាដល់អាជ្ញាធរខេត្ត ឱ្យពង្រឹងការត្រួតពិនិត្យ ដើម្បីធានាបានថា ពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃទាំងអស់ ឆ្លងកាត់ច្រកព្រំដែនខេត្តនេះ គឺត្រូវបាន ដាក់ឱ្យធ្វើចត្តាឡីស័ក តាមកាលកំណត់។ អភិបាលខេត្តឧត្តរមានជ័យឯកឧត្តម ប៉ែន កុសល្យ នៅថ្ងៃនេះ បានជំរុញឱ្យអាជ្ញាធរមានសមត្ថ កិច្ចពាក់ព័ន្ធទាំងអស់ ដែលឈរជើងតាមច្រកព្រំដែន និងច្រករបៀងនានា ត្រូវតែអនុវត្តការងារឱ្យបានហ្មត់ចត់ តាមបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការនាំចូលនូវមេរោគកូវីដ–១៩ តាមរយៈ ពលករ ដែលមកពីប្រទេសថៃ ដោយធានាថា អ្នកទាំងឡាយដែលទើបមកពីប្រទេសនេះ ដែលកំពុងតែរេង នូវការឆ្លងរាតត្បាតនៃមេរោគកូវីដ–១៩ ក្នុងសហគមន៍នោះ ត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក គ្រប់ចំនួនថ្ងៃកំណត់។

ឯកឧត្តម បានអំពាវនាវដល់មន្ត្រីទាំងអស់ កុំមានការពាក់ព័ន្ធនឹងការជួយសម្រួលឱ្យពលរដ្ឋមកពី ថៃ ពិសេស ត្រូវរែកមុខមេខ្យល់ ដែលតែងតែអូសទាញពលករលបលួចឆ្លងដែនខុសច្បាប់ឲ្យបាន ដើម្បី យកមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់។ ឯកឧត្តម បានបញ្ជាក់ថា បច្ចុប្បន្ននេះ កូវីដ–១៩ បាននឹងកំពុងរីករាលដាលក្នុងប្រទេសថៃ

ដែល ជាប្រទេសជាប់ព្រំដែនជាមួយកម្ពុជា ហើយថ្មីៗនេះដែរ មានការរកឃើញថា ពលករមកពីប្រទេសថៃ មានវិជ្ជមានកូវីដ–១៩ ដែលជាកត្តាមួយធ្វើឱ្យខេត្តជាប់ព្រំដែនមានការព្រួយបារម្ភ។ អត្ថបទ៖ ឃិន សារិទ្ធ

## សង្គមស៊ីវិលថា ចំណាត់ការលើអធិការប៉ូលិសម្នាក់នៅខេត្តបាត់ដំបងមិនអាចទប់ស្កាត់មេខ្យល់បានទេ

https://www.rfa.org/ ដោយ មួង ណារ៉េត 2021-02-16

មន្ត្រីអង្គការសង្គមស៊ីវិល ចាត់ទុកវិធានការរបស់លោកហ៊ុន សែន នេះ ថាជាការធ្វើឱ្យល្អមើលច្រើនជាងការយកចិត្តទុកដាក់ដល់សង្គមជាតិ និងសេចក្ដីសុខរបស់ប្រជាពលរដ្ឋ។ ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា លោក ឌិន ពុទ្ធី ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ថា ប៉ូលិសនិងទាហានប្រចាំការនៅតំបន់ព្រំដែនជាប់ប្រទេសថៃភាគច្រើនប្រព្រឹត្តអំពើពុករលួយពាក់ព័ន្ធនឹងការនាំពលករឆ្លងដែនខុសច្បាប់។ លោកបញ្ជាក់ថា បញ្ហានេះកើតមានជាច្រើនឆ្នាំមកហើយ ហើយពុំមានអាជ្ញាធរណាចាត់វិធានការបាននោះដែរ។ លោកថា ប្រសិនបើកងកម្លាំងទាំងនោះ អនុវត្តច្បាប់បានត្រឹមត្រូវ នោះក្រុមមេខ្យល់នឹងមិនអាចលួចនាំពលករឆ្លងដែនបានឡើយ៖ «អ៊ីចឹងទេ យើងគួរតែមើលហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធ និងក្រុមជនពុករលួយទាំងអស់ហ្នឹង។ ព្រោះអីវាមានមេមានកើយមិនមែនមានតែម្នាក់ហ្នឹងទេ គេមានបណ្ដាញរបស់គេ។ រដ្ឋាភិបាលលោកដឹងហើយគ្រាន់តែថា ការចាត់វិធានការណ៍ហ្នឹងច្រើនតែប៉ះសាច់ឯង បើសាច់ស្អុយហើយគួរតែកាត់បោះចោលឱ្យអស់ទៅកុំឱ្យវាកើតមហារីកបន្តទៀត។ វាបំផ្លាញសង្គមជាតិច្រើន បំផ្លាញផលប្រយោជន៍ និងអាយុជីវិតរបស់ប្រជាពលរដ្ឋច្រើនមែនទែនពាក់ព័ន្ធអំពើពុករលួយដែលបណ្ដោយឱ្យពលករចេញខុសច្បាប់ហ្នឹង»។

ស្រដៀងគ្នានេះដែរ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) បាត់ដំបង លោក ឃិន ម៉េងលី យល់ថា ការដកតំណែងអធិការនគរបាលស្រុកកំរៀងលោក គឹម ពន្លក មិនទាន់គ្រប់គ្រាន់នោះទេ ពីព្រោះរឿងនេះ អាចមានមន្ត្រីពាក់ព័ន្ធជាច្រើននាក់ទៀត ទើបបណ្ដាលឱ្យពលករអាចលួចឆ្លងដែនចេញ និងចូលកម្ពុជាបាន។ បន្ថែមពីនេះ រដ្ឋាភិបាលគួរតែចាត់វិធានការលើមន្ត្រីខិលខូចទាំងនោះឱ្យបានធ្ងន់ធ្ងរតាមច្បាប់ បន្ទាប់ពីដកស័ក្តិពួកគាត់ ដើម្បីកុំឱ្យមន្ត្រីព្រំដែនបណ្ដែតបណ្ដោយឱ្យពលករលួចឆ្លងដែនតាមអំពើចិត្តទៀត៖ «មេខ្យល់គឺជាមនុស្សម្នាក់ ឬជាមនុស្សមួយក្រុមដែលគេស្គាល់ច្រករបៀងច្បាស់លាស់ ហើយច្រករបៀងបើតាមខ្ញុំដឹងគឺមានកម្លាំងនគរបាល និងទាហានព្រំដែនប្រចាំការ។ អ៊ីចឹងកាលណាឆ្លងកាត់ច្រករបៀងត្រូវឆ្លងកាត់មន្ត្រីទាំងអស់ហ្នឹង។ អ៊ីចឹងបានយើងចង់ឱ្យមានការរឹតបន្តឹងទៅលើមន្ត្រីទាំងអស់ហ្នឹងថែមទៀត ដើម្បីធានាថាមិនមាននរណាម្នាក់ដែលឆ្លងកាត់ច្រករបៀងបានដោយមិនមានការធ្វើចត្តាឡីស័កនោះ»។

ប្រតិកម្មរបស់មន្ត្រីសង្គមស៊ីវិលនេះ ធ្វើឡើងក្រោយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចេញអនុក្រឹត្យបញ្ចប់មុខតំណែងអធិការនគរបាលស្រុកកំរៀងលោក គឹម ពន្លក បន្ទាប់ពីអាជ្ញាធរបានរកឃើញថា លោកបានដោះលែងមេខ្យល់ជាច្រើននាក់ ដែលលួចនាំពលករឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់អំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩ នៅប្រទេសថៃលើកទី២។ តាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបងកាលពីថ្ងៃទី១២ ខែកុម្ភៈ លោក គឹម ពន្លក វ័យ ៤៦ឆ្នាំរូបនេះត្រូវបានបង្គាប់ឲ្យនាំយកទៅឃុំខ្លួននៅពន្ធនាគារខេត្តនេះពីបទនាំពលករឆ្លងដែនមិនស្របច្បាប់។ មួយថ្ងៃក្រោយការដកតំណែងមេប៉ូលិសស័ក្តិ៥រូបនេះ អាជ្ញាធរខេត្តជាប់ព្រំដែនប្រទេសថៃ ដូចជានៅខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យជាដើម បានដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធជាច្រើននាក់ យាមការពារយ៉ាងតឹងតែងនៅតំបន់ព្រំដែន ដើម្បីទប់ស្កាត់ពលករខ្មែរលួចឆ្លងដែនទៅលេងស្រុកកំណើតដោយមិនបានធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ។

ចាប់តាំងពីចុងឆ្នាំ២០២០ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករខ្មែរជាង ៣ម៉ឺន ៥ពាន់នាក់ហើយ (៣៥,៦៦៥) ដែលបានត្រឡប់មកពីធ្វើការនៅថៃ ដោយសារការរាតត្បាតជំងឺកូវីដ១៩លើកទី២ នៅក្នុងប្រទេសនោះ ហើយពួកគាត់ពុំមានការងារធ្វើដូចមុន។ ក្នុងនោះក្រសួងសុខាភិបាលរកឃើញពលករខ្មែរចំនួន ៨៩នាក់ បានឆ្លងជំងឺកូវីដ-១៩ ពេលត្រឡប់ពីប្រទេសថៃមកវិញ។ ពលករខ្មែរជិត ១៦០នាក់ទៀត ត្រូវបានក្រសួងសុខាភិបាលថៃរកឃើញថា មានផ្ទុកជំងឺនេះនៅប្រទេសថៃ កាលពីខែមករា។ ពលករខ្មែរនៅក្នុងប្រទេសថៃភាគច្រើន ជាពិសេសអ្នកធ្វើការខុសច្បាប់កំពុងជួបវិបត្តិទ្វេដង ពោលគឺនៅក្នុងប្រទេសថៃក៏អត់ការងារធ្វើ ដោយសារការរាតត្បាតនៃជំងឺកូវីដ ត្រឡប់មកកម្ពុជាវិញក៏មានបញ្ហា។ មន្ត្រីសង្គមស៊ីវិលឱ្យដឹងថា ការលួចឆ្លងដែនអំឡុងពេលនេះ ជាការប្រថុយប្រថាននឹងគ្រោះថ្នាក់ច្រើនជាងពេលមុនៗ ដូចជាប្រឈមនឹងអាជ្ញាធរថៃចាប់ខ្លួន ដើរជាន់គ្រាប់មីនផ្ទុះស្លាប់ និងជំងឺកូវីដចម្លងចូលក្នុងសហគមន៍ជាដើម ប្រសិនបើពួកគាត់មិនបានធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ មុននឹងត្រឡប់ទៅស្រុកកំណើតនោះ៕

## ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បញ្ជាកងកម្លាំងបង្កើនការយាមល្បាតត្រួតពិនិត្យតាមព្រំដែនឲ្យបានម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់

http://cambodiapolice.com/policekh/ 4:14 pm 16 កុម្ភៈ 2021

បន្ទាយមានជ័យ ៖ ដោយមានបទបញ្ជាយ៉ាងម៉ឺងម៉ាត់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានចាត់តាំងឱ្យ លោក-លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ ស្នងការរង ទទួលខុសត្រូវតាមបណ្តាស្រុក/ក្រុង ជាប់ព្រំដែនចុះដឹកនាំកម្លាំងនគរបាលព្រំដែន និងអធិការដ្ឋាននគរបាលស្រុកក្រុង ល្បាតត្រួតពិនិត្យទាំងថ្ងៃទាំងយប់ ដើម្បីទប់ស្កាត់បងប្អូនប្រជាពលរដ្ឋចេញចូល និងបង្ក្រាបមេខ្យល់នាំឆ្លងដែនខុសច្បាប់ តាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាគោរពតាមបទបញ្ជាដឹកនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ៕

## នគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនមេខ្យល់ម្នាក់នាំមនុស្សឆ្លងដែនខុសច្បាប់ទៅសាលាដំបូងខេត្តចាត់ការតាមនិតិវិធីច្បាប់

http://cambodiapolice.com/policekh/ 2:00 pm 16 កុម្ភៈ 2021

បន្ទាយមានជ័យ ៖ ស្ត្រីម្នាក់ជាមេខ្យល់ធ្លាប់នាំមនុស្សឆ្លងដែនដោយខុសច្បាប់យ៉ាងសកម្ម ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឃាត់ខ្លួនកសាងសំណុំរឿងបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៦ខែ កុម្ភៈ ឆ្នាំ២០២១ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

លោកវរសេនីយ៍ឯក សែស វិបុល អធិការនគរបាលស្រុកអូរជ្រៅ បានឲ្យដឹងថា៖ ជនសង្ស័យឈ្មោះ ខន សុឃឿត ភេទស្រី អាយុ៣៦ឆ្នាំ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ជននេះត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រមដែនគោកលេខ៩១១ ចុះល្បាតតាមបន្ទាត់ព្រំដែន ហើយបានធ្វើការចាប់ឃាត់ខ្លួននៅវេលាម៉ោង១៦និង០៨នាទី ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ចំណុចភូមិសាស្ត្រភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខណៈពេលកំពុងនាំមនុស្សឆ្លងដែនចេញពីប្រទេសថៃចូលមកកម្ពុជា តាមច្រករបៀងខុសច្បាប់គេចពីការធ្វើចត្តាឡីស័ក ហើយបានបញ្ជូនមកអធិការដ្ឋាន ដើម្បីសាកសួរដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងមានការសម្របសម្រួលពីឯកឧត្តម មាស ច័ន្ទ

ពិសិដ្ឋ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ ជនសង្ស័យត្រូវបានឃាត់ខ្លួន និងរៀបចំសំណុំរឿងតាមនិតិវិធី ច្បាប់ ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ នគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឲ្យដឹងថា៖ នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានសារភាពថា ខ្លួនបានលួចនាំមនុស្សចេញ-ចូលឆ្លងដែនចំនួន០៥លើករួចមកហើយ ចាប់ពីខែមករា ឆ្នាំ២០២១មក ខ្លួនបានជូនគេទៅធ្វើការដកដំឡូងនិងកាប់អំពៅ ក្នុងរយៈពេល០១អាទិត្យឬ១០ថ្ងៃទើបវិលមកខ្មែរវិញ ដោយយកគេក្នុង០១ឬ០២នាក់តម្លៃ៣០០បាត ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារយេនឌ័រនិងប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានបញ្ជាក់ថា៖ ដោយផ្អែកតាមចម្លើយសារភាពរបស់ជនសង្ស័យ បច្ចុប្បន្នជនសង្ស័យឈ្មោះ ខន សុឃឿត ត្រូវបានកម្លាំងជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន រៀបចំសំណុំរឿងបញ្ជូនខ្លួនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ៕

## ពលករខ្មែរ ដែលត្រូវថៅកែថៃ វាយនឹងកាំភ្លើង បែកក្បាល ទទួលបានយុត្តិធម៌

https://dap-news.com/ ByPH104 Posted on February 16, 2021

**ភ្នំពេញ ៖ ពលករខ្មែរម្នាក់ ឈ្មោះ ណាំ សុខ ភេទប្រុស អាយុ៣៤ឆ្នាំ មានស្រុកកំណើត នៅខេត្តបាត់ដំបង ដែលត្រូវនិយោជក ប្រើប្រាស់អំពើហិង្សា វាយនឹងកាំភ្លើង បណ្តាលឲ្យបែកក្បាល កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ នៅបរិវេណផ្សារបានម៉ែ ខេត្តឆាក់ឈើងសៅនោះ បានទទួលយុត្តិធម៌វិញហើយ ។ នេះបើតាមការចុះផ្សាយ របស់ផេក ទូតខ្មែរ ប្រចាំក្រុងបាងកក ។** ការទទួលបានយុត្តិធម៌នេះ ដោយសារតំណាងស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បានសហការជាមួយអាជ្ញាធរ ពាក់ព័ន្ធចុះមកស្នងការដ្ឋាន នគរបាលខេត្តឆាក់ឈើងសៅ ដើម្បីតាមដានដោះស្រាយបញ្ហាឲ្យនាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ។ បន្ទាប់ពីប្រជុំ រកដំណោះស្រាយរួមគ្នារួចមក ពលករ ទទួលបានភាពយុត្តិធម៌ នូវបញ្ហាដែលគាត់បានទាមទារ ចំនួន៤ចំណុច និងមានទឹកចិត្តសប្បាយរីករាយ ចំពោះលទ្ធផល នៃចំណាត់ការរបស់អាជ្ញាធរ ។ ក្នុងនោះអាជ្ញាធរថៃ នឹងមានចំណាត់ការ បន្តផ្តន្ទាទោស ទៅលើនិយោជក តាមច្បាប់ក្នុងប្រទេសថៃ ៕

## ពលករខ្មែរជាង ២០ ម៉ឺននាក់ ទទួលភាពស្របច្បាប់ពីរដ្ឋាភិបាលថៃ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 16 February 2021 | 10:14 ICT

**ភ្នំពេញៈ** មានពលករខ្មែរជាង ២០ ម៉ឺននាក់ បានទទួលភាពស្របច្បាប់ពីរដ្ឋាភិបាលថៃនៅក្នុងអំឡុងពេលដែលប្រទេសថៃបានផ្តល់ពេល ១ ខែ ឱ្យពលករដែលរស់នៅ និងធ្វើការខុសច្បាប់អាចបំពេញភាពស្របច្បាប់វិញ។ ចាប់ពីថ្ងៃទី ១៥ ខែមករា ដល់ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ពលករចំណាកស្រុកបរទេសខុសច្បាប់ទាំង ៣ សញ្ជាតិ មានកម្ពុជា ឡាវ និងភូមា ត្រូវបានអាជ្ញាធរថៃអនុញ្ញាតឱ្យដាក់ពាក្យស្នើសុំធ្វើការងារ និងស្នាក់នៅស្របច្បាប់ក្នុងប្រទេសថៃរយៈពេល ២ ឆ្នាំ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ កាលពីម្សិលមិញថា ចាប់ពីថ្ងៃទី ១៥ ខែមករា ដល់ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ពលករបរទេសដែលបានចុះឈ្មោះជាមួយក្រសួងការងារថៃមានចំនួន ៦៥៤ ៨៦៤ នាក់ ក្នុងនោះមានពលករកម្ពុជាចំនួន ២០៣ ៦៧០ នាក់។ លោកបន្តថា៖ «ពលករបរទេសទាំង ៣ ប្រទេសត្រូវបានចែកចេញជាពលករមាននិយោជកចំនួន ៥៩៦ ៥០២ នាក់ ក្នុងនោះពលករកម្ពុជាមានចំនួន ១៨០ ៤៧៦ នាក់ ហើយពលករមិនមាននិយោជកចំនួន ៥៨ ៣៦២ នាក់ ក្នុងនោះពលករកម្ពុជាមានចំនួន ២៣ ២០៣ នាក់»។ យ៉ាងណាក្តី លោក ហេង សួរ បានអះអាងថា ក្នុងករណី

ដែលផុតការអនុគ្រោះនេះ ហើយរដ្ឋាភិបាលថៃចាប់ផ្តើមអនុវត្តវិធានការតឹងរ៉ឹងលើពលករខុសច្បាប់ នោះគឺជាសិទ្ធិរបស់រដ្ឋាភិបាលនៃប្រទេសមួយនេះ ខណៈរដ្ឋាភិបាលកម្ពុជា បានខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីជួយពលករខ្មែរទាំងនោះ។ លោកបញ្ជាក់ថា៖ «តម្លៃធ្វើបណ្ណនេះចន្លោះពី ៣០០ ទៅ ៤០០ ដុល្លារ) យើងបានរួមគ្នាជាមួយប្រទេស ២ ទៀតស្នើសុំឱ្យរដ្ឋាភិបាលថៃ ពិចារណាបន្ធូរបន្ថយកម្រៃសេវានេះ ហើយសេវានេះមិនមែនបង់ដោយបងប្អូនពលករទាំងស្រុងទេ គឺមានកាតព្វកិច្ចរបស់និយោជកខ្លះផងដែរ»។

កញ្ញា ប៊ូ វ៉ាន ជាពលករដែលបានបន្តភាពស្របច្បាប់នៅប្រទេសថៃ ក្នុងអំឡុងខែមករាបានប្រាប់ ភ្នំពេញប៉ុស្ដិ៍ កាលពីម្សិលមិញថា សម្រាប់ពលករដែលកំពុងធ្វើការស្របច្បាប់នៅប្រទេសថៃ គឺមិនសូវជាជួបបញ្ហាប្រឈមប៉ុន្មាននោះទេ បើពួកគេបាននិយោជកដែលគិតគូរពីសុខទុក្ខកម្មករ។ ប៉ុន្តែកញ្ញា មើលឃើញថាសម្រាប់ពលករដែលរស់នៅ និងធ្វើការខុសច្បាប់វិញ គឺពួកគាត់មានបញ្ហាប្រឈមជាច្រើន ហើយការទទួលបានភាពស្របច្បាប់ពីរដ្ឋាភិបាលថៃនេះក៏មានការលំបាកផងដែរ ជាពិសេសបញ្ហាជីវភាព។ កញ្ញា បន្តថា៖ «បើសិនជាវិធានការនៅថៃ គេបន្តរឹតបន្តឹងគឺអាចប៉ះពាល់ដល់ពលករខ្មែរដែលគាត់មកដោយមិនស្របច្បាប់។ ទី១ ចំណាយលើលិខិតឆ្លងដែន ហើយពួកយើងក៏មិនមានប្រាក់ច្រើននោះដែរ បើសិនជាអាចចង់ឱ្យរដ្ឋាភិបាលខ្មែរ និងថៃសម្រួលនូវនីតិវិធីឱ្យបានល្អ ដើម្បីឱ្យពលករចូលមកធ្វើការក្នុងប្រទេសនេះស្របច្បាប់។ ១ ទៀតសុំយកតម្លៃសេវាអ្វីក៏ដោយឱ្យទាបបន្តិចទៅ»។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការ Central បានលើកឡើងថា មានពលករខ្មែរចំនួនតិចតួចដែលទទួលបានភាពស្របច្បាប់ តាមរយៈការផ្តល់ឱ្យដោយរដ្ឋាភិបាលថៃ ខណៈមានពលរដ្ឋខ្មែរជាច្រើនមិនបានទទួលឱកាសនេះ ព្រោះតែគ្មានថវិកា និងលក្ខខណ្ឌផ្សេងៗ។ លោកបារម្ភថា នៅពេលដែលរដ្ឋាភិបាលបិទបញ្ចប់គោលនយោបាយនេះ ហើយចាប់ផ្តើមរឹតបន្តឹងការអនុវត្តច្បាប់នោះ មានពលរដ្ឋខ្មែរច្រើនណាស់នឹងជួបបញ្ហាប្រឈម។ លោកបន្តថា៖ «រយៈពេល ១ ខែ ដែលផ្តល់បណ្ណស៊ីជម្ពូ (ភាពស្របច្បាប់) នេះដល់ពលករគឺមិនគ្រប់គ្រាន់សម្រាប់ពួកគាត់ទេ ព្រោះអ្នកខ្លះមានបញ្ហាប្រឈមអត់មានការងារធ្វើ អត់មានលុយគ្រប់គ្រាន់ក្នុងការចំណាយទៅលើការចុះបញ្ជីចន្លោះពី ៣០០ ទៅ ៤០០ ដុល្លារ។ អ៊ីចឹងនេះហើយដែលជាភាពអយុត្តិធម៌សម្រាប់ពលករ»។ លោក ឌី ថេហូយ៉ា រំពឹងថា រដ្ឋាភិបាលកម្ពុជាក៏ដូចជារដ្ឋាភិបាលថៃ គួរតែមានការចរចាក្នុងការផ្តល់អត្ថប្រយោជន៍ និងភាពងាយស្រួលបន្ថែមទៀតដល់ពលករខ្មែរ ដើម្បីឱ្យពួកគាត់អាចទទួលបានសិទ្ធិធ្វើការស្របច្បាប់ក្នុងប្រទេសថៃ អំឡុងពេលប្រឈមនឹងវិបត្តិកូវីដ ១៩៕

## រដ្ឋាភិបាលថៃ ព្រមានចាត់វិធានការផ្លូវច្បាប់តឹងរ៉ឹង ចំពោះពលករបរទេសខុសច្បាប់

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2021-02-16

ពលករខ្មែរមួយចំនួន ដែលកំពុងធ្វើការនៅប្រទេសថៃ កាន់តែព្រួយបារម្ភពីការចាប់ខ្លួនបញ្ជូនទៅស្រុកខ្មែរវិញ បន្ទាប់ពីរដ្ឋាភិបាលថៃ ព្រមានចាត់វិធានការផ្លូវច្បាប់តឹងរ៉ឹងលើពលករបរទេស ដែលធ្វើការងារខុសច្បាប់ក្នុងប្រទេសរបស់ខ្លួន។ មន្ត្រីសង្គមស៊ីវិល យល់ថា អយុត្តិធម៌សម្រាប់ពលករ និងជំរុញឱ្យរដ្ឋាភិបាលកម្ពុជា ព្យាយាមប្រើប្រាស់តួនាទីដោះស្រាយបញ្ហាប្រឈមនេះ។

ក្រសួងការងារថៃ ប្រកាសថា មានកម្មករជាង៦៥ម៉ឺននាក់( ៦៥៤.៨៦៤) មកពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា (Myanmar) ឬភូមា បានដាក់ពាក្យសុំស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ដោយស្របច្បាប់រយៈពេល ២ឆ្នាំ ក្រោមកម្មវិធីលើកលែងទោសការងាររបស់រដ្ឋាភិបាលថៃ ។ ការសែតបាងកកប៉ុស្ដិ៍ ចុះផ្សាយនៅថ្ងៃទី១៥ កុម្ភៈ ដោយស្រង់សម្តីរបស់ រដ្ឋមន្ត្រីការងារថៃ លោក ស៊ូឆាត ធុំក្លីន (Suchart Chomklin) ថា "កម្មវិធីចុះឈ្មោះ ដើម្បីស្នាក់នៅ និងធ្វើការស្របច្បាប់ក្នុងប្រទេសថៃ ត្រូវបានបិទបញ្ចប់ជាផ្លូវការហើយ ដូច្នេះអាជ្ញាធរថៃ នឹងចាប់ផ្តើមចាត់វិធានការផ្លូវច្បាប់តឹងរ៉ឹង ចំពោះពលករចំណាកស្រុកខុសច្បាប់ ដែលមិនបានចុះឈ្មោះជាមួយអាជ្ញាធរថៃ និង

និយោជិករបស់ពួកគេ។ លោកបន្តថា អាជ្ញាធរថៃនឹងបញ្ជូនពួកគេត្រឡប់ទៅប្រទេសដើមវិញ និងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងសហគ្រាស ដែលបានជួលពួកគេ"។

ពលករខ្មែរដែលកំពុងធ្វើការខុសច្បាប់នៅថៃម្នាក់ គឺលោកស្រី ធុង នាថ ប្រាប់អាស៊ីសេរីថា ជីវភាពរបស់គ្រួសារលោកស្រីរាល់ថ្ងៃដុនដាបខ្លាំង ព្រោះដើរស៊ីឈ្នួលបោះខោអាវ រើសគ្រឿងសមុទ្រឱ្យគេបានប្រាក់កម្រៃមួយថ្ងៃរស់បានតែមួយថ្ងៃ។ អ្នកស្រីបន្តទៀតថា សព្វថ្ងៃនេះ លោកស្រី ត្រូវរ៉ាប់រងចិញ្ចឹមកូនប្រាំនាក់នៅក្នុងបន្ទុក ខណៈមានការងារធ្វើបន្តិចបន្តួច ដោយសារជំងឺកូវីត១៩ អូសបន្លាយពេល។ អ្នកស្រីប្រាប់ថា ពុំលទ្ធភាពទៅចុះឈ្មោះធ្វើប័ណ្ណការងាររបស់រដ្ឋាភិបាលថៃនោះទេ ព្រោះប័ណ្ណនោះមានតម្លៃថ្លៃហួស ពីសមត្ថភាពជីវភាពគ្រួសារ។ អ្នកស្រីមានបំណងចង់ត្រឡប់ទៅស្រុកខ្មែរវិញ ប៉ុន្តែច្រកនៅតាមព្រំដែនត្រូវបានបិទ៖ «ខ្ញុំមានអារម្មណ៍ថាភ័យ ភ័យដូចតែគ្នា ប៉ុន្តែបើគេចាប់ក៏គិតតាមច្បាប់ ទោះខ្ញុំចង់ទៅផ្ទះ ក៏ខ្ញុំអត់មានលុយទៅផ្ទះដែរ ចេះតែនៅហ្នឹងចិញ្ចឹមកូន ធ្វើការ គេជួលអ៊ីចេះធ្វើទៅ ខ្ញុំធ្វើម៉េចឱ្យតែគេជួលទៅខ្ញុំធ្វើ»។

ស្រដៀងគ្នានេះដែរ ពលការិនីម្នាក់ទៀត លោកស្រី ម៉ៅ សុភាព ប្រាប់អាស៊ីសេរីថា រយៈពេលជាង ៤ឆ្នាំហើយ ដែលលោកស្រី លួចធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ។ អ្នកស្រី បន្តរៀបរាប់ថា រាល់ថ្ងៃលោកស្រីធ្លាក់ខ្លួនឈឺ គ្មានប្រាក់ព្យាបាលជំងឺប្រចាំកាយឡើយ។ ស្ត្រីវ័យ ៣៦ឆ្នាំរូបនេះថា ការធ្វើប័ណ្ណការងាររបស់រដ្ឋាភិបាលថៃមានតម្លៃថ្លៃពេក ដែលលោកស្រីគ្មានលទ្ធភាពចំណាយនោះទេ ហេតុនេះហើយ អ្នកស្រីសុខចិត្តរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ទោះបីប្រឈមការគំរាមកំហែង ឬចាប់ខ្លួនបញ្ជូនត្រឡប់ទៅខ្មែរវិញក៏ដោយ។ ពលការិនីរូបនេះអំពាវនាវទៅរដ្ឋាភិបាលកម្ពុជា ឱ្យជួយអន្តរាគមន៍ទៅរដ្ឋាភិបាលថៃជួយបញ្ចុះតម្លៃប័ណ្ណការងារ ដើម្បីមានសិទ្ធិធ្វើការស្របច្បាប់ក្នុងប្រទេសនេះ៖ «អំពាវនាវឱ្យគាត់មកសម្របសម្រួល ឱ្យចុះថ្លៃតិចទៅកុំឱ្យយកថ្លៃពេក ពួកខ្ញុំអត់មានលទ្ធភាពទេ ព្រោះថា មកស៊ីឈ្នួលគេបានតែទិញហូប បើធ្លាក់ខ្លួនឈឺទៀត ឥឡូវកំពុងឈឺ ពិបាកខ្ចីថៅកែ ជំពាក់ថៅកែទៀត»។

ក្រសួងការងារថៃ បានបើកឱ្យពលករបរទេសចុះឈ្មោះធ្វើប័ណ្ណស្នាក់នៅ និងធ្វើការស្របច្បាប់ក្នុងប្រទេសថៃរយៈពេល ២ឆ្នាំ ចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ។ ដំណើរការនៃការចុះឈ្មោះនេះ អាជ្ញាធរថៃតម្រូវឲ្យពលករបង់ប្រាក់ប្រមាណ ៩ពាន់បាត (៩.០០០) ស្មើនឹងប្រមាណ ៣រយដុល្លារអាមេរិក (៣០០)។ អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីទទួលបន្ទុកការងារស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំការឆ្លើយតបរឿងនេះបាននៅឡើយទេ ដោយទូរស័ព្ទចូលច្រើនដងគ្មានអ្នកទទួល។

មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកសិទ្ធិការងារលោក ឌី ថេហូយ៉ា យល់ថា ប្រសិនបើរដ្ឋាភិបាលថៃចាត់វិធានការផ្លូវច្បាប់ ចំពោះពលករធ្វើការខុសច្បាប់នេះរឿងអយុត្តិធម៌សម្រាប់ពលករខ្មែររងគ្រោះ។ លោកបន្តថា ពលករមានបំណងចង់ទៅបំពេញផ្លូវច្បាប់ ប៉ុន្តែពួកគាត់ពុំមានលទ្ធភាព ដោយសាររងគ្រោះពីវិបត្តិជំងឺកូវីត ១៩ បង់ការងារធ្វើ គ្មានប្រាក់ចំណូល និងត្រូវបំពេញផ្លូវច្បាប់ស្មុគស្មាញ។ មន្ត្រីសង្គមស៊ីវិលរូបនេះថា រដ្ឋាភិបាលកម្ពុជាគួរនិយាយជាមួយរដ្ឋាភិបាលថៃ ដើម្បីដោះស្រាយចំណុចប្រឈមទាំងអស់នេះ៖ «ទាំងប្រទេសបញ្ជូន មានន័យថា ប្រទេសកម្ពុជា និងប្រទេសគោលដៅហ្នឹង ដល់ពេលគាត់រងគ្រោះ បែរជាដាក់បន្ទុកបន្ថែមទៅលើទាំងអស់ហ្នឹង ខ្ញុំគិតថា ទង្វើអសីលធម៌ អយុត្តិធម៌ណាស់សម្រាប់គាត់ អ្វីដែលយើងពិចារណាមើល តថភាពជាក់ស្តែង ដែលកំពុងកើតឡើងចំពោះគាត់»។

ក្រសួងការងារថៃបង្ហាញរបាយការណ៍ថា ក្នុងចំណោម ពលករជាង ៦៥ម៉ឺននាក់ ដែលបានចុះឈ្មោះ ដើម្បីស្នាក់ និងធ្វើការងារស្របច្បាប់នោះ មានពលករខ្មែរជាង ២០ម៉ឺននាក់ (២០៣.៦៦៩)។ ទោះជាយ៉ាងណាក្តី មន្ត្រីសិទ្ធិការងារលោក ឌី ថេហូយ៉ា ធ្លាប់បញ្ជាក់ថា ពលករខ្មែរធ្វើការងារនៅប្រទេសថៃមានជាង ១លាន ៨សែននាក់

ក្នុងនោះពលករធ្វើការខុសច្បាប់មានជាង ៤សែន (៤០០.០០០) នាក់។ មន្ត្រីសង្គមស៊ីវិលរូបនេះ ជឿថា ពលករខ្មែរជាង ២សែននាក់ កំពុងក្លាយទៅ ជាពលករខុសច្បាប់ ហើយអាជ្ញាធរថៃ អាចនឹងចាប់បញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ ឬចាប់ដាក់ពន្ធនាគារជាបន្តបន្ទាប់ ប្រសិនបើរដ្ឋាភិបាលកម្ពុជា មិនបានជួយអន្តរាគមន៍ជាមួយរដ្ឋាភិបាលថៃ ទាន់ពេលវេលាទេនោះ៕

# ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

## មេក្លោង២នាក់ ជំនាញនាំពលរដ្ឋឆ្លងដែនខុសច្បាប់ពីវៀតណាមចូលកម្ពុជា តាមខេត្តកំពតត្រូវកម្លាំងនគរបាលចាប់ខ្លួន

http://www.freshnewsasia.com/ 2021-02-17 12:12pm

**(កំពត)៖** មេក្លោង២នាក់ ជំនាញនាំប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់ ពីប្រទេសវៀតណាមចូលមកកម្ពុជា តាមខេត្តកំពត ត្រូវកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោលលេខ ៦០១ នៃស្នងការដ្ឋាននគរបាលខេត្តកំពត នៅវេលាម៉ោង៣ទាបភ្លឺ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១នេះ។

ស្នងការនគរបាលខេត្តកំពត លោកឧត្តមសេនីយ៍ទោ ម៉ៅ ច័ន្ទមធុរិទ្ធ បានប្រាប់បណ្ដាញព័ត៌មាន Fresh News ឲ្យដឹងនៅព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១នេះថា មេខ្យល់ទាំង២នាក់ ដែលជំនាញនាំប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់នេះ ត្រូវបានចាប់ខ្លួននៅចំណុចភូមិកោះចំការ ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច។ បើតាមលោកឧត្តមសេនីយ៍ស្នងការ មេខ្យល់ទាំង២នាក់នេះឈ្មោះ ហុន ថន អាយុ៤៣ឆ្នាំ រស់នៅភូមិកោះចំការ ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច និងឈ្មោះ ហុន រីក អាយុ៣៣ឆ្នាំ រស់នៅភូមិថ្កូវ ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច។ ក្នុងនោះកម្លាំងនគរបាលក៏បានឃាត់ខ្លួនជនជាតិវៀតណាម៣នាក់ផងដែរ ដែលលួចឆ្លងដែនខុសច្បាប់ តាមរយៈមេខ្យល់ខាងលើ។ តាមការសាកសួរជនជាតិវៀតណាមនោះ បានបញ្ជាក់ថា ខ្លួនត្រូវបានមេខ្យល់នាំឆ្លងដែនខុសច្បាប់ចូលកម្ពុជាប្រាកដមែន។ បច្ចុប្បន្នកម្លាំងសមត្ថកិច្ចបានប្រគល់ជនជាតិវៀតណាមជូនយោធាការពារព្រំដែនវៀតណាម ហើយបានសំណូមពរភាគីវៀតណាម ក្រោយពីធ្វើចត្តាឡីស័ករួច សូមផ្ដល់ព័ត៌មានអំពីលទ្ធផលនៃការធ្វើតេស្តមកកម្ពុជាវិញ។ ចំណែកមេខ្យល់ជនជាតិខ្មែរ សមត្ថកិច្ចកំពុងកសាងសំណុំរឿងដើម្បីចាត់ការបន្តតាមនីតិវិធី។

គួរជម្រាបថា រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា បានពង្រឹងការងារគ្រប់គ្រងការឆ្លងដែនតាមបន្ទាត់ព្រំដែនប្រទេសយ៉ាងតឹងរឹងបំផុត ដើម្បីការពារ និងទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ពីប្រទេសជិតខាង។ រាល់ការចេញចូលតាមព្រំដែនទាំងអស់គឺតម្រូវឲ្យធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ដោយគ្មានការលើកលែងនោះឡើយ។ ពាក់ព័ន្ធការចាប់ខ្លួនមេខ្យល់នាំពលករខុសច្បាប់នេះ សម្ដេចតេជោ ហ៊ុន សែន បានចេញអនុក្រឹត្យដកស័ក្តិ និងបណ្ដេញចេញពីក្របខ័ណ្ឌ អធិការនគរបាលស្រុកកំរៀង ខេត្តបាត់ដំបងម្នាក់ផងដែរ ឈ្មោះ គឹម ពន្លក ដែលបានដោះលែងខ្យល់ត្រឡប់ទៅវិញ ក្រោយទទួលបានលុយចំនួនពីការសូកប៉ាន់។ រហូតមកដល់ពេលនេះ អតីតអធិការស្រុកកំរៀង ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ហើយក៏ត្រូវតុលាការឃុំខ្លួនផងដែរ៕

## បញ្ជូនមេខ្យល់ម្នាក់ទៅតុលាការ និងពលករ៧នាក់ ទៅមណ្ឌលធ្វើចត្តាឡីស័ក

https://www.kampucheathmey.com/ on February 17, 2021By Sorn Phanith

នគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានបញ្ជូនមេខ្យល់១នាក់ទៅតុលាការខេត្តបន្ទាយមានជ័យ ក្នុងករណីជូនពលករឆ្លងដែនខុសច្បាប់ និង៧នាក់ទៀត ជាពលករបញ្ជូនទៅមណ្ឌលចត្តាឡីស័ក នៅព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ការឃាត់ខ្លួនមេខ្យល់នេះ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ លោកបានដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់កម្លាំងនគរបាលទាំងទាំងអស់ ត្រូវចុះបង្ក្រាបមេខ្យល់ ដែលលួចជូនពលករឆ្លងដែនយកទៅធ្វើការនៅស្រុកថៃដោយខុសច្បាប់ ទើបនគរបាលស្រុកស្វាយចេកចុះស្រាវជ្រាវឈានដល់ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បាន១នាក់ ឈ្មោះ ប៉ា សាមិត្រ ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដោយពាក់ព័ន្ធនឹងនាំមនុស្សឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ត្រង់ចំណុចភូមិល្បើកស្វាយ ដំណាក់កកោះ ឃុំស្វាយចេក ស្រុកស្វាយចេក ចំនួន២នាក់ ទី១. ឈ្មោះ នុត សាវណ្ណ អាយុ២៥ឆ្នាំ, ទី២. ឈ្មោះ វ៉ាន់ថា ស្រីមុំ អាយុ២៥ឆ្នាំ ជាប្តីប្រពន្ធនិងគ្នាបម្រុងជូនឆ្លងដែនទៅប្រទេសថៃ។

លោកស្រីឧត្តមសេនីយ៍ ឌី សុជាតិ បានបញ្ជាក់ទៀតថា បន្តមកទៀតកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ បានជួបប្រទះពលករខ្មែរចំនួន៥នាក់ទៀត មកពីខេត្តកំពង់ធំ នៅចំណុចរង្វង់មូលបឹងត្រកួន ក្នុងភូមិសាស្ត្រ ភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ពេលសួរនាំពួកគេប្រាប់ថាទៅថៃ ហើយបានធ្វើការឃាត់ខ្លួន និងផ្តល់ព័ត៌មានឲ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកថ្មពួក មកទទួលយក។ ចំពោះពលករទាំង៧នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក វិទ្យាល័យសម្តេចឪ នៅក្រុងសិរីសោភ័ណ ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១នេះផងដែរ ៕ **អត្ថបទ៖ វ៉ាន់ ណាង**

## នគរបាលឃាត់ខ្លួនមេខ្យល់ ៤ នាក់ ដឹកពលករខុសច្បាប់បញ្ជូនទៅតុលាការ

https://www.postkhmer.com/ វ៉ែន ដារ៉ា | Publication date 17 February 2021 | 13:32 ICT

**បាត់ដំបង:** កម្លាំងនគរបាលខេត្តបាត់ដំបង បានឆែករថយន្តដឹកផ្លែឈើចេញពីប្រទេសថៃចំនួន ២ គ្រឿង កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ចូលមកកាន់ប្រទេសកម្ពុជា តាមរយៈច្រកអន្តរជាតិដូង ព្រំប្រទល់កម្ពុជា-ថៃ ស្ថិតក្នុងស្រុកកំរៀង ក្នុងខេត្តបាត់ដំបង ក្នុងនោះឃាត់ខ្លួនមនុស្ស ៤ នាក់ ជាជនសង្ស័យនាំពលករចេញ-ចូលដោយខុសច្បាប់ និងរកឃើញពលករ ៥ នាក់ នៅក្នុងរថយន្តទាំង ២ គ្រឿងនោះ។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរង និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង ថ្លែងប្រាប់ ភ្នំពេញប៉ុស្ដិ៍ កាលពីម្សិលមិញថា៖ «ឡានដឹកផ្លែឈើ ២ គ្រឿងលួចដឹកពលករ ៥ នាក់ ក្រោយការសួរនាំរួច ពលករយើងបញ្ជូនទៅធ្វើចត្តាឡីស័កហើយអ្នកបើកឡាន និងព្រូឡាន ៤ នាក់ទៀត យើងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីអនុវត្តតាមច្បាប់»។

លោក ស៊ុម អាត អនុប្រធានក្រុមការងារទំនាក់ទំនងកិច្ចការព្រំដែនកម្ពុជា-ថៃ ច្រកអន្តរជាតិដូង បានឱ្យដឹងកាលពីម្សិលមិញដែរថា ក្រុមការងារនៅព្រំដែនបានសហការគ្នាជាមួយកងកម្លាំងគ្រប់ផ្នែក ដើម្បីរឹតបន្តឹងការចេញចូលតាមច្រកព្រំដែន ពិសេសពិនិត្យគ្រប់ឡានដឹកទំនិញទាំងអស់។ លោកថ្លែងថា៖ «កម្លាំងយើងបានរឹតបន្តឹងត្រួតពិនិត្យគ្រប់ឡានចេញចូលទាំងអស់ ចំណែកនៅច្រករបៀងកងកម្លាំងយើងគឺនៅប្រចាំការគ្រប់ច្រកទាំងអស់»។

លោក ប៊ុនរិទ្ធិ អ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបងបានឱ្យដឹងថា កន្លងមកនគរបាលឃាត់ខ្លួនមេខ្យល់ដែលនាំពលករចេញ-ចូល ច្រកព្រំដែនខុសច្បាប់បាន ១១ នាក់ហើយ ក្នុងនោះបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ៩ នាក់។ លោក សឿម ប៊ុនរិទ្ធិ បានឱ្យដឹងថា កាលពីម្សិលមិញនេះលោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង និង លោក សម វណ្ណវីរៈ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការនគរបាលជាតិបានដឹកនាំកិច្ចប្រជុំ ដើម្បីរឹតបន្តឹងបន្ថែម និងចាត់វិធានការថ្មីៗ ទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលករនៅក្នុងភូមិសាស្ត្រស្រុកកំរៀង ភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបងផងដែរ។ លោកថា ក្នុងកិច្ចប្រជុំម្សិលមិញនេះ ឯកឧត្តមអភិបាលខេត្តបានដាក់បទបញ្ជាឱ្យកងកម្លាំងបញ្ជាការឯកភាពខេត្តទាំងអស់ ពង្រឹងការរឹតបន្តឹងការចេញចូលតាមច្រកនានាបន្ថែមទៀត និងត្រូវឈរជើងរួមគ្នាលើបញ្ហាមិនប្រក្រតី៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៦៧នាក់ ស្រី ២៣នាក់ ក្នុងនោះកុមារា ១០នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៤នាក់ ស្រី ៥នាក់ កុមារា ១នាក់ កុមារី ០០នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៥នាក់ ស្រី ៥នាក់ កុមារា ៣នាក់ កុមារី ០០នាក់។

4-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន៣២ ៨នាក់ ស្រី ១៣នាក់ កុមារា ៦នាក់ កុមារី ២នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ២៩នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៣៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរខេត្តបាត់ដំបងបន្តប្រមាញ់មេខ្យល់ខណៈ១៤នាក់ ហើយត្រូវបានឃាត់ខ្លួន

http://btv.com.kh/ 17/02/2021

បាត់ដំបង ៖ អាជ្ញាធរខេត្តបាត់ដំបង កំពុងបន្តប្រមាញ់ចាប់ខ្លួនមេខ្យល់ ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ អំឡុងប្រតិបត្តិការទប់ស្កាត់ការឆ្លងរាលដាលមេរោគកូវីដ–១៩ ខណៈមេខ្យល់១៤នាក់ហើយ ត្រូវបានឃាត់ខ្លួនមកទល់ពេលនេះ។ អាជ្ញាធរខេត្តបាត់ដំបង បានឱ្យដឹងថា កាលពីយប់ថ្ងៃទី១៦ ខែកុម្ភៈ អាជ្ញាធរថៃ បានឃាត់ខ្លួន និងបញ្ជូនមេខ្យល់ជាតិខ្មែរ ចំនួនពីរនាក់ ដែលតែងនាំពលករឆ្លងដែនខុសច្បាប់ មកកាន់ភាគីកម្ពុជា តាមច្រកទ្វារអន្តរជាតិដូង (ឡែម) ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

លោក សុខ គឹមខុន អភិបាលស្រុកកំរៀង ប្រាប់BTV នៅព្រឹកថ្ងៃទី១៧ ខែកុម្ភៈនេះថា បច្ចុប្បន្នមេខ្យល់ទាំង ២នាក់ កំពុងធ្វើការឃាត់ខ្លួននៅក្នុងអធិការស្រុកកំរៀង ដើម្បីចាត់ការតាមនីតិវិធី។ បើតាមសមត្ថកិច្ចការពារព្រំដែន បានឱ្យដឹងថា ចាប់ពីការរឹតបន្តឹងការចេញចូលនៃមនុស្សឆ្លងកាត់ព្រំដែន ក្រោយការផ្ទុះរីករាលដាលកូវីដ–១៩ នៅក្នុងសហគមន៍ប្រទេសថៃនោះ សមត្ថកិច្ចការពារព្រំដែន បានឃាត់ខ្លួនមេខ្យល់ សរុបចំនួន១៤នាក់ បញ្ជូនទៅតុលាការ ខណៈប្រតិបត្តិការឃាត់ខ្លួននេះ ក៏មានការចូលរួមពីអាជ្ញាធរថៃផងដែរ។ សមត្ថកិច្ច បានឱ្យដឹងទៀតថា ក្រុមមេខ្យល់ ដែលតែងតែលួចនាំពលករឆ្លងដែននោះ មានមួយ ចំនួន បានបំភ័យបំផុស បំផុលពលករថា ពេលឆ្លងដែនមកខ្មែរ បើជួបសមត្ថកិច្ចនឹងត្រូវឃាត់ខ្លួន ហើយនាំទៅធ្វើចត្តាឡីស័ក និងអស់លុយទៀត និងពួកមេខ្យល់ខ្លះមិននាំពលករឆ្លងដែនមកផ្ទាល់នោះទេ ពួកគេនៅខាងទឹកដីថៃ ហើយបង្ហាញផ្លូវឲ្យពលករឆ្លងដែនមកកម្ពុជា រួមទាំងញុះញង់ពលករឲ្យស្អប់សមត្ថកិច្ច និងចោទប្រកាន់យ៉ាងនេះមួយ យ៉ាងនោះមួយ និងបច្ចុប្បន្ន សមត្ថកិច្ចការពារព្រំដែន កំពុងស្វែងរកចាប់ខ្លួនមេខ្យល់មួយចំនួនទៀត។

ក្នុងពេលចុះពិនិត្យសភាពការណ៍នៅព្រំដែន លោក សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ ដំបង បានជំរុញឱ្យសមត្ថកិច្ចការពារព្រំដែន បន្តស្វែងរក និងឃាត់ខ្លួនក្រុមមេខ្យល់ទាំងអស់ យកមកអនុ វត្តច្បាប់ ហើយមួយវិញទៀត បើសង្ស័យអ្នកណាម្នាក់ ថាធ្លាប់ធ្វើជាមេខ្យល់ ក៏ត្រូវនាំគេមកអប់រំ ដើម្បីកុំឲ្យ ធ្វើអំពើបែបនោះបន្តទៀត ។ ពាក់ព័ន្ធនឹងការនាំពលករឆ្លងដែន និងគេចវេសធ្វើចត្តាឡីស័កនេះ អាជ្ញាធរខេត្តបាត់ដំបង បាន រឹបអូសរថយន្តបីគ្រឿង នៅស្រុកសំពៅលូន និងស្រុកកំរៀង ព្រមទាំងនាំពលករ អ្នកបើកបររថយន្ត និង ព្រូឡាន ជាង១០នាក់ ទៅធ្វើចត្តាឡីស័ក ខណៈដែលអ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនពលករនោះ បន្ទាប់ពីធ្វើចត្តាឡីស័កចប់ សមត្ថកិច្ចនឹងបន្តនីតិវិធីបន្ថែមទៀត៕ អត្ថបទ៖ បាន សុខរិទ្ធ

## ពលករខ្មែរ ជាអ្នកស្មោរគ្រីនៅប្រទេសថៃ លួចឆ្លងដែនតាមទូកពីខេត្តត្រាត ចូលតាមខេត្តកោះកុង រួចឡើងតាក់ស៊ីមកដល់ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

https://khmernote.com.kh/ February 18, 2021 Khmernote Media

ខេត្តព្រះសីហនុ៖ ករណីឆ្លងដែនខុសច្បាប់មួយដោយបុរសជនជាតិខ្មែរម្នាក់បានរត់ពីប្រទេសថៃ មកដល់ស្រុកកំណើតក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុ សហការណ៍ជាមួយក្រុមគ្រូពេទ្យនាំយកទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារមួយកន្លែង។ បើតាមប្រភពព័ត៌មានបានអោយដឹងថា បុរសជនជាតិខ្មែរអាយុ៤១ឆ្នាំខាងលើ មានឈ្មោះថា កា យ៉ុន មានទីលំនៅភូមិតាអោងធំ ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ បើយោងតាមរបាយកាណ៍របស់សមត្ថកិច្ចបានអោយដឹងដែរថា កាលពីយប់ទៀបភ្លឺ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ បុរសរូបនេះបានលួចឆ្លងដែនចេញពីខេត្តត្រាត ប្រទេសថៃ តាមទូកមកដល់ព្រំប្រទល់ប្រទេសខ្មែរ ស្ថិតក្នុងខេត្តកោះកុង រួចបានឡើងតាក់ស៊ី ជិះមកដល់ផ្សារវាលរេញ មុននឹងធ្វើដំណើរបន្តទៅកាន់ផ្ទះរបស់ខ្លួនដែលស្ថិតនៅក្នុងភូមិតាអោងធំ ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ៕

## ប្រធានអង្គការ IOM ប្រចាំកម្ពុជា ស្នើឱ្យដាក់ពលករចំណាកស្រុកជាក្រុមអាទិភាពទទួលបានវ៉ាក់សាំងកូវីដ

https://www.postkhmer.com/ នៀម ឆេង | Publication date 18 February 2021 | 09:24 ICT

**ភ្នំពេញ:** ប្រធានបេសកកម្មនៃអង្គការទេសន្តរប្រវេសន៍ អន្តរជាតិ (IOM) ប្រចាំកម្ពុជា លោកស្រី គ្រីស្ទីន ប៉ាកូ (Kristin Parco) បានស្នើឱ្យដាក់ពលករចំណាកស្រុកក្នុងក្រុមមនុស្សអាទិភាព ដែលទទួលបានវ៉ាក់សាំងកូវីដ ១៩។ ក្រសួងសុខាភិបាលផ្តល់អាទិភាពចាក់វ៉ាក់សាំងដល់ខេត្តនៅជាប់ព្រំដែនថៃ និងវៀតណាម ប៉ុន្តែប្រុងប្រយ័ត្ន

ក្នុងការកំណត់ក្រុមមនុស្សដែលនឹងទទួលបានវ៉ាក់សាំង។ IOM ប្រចាំកម្ពុជាបានបង្ហោះសារនៅលើបណ្ដាញសង្គមរបស់ខ្លួនដោយស្រង់សម្ដីលោកស្រី ប៉ាកូ ថា៖ «ពលករគឺជាវីរជនប្រចាំថ្ងៃ ដែលបានបន្តចូលរួមចំណែកដល់សេដ្ឋកិច្ច សូម្បីតែក្នុងពេលដែលមានជំងឺរាតត្បាតក៏ដោយ។ ពួកគេគួរតែត្រូវបានបញ្ចូលពេញលេញទៅក្នុងផែនការជាតិនៃការចាក់វ៉ាក់សាំងកូវីដ ១៩»។ លោកស្រី ប៉ាកូ ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ តាមអ៊ីមែលបន្ថែមថា ពលករចំណាកស្រុក គួរតែទទួលបានការពិចារណាសម្រាប់ការចាក់វ៉ាក់សាំងនេះ ហើយពួកគេមិនគួរត្រូវបានមិនរាប់បញ្ចូលដោយសារតែពួកគេជាពលករចំណាកស្រុកឡើយ។ ប្រសិនបើអាទិភាពថ្នាក់ជាតិសំដៅលើបុគ្គលិកពេទ្យនោះ ការងារពាក់ព័ន្ធនឹងសុខភាពពលករ ក៏គួរតែត្រូវបានផ្ដល់អាទិភាពដូចគ្នាដែរ។ ប្រសិនបើមនុស្សចាស់ត្រូវបានចាត់ទុកថា ជាអាទិភាពពលករចំណាកស្រុកវ័យចំណាស់ក៏គួរតែមានអាទិភាពដូចគ្នាដែរ។

ពលករចំណាកស្រុកមួយចំនួនស្ថិតក្នុងស្ថានភាពមិនប្រក្រតី រួមមានប្រឈមនឹងហានិភ័យផ្សេងៗដូចជាស្ថានភាពការងារ និងស្ថានភាពរស់នៅមិនល្អ ការភ័យខ្លាច និងការរើសអើង ឬខ្វះការទទួលបានសេវាសុខភាព។ នៅក្នុងប្រទេសជាច្រើន ពលករចំណាកស្រុកគឺជាក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់ នៅពេលប្រទេសទាំងនោះ រៀបចំផែនការចែកចាយ និងចាក់វ៉ាក់សាំង។ ប៉ុន្តែ ផែនការចាក់វ៉ាក់សាំង គួរតែពិចារណាសម្រាប់ក្រុមពលករចំណាកស្រុកជាក់លាក់ដែលអាចមានហានិភ័យខ្ពស់។ នេះជាការលើកឡើងរបស់លោកស្រី ប៉ាកូ។ លោកស្រីថ្លែងថា៖ «ជំងឺរាតត្បាតបង្ហាញយើងថា ពេលនិយាយពីសុខភាពសាធារណៈ គ្មានអ្នកណាម្នាក់ត្រូវបានការពារទេ ដរាបណាមនុស្សគ្រប់គ្នាមិនត្រូវបានការពារនោះ។ ដូច្នេះវាមានភាពចាំបាច់ណាស់ ដែលរដ្ឋាភិបាលនានាត្រូវទទួលស្គាល់ពីសារៈសំខាន់នៃសុខភាពសាធារណៈសម្រាប់ពលករចំណាកស្រុកគ្រប់ប្រភេទ ដោយមិនគិតពីឋានៈផ្លូវច្បាប់ និងបញ្ចូលពួកគេក្នុងផែនការចាក់វ៉ាក់សាំងថ្នាក់ជាតិ»។ លោកស្រី ប៉ាកូ មើលឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងក្នុងកិច្ចការធ្វើផែនការចែកចាយ និងចាក់វ៉ាក់សាំង និងធានាការចាក់វ៉ាក់សាំងដោយរលូន។ IOM ត្រៀមខ្លួនរួចរាល់ដើម្បីជួយដល់រដ្ឋាភិបាលនានា រួមទាំងកម្ពុជាផង និងដៃគូក្នុងកិច្ចការផ្ដល់វ៉ាក់សាំងកូវីដ ១៩ ដើម្បីពង្រីកយុទ្ធនាការចាក់វ៉ាក់សាំងដល់ពលរដ្ឋជាជនចំណាកស្រុក និងអ្នកដែលតែងធ្វើដំណើរឯទៀតៗ។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលបានថ្លែងពីម្សិលមិញថា វ៉ាក់សាំងស៊ីណូហ្វាមដែលជាជំនួយរបស់ចិនចំនួន ៣០ ម៉ឺនដូសនឹងត្រូវចាក់លើមនុស្សចំនួន ១៤ ម៉ឺន ៩ ពាន់ ៥០០ នាក់។ ក្រសួងសុខាភិបាលកំពុងត្រៀមលក្ខណៈឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងផ្ដល់វ៉ាក់សាំងដល់បណ្ដារាជធានីខេត្ត ដើម្បីចូលរួមការចាក់វ៉ាក់សាំងបង្ការជំងឺដល់ក្រុមមនុស្សអាទិភាពដែលនឹងប្រកាសជាបន្តបន្ទាប់ ដោយសារតែចំនួនវ៉ាក់សាំងមានកម្រិត។ លោកស្រីថ្លែងថា៖ «តាមពិតទៅ យើងចង់ធ្វើឱ្យបានទូលំទូលាយ ប៉ុន្តែដោយសារវ៉ាក់សាំងយើងមានកម្រិត ដូច្នេះការផ្ដល់វ៉ាក់សាំងរបស់យើងក៏ត្រូវកំណត់ទៅតាមក្រុមមនុស្សដែលត្រូវមកទទួលតាមវគ្គៗរបស់យើង ធ្វើយ៉ាងណាធានាឱ្យមានវ៉ាក់សាំងឱ្យបានគ្រប់គ្រាន់សម្រាប់បុគ្គលដែលស្ម័គ្រចិត្តទទួលវ៉ាក់សាំងកូវីដ ១៩ នេះ ឱ្យបានគ្រប់ ២ ដូស។ ដូច្នេះហើយបានជាយើងមានការប្រុងប្រយ័ត្នក្នុងការអនុញ្ញាតឱ្យក្រុមមនុស្សដែលនឹងមកទទួលវ៉ាក់សាំងដោយគិតទៅតាមអាទិភាពសំខាន់ៗនៃក្រុមមនុស្សដែលនឹងទទួលជាបន្តបន្ទាប់»។

លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េដែលជាប្រទេសមានពលករចំណាកស្រុកពីកម្ពុជាច្រើនដែរនោះ ថ្លែងថា សាធារណរដ្ឋកូរ៉េនឹងចាប់ផ្ដើមចាក់វ៉ាក់សាំងប្រឆាំងកូវីដ ១៩ ចាប់ពីថ្ងៃទី ២៦ ខែកុម្ភៈ ដល់ខែវិច្ឆិកា ឆ្នាំ ២០២១ សម្រាប់ពលរដ្ឋទាំងអស់នៅក្នុងប្រទេសកូរ៉េ។ សម្រាប់រូបលោកដែលជាមន្ត្រីការទូតគឺចូលក្នុងក្រុមមនុស្សអាទិភាពហើយនឹងទទួលបានការចាក់វ៉ាក់សាំងដោយឥតគិតថ្លៃដូចពលរដ្ឋកូរ៉េដែរ។ លោកបន្តថា៖ «បរទេសដទៃទៀតដែលរស់នៅ ធ្វើការ រៀនសូត្រនៅកូរ៉េ ដូចជាពលករខ្មែរជាដើមនេះក៏នឹងទទួលបានការ

ចាក់វ៉ាក់សាំងដូចប្រជាជនកូរ៉េដទៃទៀតដែរ ដោយមិនមានការរើសអើង ប៉ុន្តែគ្រាន់តែថា កម្មវិធីសម្រាប់បរទេសដទៃទៀតត្រូវធ្វើនៅពេលណា ខ្ញុំមិនទាន់ទទួលបានការណែនាំផ្លូវការនៅឡើយ»។

ពលករចំណាកស្រុកពីកម្ពុជាដែលធ្វើការនៅប្រទេសថៃប្រមាណ ១ លាននាក់។ មន្ត្រីស្ថានទូតថៃប្រចាំកម្ពុជាឱ្យដឹងពីម្សិលមិញថា ប្រទេសថៃ បានបែងចែកផែនការចាក់វ៉ាក់សាំងជាដំណាក់កាល ដោយដំណាក់កាលទី១ ចាប់ពីខែកុម្ភៈ ដល់ខែឧសភា និងទី២ ពីខែមិថុនា ដល់ដំណាច់ឆ្នាំ ២០២១។ មនុស្សអាទិភាពទី១ គឺក្រុមបុគ្គលិកសុខាភិបាល ហើយក្រុមបន្ទាប់ដែលមានហានិភ័យខ្ពស់នឹងត្រូវកំណត់ និងពង្រីកទៅក្របខ័ណ្ឌទូទាំងប្រទេស។ មន្ត្រីស្ថានទូតថ្លែងថា៖ «សេចក្ដីព្រាងយុទ្ធសាស្ត្រចាក់វ៉ាក់សាំងរបស់ប្រទេសថៃធ្វើឡើងដោយការចាក់វ៉ាក់សាំងបង្ការផ្អែកលើហានិភ័យ ដោយមិនគិតពីសញ្ជាតិ និងដោយគោលការណ៍ស្ម័គ្រចិត្ត»។ មន្ត្រីរូបនេះបន្តថា ប្រទេសថៃ ចាត់ទុកសុខភាព និងការព្យាបាល គឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សដោយរាប់ទាំងពលករចំណាកស្រុកផងដែរ។ «សម្រាប់ការទទួលបានវ៉ាក់សាំង យុទ្ធសាស្ត្រចាក់ថ្នាំបង្ការរបស់យើងធ្វើឡើងផ្អែកលើហានិភ័យ មិនផ្អែកលើឋានៈ ឬសញ្ជាតិទេ។ ប្រសិនបើពលករចំណាកស្រុកស្ថិតក្នុងផ្នែកដែលមានហានិភ័យនេះ ពួកគេក៏នឹងត្រូវចូលទៅក្នុងផែនការថ្នាក់ជាតិផងដែរ»៕

## ពលករខ្មែរម្នាក់ ប្ដឹងស្ថានទូតខ្មែរឱ្យជួយអន្តរាគមន៍រឿងថៅកែថៃវាយក្បាល នឹងកាំភ្លើងខ្លីរបួសធ្ងន់

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2021-02-16

ពលករខ្មែរជនរងគ្រោះម្នាក់ ដាក់បណ្ដឹងទៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកឱ្យជួយអន្តរាគមន៍ពាក់ព័ន្ធនឹងរឿងថៅកែថៃយកកាំភ្លើងខ្លីវាយក្បាលបណ្ដាលឱ្យរបួសធ្ងន់ ក្នុងពេលធ្វើការនៅប្រទេសថៃ កាលពីថ្ងៃទី១៣ កុម្ភៈ។ មន្ត្រីសង្គមស៊ីវិលយល់ថា មន្ត្រីស្ថានទូតខ្មែរគួរតែជំរុញទៅអាជ្ញាធរថៃឱ្យចាប់ជនល្មើសផ្ដន្ទាទោសឱ្យបានធ្ងន់ធ្ងរតាមច្បាប់។ ជនរងគ្រោះកំពុងព្រួយបារម្ភអំពីសុវត្ថិភាពខ្លួន និងស្នើសុំឱ្យមន្ត្រីស្ថានទូតខ្មែរជម្លៀសគាត់ចេញទៅធ្វើការនៅកន្លែងផ្សេង។

ពលករមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យលោក ណាន់ សុខ ប្រាប់អាស៊ីសេរីថា លោកមិនហ៊ាននៅបន្តធ្វើការងារជាមួយថៅកែថៃ ដែលបានយកកាំភ្លើងខ្លីវាយក្បាលរបស់លោកបណ្ដាលឱ្យហូរឈាមរបួសធ្ងន់នោះទេ។ ពលករវ័យ ៤១ឆ្នាំរូបនេះថ្លែងថា ម្ចាស់ហាងលក់គុយទាវនៅខេត្តឆាក់ឈើងសៅ (Chak Cheurng Sao) ជាជនជាតិថៃ បានខឹងលោកនិយាយតមាត់មិនព្រមធ្វើតាមបញ្ជា។ លោកថា នៅពេលនោះលោកជាប់រវល់ ហើយបានប្រាប់ថៅកែថៃរូបនោះឱ្យជួយហាន់សាច់ជ្រូកដាក់ចានជំនួសគាត់ ក៏ខឹងលោករួចស្ទុះទៅយកកាំភ្លើងខ្លីមកវាយក្បាលរបស់លោកបណ្ដាលឱ្យបែកក្បាលហូរឈាម៖ «រឿងគេសុំរបស់ឱ្យហាន់សាច់ជ្រូក ខ្ញុំប្រាប់ថា ខ្ញុំហាន់អត់ទាន់ទេ បងឯងហាន់ខ្លួនឯងខ្លះទៅ។ រឿងតូចប៉ុណ្ណោះឯង គាត់ស្ទុះមកវាយខ្ញុំបណ្ដោយ មួយដងកាំភ្លើង។ តាមសំណើរបស់ខ្ញុំ ចង់ឱ្យគេយកខ្ញុំទៅដាក់កន្លែងផ្សេង»។ ភ្លាមៗ ក្រោយពេលកើតហេតុពលកររូបនេះ បានទូរស័ព្ទប្ដឹងទៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីឱ្យជួយអន្តរាគមន៍ដល់គាត់ដែរ ប៉ុន្តែមន្ត្រីស្ថានទូតមិនបានចុះអន្តរាគមន៍តាមការស្នើសុំនោះទេ។ ក្រោយមកសាច់ញាតិរបស់ពលករបានបង្ហោះសារអំពាវនាវឱ្យអាជ្ញាធរខ្មែរជួយអន្តរាគមន៍ដល់ពួកគាត់ ទើបមន្ត្រីស្ថានទូតខ្មែរបានចុះជួបជនរងគ្រោះ នៅព្រឹកថ្ងៃទី១៥ កុម្ភៈ។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី១៥ កុម្ភៈ ដោយសារទូរស័ព្ទចូលជាច្រើនដង ពុំមានអ្នកទទួល។ ប៉ុន្តែហ្វេសប៊ុកស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកបានចុះផ្សាយថា មន្ត្រីទូតខ្មែរបានសហការជាមួយអាជ្ញាធរថៃចុះដោះស្រាយលើរឿងនេះហើយ។ ស្ថានទូត

បន្តថា ជនរងគ្រោះកំពុងស្ថិតនៅកន្លែងមានសុវត្ថិភាព ដោយមានការការពារពីស្ថានទូត និងអាជ្ញាធរថៃ។ ទោះជាយ៉ាងណាក្តី ស្ថានទូតមិនបានបញ្ជាក់អំពីវិធានការលើជនល្មើសថា យ៉ាងណានៅឡើយទេ។

ទាក់ទិននឹងការប្រើហិង្សាលើពលករខ្មែរនេះ មន្ត្រីអង្គការសង់ត្រាល់ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា យល់ថា មន្ត្រីស្ថានទូតខ្មែរ និងអាជ្ញាធរថៃគួរតែផ្តន្ទាទោសជនល្មើសឱ្យបានធ្ងន់ធ្ងរតាមច្បាប់របស់ប្រទេសថៃ ដើម្បីកុំឱ្យថៅកែថៃចេះតែធ្វើបាបពលករខ្មែរតាមអំពើចិត្តបន្តទៀត៖ «ខ្ញុំមើលឃើញចំណុចនេះ វាជាចំណុចមួយដែលមិនគួរកើតមាន ទាល់តែមហាជនដឹងឮបានយកចិត្តទុកដាក់អីជាដើម អ៊ីចឹងខ្ញុំគិតថា អត់ឆ្លុះបញ្ចាំង ក្នុងនាមជាអាណាព្យាបាលទទួលខុសត្រូវ ក៏ដូចជាអ្នកបម្រើប្រជាពលរដ្ឋទេ។ នេះហើយគឺជាអ្វីដែលយើងបានសង្កេតកន្លងមក មិនថាករណីកើតឡើងនៅចិន នៅម៉ាឡេស៊ី ឬនៅប្រទេសណាក៏ដោយ ទាល់តែករណីហ្នឹងល្បីមហាជនដឹងឮឈឺចាប់គ្រប់គ្នាអ៊ីចឹងទៅ មានការយកចិត្តទុកអើពើដោះស្រាយ»។ មន្ត្រីសង្គមស៊ីវិលរូបនេះ ឱ្យដឹងទៀតថា កន្លងមកមានពលករខ្មែរធ្វើការនៅប្រទេសថៃជាច្រើននាក់ ត្រូវបានថៅកែគំរាមបាញ់សម្លាប់ និងប្រើហិង្សាជាបន្តបន្ទាប់ ហើយពួកគេភាគច្រើនមិនទទួលបានយុត្តិធម៌នោះឡើយ។

កាលពីចុងខែមិថុនា ឆ្នាំ២០២០ មានករណីមេការសំណង់ជនជាតិថៃម្នាក់ បានប្រើកាំភ្លើងបាញ់ពលករខ្មែរ ៣នាក់បណ្តាលឲ្យស្លាប់ម្នាក់ និងរបួសធ្ងន់ស្រាល ២នាក់ ហើយមេការថៃរូបនោះ ក៏ត្រូវបានប្រជាពលរដ្ឋ ព្រួតវាយបណ្តាលឲ្យស្លាប់នៅនឹងកន្លែងកើតហេតុដែរ។ ករណីដោយឡែកមួយទៀត កាលពីឆ្នាំចុងឆ្នាំ២០២០ មានពលករខ្មែរមួយគ្រួសារត្រូវបានថៅកែថៃយកកាំភ្លើងខ្លីគំរាមសម្លាប់ ដោយសារតែខឹងពួកគាត់សុំត្រឡប់ទៅកម្ពុជា បន្ទាប់ពីធ្វើការជិត ២ខែមិនទទួលបានប្រាក់ឈ្នួល។ ពេលនោះថៅកែថៃ និយាយថា ពលករខ្មែរជំពាក់ប្រាក់ថ្លៃធ្វើលិខិតឆ្លងដែនមិនទាន់សងអស់នៅឡើយ។ អាជ្ញាធរថៃបានសម្របសម្រួលបញ្ចប់សំណុំរឿងនេះ ដោយមិនមានការផ្តន្ទាទោសលើថៅកែនោះតាមច្បាប់ឡើយ។ មន្ត្រីសិទ្ធការងារលោក ឌី ថេហូ យ៉ា ជឿថា ការធ្វើបែបនេះនឹងធ្វើឱ្យថៅកែថៃមិនខ្លាចច្បាប់ ហើយនឹងអាចមានករណីប្រើហិង្សាលើពលករខ្មែរជាបន្តបន្ទាប់ទៀត៕

## តំណាងស្ថានទូតខ្មែរនៅថៃបានរកយុត្តិធម៌ឱ្យពលករខ្មែរម្នាក់ ដែលត្រូវថៅកែថៃប្រើកាំភ្លើងវ៉ៃបែកក្បាល

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 17 February 2021 | 09:59 ICT

**ភ្នំពេញ៖** តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានទាមទារយុត្តិធម៌ដល់ពលករខ្មែរម្នាក់ ដែលត្រូវនិយោជកថៃប្រើអំពើហិង្សាវាយនឹងកាំភ្លើងបណ្តាលឱ្យបែកក្បាល បន្ទាប់ពីជនរងគ្រោះបានស្វែងរកកិច្ចអន្តរាគមន៍ ដោយក្នុងនោះជនល្មើសប្រឈមនឹងការទទួលទោសទណ្ឌតាមផ្លូវច្បាប់។ កាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២១ ពលករខ្មែរម្នាក់មានឈ្មោះ ណាំ សុខ ភេទប្រុស អាយុ ៣៤ ឆ្នាំ មានស្រុកកំណើតនៅខេត្តបាត់ដំបងត្រូវបាននិយោជកប្រើអំពើហិង្សាវាយនឹងកាំភ្លើង បណ្តាលឱ្យបែកក្បាលនៅបរិវេណផ្សារបានម៉ៃ ខេត្តឆាក់ឈើងសៅ។ ក្រោយកើតហេតុភ្លាមៗ ជនរងគ្រោះក៏បានស្វែងរកកិច្ចអន្តរាគមន៍ពីសំណាក់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដើម្បីស្វែងរកយុត្តិធម៌។

ទំព័រហ្វេសប៊ុករបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានឱ្យដឹងកាលពីថ្ងៃទី ១៥ កុម្ភៈថា ការចុះអន្តរាគមន៍នេះបានធ្វើឡើងកាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២១ នៅស្នងការដ្ឋាននគរបាលខេត្តឆាក់ឈើងសៅ ដោយមានតំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសហការជាមួយអាជ្ញាធរថៃ ដើម្បីជួបចរចាស្វែងរកដំណោះស្រាយ។ ទំព័រហ្វេសប៊ុកដដែលបានបញ្ជាក់ថា៖ «បន្ទាប់ពីប្រជុំរកដំណោះស្រាយរួមគ្នារួចមក ពលករទទួលបានភាពយុត្តិធម៌នូវបញ្ហាដែលគាត់បានទាមទារចំនួន ៤ ចំណុច និងមានទឹកចិត្តសប្បាយរីករាយចំពោះលទ្ធផលនៃចំណាត់ការ

របស់អាជ្ញាធរ»។ ក្រៅពីផ្តល់យុត្តិធម៌នេះស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ក៏បានអះអាងថា អាជ្ញាធរថៃនឹងមានចំណាត់ការបន្តតាមច្បាប់ក្នុងប្រទេសថៃ ដើម្បីផ្តន្ទាទោសទៅលើនិយោជកដែលបានប្រើអំពើហិង្សាលើពលករខ្មែរ។

ភ្នំពេញប៉ុស្តិ៍មិនអាចស្វែងរកលេខទំនាក់ទំនង លោក ណាំ សុខ ជាជនរងគ្រោះក្នុងហេតុការណ៍អំពើហិង្សានេះបានទេ។ ចំណែកមន្ត្រីស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ ក៏មិនអាចទាក់ទងសុំការអត្ថាធិប្បាយបន្ថែមបានដែរកាលពីម្សិលមិញ ព្រោះមិនមានអ្នកលើកទូរស័ព្ទ។

ប៉ុន្តែលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានប្រាប់ភ្នំពេញប៉ុស្តិ៍យ៉ាងខ្លីថា ស្ថានទូតកម្ពុជាបានជួយដោះស្រាយជូនជនរងគ្រោះរួចរាល់ហើយ។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃការអង្គការ Central បានសាទរចំពោះដំណោះស្រាយដែលពលកររូបនេះទទួលបានហើយរំពឹងថា បញ្ហារបស់ពលករ-កម្ពុជានឹងត្រូវបានយកចិត្តទុកដាក់និងដោះស្រាយគ្រប់ៗគ្នា ដោយគ្មានការរើសអើង។ លោកបញ្ជាក់ថា៖ «យើងមិនទាន់ទទួលបានព័ត៌មានពេញលេញទេថា គាត់ទទួលបានយុត្តិធម៌នៅឡើយទេ ដោយគ្រាន់តែទទួលបានថា មានការអន្តរាគមន៍។ ដូច្នេះបើអាជ្ញាធរកម្ពុជា ឬថៃ បានបំពេញកាតព្វកិច្ចនេះ គឺជារឿងសាទរ ចំពោះការបំពេញការងារ ហើយមួយទៀតក៏ដូចជាអាជ្ញាធរថៃដែរ ដែលត្រូវតែចាត់វិធានការ»។ បន្ថែមពីនេះ លោក ឌី ថេហូយ៉ា បាននិយាយថា ប្រសិនបើការទាមទារនេះគ្រាន់តែជាការសងសំណងជំងឺចិត្តនោះ គឺមិនគ្រប់គ្រាន់នោះទេ ព្រោះសមត្ថកិច្ចត្រូវតែមានការអនុវត្តទៅតាមច្បាប់ឱ្យមានប្រសិទ្ធភាព និងយុត្តិធម៌ដើម្បីចៀសវាងថៅកែថៃផ្សេងៗទៀត យកធ្វើជាគំរូអាក្រក់ដោយសំអាងតែខ្លួនឯងមានអំណាចផ្នែកសេដ្ឋកិច្ច ចង់ធ្វើអ្វីក៏បាន។ «នេះគឺជារឿងមួយអសីលធម៌ណាស់ ហើយប្រើហិង្សាដោយកំពេលយកកាំភ្លើងវាយក្បាលនេះ គឺក្នុងន័យមើលងាយ មិនគោរពភាពជាមនុស្សសោះ»៕

## ពលករចំណាកស្រុកជាង ៦០ម៉ឺននាក់បានសម្រុកទៅចុះឈ្មោះជាមួយក្រសួងការងារថៃ ក្នុងនោះពលករចំណាកស្រុកមកពីកម្ពុជាមានចំនួនច្រើនជាងគេ

https://www.khmer-press.com/ Khmer pressFebruary 17, 2021 at 4:30 pm

ថៃ៖ បើតាមរយៈសារព័ត៌មាន The Thaiger បានរាយការណ៍ថា គិតមកទល់នឹងពេលនេះមានពលករចំណាកស្រុកជាង ៦០០ ០០០ នាក់ហើយ ដែលបានទៅចុះឈ្មោះជាមួយនឹងក្រសួងការងារនៃប្រទេសថៃ ហើយយុទ្ធនាការនៃការចុះឈ្មោះនេះបានចាប់ផ្តើមតាំងពីថ្ងៃទី១៥ ខែមករា និងត្រូវបញ្ចប់នៅថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០២១ កន្លងទៅថ្មីៗនេះ។ គួររម្លឹកជូនថា ការសម្រុកទៅចុះឈ្មោះពីសំណាក់ក្រុមពលករចំណាកស្រុកនៅពេលនេះ ត្រូវបានធ្វើឡើងក្រោយអាជ្ញាធរថៃបានប្រកាសឲ្យក្រុមពលករ ដែលបានចូលក្នុងប្រទេសថៃ ដោយខុសច្បាប់ទាំងអស់ត្រូវតែប្រញាប់មកចុះឈ្មោះ ដើម្បីទទួលសិទ្ធធ្វើការងារដោយស្របច្បាប់នៅក្នុងប្រទេសថៃរយៈពេល ២ឆ្នាំ ខណៈដែលការចុះឈ្មោះនេះក៏អាចធ្វើឲ្យអាជ្ញាធរថៃងាយស្រួលក្នុងការគ្រប់គ្រងការរាតត្បាតនៃជំងឺ COVID-19 ផងដែរ។

ជម្រាបផងដែរថា ការផ្ទុះឡើងនៃជំងឺ COVID-19 រលកចុងក្រោយដែលកំពុងរាលដាលនៅប្រទេសថៃ គឺភាគច្រើន បានកើតមានក្នុងចំណោមពលករចំណាកស្រុកនេះផ្ទាល់តែម្តង ដូច្នេះការចុះឈ្មោះនេះគឺនឹងជួយសម្រាលបន្ទុកដល់អាជ្ញាធរ ក្នុងការកំណត់អត្តសញ្ញាណពលករទាំងនោះ។ ប្រភពខាងលើបានបញ្ជាក់ថា ចំនួនពលករសរុបដែលបានទៅចុះឈ្មោះស្របច្បាប់ជាមួយក្រសួងការងារថៃ គិតមកទល់ពេលនេះគឺមានចំនួន ៦៥៤ ៨៦៤ នាក់ ដែលក្នុងនោះមានពលករចំនួន ២០៣ ៦៧៩ មកពីប្រទេសកម្ពុជា, ពលករចំនួន ៦៧ ១០៨ នាក់មកពីប្រទេសឡាវ និងពលករចំនួន ៣៨៤ ០៧៧ នាក់ មកពីប្រទេសមីយ៉ាន់ម៉ា។ ក្រុមពលករទាំងអស់នេះភាគច្រើនគឺធ្វើការងារនៅក្នុងវិស័យសំណង់ និងឧស្សាហកម្មកសិកម្ម ហើយចំនួនតិចតួចធ្វើការក្នុងវិស័យលក់ចំណីអាហារនិង

ភេសជ្ជៈ។ ចំពោះទីកន្លែងដែលពួកគេត្រូវទៅធ្វើការងារវិញគឺភាគច្រើននៅក្នុងក្រុងបាងកក ខេត្តធុនបូរី ខេត្តផាទុមថានី ខេត្តសាមុតសង្គ្រាន និងខេត្តសាមុតសាខនជាដើម៕

## លោកលឹង សុផុនៈ ពលករខ្មែរជាងមួយសែននាក់នឹងប្រឈមបញ្ហាផ្លូវច្បាប់ពីអាជ្ញាធរថៃ ដោយសារមិនធ្វើបណ្ណស្របច្បាប់

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 17/02/2021 - 11:43 ដោយ៖ជួប នរក្សា

ពលករខ្មែរនៅប្រទេសថៃ ត្រូវបានអាជ្ញាធរថៃតម្រូវឲ្យធ្វើបណ្ណស្របច្បាប់ ដើម្បីឲ្យពួកគេអាចបន្តធ្វើការងារ និងសម្រួលដល់ការរស់នៅរបស់ពួកគេក្នុងប្រទេសថៃ។ ដំណើរការធ្វើបណ្ណស្របច្បាប់នេះមានរយៈពេលមួយខែចាប់ពីថ្ងៃទី១៥មករា ដល់ថ្ងៃទី១៣កុម្ភៈ។ យ៉ាងណាក៏ដោយគិតត្រឹមថ្ងៃទី១៧កុម្ភៈនេះ លោកលឹង សុផុន មន្ត្រីទទួលបន្ទុកកិច្ចការអន្តោប្រវេសន៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិពីខេត្តឈុនបុរីប្រទេសថៃ ថា មានពលកររហូតដល់ទៅ១សែននាក់ មិនទាន់បានចុះឈ្មោះធ្វើបណ្ណស្របច្បាប់ទៅតាមវិធានការរបស់អាជ្ញាធរថៃ។ បើតាមលោកលឹង សុផុន ការខកខានមិនបានធ្វើបណ្ណស្របច្បាប់ដូច្នេះនឹងធ្វើឲ្យពលករខ្មែរទាំងជាង១សែននាក់នោះនឹងប្រឈមបញ្ហាផ្លូវច្បាប់ពីសំណាក់អាជ្ញាធរថៃ។

# ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១

## បទ្កប់ខ្លួនក្នុងទូកលួចឆ្លងដែនទាំងយប់ពីថៃ ចាប់បានកណ្តាលសមុទ្រខេត្តកោះកុង

https://www.kampucheathmey.com/ on February 18, 2021By Dy Bunnara

នៅវេលាម៉ោង១និង២៥នាទី រំលងអាធ្រាត្រឈានចូលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ កម្លាំងល្បាតរបស់វរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ ប្រចាំខេត្តកោះកុង បានចាប់ឃាត់ទូក១គ្រឿង និងមនុស្ស៣នាក់ ដែលលួចឆ្លងដែនពីប្រទេសថៃចូលមកប្រទេសកម្ពុជា តាមច្រកព្រំដែនទឹកខេត្តកោះកុង។

បើតាម ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ពលៈ ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក បានប្រាប់អោយដឹងថា នៅវេខាងលើកម្លាំងល្បាតរបស់វរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ ប្រចាំខេត្តកោះកុង បានធ្វើការល្បាតត្រួតពិនិត្យជួបទូក១គ្រឿង ដឹកមនុស្ស៣នាក់ ដែលលួចឆ្លងដែនខុសច្បាប់ ចេញពីខ្លងស្រ៊ុន ខេត្តត្រាត ប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមផ្លូវសមុទ្រ ហើយត្រូវបានកម្លាំងយើងធ្វើការចាប់ឃាត់នៅត្រង់ចំណុចភូមិសាស្ត្រកោះនូ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ជនទាំង៣នាក់ ដែលកម្លាំងវរសេនាតូចការពារព្រំដែនទឹកលេខ២៦៩ ចាប់ឃាត់ខ្លួនទី១.ង៉ែត សៀង ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ អ្នកបើកបរទូក មានទីលំនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ទី២.ឈ្មោះ លន់ ឈំ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករទូក មានទីលំនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ទី៣.ឈ្មោះ អូន វ៉ាត ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរពលកររស់នៅប្រទេសថៃ មានទីលំនៅស្រុកកំចាយមា ខេត្តព្រៃវែង។

ក្រោយពេលចាប់ឃាត់ខ្លួនជនទាំង៣នាក់ កម្លាំងបានប្រគល់ទៅអោយក្រុមការងារចត្តាឡីស័កខេត្តកោះកុង ដើម្បីអនុវត្តនីតិវិធីបន្ត។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ពលៈ បញ្ជាក់បន្តថា ក្រោយពេលចាប់ឃាត់ខ្លួនជនទាំង៣នាក់ខាងលើរួចមក នៅវេលាម៉ោង៨និង២០នាទី ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ កម្លាំងសមត្ថកិច្ចយើងបានធ្វើការស្រាវជ្រាវ និងចាប់ឃាត់ខ្លួនមេខ្យល់ជំម្នាក់ទៀតឈ្មោះ ម៉ៅ ស៊ុនឡាយ ភេទប្រុស អាយុ៦៦ឆ្នាំ មានទីលំនៅ

សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ រួចប្រគល់អោយស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីអនុវត្តនីតិវិធីបន្ត៕

## មេខ្យល់២នាក់មានស្រី-ប្រុស ជាបណ្តាញនាំមនុស្សទៅឲ្យមេខ្យល់នៅប្រទេសថៃខុសច្បាប់ ទៅតុលាការ

https://www.kampucheathmey.com/ on February 18, 2021By Mey Soklim

សមត្ថកិច្ចខេត្តបន្ទាយមានជ័យចុះឃាត់ខ្លួនមេខ្យល់២នាក់ មានប្រុស និងស្រីមានឈ្មោះ រឹង វាសនា ភេទប្រុសអាយុ ៤៨ឆ្នាំ និងម្នាក់ទៀតឈ្មោះ ហ៊ួន ពៅ ភេទស្រីអាយុ៤៣ឆ្នាំ ទាំង២នាក់នេះជាបណ្តាញមេខ្យល់ឈ្មោះ ចៃ ណយ ។ ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យនៅរសៀលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា បន្ទាប់ធ្វើការឃាត់ខ្លួនពលករខ្មែរចំនួន៥នាក់ មកពីភូមិប្រកនាគឃុំ ចើងដឹងស្រុកបារាយការណ៍ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ យកមកសួរនាំនៅអធិការដ្ឋាននគរបាលស្រុកថ្មពួក រួចមកកម្លាំងនគរបាលបានធ្វើការស្រាវជ្រាវ រហូតឈានដល់ឃាត់ខ្លួនមុខសញ្ញាជាបណ្តាញនាំមនុស្សឆ្លងដែនពីខ្មែរទៅថៃ ដែលមានមេខ្យល់ឈ្មោះចៃណយ កំពុងនៅប្រទេសថៃ ឈ្មោះ រឹង វាសនារស់ នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មុខរបរជាអ្នករត់តាក់ស៊ីស្វាយទៅបឹងត្រកួន និងឈ្មោះ ហ៊ួន ពៅ ភេទស្រី អាយុ ៤៣ឆ្នាំ នៅភូមិកៀនកេះ ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបងរត់តាក់ស៊ី បាត់ដំបងមកស្វាយ ជនសង្ស័យទាំង ២នាក់ ពាក់ព័ន្ធក្នុងការដឹកជញ្ជូនពលករយកទៅឲ្យឈ្មោះចៃ ណយ ជាមេខ្យល់ នៅចំណុចបឹងត្រកួន ដើម្បីធ្វើដំណើរដោយខុសច្បាប់ទៅប្រទេសថៃ។ នេះបើយោងតាមការបំភ្លឺរបស់ពលកររងគ្រោះទាំង៥នាក់និងចម្លើសារភាពជនសង្ស័យទាំង២នាក់ ។លោកស្រីបានបញ្ជាក់ថាសមត្ថកិច្ចកំពុងតាមស្រាវជ្រាវដើម្បីរែករកមុខមេខ្យល់និងបក្ខពួកបន្ថែមទៀត៕ វ៉ាន់ ណាង

## សមត្ថកិច្ចឃាត់មេខ្យល់ម្នាក់ និងមនុស្ស៣នាក់ផ្សេងទៀតលួចឆ្លង ដែនតាមផ្លូវទឹកទៅថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 18/02/2021

**កោះកុង ៖** កម្លាំងសមត្ថកិច្ច ពាក់ព័ន្ធ បានឃាត់ខ្លួនមេខ្យល់ ម្នាក់ ព្រមទាំងមនុស្ស៣នាក់ ជិះទូកតូចមួយបម្រុងលួច ឆ្លងដែនចូលទៅប្រទេសថៃ ។ ការឃាត់ខ្លួននោះធ្វើឡើងនៅតាមផ្ទៃទឹកជិតខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ កាលពីម៉ោង៩និង៤០យប់ថ្ងៃទី១៧ ខែកុម្ភៈ ២០២១ម្សិលមិញ ។ តាមព័ត៌មានទទួលបានមេខ្យល់ដែលជាអ្នកដឹកជញ្ជូនបានយកលុយក្នុងមនុស្សម្នាក់ចំនួន១២០០បាត ដើម្បីចូលទៅធ្វើការ នៅខេត្តត្រាត ប្រទេសថៃ ៕

## តុលាការចោទប្រកាន់ និងឃុំខ្លួនអតីតអធិការស្រុកកំរៀង ពាក់ព័ន្ធករណីដោះលែងមេខ្យល់ នាំពលករទៅថៃ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 18 February 2021 | 10:27 ICT

**បាត់ដំបង:** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបងបានសម្រេចចោទប្រកាន់ លោក គឹម ពន្លក អតីតអធិការនគរបាលស្រុកកំរៀង ដាក់ពន្ធនាគារនៅថ្ងៃទី ១៦ ខែកុម្ភៈ តាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ នេះបើតាមលោក ផាន រតនា អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តបាត់ដំបង។ លោក ផាន រតនា បានថ្លែងប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ថា៖ «ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួន លោក គឹម ពន្លកហើយតាមបទ

ចោទការនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទតាមមាត្រា ៨ និងមាត្រា ១១»។

លោក គឹម ពន្លក ត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចេញអនុក្រឹត្យឱ្យអនុវត្តពិន័យមន្ត្រីនគរបាលជាតិ សម្រេចដកហូត និងបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាកាលពីថ្ងៃទី ១៥ ខែកុម្ភៈពាក់ព័ន្ធករណី ការដោះលែងមេខ្យល់នាំពលករចេញ-ចូលតាមច្រកព្រំដែនកម្ពុជា-ថៃខុសច្បាប់ និងគេចវេះពីវិធានការសុខាភិបាល។ លោកនាយករដ្ឋមន្ត្រីបានថ្លែងប្រាប់បណ្តាញព័ត៌មានក្នុងស្រុកថា ករណីលោក គឹម ពន្លក នេះក្រៅពីដកឋានន្តរស័ក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌ លោកបានបញ្ជាឱ្យអភិបាលខេត្ត និងអគ្គស្នងការនគរបាលជាតិត្រូវបន្តចាត់ការអនុវត្តតាមផ្លូវច្បាប់បន្ថែមទៀតដើម្បីផ្តន្ទាទោសមន្ត្រីពុករលួយរូបនេះដាក់ពន្ធនាគារទុកជាការព្រមានដល់ជនទាំងឡាយផ្សេងទៀតកុំឱ្យប្រព្រឹត្តទង្វើបែបនេះ។

លោក យិន ម៉េងលី មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តបាត់ដំបងបានទទូចឱ្យសមត្ថកិច្ចអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងចំពោះសមត្ថកិច្ចដែលឃុបឃិតជាមួយមេខ្យល់ នាំពលករចេញ-ចូលតាមច្រកព្រំដែន ដែលមិនគោរពតាមវិធានសុខាភិបាល និងការណែនាំរបស់រាជរដ្ឋាភិបាលបែបនេះ។ លោកថ្លែងថា៖ «ការឃុបឃិតដោះលែងមេខ្យល់នាំពលករឆ្លងដែនបើមើលទៅហាក់បីដូចជារឿងតូច ប៉ុន្តែរឿងនេះជាបញ្ហាធំប៉ះពាល់ដល់សន្តិសុខជាតិ ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចសង្គមទាំងមូល។ បើសិនជាមេខ្យល់នាំពលករចូលទៅក្នុងផ្ទៃប្រទេសហើយបើមានផ្ទុកមេរោគកូវីដ ១៩ វានឹងបង្កផលប៉ះពាល់ដល់ខេត្ត ស្រុក ឬឈានដល់ការបិទខេត្ត ឬស្រុកនោះថែមទៀត»។ លោកបានអំពាវនាវឱ្យមានការអនុវត្តច្បាប់តឹងរ៉ឹងចំពោះទង្វើល្មើសច្បាប់របស់សមត្ថកិច្ចអនុវត្តច្បាប់បែបនេះ ដើម្បីទុកជាគំរូដល់ជនខិលខូចជាមេខ្យល់ពាក់ព័ន្ធក្នុងការនាំពលករចេញ-ចូលដោយខុសច្បាប់ ដែលគេចវេះពីវិធានការសុខាភិបាល។

លោក ហ៊ុន សែន កាលពីថ្ងៃទី ១៥ ខែកុម្ភៈ បានដាក់បទបញ្ជាឱ្យបណ្តាខេត្តនៅជាប់ព្រំដែន អនុវត្តឱ្យបានម៉ឺងម៉ាត់ចំពោះមេខ្លោងដែលនាំពលករឆ្លងកាត់ព្រំដែនគេចវេះពីការធ្វើចត្តាឡីស័ក និងត្រូវធ្វើការស្រាវជ្រាវរកមេខ្លោងដែលនាំពលករឆ្លងកាត់ព្រំដែនដោយខុសច្បាប់ គេចវេះពីវិធានការសុខាភិបាលនេះទៅតាមច្បាប់។

យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ មាត្រា ៨ ចែងថា ការនាំចេញដោយមិនស្របច្បាប់មានន័យថា ការធ្វើឱ្យមនុស្សម្នាក់ ផ្លាស់ទីពីកន្លែងដែលកំពុងរស់នៅទៅកាន់កន្លែងដទៃស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួនតាមមធ្យោបាយបង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬល្បួងលោម។ ការនាំអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ដោយគ្មានអំណាចតាមផ្លូវច្បាប់ចេញពីការគ្រប់គ្រងស្របច្បាប់នោះ។ មាត្រា ១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនគឺជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅប្រទេសកម្ពុជាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ឆ្នាំ ដល់ ២០ ឆ្នាំ ក្នុងករណីដែលអំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានអំណាចរបស់ខ្លួនមកលើជនរងគ្រោះ៕

## ប៉ូលិសឃាត់ខ្លួនមនុស្សពីរនាក់ និងម្នាក់ទៀតបញ្ជូនទៅតុលាការ ករណីនាំមនុស្សឆ្លងដែនខុសច្បាប់

https://www.rfa.org/khmer/ ដោយ សន ចាន់រដ្ឋា 2021-02-18

កងកម្លាំងការពារព្រំដែនគោក លេខ៦០១ បានឃាត់បុរសខ្មែរចំនួន ២នាក់ នៅខេត្តកំពត ដែលបាននាំជនជាតិវៀតណាមចំនួន ៣នាក់ ឆ្លងដែនខុសច្បាប់ពីប្រទេសវៀតណាម ចូលមកខេត្តកំពត។ កងកម្លាំងការពារព្រំដែនគោក លេខ ៦០១ កាលពីថ្ងៃទី១៧ កុម្ភៈ បានឃាត់ខ្លួនមេខ្យល់ជនជាតិខ្មែរទាំង ២នាក់ នៅវេលាម៉ោង ៣ និង

៣០នាទីទៀបភ្លឺ។ សមត្ថកិច្ចបានកសាងសំណុំរឿង មេខ្យល់ជនជាតិខ្មែរទាំងពីរនាក់ ដើម្បីអនុវត្តតាមនីតិវិធី។ ចំណែកជនជាតិវៀតណាម ដែលលួចឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់នោះ សមត្ថកិច្ចបានបញ្ជូនពួកគេ ប្រគល់អោយ យោធាការពារព្រំដែនវៀតណាម ដើម្បីធ្វើចត្តាឡីស័ក និងស្នើខាងភាគីវៀតណាម ផ្តល់លទ្ធផលធ្វើតេស្តជំងឺកូវីដ១៩ មកខាងកម្ពុជា នៅពេលទទួលបានលទ្ធផល។

ស្រដៀងគ្នានេះដែរ សមត្ថកិច្ចខេត្តបន្ទាយមានជ័យ ឯណោះវិញ ក៏បានបញ្ជូនបុរសជនជាតិខ្មែរម្នាក់ ឈ្មោះ ប៉ា សាមិត្រ អាយុ ៣២ឆ្នាំទៅតុលាការ បន្ទាប់ពីបុរសរូបនេះនាំមនុស្សឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ កម្លាំងយោធាកងល្បាតទី៤ បានឃាត់ខ្លួន ប្ដីប្រពន្ធមួយគូនៅឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ប្ដីប្រពន្ធមួយគូនេះ បានរៀបរាប់ប្រាប់សមត្ថកិច្ចថា ពួកគេបានបង់លុយឱ្យបុរសម្នាក់ឈ្មោះ ប៊ុន ណយ ក្នុងម្នាក់ ៤.០០០បាត ដើម្បីជួយឱ្យពួកគេឆ្លងដែនមកធ្វើការនៅប្រទេសថៃ។ ពួកគេរៀបរាប់បន្ថែមថា បុរសឈ្មោះ ប៊ុន ណយ បានជូនពួកគេមកដល់ ភូមិល្បើកស្វាយ រួចពួកគេរង់ចាំដល់ទៀបភ្លឺម៉ោង ១ និងដើរចម្ងាយ ៤គីឡូម៉ែត្រ នឹងមានរថយន្តថៃមកចាំទទួល។

កងកម្លាំងយោធាល្បាត បានឱ្យពីរនាក់ប្ដីប្រពន្ធ ទូរស័ព្ទហៅបុរសឈ្មោះ ប៊ុន ណយ ដែលបានដឹកពួកគេមក ឱ្យមកទទួលពួកគេវិញ។ ប៉ុន្តែបុរសឈ្មោះ ប៊ុន ណយ មិនបានមក បែរជាឃើញបុរសម្នាក់ទៀតឈ្មោះ ប៉ា សាមិត្រ មកទទួលជំនួសវិញ ទើបត្រូវកម្លាំងយោធា កងល្បាតលេខ ៤ ឃាត់ខ្លួនតែម្ដង។ សមត្ថកិច្ច បានបញ្ជូនលោក ប៉ា សាមិត្រ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ចំណែកពីរនាក់ប្ដីប្រពន្ធ សមត្ថកិច្ចបានបញ្ជូនពួកគេទៅធ្វើចត្តាឡីស័ក នៅក្រុងសិរីសោភ័ណ រួមជាមួយនឹងពលករចំនួន ៥នាក់ផ្សេងទៀត ដែលសមត្ថកិច្ចឃាត់ខ្លួន ពេលលួចឆ្លងដែនទៅប្រទេសថៃ កាលពីថ្ងៃទី១៦ ខែកុម្ភៈ៕

## អគ្គនាយកការពារព្រំដែន ប្រាប់ពលករខ្មែរ ដែលចូលស្រុក កុំឲ្យគេចពីអាជ្ញាធរ ដើម្បីចៀសវាងជួបគ្រោះថ្នាក់

https://thmeythmey.com/ 18, Feb 2021 , 3:53 pm ដោយ: សារព័ត៌មានថ្មីៗ

នាយកដ្ឋាននគរបាលការពារព្រំដែនគោក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានអំពាវនាវដល់ពលករកម្ពុជា ដែលវិលត្រឡប់ចូលកម្ពុជាវិញ តាមច្រកព្រំដែនគោក ឲ្យសហការជាមួយកម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ក្នុងការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ តាមរយៈសេចក្តីអំពាវនាវចេញនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នាយកដ្ឋាននគរបាលការពារព្រំដែនគោក ប្រាប់ពលករ កុំឲ្យជឿមេខ្យល់ ដែលនាំឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់ និងនាំគេចវេះពីការត្រួតពិនិត្យរបស់កងកម្លាំងការពារព្រំដែន។ នាយកដ្ឋាននគរបាលការពារព្រំដែនគោក ប្រាប់ដូច្នេះ ព្រោះដើម្បីឲ្យពលករ ចៀសផុតពីគ្រោះថ្នាក់ជាយថាហេតុណាមួយ ដែលអាចកើតឡើងក្នុងពេលធ្វើដំណើរឆ្លងដែន ដូចជា ជាន់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជាដើម។

ថ្មីៗនេះ មានបុរសវ័យជាង៣០ឆ្នាំម្នាក់ ជាពលករខ្មែរនៅថៃ បានជាន់មីនផ្ទុះដាច់ជើងខាងស្ដាំ ក្នុងខេត្តបន្ទាយមានជ័យ ពេលវិលមកកម្ពុជាវិញ។ បុរសនោះ មិនបានចូលតាមច្រក ដែលមានសមត្ថកិច្ចឈរជើងចាំត្រួតពិនិត្យនោះទេ ដោយគេចពីសមត្ថកិច្ច ហើយលួចចូលតាមផ្លូវផ្សេង ដែលគ្មានសមត្ថកិច្ច។ ជាមួយគ្នានេះ នាយកដ្ឋាននគរបាលការពារព្រំដែនគោក បញ្ជាក់ជាថ្មីថា អ្នកធ្វើចត្តាឡីស័ក មិនត្រូវចំណាយថវិកាលើការស្នាក់នៅនិងការហូបចុកឡើយ ដោយការចំណាយទាំងនេះ គឺជាបន្ទុករបស់រដ្ឋាភិបាល។ អ្នកដែលគេចវេះពីការធ្វើចត្តាឡីស័ក និងអ្នក ដែលគេចវេះពីកន្លែងធ្វើចត្តាឡីស័ក ក្នុងអំឡុងធ្វើចត្តាឡីស័ក ត្រូវពិន័យប្រាក់ពី១លានរៀលដល់៥លានរៀល។ នេះបើតាមអនុក្រឹត្យថ្មីរបស់រដ្ឋាភិបាល ដែលចេញនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបញ្ជាទៅកងកម្លាំង និងមន្ត្រីពាក់ព័ន្ធ ឲ្យពិនិត្យការឆ្លងដែនឲ្យបានម៉ត់ចត់ ហើយប្រជាពលរដ្ឋ ដែលឆ្លងដែនពីប្រទេសជិតខាង គឺ ថៃ វៀតណាម និង ឡាវ ចូលមកកម្ពុជាវិញ ចាំបាច់ត្រូវយកទៅធ្វើចត្តាឡីស័ក។ សម្តេចនាយករដ្ឋមន្ត្រី ក៏បានបញ្ជាទៅមន្ត្រីផ្នែកច្បាប់ដែរ ឲ្យអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង លើមេខ្យល់ឬមេខ្លោង ដែលនាំប្រជាពលរដ្ឋ ចូលមកកម្ពុជា ហើយនាំប្រជាពលរដ្ឋគេចពីការធ្វើចត្តាឡីស័ក។ រដ្ឋាភិបាលកម្ពុជា ចាត់វិធានការកាន់តែតឹងរឹងក្នុងការត្រួតពិនិត្យលើអ្នកឆ្លងដែន ពិសេសការនាំអ្នកឆ្លងដែន ទៅធ្វើចត្តាឡីស័ក គឺស្របពេលប្រទេសជិតខាង គឺថៃ និង វៀតណាម ផ្ទុះជំងឺកូវីដ-១៩ខ្លាំង ជាថ្មីឡើងវិញ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និង ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ១២៩នាក់ ស្រី ៥៦នាក់ ក្នុងនោះ កុមារា ១៥នាក់ កុមារី ៦នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥៧នាក់ ស្រី ២២នាក់ កុមារា ៩នាក់ កុមារី ៣នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១១នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៥នាក់ ស្រី ២៣នាក់ កុមារា ៥នាក់ កុមារី ៣នាក់។

5- ច្រកដូង ស្រុកកំរៀង៖ ចំនួន ១៦នាក់ ស្រីចំនួន ៧នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៦៨នាក់, ខេត្តបាត់ដំបង ចំនួន ១៦នាក់ និងឧត្តរមានជ័យចំនួន ៤៥នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## សាច់ញាតិ និងសមត្ថកិច្ចព្រំដែន អំពាវនាវពលករធ្វើការនៅថៃ កុំជឿការញុះញង់ពួកមេខ្យល់

http://btv.com.kh/ 18/02/2021

បាត់ដំបង ៖ ពលរដ្ឋរស់នៅក្នុងប្រទេស ដែលត្រូវជាសាច់ញាតិ រួមទាំងកងកម្លាំងកំពុងការពារព្រំដែន បានអំពាវនាវដល់ពលករធ្វើការនៅប្រទេសថៃ បើត្រឡប់មកស្រុកកំណើតវិញ សូមកុំជឿតាមការញុះញង់ របស់ពួកមេខ្យល់នាំឆ្លងដែនខុសច្បាប់ និងគេចវេសពីការធ្វើចត្តាឡីស័ក គឺត្រូវចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ទាំងអស់គ្នា ។ ពលរដ្ឋរស់នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង មានបងប្អូនជាច្រើននាក់ កំពុងធ្វើការនៅប្រទេសថៃ បានលើកឡើងថា បងប្អូនទាំងអស់គ្នាបើមិនមានកិច្ចការអ្វីចាំបាច់នោះទេ កុំទាន់ធ្វើដំណើរបំលាស់ទី គឺបើធ្វើការឬស្នាក់នៅកន្លែងណា ត្រូវបន្តនៅទីនោះទៀត ចៀសវាងមានការឆ្លងជំងឺកូវីដ១៩ ។ ពលរដ្ឋ បានបន្តថា ប៉ុន្តែបើត្រឡប់មកស្រុកកំណើតវិញ ត្រូវអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្នុងវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ គឺត្រឡប់តាមច្រកព្រំដែនស្របច្បាប់ កុំជឿតាមការញុះញង់អូសទាញរបស់ពួកមេខ្យល់ នាំឆ្លងដែន

ច្រករបៀងខុសច្បាប់ ឬឆ្លងអូរព្រំដែនជាដើម ព្រោះបើមកតាមច្រកស្របច្បាប់ គឺអាជ្ញាធរស្រួលគ្រប់គ្រង និងធ្វើចត្តាឡីស័កបានត្រឹមត្រូវ ការហូបចុកដោយឥតគិតថ្លៃ មិនមានយកប្រាក់នោះទេ ។

ក្នុងកិច្ចប្រជុំពិភាក្សាការទប់ស្កាត់ការឆ្លងដែនខុសច្បាប់របស់ពលករ ក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ១៩នេះ កាលពីដើមសប្តាហ៍នេះ ដោយមានការចូលរួមពីឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង លោក កែវ សេងឡូត មេបញ្ជាការកងពលតូចថ្មើរជើង លេខ៥៣ បានលើកឡើងថា ក្នុងបេសកម្ម ចាំឃ្លាំមើលសកម្មភាពរបស់ពលករឆ្លងដែនដោយខុសច្បាប់នៅភូមិសាស្ត្រខេត្តបាត់ដំបង គឺកងកម្លាំងនៅពេលយប់ដើរល្បាតទល់ភ្លឺ ហើយនៅពេលថ្ងៃដាក់វេនគ្នាសម្រាក ។ លោក បានបន្តថា សម្រាប់កងកម្លាំងការពារនៅជាប់មាត់អូរវិញ ពិសេសនៅភូមិសាស្ត្រស្រុកកំរៀង ជិតច្រកទ្វារអន្តរជាតិដូង (ឡែម) គឺមានសភាពស្អុយដែលពិបាកទ្រាំ ប៉ុន្តែក្នុងការចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ មើលសកម្មភាពលួចឆ្លងដែនរបស់ពលករ គេចវេសការធ្វើចត្តាឡីស័ក កងកម្លាំងត្រូវសម្រាក ហូបចុកអាហារនៅជាប់នឹងមាត់អូរ ដែលមានក្លិនស្អុយនោះជារៀងរាល់ថ្ងៃ ។ លោកមេបញ្ជាការ បានបញ្ជាក់ថា ទោះជាយ៉ាងនេះក្តៅ ក៏កងកម្លាំងនៅតែបន្តការពារផលប្រយោជន៍ពលរដ្ឋ និងស្នើពលករចូលរួមអនុវត្តវិធានការសុខាភិបាល តាមការណែនាំរបស់ក្រសួងសុខាភិបាល ។

គួរបញ្ជាក់ថា ចាប់ពីមានការផ្ទុះរីករាលដាលក្នុងសហគមន៍ខេត្តសាមុទសាខន ប្រទេសថៃ នៃជំងឺកូវីដ១៩ មានពលករចូលតាមច្រកព្រំដែនជាប់ខេត្តបាត់ដំបង ចំនួនជាង ៧៤០០នាក់ បាន បញ្ចប់ចត្តាឡីស័ក និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញជិត ៤ ០០០នាក់ និងកំពុងចត្តាឡីស័ក តាមមណ្ឌលនានាក្នុងខេត្តបាត់ដំបង ចំនួន ៣១០០ នាក់ និងបានយកសំណាកជាង ៧ ១០០នាក់ ៕ អត្ថបទ ៖ បាន សុខរិទ្ធ

## ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

### សម្ដេចតេជោ ៖ ប្រមូលមេខ្យល់ នាំមនុស្សឆ្លងដែន ខុសច្បាប់ទុកម្តុំ ចាំផុតកូវីដ-១៩ កាត់ទោស ក៏មិនទាន់ហួសពេលដែរ

https://dap-news.com/national/ ByRC105 Posted on February 20, 2021

ភ្នំពេញ ៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានចេញបញ្ជាទៅកាន់អាជ្ញាធរថា ត្រូវប្រមូលពួកមេខ្យល់នាំមនុស្សឆ្លងដែនខុសច្បាប់ទុកម្តុំ រួចហើយចាំផុតជំងឺកូវីដ-១៩ កាត់ទោសក៏មិនទាន់ហួសដែរ ខណៈសម្ដេចថា ការធ្វើបែបនេះ ដើម្បីការពារប្រជាពលរដ្ឋខ្មែរកុំឲ្យឆ្លងជំងឺកូវីដ-១៩។ តាមរយៈសារសំឡេង នៅយប់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ សម្ដេចតេជោបានថ្លែងថា «មុខសញ្ញាទាក់ទិនជាមួយនឹងពួករត់ពន្ធមនុស្ស មេខ្យល់នាំមនុស្ស និងអ្នកឆ្លងកាត់ គឺប្រមូលដាក់ម្តុំទៅ ចាំប៉ុន្មានឆ្នាំ ចាំប៉ុន្មានខែទៀត ចាំផុតកូវីដ កាត់ទោសក៏មិនទាន់យឺតពេលដែរ»។ សម្ដេចតេជោបន្តថា ការធ្វើបែបនេះគឺការពារអាយុជីវិតប្រជាជនខ្មែរ ហើយតុលាការកាត់ទោសរួច គឺបញ្ជូនទៅពន្ធនាគារតែម្តង។ សម្ដេចបញ្ជាក់សារជាថ្មីថា ឥឡូវនេះមិនឲ្យប្រជាពលរដ្ឋខ្មែរចេញទៅប្រទេសថៃឡើយ ទោះបីស្របច្បាប់ ក៏ដោយ។ សម្ដេចតេជោ បន្ថែមថា ប្រជាពលរដ្ឋខ្មែរចូលមកកម្ពុជាវិញដោយស្របច្បាប់ ត្រូវធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវផងដែរ ។ សម្ដេចផ្ដាំផ្ញើទៅអាជ្ញាធរ ត្រូវប្រមូលពួកអ្នករត់ពន្ធមនុស្សឲ្យអស់ ដើម្បីកាត់បន្ថយពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់។ សម្ដេចបញ្ជាក់ថា «នេះជាគោរពសិទ្ធិរស់រានមានជីវិត គោរពសិទ្ធិរបស់ប្រជាជនទូទាំងប្រទេស»។ ជាងនេះទៅទៀត សម្ដេចតេជោ ហ៊ុន សែន ក៏បានលើកឡើងថា ខាងខេត្តឧត្តមមានជ័យ ចំពោះអ្នក ពាក់ព័ន្ធនាំផ្លូវមនុស្សឆ្លងដែនខុសច្បាប់ គឺចាប់បានយកធ្វើចត្តាឡីស័កនៅមន្ទីរឃុំឃាំង ហើយចាំ៥ឆ្នាំទៀតកាត់ទោសក៏បានដែរ ខណៈសម្ដេចថា ចាប់ពួកមេខ្យល់ អ្នករត់ពន្ធមនុស្សអស់ហើយ ពោរគឺអស់អ្នកឆ្លងដែន។

សូមរំលឹកថា នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញវិធានការយ៉ាងតឹងរ៉ឹង ដើម្បីទប់ស្កាត់ការលួចឆ្លងដែន និងការមិនធ្វើចត្តាឡីស័ក ស្របពេលដែលជំងឺកូវីដ១៩ កំពុងរីករាលដាលយ៉ាងខ្លាំងនៅប្រទេសថៃ និងវៀតណាម។ អ្នកគេចវេសមិនធ្វើចត្តាឡីស័ក នឹងត្រូវផាកពិន័យ១លាន ទៅ៥លាន ចំណែកអ្នកសម្របសម្រួល ឬមេខ្យល់នឹងត្រូវផាកពិន័យពី១០លានទៅ៥០លានរៀលផងដែរ។ ចំណែកគ្រឹះស្ថានសុខាភិបាលឯកជន ដែលលាក់បាំង និងមិនបានជូនដំណឹងបន្ទាន់ពីអ្នកជំងឺដែលគេចវេស មិនធ្វើចត្តាឡីស័កនឹងពិន័យដូចមេខ្យល់ ផងដែរ៕

## មតិពលករខ្មែរនៅថៃ និងមន្ត្រីសិទ្ធិការងារជុំវិញការវិលត្រឡប់មកលេងស្រុកកំណើតថ្ងៃចូលឆ្នាំ

https://www.rfa.org/ ដោយ ខៃ សុណង 2021-02-19

ពលករចំណាកស្រុកដែលកំពុងធ្វើការនៅប្រទេសថៃបារម្ភ មិនបានទៅលេងផ្ទះ ឬជួបជុំសាច់ញាតិក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ខាងមុខនេះទេ ដោយសារតែវិបត្តិជំងឺកូវីដ-១៩។ សង្គមស៊ីវិលយល់ថា មានចំណុចល្អខ្លះ ប្រសិនបើពលករមិនវិលចូលស្រុកវិញក្នុងពេលនេះ។ ពលករមួយចំនួនប្រឈមបាត់បង់ការងារធ្វើនិងគ្មានកន្លែងស្នាក់នៅ ប្រសិនបើហ៊ានចេញពីស្រុកថៃ ទៅលេងស្រុកកំណើតជួបជុំគ្រួសារ ក្នុងពេលដែលប្រទេសថៃកំពុងរឹតត្បិតនិងដាក់ប្រទេសក្នុងគ្រាអាសន្ន ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩។

បុគ្គលិកផ្នែកសំអាតនៅតាមហាងសំអាងកាយ ក្នុងខេត្តឈុនបុរី លោកស្រី ទេស ស្រីយ៉ា ថ្លែងនៅថ្ងៃទី១៨ ខែកុម្ភៈ ថា លោកស្រីនឹងមិនអាចបានទៅលេងផ្ទះទេក្នុងឆ្នាំនេះ ព្រោះថៅកែនឹងមិនអនុញ្ញាតឱ្យគាត់បានចូលធ្វើការវិញឡើយ បើទោះជាលោកស្រីមានច្បាប់ការងារអាចបន្តធ្វើការបានក៏ដោយ។ លោកស្រីបន្តថា ក្នុងកាលៈទេសៈនេះ មិនអំណោយផលឱ្យគាត់ទៅផ្ទះទេ ព្រោះនៅពេលត្រឡប់មកវិញ ក្រៅតែពីគ្មានការងារធ្វើ សូម្បីតែកន្លែងស្នាក់នៅក៏គ្មានផង ព្រោះថៅកែនឹងបដិសេធពួកគាត់៖ «ខ្ញុំអត់ទៅទេឥឡូវហ្នឹងព្រោះអីការទៅហ្នឹងគេឃុំខ្លួន១៤ថ្ងៃ ហើយនៅនេះកាលដែលយើងត្រឡប់មកវិញក៏គេអត់ឱ្យត្រឡប់ដែរ បើថា នៅក្នុងប្រទេសថៃឥឡូវហ្នឹងគឺអត់អីទេ បើថាយើងចេញក្រៅប្រទេសគឺមានបញ្ហា។ ខាងខ្មែរក៏មានខាងថៃក៏មានគេអត់ទទួលយើងដូចដំបូងៗអ៊ីចឹងណា។ ទៅណាក៏ខ្លាចព្រោះអត់ដឹងអ្នកនៅខាងណោះ គេមានអីខ្លះ ការមើលថៃខាងណោះគេមើលថៃប៉ុណ្ណាអី នេះមតិខាងថៅកែថៃគេអត់ទាន់ចង់ឱ្យចេញទៅស្រុកខ្លួនឯងឥឡូវ បើថាអត់ចាំបាច់ខ្លាំង អត់មាននរណាគេឈឺ ស្លាប់អីចឹងណា ទោះថាស្លាប់ក៏សឹងថាទៅអត់ទាន់ដង្ហើមដែរ ព្រោះអីកាក់ខ្លួនយើងអត់ឱ្យទៅណាអ៊ីចឹងណា»។

ចំណែកសន្តិសុខសណ្ឋាគារនៅតំបន់ប៉ាតាយ៉ា (Pattaya) ប្រទេសថៃ លោក ម៉ាន ម មានប្រសាសន៍ថា លោកពិតជាពិបាកទ្រាំបន្តនឹករលឹកដល់ក្រុមគ្រួសារដែលនឹងជួបគ្នាមួយឆ្នាំបានតែម្តង។ ប៉ុន្តែលោកថា មិនទៀងដែរ បើសិនជាអាចលោកនឹងវិលទៅលេងគ្រួសារ ដោយប្រកាន់ខ្ជាប់នូវវិធានការការពារ និងអនាម័យឱ្យបានត្រឹមត្រូវក្នុងពេលធ្វើដំណើរ នោះនឹងអាចទប់ស្កាត់ការឆ្លងជំងឺបាន៖ «ខ្ញុំអត់មានគម្រោងបានទៅទេ ព្រោះអីជាប់ធ្វើការជាប់ការងារដែរ ប៉ុន្តែបើសិនជាថាទៅក៏ត្រូវតែទៅដែរ បើសិនជាត្រូវទៅ ព្រោះអត់មានច្បាប់ខាងរដ្ឋាភិបាលអីហាមឃាត់បានទេ អត់ទេ ឱ្យតែយើងចេះការពារសុវត្ថិភាពខ្លួនយើង។ កន្លែងទិញសំបុត្រឡានឈ្នួលថៃគេសុទ្ធតែត្រួតពិនិត្យកម្តៅមុនឡើងឡាន ថៃគេប្រយ័ត្នណាស់ គេប្រយ័ត្នជាងយើង»។

ទោះបីជាយ៉ាងណារដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង ថ្លែងថា បើគ្រាន់តែចង់មកលេងសប្បាយជួបជុំគ្រួសារក្នុងពិធីបុណ្យទេ គួរកុំទាន់មកលេង ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនូវជំងឺកូវីដ-១៩ នេះ។ លោកថ្លែងដូច្នោះនៅពេល សួរសុខទុក្ខពលករខ្មែរដែលកំពុងធ្វើចត្តាឡីស័កក្នុងខេត្តបាត់ដំបង កាលពីរសៀលថ្ងៃទី១៦ ខែកុម្ភៈ។

មន្ត្រីសិទ្ធិការងារ យល់ស្របថា មានចំណុចល្អខ្លះ ប្រសិនបើពលករមិនវិលចូលស្រុកវិញក្នុងពេលនេះ។ មន្ត្រីទទួលបន្ទុកសិទ្ធិការងារនៃអង្គការសេង់ត្រាល់ (Central) លោក ឌី ថេហ្សូយ៉ា ថ្លែងថា មានកត្តាប្រឈមសំខាន់ ៤ នោះគឺពលករនឹងចំណាយថ្លៃសោហ៊ុយធ្វើដំណើរខ្ពស់ ប្រឈមឆ្លងមេរោគពេលធ្វើដំណើរ ហើយនៅពេលត្រឡប់ចូលប្រទេសថៃវិញប្រឈមបាត់បង់ការងារ និងប្រឈមផ្លូវច្បាប់ផង ក្នុងពេលដែលប្រទេសថៃកំពុងបន្តដាក់ប្រទេសក្នុងគ្រាអាសន្ន។ ប៉ុន្តែលោកថា ចំណុចល្អនោះគឺ គាត់បានជួបជុំគ្រួសារសាច់ញាតិ បាត់ក្តីនឹករលឹក។ លោកសង្កត់ធ្ងន់ថា ការសម្រេចចិត្តយ៉ាងណានោះ គឺជាសិទ្ធិសេរីភាពរបស់ពលករះ «បើខ្ញុំវិភាគទៅលើផលវិជ្ជមាននិងអវិជ្ជមាន ខ្ញុំគិតថា បើសិនគាត់អាចទ្រាំបាននៅខ្ញុំគិតថា វាជាជម្រើសល្អសម្រាប់គាត់ដែរ ពេលដែលគាត់មកវិញមិនប្រាកដថា គាត់បានចូលមកវិញទេ ព្រោះកាលៈទេសៈគេមិនទាន់បើកប្រទេសណា ទៅវិញក្នុងន័យតាមច្រកមិនផ្លូវការ ត្រូវឱ្យលុយគេ ត្រូវប្រឈមការចាប់ពីអាជ្ញាធរអើចឹងទៅ។ តែវាជាជម្រើសរបស់គាត់ទេ ធម្មតាគាត់ចេញពីផ្ទះទៅច្រើនឆ្នាំច្រើនខែ គាត់ត្រូវនឹកត្រូវអី ជួនកាលលុយវាសំខាន់ហើយតែការចង់ជួបកូនជួបម្តាយក្នុងរដូវបុណ្យទានគឺជាជម្រើសរបស់គាត់ទេ គ្រាន់តែថាអ្វីដែលខ្ញុំលើកឡើងគឺជាចំណុចអវិជ្ជមានបើសិនជាគាត់មកមានចំណុចទាំងហ្នឹងដែលគាត់ត្រូវដឹងខ្លួនព្រោះគាត់ដឹងច្បាស់ហើយអាហ្នឹងណាបាទ»។

ក្នុងស្ថានភាពប្រទេសថៃ រងការរាតត្បាតដោយជំងឺកូវីដ-១៩ ផ្ទុះឡើងលើកទី២ អាជ្ញាធរថៃបានដាក់ប្រទេសក្នុងគ្រាអាសន្នដោយមិនកំណត់ពេលវេលាជាក់លាក់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ។ អាជ្ញាធរថៃ បានអំពាវនាវឱ្យពលករបន្តស្នាក់នៅក្នុងប្រទេស មិនឱ្យចល័តទីតាំងធ្វើការងារពីតំបន់មួយទៅតំបន់មួយនោះទេ។ ក្រសួងការងាររបស់ថៃបានបើករយៈពេលជិត១ខែឱ្យពលករបរទេសចុះឈ្មោះធ្វើកាតពណ៌ស៊ីជម្ពូ ដើម្បីមានសិទ្ធិធ្វើការងារស្របច្បាប់ទៀតផង។ ក្រសួងការងារថៃឱ្យដឹងថា ចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី១៣ កុម្ភៈ មានពលករខ្មែរជាង២សែន៣ពាន់នាក់ បានចុះឈ្មោះ។ ប៉ុន្តែនៅមានពលកររាប់សែននាក់ទៀតមិនទាន់បានចុះឈ្មោះនៅឡើយ។ ជុំវិញបញ្ហានេះ អាជ្ញាធរថៃធ្លាប់ព្រមានចាត់វិធានការលើពលករណាដែលគ្មានឯកសារច្បាប់នេះ នៅថ្ងៃបន្ទាប់ គឺចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ តទៅ។ អ្នកឃ្លាំមើលសិទ្ធិការងារនៅប្រទេសថៃ សង្កេតឃើញថា មកដល់ពេលនេះពុំទាន់ឃើញមានវិធានការពីអាជ្ញាធរថៃនៅឡើយ៕

## សមត្ថកិច្ចស្រុកស្វាយចេក ឃាត់ខ្លួនមេខ្យល់២នាក់ និងពលករចំនួន៤នាក់

https://www.kampucheathmey.com/ on February 19, 2021By Sokhom Khon

នៅវេលាម៉ោង៨ និង១៥នាទីយប់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងនគរបាលខេត្ត និងកម្លាំងនគរបាលស្រុកស្វាយចេក បានធ្វើការឃាត់រថយន្ត១គ្រឿង ម៉ាកកាម៉ារីបាឡែន ពណ៌ឆ្នូត ពាក់ស្លាកលេខ បាត់ដំបង 2A.8587 ដឹកជញ្ជូនពលករខ្មែរប្រុស ស្រី ចំនួន៤នាក់ នៅចំណុចមុខក្លោងទ្វារផ្លូវចូលភូមិតេជោភ្នំធំត្រ ស្ថិតក្នុងភូមិតេជោភ្នំធំត្រ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក ជា ស្លួញ អធិការនគរបាលស្រុកស្វាយចេក បានឲ្យដឹងថា ការឃាត់ខ្លួនមានមេខ្យល់ និងពលករនេះអនុវត្តតាមបទបញ្ជាយ៉ាងម៉ឺងម៉ាត់របស់ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងមានការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ។ លោកវរសេនីយ៍ឯក ជា ស្លួញ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា អ្នកបើករថយន្តឈ្មោះ ហ៊ឹង ពេជ្រ ភេទប្រុស អាយុ៤៣ឆ្នាំ នៅភូមិថ្នល់បំបែក ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ រថយន្ត ម៉ាកកាំម៉ារីបាឡែន ពណ៌ឆ្នូត សេរី2002 ពាក់ស្លាកលេខបាត់ដំបង2A.8587 នៅក្នុងរថយន្តមានពលករខ្មែរចំនួន៤នាក់ ស្រី២នាក់១ឈ្មោះ ម៉ៃ រ៉ុង ប្រុស អាយុ៤៣ឆ្នាំ២ឈ្មោះ កិន ឡា ភេទស្រី អយុ៣៦ឆ្នាំ ទាំង២នាក់ នៅភូមិអំពៅដៀប ឃុំ

ជ្រួយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប៣ឈ្មោះ ផុន ម៉េត ប្រុស អាយុ២០ឆ្នាំ៤ឈ្មោះ គង់ ចាន់ណាត ភេទស្រី អាយុ ២៣ឆ្នាំ ទាំង២នាក់នៅ ភូមិស្លែងស្ពាន ឃុំស្លែងស្ពាន ស្រុកស្រីស្នំ ខេត្តសៀមរាប ។ លោកវរសេនីយ៍ឯក បានបញ្ជាក់ថា ក្រោយពីឃាត់ និងសួរនាំអ្នកបើករថយន្ត និងពលករទាំង៤នាក់ កម្លាំងសមត្ថកិច្ចបានបន្តឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់បានចំនួន២នាក់ នៅលើផ្លូវជាតិលេខ៥៨ខាងជើង ភូមិក្តីបថ្ម ចម្ងាយប្រហែល២៥០ម៉ែត្រ ស្ថិតក្នុងឃុំគោករមៀត ស្រុកថ្មពួក ខេត្ត ន្ទាយមានជ័យ មាន១ឈ្មោះ ចាំ ណុយ ភេទប្រុស អាយុ៣៤ឆ្នាំ២ឈ្មោះ សរ វិត ភេទប្រុស អាយុ២២ឆ្នាំ ជនសង្ស័យទាំង២នាក់ រស់នៅភូមិថ្មល់បំបែក ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ លោកអធិការបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ជនសង្ស័យជាមេខ្យល់ទាំង២នាក់ និងអ្នកដឹកជញ្ជូន១នាក់ និងពលករខ្មែរចំនួន៤នាក់ កំពុងធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលស្រុកស្វាយចេក និងរៀបចំសំណុំរឿងបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្ត ដើម្បីមានវិធានការបន្ត ៕ អត្ថបទ ៖ វ៉ាន់ ណាង

## នគរបាលការពារព្រំដែនទឹក ចាប់ឃាត់ខ្លួនមនុស្ស៤នាក់ មានម្នាក់ជាមេខ្យល់ធំនាំពលករឆ្លងដែនខុសច្បាប់ពីប្រទេសថៃ ចូលមកកម្ពុជា

https://khmernote.com.kh/news/ ព័ត៌មានជាតិ February 19, 2021 Khmernote Media

កោះកុង÷ ដោយអនុវត្តន៍តាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងបទបញ្ជារបស់ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ចំពោះវិធានការបង្ការទប់ស្កាត់ការីករាលដាលជំងឺកូវីដ-១៩ នៅវេលាម៉ោង១ និង២៥ នាទី រំលងអាធ្រាត្រឈានចូលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ កម្លាំងល្បាតរបស់វរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ ប្រចាំខេត្តកោះកុង ចំណុះនាយកដ្ឋាននគរបាលការពារព្រំដែនទឹក បានចាប់ឃាត់ទូក១គ្រឿង និងមនុស្ស៣នាក់ ដែលលួចឆ្លងដែនពីប្រទេសថៃចូលមកប្រទេសកម្ពុជា តាមច្រកព្រំដែនទឹកខេត្តកោះកុង។

បើតាម ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ពល: ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក បានប្រាប់អោយដឹងថា នៅវេលាខាងលើកម្លាំងល្បាតរបស់វរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ ប្រចាំខេត្តកោះកុងបានធ្វើការល្បាតត្រួតពិនិត្យជួបទូក១គ្រឿង ដឹកមនុស្ស៣នាក់ ដែលលួចឆ្លងដែនខុសច្បាប់ ចេញពីខ្លងស្រ៊ុន ខេត្តត្រាត ប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមផ្លូវសមុទ្រ ហើយត្រូវបានកម្លាំងយើងធ្វើការចាប់ឃាត់នៅត្រង់ចំណុចភូមិសាស្ត្រកោះនូ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ពល: បានបញ្ជាក់ថា ជនទាំង៣នាក់ ដែលកម្លាំងវរសេនាតូចការពារព្រំដែនទឹកលេខ២៦៩ ចាប់ឃាត់ខ្លួនទី១.ង៉ែត សៀង ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ អ្នកបើកបរទូក មានទីលំនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ទី២.ឈ្មោះ លន់ ឈំ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករទូក មានទីលំនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ទី៣.ឈ្មោះ អួន វ៉ាត ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរពលកររស់នៅប្រទេសថៃ មានទីលំនៅស្រុកកំចាយមា ខេត្តព្រៃវែង។ ឯកឧត្តមប្រធាននាយកដ្ឋាន បញ្ជាក់ទៀត ក្រោយពេលចាប់ឃាត់ខ្លួនជនទាំង៣នាក់ កម្លាំងបានប្រគល់ទៅអោយក្រុមការងារចេត្តាឡីស័កខេត្តកោះកុង ដើម្បីអនុវត្តនីតិវិធីបន្ត។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ពល: បញ្ជាក់បន្តថា ក្រោយពេលចាប់ឃាត់ខ្លួនជនទាំង៣នាក់ខាងលើរួចមក នៅវេលាម៉ោង៨ និង២០នាទី ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ កម្លាំងសមត្ថកិច្ចយើងបានធ្វើការស្រាវជ្រាវ និងចាប់ឃាត់ខ្លួនមេខ្យល់ធំម្នាក់ទៀតឈ្មោះ ម៉ៅ ស៊ុនឡាយ ភេទប្រុស អាយុ៦៦ឆ្នាំ មានទីលំនៅសង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ រួចប្រគល់អោយស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីអនុវត្តនីតិវិធីបន្ត៕

## បញ្ជូនជនសង្ស័យចំនួន០៣នាក់ទៅតុលាការ ករណីដឹកជញ្ជូនពលករឆ្លងដែនដោយខុសច្បាប់ទៅប្រគល់មេខ្យល់ ទៅធ្វើការនៅប្រទេសថៃ

https://www.cen.com.kh/ February 19, 2021

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានបញ្ជូនខ្លួនមុខសញ្ញាប្រុស ស្រីចំនួន០៣នាក់ ពាក់ព័ន្ធករណីនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ត្រូវបានទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារ ប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន បានឲ្យដឹងថា៖ជនសង្ស័យទាំង០៣នាក់ មាន៖ ១-ឈ្មោះ ឈឿត ឈៀត ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅ ភូមិថ្មល់បំបែក ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ ២-ឈ្មោះ ប៊ុន សារឿត ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ ៣-ឈ្មោះ អ៊ុន សំអាត ហៅយាយញី ភេទស្រី អាយុ ៤២ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ លោកស្រី ឧត្តមសេនីយ៍ស្នងការរង បានបញ្ជាក់ថា៖ ដោយអនុវត្តតាមបទបញ្ជា របស់លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ ស្នងការនគរបាលខេត្តនិង មានការសម្របសម្រួលពីឯកឧត្តម មាស ច័ន្ទពិសិដ្ឋ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។ ជនទាំង០៣នាក់នេះត្រូវបានឃាត់ខ្លួននៅវេលាម៉ោង១២ថ្ងៃត្រង់ ថ្ងៃទី១៨ខែកុម្ភៈឆ្នាំ២០២១ ពាក់ព័ន្ធនឹងករណី នាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ទៅធ្វើការនៅប្រទេសថៃ ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ បានបញ្ជាក់បន្ថែមថា៖ នៅចំពោះមុខសមត្ថកិច្ចជនទាំង០៣នាក់ បានសារភាពថា ពួកខ្លួនពិតជាបានដឹកជញ្ជូនពលករដោយខុសច្បាប់ទៅប្រគល់មេខ្យល់ ឈ្មោះ យាយ ណយ ភេទស្រី អាយុ៤០ឆ្នាំ នៅចំណុចបឹងត្រកួន ឃុំគោករមៀត ស្រុកថ្មពួក ប្រាកដមែន ។ ដោយផ្អែកលើចម្លើយសារភាព របស់ជនសង្ស័យទាំង០៣នាក់ បច្ចុប្បន្ន កម្លាំងនគរបាលការិយាល័យបានបំពេញសំណុំរឿងបញ្ជូនទៅសលាដំបូង ខេត្តបន្ទាយមានជ័យ ចាត់ការតាមនិតិវិធីច្បាប់ ហើយដែរ ៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## ឃាត់ខ្លួនមេខ្យល់ម្នាក់បម្រុងនាំឆ្លងដែនទៅប្រទេសថៃបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ

https://gntimes.com/features/ February 20, 2021 at 2:40 pm )

បន្ទាយមានជ័យ៖ កម្លាំងមូលដ្ឋានអាវុធហត្ថក្រុងប៉ោយប៉ែត នៅវេលាម៉ោងជាង០១នាទីយប់ឈានចូលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ បានធ្វើការចុះល្បាតក្នុងភូមិសាស្ត្រក្រុង និងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ហើយបានឃាត់ខ្លួនពលករឆ្លងដែនដោយខុសច្បាប់ចំនួន០៧នាក់ នៅចំណុចមុខបុរីធីធី ស្ថិតក្នុងភូមិអូរជ្រៅ សង្កាត់/ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលពលករទាំងនោះត្រូវមេខ្យល់បម្រុងនាំឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេស។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងអាវុធហត្ថខេត្តទទួលការងារស្រាវជ្រាវ និងបង្ក្រាបបទល្មើសបានឱ្យដឹងថា ក្រោយពីសាកសួររួចពលករខាងលើបានប្រាប់ពីតម្រុយមេខ្យល់បម្រុង នឹងនាំពួកគាត់ឆ្លងដែនទៅប្រទេសថៃ។ ចំណែកពលករត្រូវបានកម្លាំងអាវុធហត្ថក្រុងបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សាព្រហ្មនិមិត្តក្នុងក្រុងប៉ោយប៉ែត។ ក្រោយពីបានធ្វើការស្រាវជ្រាវរហូតដល់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងបានឃាត់ខ្លួនមេខ្យល់ម្នាក់ឈ្មោះ យីន ផល្លា ភេទប្រុស អាយុ៣៤ឆ្នាំ និងដកហូតវត្ថុតាងរថយន្ត០១គ្រឿង ម៉ាកតូយូតាកាមេរីពណ៌បៃតងចាស់ រួចនាំមកមូលដ្ឋានអាវុធហត្ថក្រុងដើម្បីសាកសួរចម្លើយ។ លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ បាន

បន្តទៀតថា ក្រោយពីសាកសួរចម្លើយរួចជនសង្ស័យបានឆ្លើយសារភាពថា រូបគេពិតជាបានទំនាក់ទំនងជាមួយពលករទាំង០៧នាក់ ដើម្បីឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃពិតប្រាកដមែន តាមរយៈដឹកតាមរថយន្តម៉ាកកាមេរីដែលសមត្ថកិច្ចបានដកហូតខាងលើទិសដៅយកចេញតាមច្រកម៉ាឡៃ ដោយយកតម្លៃឈ្នួលដឹកក្នុងម្នាក់២០ម៉ឺនរៀល។

ដោយផ្អែកលើការឆ្លើយបំភ្លឺរបស់ពលករទាំង០៧នាក់ និងចម្លើយសារភាពរបស់ជនសង្ស័យ បច្ចុប្បន្នជនសង្ស័យឈ្មោះ ឃីន ផល្លា និងរថយន្តត្រូវបានកម្លាំងជំនាញមូលដ្ឋានអាវុធក្រុងកសាងសំណុំរឿងបញ្ជូនមកបញ្ជាការដ្ឋានអាវុធហត្ថខេត្តចាត់ការបន្តបន្ទាប់មកកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សអាវុធហត្ថខេត្ត បញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមច្បាប់ហើយនៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២១នេះ៕

## កម្លាំងចម្រុះ បានទទួលប្រជាពលរដ្ឋ ចំនួន៣ នាក់ពីយោធាថៃ បានបញ្ជូនវិលត្រឡប់ចូលប្រទេសកម្ពុជាវិញ

https://www.rdnasia.com/ ចុះផ្សាយដោយ: February 21, 2021 by Rdn.asia.com

ខេត្តបាត់ដំបង៖នា ថ្ងៃសៅរ៍ ទី២០ ខែកុម្ភៈ ឆ្នាំ២០២១វេលាម៉ោង០៣និង១០នាទីភូមិគីឡូ១៣.ឃុំសន្តិភាព.ស្រុកសំពៅ លូន.ខេត្តបាត់ដំបង.ស្ថិតក្រោយជំនោរជាយដែន ប្រជាពលរដ្ឋខ្មែរ០៣នាក់ត្រូវបានថៃបញ្ជូនមកឱ្យកម្លាំង ចម្រុះដែលឈរជើ ងនៅតាមខ្សែបន្ទាត់ព្រំដែន កម្ពុជាថៃ ចំណុចខាងលើ។សមត្ថកិច្ចបានឲ្យដឹងថា ប្រជាពលរដ្ឋ ទាំង០៣នាក់មានឈ្មោះ ដូចខាងក្រោម៖

១,ឈ្មោះភី ស្រីនិច ភេទស្រីអាយុ ២៦ឆ្នាំ ឃុំសំបូរ ស្រុកបាជា យ ខេត្តកំពង់ចាម

២,ឈ្មោះភី ស្រីនាថ ភេទស្រីអាយុ ២៨ឆ្នាំ ឃុំសំបូរ ស្រុកបា ជាយ ខេត្តកំពង់ចាម

៣,លីនស្រីនីត ៣ឆ្នាំភេទស្រី រស់នៅភូមិឃុំខាងលើត្រូវជាកូន ។ ប្រជាពលរដ្ឋ ទាំង ០៣នាក់ក្រោយពីកម្លាំងសមត្ថកិច្ចបានទទួលពីកម្លាំងយោធាថៃនឹងបានរៀបចំបញ្ជូនទៅ កាន់ មណ្ ឌលចត្តាឡីស័កនៅវិទ្យាល័យកូនភ្នំ៣២ នៅក្នុងភូមិសាស្រ្តស្រុកសំពៅលូនខេត្តបាត់ដំបង៕

## ព្រះរាជអាជ្ញា តូច សុភក្តី៖ មេខ្យល់ម្នាក់ ដែលនាំមនុស្ស៣នាក់ឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ត្រូវបានឃុំខ្លួន

http://www.freshnewsasia.com/ 2021-02-20 09:18pm

**(ឧត្តរមានជ័យ)៖** បុរសម្នាក់ ដែលពាក់ព័ន្ធនឹងករណីនាំស្រ្តី៣នាក់ លួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ត្រូវបានសមត្ថកិច្ចចាប់ខ្លួន នៅចំណុចក្រោយកាស៊ីណូ លឹម ហេង ស្ថិតក្នុងភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីវេលាម៉ោង៧៖៣០នាទីល្ងាច ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ខណៈរូបគេនាំស្រ្តី៣នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។

លោក តូច សុភក្តី ព្រះរាជអាជ្ញាខេត្តឧត្តរមានជ័យ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា បុរសជាមេខ្យល់ខាងលើមានឈ្មោះ វ៉េត ម៉េងឈួ ភេទប្រុស អាយុ២៧ឆ្នាំ មានទីលំនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ដែលត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ «ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន» ដែលអាចប្រឈមនឹងការដាក់ពន្ធនាគារពី៧ឆ្នាំដល់១៥ឆ្នាំ។

ជនត្រូវចោទខាងលើ បាននាំស្រ្តី៣នាក់បងប្អូន រួមមានទី១៖ ឈ្មោះ ខូយ ស៊ីវហេង ភេទស្រី អាយុ២៨ឆ្នាំ , ទី២៖ ឈ្មោះ ខូយ វិច្ឆិកា ភេទស្រី អាយុ ៣២ឆ្នាំ (ជាបងស្រីបង្កើតរបស់ឈ្មោះ ខូយ ស៊ីវហេង) និងទី៣៖ ឈ្មោះ ខូយ ស៊ីវហួន ភេទស្រី អាយុ ៤២ឆ្នាំ មានទីលំនៅភូមិ អូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ប្រុងឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ ឈ្មោះ វ៉េត ម៉េងឈួ បាននាំអ្នកទាំង៣ឱ្យដេីរតាមខ្លួនចូលទៅថៃ តែថៃជន្យពេលពួកគេដើរ

តាមផ្លូវមុខផ្សារស្បូវ ឆ្ពោះទៅទិសខាងជើងឈាងខាងលិច កាត់តាមដុបព្រៃតូចៗ ដល់ខាងក្រោយសំណង់អគារកំពុងសាងសង់របស់ក្រុមហ៊ុន លឹម ហេង ស្រាប់តែជួបសមត្ថកិច្ចនគរបាលការពារព្រំដែន ពេលនោះ សមត្ថកិច្ចក៏បានឃាត់ពួកខ្លួន បញ្ជូនមកកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរស្មាច់តែម្តង។ នេះបើតាមរបាយការណ៍សមត្ថកិច្ច។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១នេះ បុរសជាមេខ្យល់ខាងលើ ត្រូវបាន លោក ទ្រី សុភ័ត អនុប្រធាន និងជាចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តឧត្តរមានជ័យ បានសម្រេចឃុំខ្លួន ក្រោមការចោទប្រកាន់ពី «ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន» ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញវិធានការយ៉ាងតឹងរ៉ឹង ដើម្បីទប់ស្កាត់ការលួចឆ្លងដែន និងការមិនធ្វើចត្តាឡីស័ក ស្របពេលដែលជំងឺកូវីដ១៩ កំពុងរីករាលដាលយ៉ាងខ្លាំងនៅប្រទេសថៃ និងវៀតណាម។ អ្នកគេចវេសមិនធ្វេើចាត្តាឡីស័ក នឹងត្រូវផាកពិន័យ១លាន ទៅ៥លាន ចំណែកអ្នកសម្របសម្រួល ឬមេខ្យល់នឹងត្រូវផាកពិន័យពី១០លានទៅ៥០លានរៀលផងដែរ។ ចំណែកគ្រឹះស្ថានសុខាភិបាលឯកជន ដែលលាក់បាំង និងមិនបានជូនដំណឹងបន្ទាន់ពីអ្នកជំងឺដែលគេចវេសមិនធ្វើចត្តាឡីស័កនឹងពិន័យដូចមេខ្យល់ដែរ៕

## មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ជួយពលករខ្មែរ២៣និងកុមារ២នាក់

https://www.cen.com.kh/ February 20, 2021

ភ្នំពេញ ៖ លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់នៅព្រឹថ្ងៃទី២០ខែកុម្ភៈនេះថា ពលករនិងពលការិនីខ្មែរនិងកុមារ សរុបចំនួន២៥នាក់ ត្រូវបានអន្តរាគមន៍មកដល់ព្រលានយន្តហោះម៉ាឡេស៊ី ដើម្បីហោះមកកាន់កម្ពុជាវិញ។ សេចក្តីជូនព័ត៌មានរបស់ក្រសួងការបរទេស លើកឡើងថាដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករ ពលការិនីខ្មែរចំនួន២៣នាក់ និងកុមារ២នាក់ ដែលបានមកធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី នឹងធ្វើដំណើរទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះលេខ SQ5008 នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៥និង៣៥នាទីល្ងាចនេះ។ ក្រុមការងារស្ថានទូតបានជួយសម្របសម្រួលឯកសារ នាំទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ីជូនទៅធ្វើតេស្តកូវីដ១៩ ព្រមទាំងជូនពលករ ពលការិនី ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ៕ រក្សាសិទ្ធិដោយ៖CEN

## មេខ្យល់យកថ្លៃនាំពលករចេញពីប្រទេសថៃម្នាក់ 3300បាត ខណៈប្រទេសថៃកំពុងផ្ទុះកូវីដ ១៩ ពុំដែលធូរស្បើយ

https://www.cen.com.kh/ February 20, 2021

ភ្នំពេញ៖ ឯកឧត្តមរដ្ឋមន្ត្រី ខៀវ កាញារីទ្ធ បានរាយការណ៍ ព័ត៌មានលើបណ្តាញសង្គម facebook នៅថ្ងៃសៅរ៍នេះថា ក្រុមគ្រូពេទ្យស្រុកស្រែអំបិល នៅព្រឹកថ្ងៃទី១៩កុម្ភៈ ២០២១ ចុះអនុវត្តន៍ការងារពិនិត្យសុខភាព និងយកសំណាកជាលើកទី២ លើពលករឆ្លងដែនខុសច្បាប់ទាំង១៣នាក់។ ព្រោះតែលង់លក់និងការបោកបញ្ឆោតរបស់មេខ្យល់ ក្នុងគោលបំណងគេចវេសពីការធ្វើចត្តាឡីស័កមាត់ច្រកចាំយាម ពលករម្នាក់ ក្នុងចំណោមពលករទាំង១៣នាក់ បានរៀបរាប់ថា ពួកគាត់បានធ្វើដំណើរចេញពីស្រុកខ្លងយៃ ខេត្តត្រាត ប្រទេសថៃដោយថ្មើរជើងលើខ្នងភ្នំ(ខាវវង់) ចុះមកបន្តដំណើរតាមអូរប៉ះ សំដៅមកកំពង់ផែដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង រួចឡើងតាកស៊ីបន្តដំនើរមកស្រុកកំណើតនៅស្រែអំបិល មេខ្យល់យកថ្លៃនាំចេញ3300បាត៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ចុះពិនិត្យនិងពង្រឹងការងារនៅតាមខ្សែបន្ទាត់ព្រំដែនស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 2:03 pm 20 កុម្ភៈ 2021 100

បាត់ដំបង ៖ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង បានដឹកនាំការប្រជុំត្រួតពិនិត្យ ការងារការពារសន្តិសុខ និងការត្រួតពិនិត្យពលរដ្ឋ ចេញ-ចូល និងស្រាវជ្រាវរកមេខ្យល់ តាមខ្សែបន្ទាត់ព្រំដែន ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន នៅអធិការដ្ឋាននគរបាលស្រុកកំរៀង ដោយមានការចូលរួមពី ឯកឧត្តម ឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង កាលពីព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ។ ចូលរួមក្នុងឱកាសនេះ មានលោកមេបញ្ជាការ មេបញ្ជាការរង និងនាយប៉ុស្តិ៍ព្រំដែនចំណុះ វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ និងលេខ ៨១៧ អធិការដ្ឋាននគរបាលស្រុកសំ ពៅលូន អធិការដ្ឋាននគរបាលស្រុកកំរៀង និង ស្រុកភ្នំព្រឹក ។

ក្នុងឱកាសនេះដែរ លោកឧត្តមសេនីយ៍ទោស្នងការ បាននាំយកនូវទឹកបរិសុទ្ធ ជាអំណោយដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំអគ្គស្នងការនគរបាលជាតិ ជូនដល់វរសេនាតូចនគរបាលការពារព្រំដែនគោក លេខ ៨១៩ និង ៨១៧ ក្នុងមួយអង្គភាពទទួលបាន ទឹកបរិសុទ្ធចំនួន ៣០០យួរ និងថវិកា របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងមួយវរសេនាតូចចំនួន ១.០០០ .០០០រៀល។ ដោយឡែកអធិការដ្ឋាននគរបាលស្រុកកំរៀង ទទួលបានទឹកបរិសុទ្ធចំនួន ១៤០យួរផងដែរ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី២១ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ១១៨នាក់ ស្រី ៥២នាក់ ក្នុងនោះកុមារា ១២នាក់ កុមារី ៥នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៦នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤១នាក់ ស្រី ១៧នាក់ កុមារា ៤នាក់ កុមារី ១នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៧៧នាក់ ស្រី ៣៥នាក់ កុមារា ៨នាក់ កុមារី ៤នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ៦នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ១នាក់ កុមារីចំនួន ៣នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១១៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៤១នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៧៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយ ដោយ៖ ធូ កុសល

## កងពលតូចថ្មើរជើងលេខ៥១ បន្ថែមកម្លាំងតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ទប់ស្កាត់ពលករ លួចឆ្លងដែនខុសច្បាប់ដើម្បីការពារការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩

https://information.gov.kh/ AKP បន្ទាយមានជ័យ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១

លោកឧត្តមសេនីយ៍ត្រី សឹង្គទុំ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥១ បានប្រាប់ឱ្យដឹងកាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ថា កម្លាំងអន្តរាគមន៍ត្រូវបញ្ជូន ដាក់បន្ថែមទៅតាមគោលដៅមួយចំនួននៅតាមបន្ទាត់ព្រំដែនកម្ពុជាថៃក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យដោយសហការជាមួយកម្លាំងចម្រុះ និងអាជ្ញាធរមូលដ្ឋានក្នុងប្រតិបត្តិការបំពេញបេសកកម្មទប់ស្កាត់ពលករខ្មែរចេញពីប្រទេសលួចឆ្លងដែនដោយខុសច្បាប់គេចវេះពីការធ្វើចត្តា ឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺឆ្លងកូវីដ១៩ ចូលក្នុងសហគមន៍នោះ។ លោកឧត្តមសេនីយ៍ត្រីបញ្ជាក់ទៀតថា ការបន្ថែមកម្លាំងនេះតបតាមបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល,ថ្នាក់ដឹកនាំកងទ័ពជើងគោក,យោធភូមិភាគទី៥និងគណៈបញ្ជាការឯកភាពខេត្តសំដៅទប់ស្កាត់ឱ្យខានតែបាន ការលួចឆ្លងដែនចូលតាមគ្រប់រូបភាពគេចវេះពីការធ្វើចត្តាឡីស័ក តាមការណែនាំរបស់រាជរដ្ឋាភិបាលក៏ដូចក្រសួងសុខាភិបាល។

នៅក្នុងឱកាសចុះត្រួតពិនិត្យកម្លាំងតាមព្រំដែន លោកឧត្តមសេនីយ៍ត្រី មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ក៏បានដាក់បទបញ្ជាដល់កងកម្លាំងទាំងអស់បន្តយកចិត្តទុកដាក់ផ្លាស់ប្តូរវេនល្បាតត្រួតពិនិត្យ២៤ម៉ោងលើ២៤ម៉ោង គ្រប់បណ្តាគោលដៅ ដែលបានកំណត់ និងរកឱ្យឃើញនូវមេខ្យល់ដែលញុះញង់និងលួចនាំពលករចូលតាមគ្រប់រូបភាពដើម្បីកម្លាំងជំនាញចាត់វិធានការទៅតាមផ្លូវច្បាប់។ ទន្ទឹមនោះដែរលោកមេបញ្ជាការក៏បានថ្លែងកោតសរសើរនូវការខិតខំបំពេញការងារប្រកបដោយភាពទទួលខុសត្រូវខ្ពស់របស់កងកម្លាំងទាំងអស់ដែលបានឃាត់អ្នកលួចឆ្លងដែនបានជាបន្តបន្ទាប់។ ជាមួយនោះដែរលោកមេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១បានធ្វើការក្រើនរម្លឹកដល់កងកម្លាំងប្រដាប់អាវុធទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាសុខភាពដោយអនុវត្តអនាម័យជាប្រចាំតាមការណែនាំរបស់ក្រសួងសុខាភិបាលដើម្បីជៀសផុតពីការឆ្លងជំងឺកូវីដ១៩នោះ៕ ដោយ៖ ឈុន សារ៉ាត សម្រួលផ្សាយដោយ៖ ធូ កុសល

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃសៅរ៍ ទី២០ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៨៦នាក់ ស្រី ៤៩នាក់ ក្នុងនោះកុមារា ១១នាក់ កុមារី ៩នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៦នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។
2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤១នាក់ ស្រី ១៩នាក់ កុមារា ២នាក់ កុមារី ២នាក់។
3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៦នាក់ ស្រី ៨នាក់ កុមារា ២នាក់ កុមារី ២នាក់។
4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៦នាក់ ស្រី ១៧នាក់ កុមារា ៦នាក់ កុមារី ២នាក់។
5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ៦នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ១នាក់ កុមារីចំនួន ៣នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៨៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៦៣នាក់, ខេត្តបាត់ដំបង ចំនួន ៦នាក់ និងឧត្តរមានជ័យចំនួន ១៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

### ពលករខ្មែរ កាន់តែច្រើនបានសម្រុកចេញពីប្រទេសថៃ តាមច្រកព្រំដែន ខេត្តបាត់ដំបង

http://btv.com.kh/ 22/02/2021

បាត់ដំបង ៖ ពលករខ្មែរកាន់តែច្រើន បានសម្រុកចេញពីប្រទេសថៃ មកកាន់ស្រុកកំណើតវិញ តាមច្រកព្រំដែននានា នៃខេត្តបាត់ដំបង ខណៈមេខ្យល់ជាង២០នាក់ ត្រូវបានឃាត់ខ្លួន។ របាយការណ៍រដ្ឋបាលខេត្តបាត់ដំបង បានបង្ហាញថា កាលពីថ្ងៃទី២១ ខែកុម្ភៈ ម្សិលមិញ ពលករខ្មែរ ចំនួនជិត៣០០ នាក់ បានចាកចេញមកពីប្រទេសថៃ ឆ្លងកាត់ច្រកព្រំដែននានា នៃខេត្តបាត់ដំបងហើយបើគិតចាប់ពីមានការផ្ទុះឆ្លងរាលដាលកូវីដ១៩ ក្នុងសហគមន៍ប្រទេសថៃនោះ គឺពលករខ្មែរ មកពីប្រទេសថៃ មានចំនួនជាង ៨៤០០នាក់។ របាយការណ៍ បានឱ្យដឹងថា ពលករឆ្លងដែនមកពីថៃ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជា កំពុងផ្ទុះ ការឆ្លងរាលដាលក្នុងសហគមន៍សារជាថ្មីផងដែរនេះ គឺត្រូវបានតម្រូវឱ្យធ្វើចត្តាឡីស័កតាមកាលកំណត់ ទាំងអស់ ខណៈអ្នកបញ្ចប់ចត្តាឡីស័ក ចំនួនជាង៤៥០០នាក់ ត្រូវបានអនុញ្ញាតឱ្យចូលសហគមន៍ បាន យកសំណាកចំនួនជាង៨១០០នាក់។ បច្ចុប្បន្ន ក្នុងខេត្តបាត់ដំបង មានមណ្ឌលចត្តាឡីស័កចំនួន១១ នៅ ក្នុងស្រុកកំរៀង សំពៅលូន ភ្នំព្រឹក បវេល ថ្មគោល សំឡូត បាណន់ ឯកភ្នំ រតនមណ្ឌល ស្រុកមោងឫស្សី និងមន្ទីរពេទ្យបង្អែកខេត្ត។

ក្នុងពេលចុះផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ការឆ្លងរាលដាល កូវីដ–១៩ កាលពីម្សិលមិញ នៅ តាមស្រុកជាប់ព្រំដែនថៃ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានជំរុញបន្ថែមឱ្យអាជ្ញាធរស្រុក កំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន សហការជាមួយកងកម្លាំងការពារព្រំដែន បន្តរឹតបន្តឹងការឆ្លងដែន ដោយពិនិត្យឲ្យបានហ្មត់ចត់នូវសកម្មភាពឆ្លងដែនរបស់ពលករ ត្រូវពិនិត្យសុខភាព ធ្វើចត្តាឡីស័កពួកគេ ឲ្យបានគ្រប់គ្នា ខណៈកម្ពុជា កំពុងមានការឆ្លងកូវីដ–១៩ក្នុងសហគមន៍ជាថ្មីទៀតនោះ ។ ឯកឧត្តមអភិបាលខេត្ត បានជំរុញឱ្យអាជ្ញាធរទាំងអស់ ខិតខំជួយទប់ស្កាត់កុំឲ្យមានការ រីករាល ដាលខ្លាំងនៃកូវីដ១៩នេះ តាមរយៈវិធានការតាមចាប់ពួកមេខ្យល់ ដែលលួចនាំពលករឆ្លងដែន ខុសច្បាប់ គេចវេះពីការធ្វើចត្តាឡីស័ក ដោយបន្តអំពាវនាវពួកគេ ឲ្យអនុវត្តតាមការណែនាំ របស់រាជរដ្ឋាភិបាល និង ក្រសួងសុខាភិបាល៕ អត្ថបទ៖ បាន សុខរិទ្ធ

### ឃាត់ខ្លួនមេខ្យល់ ៧០នាក់ និងពលករគេចធ្វើចត្តាឡីស័កចំនួន ១៥១នាក់

https://www.cen.com.kh/ February 22, 2021

ភ្នំពេញៈ មេខ្យល់ដែលនាំមនុស្សឆ្លងកាត់ព្រំដែនខុសច្បាប់ គឺព្រំដែនកម្ពុជា-ថៃ-វៀតណាម ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនចំនួន ៧០នាក់ គិតចាប់ពីថ្ងៃទី១៣-២០ ខែកុម្ភៈ ឆ្នាំ២០២១។ នេះបើតាមការបញ្ជាក់របស់មន្ត្រីជាន់ខ្ពស់អគ្គស្នងការដ្ឋាននគរបាលជាតិប្រាប់ CEN នៅថ្ងៃទី២២ ខែកម្ភៈ ឆ្នាំ២០២១។

មន្ត្រីជាន់ខ្ពស់អគ្គស្នងការដ្ឋាននគរបាលជាតិបានបញ្ជាក់ថា មេខ្យល់នាំប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់ដែលសមត្ថកិច្ចចាប់ខ្លួនមានដូចជាៈ ខេត្តបន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ ប៉ៃលិន កំពត ស្វាយរៀង តាកែវ និងខេត្តកោះកុង។ មេខ្យល់បានប្រើល្បិចថ្មីដោយនាំមនុស្សឆ្លងដែនខុសច្បាប់ប្រើរូបភាពបន្លំភ្នែកសមត្ថកិច្ច ដោយបានដាក់បង្កប់មនុស្សនៅក្នុងរថយន្តដឹកផ្លែឈើ...។ មន្ត្រីដដែលបានបន្តថា ការស្វែងរក និងទប់ស្កាត់ពលករគេចវេសពីចត្តាឡីស័ក គឺគិតចាប់ពីថ្ងៃទី១៣-២០ ខែកុម្ភៈ ឆ្នាំ២០២១ មានចំនួន ១៥១នាក់ ក្នុងនោះស្រី ៦៧នាក់ និងបាន

បញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក។ ពលករដែលគេចវេសពីការធ្វើចត្តាឡីស័កមានដូចជាៈ ខេត្តបន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង ខេត្តតាកែវ ខេត្ត ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តសៀមរាប ...។

សូមជម្រាបថា កម្លាំងសមត្ថកិច្ចពាក់ព័ន្ធនៅខេត្តជាប់ព្រំដែនថៃ និងវៀតណាម បានខិតខំធ្វើការទប់ស្កាត់ពលករឆ្លងដែននខុសច្បាប់និងស្រាវជ្រាវរកមេខ្យល់ដើម្បីនាំយកមកផ្តន្ទាទោសតាមច្បាប់៕រក្សាសិទ្ធិដោយៈ ចេស្តារ

## មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច ចុះពង្រឹង និងពិនិត្យការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងពលករដែលត្រឡប់មកពីប្រទេសថៃ តាមខេត្តជាប់ព្រំដែន

http://freshnewsasia.com/ 2021-02-22 12:35pm

**(កោះកុង)៖** នាថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០២១ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោករដ្ឋមន្ត្រី វង សូត មានការចូលរួមពីអភិបាលរងខេត្ត ក្រុមការងារការពារជនរងគ្រោះ និងអន្តរក្រសួង បានចុះត្រួតពិនិត្យមើលការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើរជួញដូរមនុស្ស និងពលករដែលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិសំខាន់ៗនៅក្នុងខេត្តកោះកុង។

**ទីតាំងច្រកទ្វារអន្តរជាតិដែលសំខាន់ៗរួមមាន៖**

***ទី១៖ ច្រកអន្តរជាតិចាំយាម**

***ទី២៖ ច្រកគីរីវង្ស (ហៅច្រកខារវង្ស)**

***ទី៣៖ ច្រកកោះយ៉។**

ដើម្បីពង្រឹងការគ្រប់គ្រងស្ថានភាពមេរោគរាតត្បាតកូវីដ១៩ តាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ដែលមានការចូលរួមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងសុខាភិបាល និងអភិបាលរងខេត្តព្រមទាំងបានផ្តល់ម៉ាស ដែល អង្ករ មី ទឹកស៊ីវអ៊ីវ ទឹកត្រី ដល់ក្រុមការងារផងដែរ។

សូមជម្រាបថា គិតត្រឹមម៉ោងស៧៖០០នាទីព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១នេះ កម្ពុជារកឃើញអ្នកឆ្លងកូវីដ១៩ ថ្មីចំនួន៥៦៨នាក់ ក្នុងនោះអ្នកជាសះស្បើយចំនួន ៤៧៥នាក់ និងអ្នកជំងឺចំនួន ៩៣នាក់កំពុងសម្រាកនៅមន្ទីរពេទ្យ៕

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ អំពាវនាវឲ្យអាជ្ញាធរ និងសមត្ថកិច្ចស្រុកកំពង់សីលា ខេត្តព្រះសីហនុ រួមគ្នាទប់ស្កាត់បទល្មើសគ្រប់ប្រភេទ

http://www.freshnewsasia.com/ 2021-02-22 03:49pm

**(ព្រះសីហនុ)៖** នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ លោក កៅ ខុនដារ៉ា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ និងជាប្រធានក្រុមការងាចុះមូលដ្ឋានស្រុកកំពង់សីលា ដឹកនាំកិច្ចប្រជុំ បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ដោយមានអញ្ជើញចូលរួមពីក្រុមការងារពីថ្នាក់ជាតិថ្នាក់ក្រោមជាតិ និងមូលដ្ឋាន។ ក្នុងឱកាសនោះ លោក កៅ ខុនដារ៉ា ក្រោយពីស្តាប់ការចូលរួមមតិយោបល់ពីសមាជិកសមាជិកា នៃកិច្ចប្រជុំលើបញ្ហាមួយចំនួនមានជាអាទិ៍ ពិនិត្យ និងផ្តល់យោបល់ ឬផ្តល់ធាតុចូលបន្ថែមដល់សេចក្តីព្រាងរបាយការណ៍ និងទិសដៅសម្រាប់ឆ្នាំ២០២១ ដោយផ្តោតលើការអនុវត្តគោល

នយោបាយភូមិឃុំសង្កាត់មាន សុវត្ថិភាព ការផ្តល់សេវាសាធារណៈ ការទប់ស្កាត់វបទល្មើសគ្រប់ប្រភេទ ពិសេសគ្រឿងញៀន បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ បញ្ហាអគ្រានុកូលដ្ឋាន ស្ថិតិ ភូមិបាល ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមក លោកបានដាក់ចេញនូវសំណូមពរមួយចំនួនពាក់ព័ន្ធ និងស្ថាប័នអង្គភាពលើការងារ៖

*ទី១៖ ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយ គុណ ភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត

*ទី២៖ គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុស ច្បាប់ និងបទល្មើសគ្រប់ប្រភេទ

*ទី៣៖ មានសណ្តាប់ធ្នាប់សាធារណៈល្អ ពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

*ទី៤៖ គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេស ស្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង

*ទី៥៖ ដោះស្រាយវិវាទនៅមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការប្រកបដោយ គុណភាព និងប្រសិទ្ធភាព

*ទី៦៖ មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ

*ទី៧៖ ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺរាតត្បាត កូវីដ-១៩ ដ៏កាចសាហាវប្រកបដោយប្រសិទ្ធភាព។

ក្នុងឱកាសនោះដែរ លោក កៅ ខុនដារ៉ា បានថ្លែងអំណរគុណដល់សមាជិកសមាជិកា ក្រុមការងារទាំងអស់ដែលបានរួមគ្នាសម្រេចទទួលបាននូវលទ្ធផលគួរជាទីមោទនៈ និងសូមបន្តយកចិត្តទុកដាក់អនុវត្ត រាល់កិច្ចការដែលនៅសេសសល់ នៅថ្នាក់ស្រុក ថ្នាក់ ឃុំ និងភូមិ ដោយអនុវត្តន៍តាមសេចក្តីណែនាំលេខ ០១ សណនចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរបៀបរបប ការងារសម្រាប់ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្តក្នុងការបំពេញបេសសកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល៕

## មេខ្លោងនាំពលករឆ្លងដែនខុសច្បាប់ ៣នាក់ទៀត ត្រូវចាប់បញ្ជូនទៅតុលាការ

https://kohsantepheapdaily.com.kh/ Banteay Meanchey ២២ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ២០:១៦

ខេត្តបន្ទាយមានជ័យ៖ នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បានបញ្ជូនខ្លួនជនសង្ស័យ ដែលពាក់ព័ន្ធករណីនាំចេញ ដោយមិនស្របច្បាប់ ០៣នាក់ ( ស្រី ០១នាក់ ) ទៅសាលាដំបូងខេត្ត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា កម្លាំងសមត្ថកិច្ចបានទប់ស្កាត់ពលករឆ្លងដែនមិនស្របច្បាប់ និងស្រាវជ្រាវឃាត់មុខសញ្ញាពាក់ព័ន្ធករណីនាំចេញដោយមិនស្របច្បាប់ជាបន្តបន្ទាប់។ ជាមួយនោះជនសង្ស័យ ដែលពាក់ព័ន្ធនាំចេញដោយមិនស្របច្បាប់ ចំនួន ០៣នាក់ ត្រូវបានបញ្ជូនខ្លួន ទៅសាលាដំបូង ខេត្តបន្ទាយមានជ័យ មាន៖ ១/-ឈ្មោះ ប៉ោច គឹមស៊ឹង ភេទប្រុសអាយុ២៤ឆ្នាំ នៅភូមិស្រះលិច ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ២/-ឈ្មោះ សេន សារី ភេទប្រុសអាយុ ៣៨ឆ្នាំជាប្តីនិង៣/-ប្រពន្ធឈ្មោះវ៉ាន់ សាលី អាយុ៣៧ឆ្នាំ ទាំង០២នាក់ ស្នាក់នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ក៏ពាក់ព័ន្ធករណីនាំឆ្លងដែនមិនស្របច្បាប់ផងដែរ។

លោកស្រី ឧត្តមសេនីយ៍ស្នងការរង បានបញ្ជាក់ថា ឈ្មោះ ប៉ោច គឹមស៊ឹង នេះពាក់ព័ន្ធនិងការដឹកជញ្ជូនពលករខ្មែរចំនួន ០៩នាក់ ជាអ្នកដូរនៅផ្សារឡុងគឿ ប្រទេសថៃ បំរុងចូលតាមច្រកអូរបីជាន់ ដោយជននេះ បាន

ប្រាប់ពលករទាំងនោះថា បើមានសមត្ថកិច្ចសួរនាំ ឆ្លើយថា ទៅបន្ទាយផ្ទា រដើម្បីរួចពីការឃាត់ខ្លួន តែពេលសមត្ថកិច្ចឃាត់រថយន្តសួរនាំពលករទាំងនោះថា ពួកគាត់ទៅលក់ឥវ៉ាន់ នៅផ្សារឡុងគឿ ដោយគេយកថ្លៃជូនផ្លូវ ចំនួន ៣.០០០បាត ក្នុងម្នាក់។ ចំណែកឈ្មោះ ប៉ោច គីមស៊ីង ក្រោយពីឃាត់ និងសួរនាំ បានឆ្លើយសារភាពថា ខ្លួនបានយកថ្លៃដឹកជញ្ជូនទៅច្រកអូរបីជាន់ ក្នុង ម្នាក់ ១០ម៉ឺនរៀល ពីប៉ោយប៉ែតមក។ ចំណែក ០២នាក់ប្តីប្រពន្ធនេះ ធ្លាប់បានជូនមនុស្សឆ្លងដែន ដោយមិនស្របច្បាប់។ ជនសង្ស័យទាំង ០៣នាក់ ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធីច្បាប់៕ ដោយ៖ ណុប រក្សា

## ជនជាតិវៀតណាមនៅតែអាចលួចឆ្លងចូលកម្ពុជាបានតាមច្រកជ្រៃធំ ខេត្តកណ្តាល តាមរយៈមេខ្យល់, សមត្ថកិច្ចរាជធានីភ្នំពេញរកឃើញ៤នាក់នៅខណ្ឌកំបូល និងយកទៅធ្វើចត្តាឡីស័កនៅចាក់អង្រែ

http://www.freshnewsasia.com/ 2021-02-22 05:39pm

**(កណ្តាល)៖** ជនជាតិវៀតណាមចំនួន៤នាក់ ត្រូវបានសមត្ថកិច្ចខណ្ឌកំបូល នាំខ្លួនទៅធ្វើចត្តាឡីស័កក្រោយជនទាំង៤នាក់នេះ ឆ្លងដែនចូលកម្ពុជាតាមរយៈមេខ្យល់ដោយបង់ប្រាក់ចំនួន២០០ដុល្លារ ហើយឆ្លងចូលបានដល់ ខណ្ឌកំបូល ក៏ត្រូវបានសមត្ថកិច្ចដឹងទាន់ពេល រួចនាំខ្លួនមកធ្វើចត្តាឡីស័កនៅចាក់អង្រែ ខណ្ឌមានជ័យ។ ការរកឃើញ និងនាំខ្លួនជនជាតិវៀតណាមទាំង ៤នាក់នេះ ធ្វើឡើងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ដោយធ្វើការអន្តរាគមន៍ពីកម្លាំងអាវុធហត្ថកំបូលសហការ ជាមួយគណៈបញ្ជាការឯកភាពខណ្ឌកំបូល, ពេទ្យមណ្ឌលសុខភាពសង្កាត់បឹងធំ ចុះពិនិត្យ និងសាកសួរព័ត៌មានជនជាតិវៀតណាមទាំង៤នាក់ (ស្រី០១នាក់) ដែលទើបត្រឡប់ចូលមកកម្ពុជាពីប្រទេសវៀតណាម។

**ប្រភពព័ត៌មានបានឲ្យដឹងថា ជនជាតិវៀតណាមទាំង៤នាក់នេះ មានឈ្មោះដូចខាងក្រោម៖**

*ទី១៖ ឈ្មោះ ង្វៀង ធីយុង ភេទស្រី អាយុ៤១ឆ្នាំ

*ទី២៖ ឈ្មោះ ង្វៀង កឿង ភេទប្រុស អាយុ៤២ឆ្នាំ

*ទី៣៖ ឈ្មោះ ដូ ហ៊ូតយ ភេទប្រុស អាយុ៤៤ឆ្នាំ

*ទី៤៖ ឈ្មោះ ង្វៀង វ៉ាន់ហ្វូវ ភេទប្រុស អាយុ២៧ឆ្នាំ។ ជនជាតិវៀតណាមទាំងនេះមាន ស្រុកកំណើតភូមិតឹងភូ ឃុំតាំងប៊ិញ ស្រុកធិញប៊ិញ ខេត្តដុងថាប់។

ជនជាតិវៀតណាមទាំង ៤នាក់នេះ បានចាកចេញពីកម្ពុជាទៅវៀតណាមកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ហើយពេលទៅដល់វៀតណាមបានធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ លុះពេលត្រឡប់មកកម្ពុជា មកដល់សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ វេលាម៉ោង ៦ព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ដោយលួចឆ្លងតាមច្រករបៀង (ជ្រៃធំ) ស្រុកកោះធំ ខេត្តកណ្តាល តាមរយៈអ្នករត់ការពីវៀតណាម និងកម្ពុជា តាមឡានតូចតម្លៃ ២០០ដុល្លារ ដោយមិនបានធ្វើចត្តាឡីស័កនោះទេ។ បច្ចុប្បន្នអ្នកទាំង៤នាក់នេះ ត្រូវបានឡានពេទ្យដឹក បញ្ជូនទៅមន្ទីរពេទ្យចាក់អង្រែ ដើម្បីធ្វើចត្តាឡីស័ក។

គួរជម្រាបជូនថា អភិបាលខេត្តកណ្តាល លោកគង់ សោភ័ណ្ឌ និងអគ្គស្នងការរងនគរបាលជាតិ លោកលោកឧត្តមសេនីយ៍ឯក តេង សួន នាពេលកន្លងទៅថ្មីៗនេះ បានចេញបទបញ្ជាកងកម្លាំងនគរបាល នៃទីបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦០៥ ត្រូវយកចិត្តទុកដាក់ខ្ពស់ សហការជាមួយកម្លាំងយោធា ដាក់គោលដៅប្រចាំការ និងចេញល្បាតជាប្រចាំ ធ្វើយ៉ាងណាទប់ស្កាត់កុំអោយមានប្រជាពលរដ្ឋលួចឆ្លងដែន ក្នុងករណីពលរដ្ឋណាចង់ឆ្លងដែនជាចាំបាច់ ដាច់ខាតត្រូវអោយពួកគាត់ធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃឲ្យខានតែបាន ដើម្បី

ទប់ស្កាត់ការីករាលដាលនៃជម្ងឺកូវីដ១៩ ពីប្រទេសជិតខាង។ ប៉ុន្តែដោយសារការធ្វេសប្រហែស មិនយកចិត្តទុកដាក់ ទើបជនជាតិវៀតណាមអាចឆ្លងដែនខុសច្បាប់បានមួយសេរីយ៉ាងដូច្នេះ៕

## មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥៣ ដាក់បទបញ្ជាតឹងរ៉ឹងដល់កងកម្លាំងស៊ើបចាប់ខ្លួន មេខ្យល់នាំពលករឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 22-02-2021

ខេត្តបន្ទាយមានជ័យ៖ ស្ថិតក្នុងស្ថានភាពពលករនៅតែលួចឆ្លងដែនខុសច្បាប់ ចូលមកក្នុងទឹកដីកម្ពុជាកាន់តែច្រើន ឧត្តមសេនីយ៍ត្រី កែវ សេងលន មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥៣ បានបញ្ជាដល់កងកម្លាំងត្រូវចាត់វិធានការក្តៅស្វែងចាប់ខ្លួនពួកមេខ្យល់នាំផ្លូវពលករលួចឆ្លងដែន។ លោកបន្តថា ពួកមេខ្យល់ទាំងនោះហើយដែលនាំបញ្ហាស្មុគ្រស្មាញដល់សង្គមជាតិ ទាក់ទងទៅនឹងនាំជំងឺកូវីដ-១៩ចូលស្រុក។ លោកបញ្ជាក់ថា នៅក្នុងស្ថានភាពស្រុកទេសកំពុងតែរឹករវរដោយការឆ្លងជំងឺកូវីដ-១៩ ហើយប្រមុខរដ្ឋាភិបាលក៏បានប្រកាសឲ្យពលករឆ្លងដែនចូលតាមច្រកព្រំដែន ដែលបានកំណត់យ៉ាងណាក៏ដោយ ពួកមេខ្យល់ នៅតែនាំផ្លូវពលករលួចឆ្លងដែនខុសច្បាប់ដូច្នេះដើម្បីទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ជំងឺកូវីដ-១៩ ត្រូវតែចាប់ខ្លួនមេខ្យល់បញ្ជូនឲ្យសមត្ថកិច្ចឲ្យបាន ដើម្បីចាត់ការទៅតាមផ្លូវច្បាប់។

សូមបញ្ជាក់ថា ពលករចំណាកស្រុកភាគច្រើន ដែលលួចឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសជិតខាង ដោយសារតែមេខ្យល់នាំផ្លូវ ព្រោះពលករទាំងនោះមិនដឹងភូមិសាស្ត្រ និងគោលដៅដែលត្រូវទៅ៕

## អាជ្ញាធរថៃបន្តចាប់បញ្ជូនពលករខ្មែរជាច្រើននាក់ត្រឡប់នៅកម្ពុជាតាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា 2021-02-22

អាជ្ញាធរថៃបន្តចាប់បញ្ជូនពលករខ្មែររាប់រយនាក់ត្រឡប់ទៅកម្ពុជាវិញ តាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ ខណៈប្រទេសទាំងពីរកំពុងរឹតបន្តឹងនៅតំបន់ព្រំដែន ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលករត្រឡប់មកកម្ពុជាអំឡុងពេលនេះ អាចនឹងជួបការលំបាក ប្រសិនបើរដ្ឋាភិបាលមិនជួយរកការងារដល់ពួកគាត់។ អាជ្ញាធរខ្មែរបានបញ្ជូនពលករទាំងនោះទៅធ្វើចត្តាឡីស័កភ្លាមៗ បន្ទាប់ពីអាជ្ញាធរថៃបញ្ជូនពួកគាត់មកដល់ព្រំដែនកម្ពុជា។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកផ្នែកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២២ កុម្ភៈថា អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរជាង ២០០នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាតាមច្រករបៀងព្រំដែនក្នុងឃុំអូរបីជាន់ និងច្រករបៀងព្រំដែននៅក្នុងស្រុកម៉ាឡៃនៅព្រឹកថ្ងៃទី២២កុម្ភៈ។ បន្ថែមពីនេះ ពលករមិនអាចលួចចូលមកកម្ពុជាដោយមិនបានធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃអំឡុងពេលនេះបានឡើយ៖ «គេដឹកទៅធ្វើចត្តាឡីស័កតាមស្រុកនិងខេត្តទាំងអស់ហ្នឹងឯង។ នៅពេលពលករមកដល់គេដឹកយកទៅទាំងអស់ហ្នឹង គេអត់ទុកទេ»។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគារ យល់ថា មូលហេតុដែលពលករត្រឡប់មកកម្ពុជាអំឡុងពេលមានការរាតត្បាតជំងឺកូវីដ១៩ នេះ ដោយសារតែពួកគាត់មានជីវភាពខ្វះខាតបណ្តាលមកពីអត់ការងារធ្វើជាច្រើនខែនៅប្រទេសថៃ៖ «អ្វីដែលសំខាន់យើងឃើញថាពលករមានលក្ខណៈ២យ៉ាងដែរ ទីមួយពួកគាត់អត់ការងារធ្វើអីចឹងបើអត់ការងារធ្វើ ពួកគាត់ត្រូវត្រូវត្រឡប់មកវិញ ។បើត្រឡប់មកវិញគាត់ឱ្យគេជូនមកមានតម្លៃថ្លៃ បើសិនជាឱ្យប៉ូលិសចាប់ទៅគេបញ្ជូនមកគាត់អត់អស់លុយអីច្រើនទេ ។អីចឹងគាត់មកចូលធ្វើចត្តាឡីស័កនៅកម្ពុជាអត់មានយកលុយយកកាក់អីចឹងពួកគាត់អាចត្រឡប់មកស្រុកវិញបាន។អានេះតាមយើងបានសាកសួរពលករកន្លងមក»។

ជាមួយគ្នានេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាតាមរយៈសំឡេងសារបែកធ្លាយជាថ្មីថា អាជ្ញាធរខេត្តឧត្តរមានជ័យត្រូវទប់ស្កាត់ក្រុមមេខ្យល់លួចនាំពលរដ្ឋខ្មែរឆ្លងដែនចូលទៅប្រទេសថៃខុសច្បាប់ ក្នុងអំឡុងពេលនេះ។ លោកហ៊ុន សែន បញ្ជាក់ថា ប្រសិនបើអាជ្ញាធរចាប់បានមេខ្យល់ ត្រូវបញ្ជូនពួកគេទៅដាក់ក្នុងពន្ធនាគារ រួមចាំបញ្ជូនទៅតុលាការកាត់ទោសតាមក្រោយ៖ «អានេះជាប្រភេទជួញដូរមនុស្សកិបកេងកម្លាំងពលកម្មយកទៅធ្វើការនៅស្រុកគេហើយមិនបានប្រាក់ខែគ្រប់គ្រាន់ ត្រូវគេប្រមាណ ត្រូវគេចាប់ដាក់គុកសព្វបែបយ៉ាង។ ដូច្នេះត្រូវធ្វើកិច្ចការងារហ្នឹងឱ្យបានល្អជាមួយហ្នឹងប្រមូលជាពួកក្រុមហ្នឹងឱ្យអស់ អាហ្នឹងនាំឱ្យកាត់បន្ថយ ហើយនេះគឺជាការគោរពសិទ្ធិរស់មានជីវិតគោរពសិទ្ធិរបស់ប្រជាជនទូទាំងប្រទេសហើយ។ អីចឹងវាប៉ះពាល់ដល់អាអ្នកដែលវាមិន! ទុកឱ្យពួកអ្នកសិទ្ធិមនុស្សទៅការពារអាមនុស្សខូចម្នាក់ពីរហ្នឹងទៅ»។ បន្ថែមពីនេះមេដឹកនាំរបបក្រុងភ្នំពេញ ក៏បញ្ជាឱ្យអាជ្ញាធរខេត្តជាប់ព្រំដែនថៃ ទប់ស្កាត់មិនឱ្យពលករខ្មែរចេញ និងចូលមកកម្ពុជាដោយមិនបានធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនោះឡើយ។

អាជ្ញាធរខេត្តជាប់ព្រំដែនប្រទេសថៃ រួមមាន ខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និង ខេត្តឧត្តរមានជ័យជាដើម នៅតែបន្តដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធជាច្រើននាក់យាមការពារតឹងតែងនៅតំបន់ព្រំដែន ដើម្បីទប់ស្កាត់ពលករខ្មែរលួចឆ្លងដែនទៅលេងស្រុកកំណើត ដោយមិនបានធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ។ ចាប់តាំងពីចុងឆ្នាំ២០២០ ដល់ថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០២១ នេះមានពលករខ្មែរជាង ៣ម៉ឺន ៥ពាន់នាក់ហើយ (៣៥.៦៦៥) ហើយបានត្រឡប់មកពីធ្វើការនៅប្រទេសថៃ។ ក្នុងនោះក្រសួងសុខាភិបាល រកឃើញពលករប្រមាណ ៩០នាក់ បានឆ្លងជំងឺកូវីដ១៩។ ទោះជាយ៉ាងណាពលករខ្មែរនៅក្នុងប្រទេសថៃភាគច្រើន ជាពិសេសអ្នកធ្វើការខុសច្បាប់ កំពុងជួបវិបត្តិទូគ្រោះ គឺនៅក្នុងប្រទេសថៃអត់ការងារធ្វើដោយសារការរាតត្បាតនៃជំងឺកូវីដផង និងមិនអាចត្រឡប់មកកម្ពុជាវិញបានផង។

មន្ត្រីសិទ្ធិមនុស្សលោក ស៊ុំ ច័ន្ទគារ និយាយថា វិធានការរបស់លោក ហ៊ុន សែន នេះ អាចនឹងធ្វើឱ្យពលរដ្ឋជួបការលំបាកកាន់តែខ្លាំង ដោយសារពួកគាត់អត់ការងារធ្វើនៅក្នុងស្រុក។ មន្ត្រីសង្គមស៊ីវិលរូបនេះបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលគួរតែបញ្ជូនមន្ត្រីជំនាញពាក់ព័ន្ធចុះបង្រៀនប្រជាពលរដ្ឋធ្វើកសិកម្ម និងជួយរកទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យជូនដល់កសិករ ដើម្បីឱ្យពួកគាត់មានការងារធ្វើរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ៕

## ពលករខ្មែរនៅប្រទេសថៃត្អូញត្អែរពីផលលំបាក ក្រោយអាជ្ញាធរថៃរឹតបន្តឹង

https://www.rfa.org/khmer/ ដោយ សុជីវី 2021-02-22

ពលករខ្មែរធ្វើការនៅប្រទេសថៃ ត្អូញត្អែរពីផលលំបាករបស់ខ្លួន ក្រោយរដ្ឋាភិបាលកម្ពុជាហាមប្រាមមិនឱ្យពលកររបស់ខ្លួនឆ្លងដែនចូលទឹកដីកម្ពុជា ស្របពេលប្រទេសថៃធ្វើការរឹតបន្តឹងចំពោះពលករបរទេសខុសច្បាប់។ មន្ត្រីធ្វើការផ្នែកសិទ្ធិពលករយល់ថា រដ្ឋាភិបាលកម្ពុជាហាក់ខ្វះចន្លោះក្នុងការបំពេញការងារតាមតួនាទី និងមិនសូវយកចិត្តទុកដាក់ចំពោះទុក្ខលំបាករបស់ពលករក្រៅប្រទេសនោះទេ។ ពលករធ្វើការខុសច្បាប់នៅប្រទេសថៃមួយចំនួន កំពុងរស់នៅក្នុងជីវភាពលំបាក គ្មានការងារធ្វើ គ្មានប្រាក់ចំណូល និងបារម្ភអំពីការចាប់ខ្លួន ក្រោយរដ្ឋាភិបាលថៃចាប់ផ្ដើមចុះឆែកឆេរ ត្រួតពិនិត្យច្រើនជាងមុនលើពលករបរទេស។ ពួកគេទទូចឱ្យរដ្ឋាភិបាលកម្ពុជាជួយអន្តរាគមន៍ចំពោះពលករខ្មែរដែលកំពុងធ្វើការខុសច្បាប់នៅប្រទេសថៃនិងបន្ធូរបន្ថយការរឹតបន្តឹងតាមច្រកព្រំដែន។

ពលករខ្មែរធ្វើការនៅប្រទេសថៃលោក នួន បុណ្យ រៀបរាប់ថា លោកបានចុះបញ្ជីការងារនៅប្រទេសថៃរួចហើយ ប៉ុន្តែលោកពុំទាន់មានថៅកែដែលធានាចំពោះការងាររបស់លោក ឱ្យស្របតាមគោលការណ៍របស់រដ្ឋាភិបាលថៃនៅឡើយ។ លោកបន្តថា ការរឹតបន្តឹងរបស់រដ្ឋាភិបាលទាំង២ ធ្វើឱ្យលោកពិបាកក្នុងការរកថៅកែ ដើម្បីធានា

ចំពោះរឿងនេះ។ លោកថា អាជ្ញាធរថៃចាប់ផ្ដើមចុះត្រួតពិនិត្យជាច្រើន កន្លែងធ្វើឱ្យលោក និងពលករផ្សេងទៀត ពុំហ៊ានចេញដើរផ្ដេសផ្ដាសនោះទេ។ លោកត្អូញត្អែរថា លោកកំពុងជួបការលំបាកក្នុងជីវភាពរស់នៅ ដោយសារលោកពុំមានការងារច្បាស់លាស់មួយកន្លែងនោះទេ ពោលគឺលោកត្រូវចល័តគ្រប់កន្លែង និងមិនទៀងទាត់ដើម្បីស្វែងរកការងារធ្វើ។ លោកស្នើឱ្យរដ្ឋាភិបាលកម្ពុជា ជួយគិតគូរដល់ពលករដែលកំពុងរស់នៅប្រទេសថៃ ដែលពុំមានឯកសារការងារស្របច្បាប់ និងលាក់បំពួនដោយសារភ័យខ្លាចអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ទៅវិញ៖ «សព្វថ្ងៃនេះ ខ្ញុំនិយាយទៅចេញពីកន្លែងមួយ ចូលកន្លែងមួយ និយាយពីការងារវាមិនបានឋិតថេរ។ ទៅកន្លែងនោះក៏គ្មានការងារធ្វើ ទៅកន្លែងនេះ ក៏គ្មានការងារទេអ៊ីចឹង ហីថវិកាយើងក៏តិចតួចអ៊ីចឹង។ ខ្ញុំសុំស្នើដល់រដ្ឋាភិបាលខ្មែរហ្នឹង ដោះស្រាយពីរឿងពលករក្នុងប្រទេសថៃហ្នឹង គ្នាដាច់ការងារគ្រប់តែគ្នា។ និយាយទៅមាន ដល់គាត់អត់លុយ ហើយចាក់បានតែហូបមួយគាៗហ្នឹង»។

តំណាងពលករធ្វើការនៅប្រទេសថៃលោកស្រី ឈៀត ណៃ ថ្លែងថា ពលករជាច្រើនកំពុងធ្លាក់ខ្លួនលំបាក និងរស់នៅលាក់ពួនដោយសារខ្លាចអាជ្ញាធរថៃចាប់ខ្លួន។ លោកស្រីបន្តថា ពលករមួយចំនួន មិនមានឯកសារការងារ ដោយសាររដ្ឋាភិបាលថៃបានបិទបញ្ចប់ការចុះបញ្ជីធ្វើប័ណ្ណការងារ ខ្លះទៀតត្រូវថៅកែកិបកេងមិនបើកប្រាក់ជូនពួកគេ និងដកហូតឯកសាររបស់ពួកគេទុកជាដើម។ លោកស្រីថា អំឡុងពេលរឹតបន្តឹងនេះ ពលករជាច្រើន ត្រូវអាជ្ញាធរថៃចាប់ខ្លួន និងត្រូវបង់ប្រាក់ផាកពិន័យជាច្រើនសែនបាតឱ្យទៅប៉ូលិស ដើម្បីដោះដូរនឹងសេរីភាព ប៉ុន្តែពួកគេក្លាយជាកូនបំណុលរបស់គេទៅវិញ។ លោកស្រីទទូចឱ្យរដ្ឋាភិបាលកម្ពុជា គួរជំរុញទៅរដ្ឋាភិបាលថៃ ដើម្បីពិនិត្យ និងរៀបចំឯកសារឱ្យពលករទាំងនោះឱ្យស្របច្បាប់ឡើងវិញ ក្នុងពេលដែលមានការរឹតបន្តឹងបែបនេះ៖ «អូយ! អ្នកដែលគ្នាអត់ស្របច្បាប់ គឺជួបការលំបាកច្រើនណាស់សម័យកូវីដនេះ។ គ្នាមកគ្នាដើម្បីថា រកដោះលុយរដ្ឋ ដល់ពេលមកចេះទៅប៉ះចាប់ៗចេះទៅ ហើយ ស៊ុង (បញ្ជូន) គ្នាទៅផ្ទះវិញ គ្នាបានលុយអី? ហើយខ្ញុំ គេ បរិស័ទគេយកលុយពីខ្ញុំ ក៏ខ្ញុំក៏បង់ឱ្យគេហ្វ្រីទៅ ជាបញ្ហា អូយ!យ៉ាប់ណាស់»។

អាស៊ីសេរីបានព្យាយាមទាក់ទងទៅ អ្នកនាំពាក្យក្រសួងការបរទេសលោក កុយ គួង និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន ដើម្បីសុំការឆ្លើយតបចំពោះករណីនេះ នៅថ្ងៃទី២១ កុម្ភៈ ដោយទូរស័ព្ទចូល ប៉ុន្តែពុំមានអ្នកទទួល។

ក្រសួងការងារថៃ បានបើកឱ្យពលករបរទេសចុះឈ្មោះធ្វើប័ណ្ណស្នាក់នៅ និងធ្វើការស្របច្បាប់ក្នុងប្រទេសថៃរយៈពេល ២ឆ្នាំ ចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី១៣ ខែកុម្ភៈ។ ដំណើរការនៃការចុះឈ្មោះនេះ អាជ្ញាធរថៃតម្រូវឱ្យពលករបង់ប្រាក់ប្រមាណ ៩ពាន់បាត (៩.០០០) ស្មើនឹងប្រមាណ ៣រយដុល្លារអាមេរិក (៣០០)។ កាលបរិច្ឆេទនេះ បានផុតកំណត់ និងពលករជាច្រើនទៀតនៅតែបន្តរស់នៅខុសច្បាប់ដដែល។ រីឯរដ្ឋាភិបាលកម្ពុជាវិញ មិនបានអើពើ ឬចាត់វិធានការណាមួយ ដើម្បីជួយដល់ពលករទាំងនោះទេ ថែមទាំងចេញបទបញ្ជាថ្មីឱ្យអាជ្ញាធរនៅតាមព្រំដែន រឹតបន្តឹង និងហាមមិនឱ្យពលករខ្មែរឆ្លងដែនចូលប្រទេសខ្លួនទៅវិញ។

មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកសិទ្ធិការងារលោក ឌីថេ ហូយ៉ា ឱ្យដឹងថា អាជ្ញាធរគួរយកចិត្តទុកដាក់ចំពោះពលករដែលកំពុងរស់នៅខុសច្បាប់ក្នុងប្រទេសថៃ។ លោកបន្តថា ការហាមប្រាមមិនឱ្យពលករខ្មែរឆ្លងដែនចូលទឹកដីរបស់ខ្លួននេះ គឺជារឿងមិនសមហេតុផលនោះទេ ក្នុងពេលដែលពលករទាំងនោះកំពុងជួបបញ្ហាជាមួយអាជ្ញាធរថៃ។ លោកទទូចឱ្យរដ្ឋាភិបាលថៃគួរមានការយោគយល់បន្ថែមចំពោះពលករទាំងនោះ ដោយពន្យារពេលក្នុងការចុះបញ្ជី និងធ្វើឯកសារជូនពួកគេ ហើយពលករគួរមានភាពក្លាហានក្នុងការតស៊ូមតិ ទាមទារសិទ្ធិ និងការគាំពារពីរដ្ឋាភិបាលកម្ពុជា ហើយរដ្ឋាភិបាលកម្ពុជាគួរពង្រឹងការងារ និងការយកចិត្តទុកដាក់លើពលករបន្ថែមទៀត ដើម្បីកុំឱ្យមានការរិះគន់កាន់តែខ្លាំង៖ «ការត្រឡប់មកវិញឬមិនត្រឡប់មកវិញនេះ គឺជាជម្រើសរបស់គាត់

ឧទាហរណ៍ថា បើគាត់អត់មានការងារធ្វើ អត់មានប្រាក់ចំណូល បើមិនឱ្យគាត់ត្រឡប់មកវិញ ហើយតើគោលនយោបាយរបស់រដ្ឋហ្នឹងឆ្លើយតបការអត់មានការងារធ្វើរបស់គាត់ឬក៏អត់។ នៅថៃនេះ ខ្ញុំយល់ថា ក្នុងកាលៈទេសៈនេះថៃនៅមិនទាន់បើកប្រទេសនៅឡើយក៏ប៉ុន្តែបើសិនជាគាត់អត់មានការងារធ្វើ ហើយយើងហាមមិនឱ្យគាត់មក តើគាត់រស់នៅរបៀបម៉េច?»

អាជ្ញាធរកម្ពុជានិងថៃបានបិទច្រកទ្វារព្រំដែនប្រទេសទាំងពីរនៅខែមីនា ឆ្នាំ២០២០ ដើម្បីទប់ស្កាត់ការពតត្បាតជំងឺកូវីដ១៩ ហើយរហូតមកទល់ពេលនេះ មិនទាន់បើកដំណើរការឡើងវិញនៅឡើយទេ។ ការបិទច្រកព្រំដែននេះ បានប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់នោះ ដោយសារពួកគាត់អត់ការងារធ្វើ។ ជាមួយគ្នានេះអាជ្ញាធរខេត្តជាប់ព្រំដែនប្រទេសថៃ រួមមានខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ជាដើម បានបន្ថែមកងកម្លាំងប្រដាប់អាវុធជាច្រើននាក់ ចុះត្រួតពិនិត្យតឹងតែងនៅតំបន់ព្រំដែន ដើម្បីទប់ស្កាត់ពលករខ្មែរលួចឆ្លងដែនខុសច្បាប់ចូលកម្ពុជា ដោយពុំបានធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ។ ពលករខ្មែរឱ្យដឹងថា ពួកគាត់នៅពេលនេះ កំពុងស្ថិតក្នុងស្ថានភាពលំបាកខ្លាំងដោយរស់នៅនិងធ្វើការប្រទេសថៃមិនបាន ហើយចង់វិលទៅកម្ពុជាវិញក៏មិនកើត ប្រៀបដូចជាចុះទឹកជួបក្រពើ ឡើងលើជួបខ្លាដូច្នោះដែរ៕

## ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១

### ក្រសួងមហាផ្ទៃវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងទប់ស្កាត់សកម្មភាពប្រឆាំងការជួញដូរមនុស្សនៅខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាបៈ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងទប់ស្កាត់សកម្មភាពប្រឆាំងការជួញដូរមនុស្សនៅខេត្តសៀមរាប ដែលបានផ្តល់សុវត្ថិភាព សំដៅលើកកម្ពស់ជីវភាពរស់នៅ និងផ្តល់ការងារដល់ប្រជាពលរដ្ឋ។ ថ្លែងក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារបន្តឆ្នាំ២០២១ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃគណៈកម្មាការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ(គ ជ អ ប)មានប្រសាសន៍ថា ទោះបីសកម្មភាពជួញដូរមនុស្សនៅកម្ពុជា នៅតែកើតមាន តែសមត្ថកិច្ចពាក់ព័ន្ធបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការឆ្លើយតបបន្ទាប់ចំពោះបទល្មើសជាក់ស្តែង ដែលជនឆ្លៀតឱកាសបានបង្កើតឡើងជារូបភាពថ្មីៗ។ លោកជំទាវបញ្ជាក់ថា ខេត្តសៀមរាបក៏ជាខេត្តគំរូមួយ ក្នុងការខិតខំប្រឹងប្រែងទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់រូបភាពនៅក្នុង សង្គម ខណៈដែលខេត្តទេសចរណ៍ដ៏ល្បីល្បាញធំជាងគេនៅកម្ពុជានេះមានកម្មភាពទេសចរណ៍គ្រប់រូប ភាព ដែលងាយប្រឈមនឹងអំពើជួញដូរមនុស្ស។

សូមជម្រាបផងដែរថា ក្នុងរយៈពេលមួយឆ្នាំ២០២០កន្លងទៅ ស្នងការដ្ឋាននគរបាលខេត្តសៀមរាប កងរាជអាវុធហត្ថខេត្តនិងកម្លាំងរដ្ឋបាលពាក់ព័ន្ធ បានធ្វើការស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបានចំនួន ១៧ករណី បើប្រៀបធៀបនិងឆ្នាំ២០១៩ ថយចុះ៤ករណី ស្មើនិង២៣ភាគរយ៕

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅបន្តឆ្នាំ២០២១ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប!

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅបន្តឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ (គ.ជ.ប.ជ) ឯកឧត្តម អ៊ាន យុន ប្រធានក្រុមប្រឹក្សាខេត្ត និងវត្តមាន តំណាងសាលាដំបូងខេត្ត តំណាងព្រះរាជអាជ្ញាអយ្យការអមសាលាដំបូងខេត្ត លោក លោកស្រី ប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត អាជ្ញាធរក្រុង ស្រុក មេឃុំ-ចៅសង្កាត់ តំណាងអង្គការដៃគូជាតិ-អន្តរជាតិសរុបប្រមាណជា១៦០រូប។

ថ្លែងបើកកិច្ចប្រជុំ ឯកឧត្តម អ៊ាន យុន ប្រធានក្រុមប្រឹក្សាខេត្តមានប្រសាសន៍ថា៖ អំពើជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋមួយ ក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រទេសនានាបាននឹងកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀតអំពើជួញដូរមនុស្ស ត្រូវបានចាត់ទុកថាជាទាសភាពសម័យទំនើប ដែលមានចរិកស្មុគស្មាញប្រកបដោយល្បិចកលពាក់ព័ន្ធទៅនឹងរបត់នៃផ្នត់គំនិត ចិត្តសាស្ត្រសង្គម ការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការវិវត្តន៍នៃសេដ្ឋកិច្ច សង្គមនយោបាយជាតិ អន្តរជាតិជាដើម ដែលត្រូវការជាចាំបាច់នូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីរិះរកវិធានការ ដ៏មានប្រសិទ្ធភាពក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសពាក់ព័ន្ធ ដែលមានការចាត់តាំង និងឧក្រិដ្ឋជន ក្នុងការកាត់បន្ថយ និងឈានទៅលុបបំបាត់ឱ្យបាន។ ឯកឧត្តម សង្កត់ធ្ងន់ថា៖ឧក្រិដ្ឋជនធ្វើសកម្មភាពបទល្មើស ដោយប្រើប្រាស់គ្រប់មធ្យោបាយ និងវិធីសាស្ត្រគ្រប់រូបភាព ក្នុងគោលបំណងទុច្ចរិត ដើម្បីកេងប្រវ័ញ្ចយកផលប្រយោជន៍ពីជនរងគ្រោះ ទោះបីជាមានច្បាប់ដាក់ទោសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ឧក្រិដ្ឋជនមិនញញើតនឹងធ្វើសកម្មភាពឡើយ ឱ្យតែអាចយកផលចំណេញបាន គេនឹងធ្វើដោយមិនគិតពីការឈឺចាប់ ឬក្តីវិនាសអន្តរាយរបស់មនុស្សណាម្នាក់ឬប្រទេសជាតិណាមួយឡើយ។ ពាក់ព័ន្ធករណីនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហានេះ ហើយក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិជាច្រើន ក៏បាននិងកំពុងតែធ្វើកិច្ចការយ៉ាងសកម្ម ក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាប ដើម្បីការជួយជនរងគ្រោះ ហើយត្រូវបានផ្តន្ទាទោសជនល្មើសទៀតផង។ វេទិកានៃកិច្ចប្រជុំបានស្តាប់មតិយោបល់លើកឡើងពីចំណុចខ្លាំង និងកត្តាប្រឈម ព្រមទាំងសំណូមពរមួយចំនួនរបស់ក្រុមការងារបច្ចេកទេសចំនួន ៦ ជាសេនាធិការឱ្យគណៈកម្មាធិការខេត្តនេះ និងអង្គការសង្គមស៊ីវិលមួយចំនួនផងដែរ។

ថ្លែងបិទកិច្ចប្រជុំ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានប្រសាសន៍ថា៖ ក្នុងបរិបទជំងឺកូវីដ-១៩ បានកើតមាននូវអំពើជួញដូរមនុស្ស ក្នុងរូបភាពការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំចេញឆ្លងដែនទៅក្រៅប្រទេស និងការនាំចូលមកពីបរទេស ដែលជាសកម្មភាពខុសច្បាប់ ហើយបានជះឥទ្ធិពលមិនល្អ ក្នុងការនាំជំងឺកូវីដ-១៩ ចូលមកក្នុងប្រទេសកម្ពុជា ធ្វើឲ្យផលប៉ះពាល់ដល់សុខភាពសាធារណៈ និងអាយុជីវិតប្រជាពលរដ្ឋ។យើងសង្កេតឃើញ បទល្មើសនៅតែកើតមាន ហើយប្រជាពលរដ្ឋនៅតែបន្តរងគ្រោះជាបន្តបន្ទាប់ ដែលភាពរងគ្រោះមួយចំនួន គឺកើតឡើងនៅក្រៅប្រទេស ក្នុងពេលដែលប្រជាពលរដ្ឋធ្វើចំណាកស្រុក ជាពិសេសការធ្វើទេសន្តរប្រវេសន៍ដោយមិនមានច្បាប់ត្រឹមត្រូវ ក្នុងការស្វែងរកការងារ ទាំងការស្វែងរកគូស្រករនៅក្រៅប្រទេស។ ភាពស្មុគស្មាញនៃបទល្មើសជួញដូរមនុស្ស បានធ្វើឱ្យការអនុវត្តច្បាប់ជួបការលំបាក ក្នុងការវិភាគរកជាតុផ្សំនៃអំពើល្មើសដើម្បីបង្ក្រាប ហើយបានអូសបន្លាយឱ្យជនល្មើសរួចផុតពីការផ្តន្ទាទោស បើទោះបីមើលឃើញថា ជនទាំងនេះជាអ្នកបង្ក ឬអូសទាញឱ្យជនរងគ្រោះជួបនូវគ្រោះមហន្តរាយ ដោយការរំលោភបំពានកេងប្រវ័ញ្ច ការប្រើអំពើហិង្សា

បង្ខិតបង្ខំទាំងផ្លូវកាយ និងផ្លូវចិត្តប្រៀបបាននឹងទាសករ។ បើទោះបី យើងបានធ្វើការជំរុញផ្សព្វផ្សាយជាសាធារណៈ អប់រំទូន្មាន ដាស់តឿនក្រើនរំលឹកជាប្រចាំ យ៉ាងទូលំទូលាយ ដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែង បានដឹងបានលឺ ឬធ្លាប់បានទទួលភាពរងគ្រោះរួចហើយក្តី តែហាក់ដូចជានៅមិនទាន់បានយកចិត្តទុកដាក់ ហើយនៅតែមានអ្នកបន្តផ្សងព្រេង និងជឿលើការអូសទាញពីជនខិលខូចជាមេខ្យល់ ជាងការដាស់តឿនឱ្យប្រុងប្រយ័ត្នរបស់អាជ្ញាធរ និងអ្នកពាក់ព័ន្ធ។ លោកជំទាវ បានស្នើដល់អាជ្ញាធរគ្រប់ថ្នាក់ ធ្វើការផ្សព្វផ្សាយក៏ដូចជាដាស់តឿនដល់ប្រជាពលរដ្ឋទូទៅ កុំចាញ់បោកមេខ្យល់នាំឆ្លងដែនខុសច្បាប់បើគេចាប់បាន នោះយើង និងត្រូវជាប់ពន្ធនាគារពិសេស ក្នុងដំណាក់កាលរីករាលដាលនៃជំងឺកូវីដ- ១៩៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ចៈ អំពើជួញដូរមនុស្ស បាននិងកំពុងកើតឡើងគ្រប់ទីកន្លែង ក្នុងរូបភាពភាគច្រើន ជាឧក្រិដ្ឋកម្មឆ្លងដែន

http://www.freshnewsasia.com/ 2021-02-23 11:13am

**(សៀមរាប)៖** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានលើកឡើងថា អំពើជួញដូរមនុស្ស បាននិងកំពុងកើតឡើងគ្រប់ទីកន្លែង ក្នុងរូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន និងក្នុងប្រទេស ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះ បានជះឥទ្ធិពលជាអវិជ្ជមានដល់បុគ្គល គ្រួសារ និងសហគមន៍ ជាពិសេសទាំងនៅថ្នាក់ជាតិ តំបន់ និងពិភពលោក។ ការលើកឡើងបែបនេះធ្វើឡើងក្នុងឱកាសដែលលោក ញ៉ឹក វណ្ណារ៉ា អញ្ជើញចូលរួមក្នុងពិធីប្រគល់ទទួល សម្ភារបច្ចេកវិទ្យាសម្រាប់បន្ទប់ប្រជុំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងវគ្គបណ្តុះបណ្តាលអនឡាញទ្វេរភាគីរវាងកម្ពុជា-ថៃ ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នេះ នៅក្នុងខេត្តសៀមរាប។ លោក ញ៉ឹក វណ្ណារ៉ា បានបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងបង្កើត រៀបចំចងក្រងផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រផែនការ កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងយន្តការនានា សំដៅប្រយុទ្ធប្រឆាំង និងកាត់បន្ថយ ឲ្យបានជាអតិបរមានូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។

ដោយឡែក ក្រសួងសង្គមកិច្ច ដែលបានទទួលអណត្តិពីរាជរដ្ឋាភិបាលក្នុងការការពារ និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ ក្រសួងបានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបង្កើនភាពជាដៃគូ។ លោកថា ទោះបីក្រសួងសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏កិច្ចការពារ និងការផ្តល់សេវាជួយដល់ជនរងគ្រោះឆ្លងកាត់ព្រំដែន នៅមិនទាន់ឆ្លើយតប បានទាំងស្រុងនៅឡើយ និងនៅតែជាក្តីកង្វល់របស់រាជរដ្ឋាភិបាលកម្ពុជា អាស្រ័យដោយការសម្របសម្រួល និងការសហការរវាងកម្ពុជា ជាមួយប្រទេសគោលដៅ ក្នុងការជួយជនរងគ្រោះ ហើយការដោះស្រាយមិនទាន់គ្រប់ជ្រុងជ្រោយ និងមិនទាន់មានភាពរលូន ប្រទាក់ក្រឡាគ្នា ប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹង ស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន។ បន្ថែមពីនោះទៀត លោក ញ៉ឹក វណ្ណារ៉ា បានលើកឡើងថា ក្រសួងសង្គមកិច្ច ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល និងប្រទេសថៃ ព្រមទាំងអង្គការដៃគូអភិវឌ្ឍន៍នានា នៅកម្ពុជា ដែលបានខិតខំប្រឹងប្រែងរួមគ្នា កសាងសម្រាប់ភាគីទាំងពីរ យកទៅអនុវត្ត។ នីតិវិធីប្រតិបត្តិបទដ្ឋាននេះ ប្រកាន់ខ្ជាប់តាមក្របខណ្ឌការងារអន្តរជាតិ នៃអង្គការសហប្រជាជាតិ និងក្របខណ្ឌការងារថ្នាក់តំបន់ ដែលប្រទេសទាំងពីរបានទទួលស្គាល់ និងផ្តល់ការគាំទ្រ។

ជាពិសេសទៅទៀត នីតិប្រតិបត្តិបទដ្ឋាននេះ មានគោលបំណងសំខាន់ ដើម្បីអនុវត្តគោលការណ៍រួម ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោមទៅតាម ការអនុវត្តជាលក្ខណៈអន្តរជាតិ កំណត់អំពីតួនាទីការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធ នៃរដ្ឋភាគីទាំងពីរ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម សម្រាប់ប្រើប្រាស់ជាឯកសារយោង ដែលពាក់ព័ន្ធការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាសភាពសំខាន់ៗប្រមាណ៣០រូបប៉ុណ្ណោះ ព្រមទាំងប្រគល់សម្ភារបរិក្ខារបច្ចេកវិទ្យាជូនដល់អង្គភាពពាក់ព័ន្ធក្នុងឱកាសនោះដែរ។ លោក ញឹក វណ្ណារ៉ា ក៏បានសង្កត់ធ្ងន់ អំពីការការពារជម្ងឺកូវីដ១៩ ដោយគោរពតាមវិធានការ ការណែនាំរបស់ក្រសួងសុខាភិបាល ជាពិសេសប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺដ៏កាចសាហាវ ដែលកំពុងវាយលុកនៅក្នុងសហគមន៍នៅពេលនេះ៕

## ឃាត់ខ្លួនមេខ្យល់៧នាក់ និងពលករ២១នាក់ ក្រោយលួចឆ្លងដែនទៅប្រទេសថៃ

https://www.kampucheathmey.com/ on February 23, 2021By Sorn Phanith

ក្នុងរយៈពេល៧ថ្ងៃ នគរបាលខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនមេខ្យល់៧នាក់ និងពលករលួចឆ្លងទៅរកការងារធ្វើនៅស្រុកថៃ ២១នាក់។ កម្លាំងនគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនមេខ្យល់ជាប់ចំនួន៧ និង ឃាត់ខ្លួនពលករដែលលួចឆ្លងដែនទៅធ្វើការងារនៅស្រុកថៃ ដោយខុសច្បាប់ចំនួន២១នាក់ នៅព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យដែលត្រូវឃាត់ខ្លួនបញ្ជូនទាំង៧នាក់ ស្រី១នាក់ ក្នុងនោះក្រុងប៉ោយប៉ែត ចំនួន៣នាក់ ទី១. ឈ្មោះ ញ៉ ណាន ហៅញ៉ សង ភេទប្រុសអាយុ៤០ឆ្នាំ, ទី២. ឈ្មោះ ស៊ីង ដា ហៅរ៉ា ភេទប្រុស អាយុ៣៥ឆ្នាំ, ទី៣. ឈ្មោះ ប៉ាន់ សារួន ហៅ ជា ភេទប្រុស អាយុ៣៦ឆ្នាំ។ នៅស្រុកថ្មពួកចំនួន២នាក់ ទី១. ឈ្មោះ វ៉ាន់ ផេង ភេទប្រុស អាយុ៣៩ឆ្នាំ, ទី២. ឈ្មោះ គង់ ចក់ ភេទប្រុស អាយុ៤៧ឆ្នាំ។ ស្រុកអូរជ្រៅ ចំនួន២នាក់ ទី១.ឈ្មោះ ឡែម ឌីឡែត ភេទប្រុស អាយុ៤២ឆ្នាំ, ទី២.ឈ្មោះ លិម ពិសី ហៅម៉ាប់ ភេទស្រី អាយុ៣០ឆ្នាំ។ ចំណែកជនរងគ្រោះសមត្ថកិច្ចបានបញ្ជូននៅចត្តាឡីស័កអស់ហើយផងដែរ រីឯជនសង្ស័យសមត្ថកិច្ចបានបញ្ជូនទៅតុលាការ ដើម្បីដាក់ទោសទៅតាមផ្លូវច្បាប់អស់ហើយ ផងដែរ៕ **អត្ថបទ៖ វ៉ាន់ ណាង**

## មេខ្យល់៣នាក់ទៀត ធ្លើននិងបម្រាមអាជ្ញាធរជាប់ដុចសមត្ថកិច្ច

https://www.kampucheathmey.com/ on February 19, 2021By deth leng

មេខ្យល់ប្រុសស្រីចំនួន ៣ នាក់ទៀត ត្រូវសមត្ថកិច្ចឃាត់ខ្លួន អំឡុងពេលធ្វើសកម្មភាពលួចដឹកពលករតាមរថយន្តនៅច្រកបឹងត្រកួន ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ជនសង្ស័យទាំង ៣ ទី១ មានឈ្មោះ ឈឿត ឈៀត ភេទប្រុស អាយុ៤២ឆ្នាំ ទី២ មានឈ្មោះ ប៊ុន សារឿត ភេទប្រុស អាយុ៥៥ ឆ្នាំ និងទី ៣ មានឈ្មោះ អ៊ុន សំអាត ភេទស្រី អាយុ៤២ឆ្នាំ។ អ្នកទាំង៣ រស់នៅក្នុងឃុំគោក រមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

លោកស្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារ ប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន បានឲ្យដឹងថា ជនទាំង៣នាក់នេះត្រូវបានសមត្ថកិច្ចឃាត់ខ្លួនពីបទពាក់ព័ន្ធនិងករណីដឹកមនុស្សតាមរថយន្តទៅឲ្យមេខ្យល់នៅច្រកបឹងត្រកួនយកទៅធ្វើការនៅប្រទេសថៃខុសច្បាប់។ នៅចំពោះមុខសមត្ថកិច្ចជនទាំង៣នាក់បានសារភាពថា

ពួកគេពិតជាបានដឹកជញ្ជូនពលករទាំង៣នាក់ដោយខុសច្បាប់ទៅប្រគល់ឲ្យមេខ្យល់ ឈ្មោះយាយ ណយ ភេទស្រី អាយុ៤០ឆ្នាំ នៅចំណុចបឹងត្រកួន ឃុំគោករមៀត ស្រុកថ្មពួក ប្រាកដមែន។ ពេលនេះកម្លាំងនគរបាលការិយាល័យបានបំពេញសំណុំរឿងបញ្ជូនទៅសាលាដំបូង ខេត្តបន្ទាយមានជ័យ ចាត់ការតាមនិតិវិធីច្បាប់៕

## បញ្ជូនមេខ្យល់នាំមនុស្សឆ្លងដែនមិនស្របច្បាប់៧នាក់ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ

https://gntimes.com/ ថ្ងៃ ២៣ ខែ កុម្ភៈ , ឆ្នាំ ២០២១, (Update on February 23, 2021 at 3:31 pm)

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានបញ្ជូនខ្លួនជនសង្ស័យ៧នាក់ ស្រី០១នាក់ ពាក់ព័ន្ធករណីនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ។ ដោយមកទល់នឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ជនសង្ស័យសរុបចំនួន២១នាក់ ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឲ្យដឹងថា៖ ជនសង្ស័យដែលត្រូវឃាត់ខ្លួនបញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមច្បាប់ទាំង០៧នាក់ ស្រី០១នាក់ ។ ក្នុងនោះក្រុងប៉ោយប៉ែត ៣នាក់ មាន៖ឈ្មោះ០១/-ញ៉ ណាន ហៅញ៉ សង ភេទប្រុសអាយុ៤០ឆ្នាំ ,០២/-ឈ្មោះ ស៊ឹង ដា ហៅវ៉ា ភេទប្រុសអាយុ៣៥ឆ្នាំ,០៣/-ឈ្មោះប៉ាន់ សារួន ហៅ ដា ភេទប្រុសអាយុ៣៦ឆ្នាំ។ នៅស្រុកថ្មពួក២នាក់មាន ៖ ០១/-ឈ្មោះវ៉ាន់ ផេង ភេទប្រុសអាយុ៣៩ឆ្នាំ,០២/-ឈ្មោះគង់ ចក់ ភេទប្រុសអាយុ៤៧ឆ្នាំ។ ស្រុកអូរជ្រៅ២នាក់ មាន៖ ០១/-ឈ្មោះ ឡែម ឌីឡែត ភេទប្រុសអាយុ ៤២ឆ្នាំ ,០២/-ឈ្មោះ លិម ពិសីហៅម៉ាប់ ភេទស្រីអាយុ៣០ឆ្នាំ ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន បានបញ្ជាក់ថា៖ចាប់ពីថ្ងៃទី១៥ខែកុម្ភៈ មកទល់ពេលនេះ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យប្រុស ស្រី ដែលពាក់ព័ន្ធនិងការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែននេះ ចំនួនសរុប២១នាក់ ក្នុងនោះស្រុកអូរជ្រៅចំនួន ចំនួន០៣ករណី ឃាត់ខ្លួនជនសង្ស័យ៤នាក់ ស្រី០២នាក់ ជនរងគ្រោះ១៣នាក់ ស្រី ០៤នាក់។ ស្រុកស្វាយចេក ចំនួន០២ករណី ឃាត់ខ្លួនជនសង្ស័យ៤នាក់ ជនរងគ្រោះ៦នាក់ ស្រី០៣នាក់។ ស្រុកថ្មពួក ០៣ករណី ឃាត់ខ្លួនជនសង្ស័យ០៧នាក់ ស្រី០២នាក់ ជនរងគ្រោះចំនួន០៩នាក់ ស្រី០២នាក់។ក្រុងប៉ោយប៉ែត ០២ករណី ឃាត់ខ្លួនជនសង្ស័យ០៥នាក់ ស្រី០១នាក់ ជនរងគ្រោះចំនយន១០នាក់ ស្រី០៤នាក់។ ស្រុកម៉ាឡៃ ០១ករណី ឃាត់ខ្លួនជនសង្ស័យ០១នាក់ ជនរងគ្រោះ០៨នាក់ ស្រី០៤នាក់៕

## លោកឧត្តមសេនីយ៍ត្រី រ៉ែម រីរៈ ស្នងការរង ជម្រុញដល់កងកម្លាំងឈរតាមគោលដៅ ផ្លូវជាតិលេខ៥៨ និងបន្ទាត់ព្រំដែនបង្កើនការត្រួតពិនិត្យ

http://cambodiapolice.com/policekh/ 11:39 am 23 កុម្ភះ 2021

ខេត្តបន្ទាយមានជ័យ ៖ អនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ នៅយប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី រ៉ែម រីរៈ ស្នងការរង ទទួលផែនការងារសេនាធិការដ្ឋាន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានចុះត្រួតពិនិត្យតាមគោលដៅនីមួយៗ នៅលើដងផ្លូវជាតិលេខ៥៨ និងតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រស្រុកថ្មពួក ដែលវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ សហការជាមួយកងកម្លាំងយោធាឈរជើង ដោយចាប់ពីព្រំប្រទល់ ស្រុកបន្ទាយ

អំពិល ខេត្តឧត្តរមានជ័យ មកទល់និងព្រំប្រទល់ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ នៅក្នុងដំណើរចុះត្រួតពិនិត្យនោះ លោកឧត្តមសេនីយ៍ត្រី រ៉េម រិះ ស្នងការរង ទទួលផែនការងារសេនាធិការដ្ឋាន បានជម្រុញដល់កងកម្លាំងនគរបាលក៏ដូចជាកងកម្លាំងយោធា ដែលសហការឈរជើង តាមគោលដៅនីមួយៗនោះ ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ចំពោះការនាំចេញដោយមិនស្របច្បាប់សម្រាប់ការឆ្លងដែន និងការលួចនាំចូលប្រជាជនខ្មែរមកពីប្រទេសថៃ ដោយគេចវេះ ពីសមត្ថកិច្ចដើម្បីជៀសផុតពីការនាំខ្លួនទៅធ្វើចត្តាឡីស័ក ពីសំណាក់មេខ្យល់ ។

ក្នុងនោះដែរ លោកឧត្តមសេនីយ៍ស្នងការរង ជម្រុញឲ្យមានការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនទាំងរថយន្តលនិងអ្នករត់ម៉ូតូឌុប ដែលមានដឹកជញ្ជូនមនុស្ស ត្រូវសួរនាំឲ្យបានហ្មត់ចត់។ម្យ៉ាងវិញទៀត ត្រូវចាំឃ្លាំមើលតាមផ្លូវច្រករបៀងតូចៗ កុំឲ្យមានការលួចចេញរបស់ប្រជាពលរដ្ឋទៅថៃ បើមានប្រជាពលរដ្ឋយើងចូលមកខ្មែរវិញ ត្រូវបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័ក ដោយអប់រំណែនាំពួកគាត់ចូលរួមជាមួយការទប់ស្កាត់ការរីករាលជម្ងឺកូវីដ-១៩ ដោយអនុវត្តតាមការអំពាវនាវរបស់រាជរដ្ឋាភិបាលនិងការណែនាំ របស់ក្រសួងសុខាភិបាល ។ ទន្ទឹមនោះដែរត្រូវតែរឹតបន្តឹងតាមបន្ទាត់ព្រំដែនឲ្យបានម៉ឺងម៉ាត់ ចំពោះមេ ខ្យល់ ក៏ដូចជាអ្នកនាំផ្លូវ មិនត្រូវអត់ឱនឲ្យទេ ប្រសិនបើឃាត់ខ្លួនបានមិនត្រូវលើកលែងជាដាច់ខាត គឺត្រូវឃាត់ខ្លួនអនុវត្តតាមច្បាប់ ៕

## ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១

### សមត្ថកិច្ចចាប់មេខ្យល់នាំមនុស្សឆ្លងដែនបាន ៨០ នាក់ ក្រោយពីមានបទបញ្ជា

https://www.postkhmer.com/ ឡាយ សាមាន | Publication date 24 February 2021 | 12:20 ICT

**ភ្នំពេញៈ** អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិលោក ឆាយ គឹមខឿន បានឱ្យដឹងថា គិតត្រឹមម៉ោង ១០ ព្រឹកម្សិលមិញកម្លាំងអាជ្ញាធរមានសមត្ថកិច្ចទូទាំងប្រទេសបានឃាត់ខ្លួនមេខ្យល់ដែលនាំពលករឆ្លងព្រំដែនខុសច្បាប់ទៅប្រទេសជិតខាងបានចំនួន ៨០ នាក់ ខណៈសមត្ថកិច្ចកំពុងអនុវត្តវិធានការធ្វើចត្តាឡីស័កលើមេខ្យល់និងពលករទាំងនោះ។ ប្រតិបត្តិការនេះបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីពេលថ្មីៗនេះ បានចេញបញ្ជាយ៉ាងតឹងរ៉ឹងឱ្យចាប់មេខ្យល់ ដែលនាំពលករឆ្លងដែនខុសច្បាប់ទៅក្រៅប្រទេស ដើម្បីចូលរួមក្នុងការបង្ការការពារការឆ្លងរីករាលដាលជំងឺកូវីដ១៩។ លោក ឆាយ គឹមខឿន បានប្រាប់ភ្នំពេញប៉ុស្ដិ៍ កាលពីម្សិលមិញយ៉ាងខ្លីថា ៖ «គិតត្រឹមថ្ងៃទីម៉ោងនេះ (ថ្ងៃទី ២៣ កុម្ភៈ ម៉ោង ១០ ព្រឹក) អាជ្ញាធរពាក់ព័ន្ធបានឃាត់មេខ្យល់ចំនួន ៨០ នាក់ ហើយភាគច្រើនមេខ្យល់ទាំងនោះកំពុងធ្វើចត្តាឡីស័ក តែជាគោលការណ៍នឹងបញ្ជូនទៅធ្វើចត្តាឡីស័កទាំងអស់»។

អភិបាលរងខេត្តបាត់ដំបង លោក សឿម ប៊ុនរិទ្ធិ បានប្រាប់ភ្នំពេញប៉ុស្ដិ៍ដែរថា ក្រោយពីទទួលបានបទបញ្ជាពីលោកនាយករដ្ឋមន្ត្រី ខេត្តបាត់ដំបងឃាត់ខ្លួនមេខ្យល់បាន ៩ នាក់ និងកសាងសំណុំរឿងទៅតុលាការផងដែរ។ លោកថា៖ «មេខ្យល់ឃាត់ខ្លួនមានទាំងនាំចេញនាំចូលមេខ្យល់ខ្លះនាំប្រជាពលរដ្ឋយើងទៅធ្វើកម្លាំងពលកម្មនៅថៃ, គេសន្យាជាមួយពលរដ្ឋដែលគ្នាអត់ដឹងអីថា ទៅរកការងារតាមពិតថៃគេមិនឱ្យចូលប្រទេសគេទេ បើមានលួចចូលគេនឹងចាប់បញ្ជូនមកឱ្យសមត្ថកិច្ចយើងវិញ ហើយតែមេខ្យល់ខ្លះនាំពលករពីថៃចូលមកកម្ពុជា ដើម្បីគេចវេះពីមណ្ឌលចត្តាឡីស័ក»។ យ៉ាងណាក្ដី លោក ប៊ុនរិទ្ធិ បានបញ្ជាក់ថា ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ ចូលក្នុងសហគមន៍ ក្រុមការងារខេត្តក៏បានផ្សព្វផ្សាយពីអនុក្រឹត្យរដ្ឋាភិបាលទាក់ទងបង្កើនការផាកពិន័យលើអ្នកមិនធ្វើចត្តាឡីស័ក និងអ្នកដែលនាំរត់គេចវេះមិនធ្វើចត្តាឡីស័កដល់ពលករក៏ដូចពលរដ្ឋមូលដ្ឋានផងដែរ។ លោកថា៖ «យើងមិនត្រឹមតែចាប់មេខ្យល់ទេយើងក៏បានជួយផ្សព្វផ្សាយអនុក្រឹត្យផងដែរ ដើម្បីកុំឱ្យគាត់គេចវេះពីមណ្ឌលចត្តាឡីស័ក យើងពន្យល់គាត់កាលណារត់គេចពីមណ្ឌលចត្តាឡីស័ក មិនត្រឹមតែទទួលការពិន័យពី ១

លាន ទៅ ៥ លានរៀលទេ ហើយបើអ្នកសមគំនិតពិន័យច្រើនជាងពី ១០ ទៅ ៥០ លានរៀល ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌទៀតផង»។

ជាមួយគ្នានេះដែរ លោក លី សារី អភិបាលរងខេត្តបន្ទាយមានជ័យបានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ថា៖ «អំឡុងខែកុម្ភៈ យើងចាប់បានមេខ្យល់ទាំងអស់ ៣ នាក់ ស្រី ១ ប្រុស ២ នាក់ ក្នុងនោះប៉ូលិសចាប់បាន ២ នាក់ និងប៉េអឹមចាប់បាន ១ នាក់»។

ទាក់ទងនឹងករណីនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី ២០ កុម្ភៈ បានបញ្ជាឱ្យកម្លាំងការពារព្រំដែនរឹតបន្តឹងកុំឱ្យមានពលរដ្ឋឆ្លងដែនទោះស្របច្បាប់ក៏ដោយ។ ជាមួយគ្នានេះលោកអំពាវនាវដល់ពលករខ្មែរដែលកំពុងធ្វើការនៅថៃ ប្រសិនបើអាចកុំទាន់វិលមកកម្ពុជាអំឡុងពេលរីករាលដាលកូវីដ១៩។ លោកបានបញ្ជាក់ថា៖ «ប្រជាពលរដ្ឋរបស់យើងអាចនឹងមកចូលឆ្នាំខ្មែរក៏ផ្ដាំទៅប្រជាពលរដ្ឋរបស់យើងនៅព្រះរាជាណាចក្រថៃឱ្យបានជ្រាប បើមកក៏អត់បានចូលឆ្នាំដែរ ព្រោះអីពេលមកត្រូវធ្វើចត្តាឡីស័កនៅទល់ដែន បើថាមកមុនអត់មានបញ្ហាទេ ប៉ុន្តែបើមកដើម្បីតែចូលឆ្នាំគឺអត់បានចូលឆ្នាំទេ ច្បាស់ជាត្រូវធ្វើចត្តាឡីស័កអត់ឱ្យធ្លាយចូលមកខាងក្នុងទេ ហើយពេលត្រឡប់ទៅថៃវិញ ត្រូវធ្វើចត្តាឡីស័កនៅថៃ ១៤ ថ្ងៃ អ៊ីចឹងមកកម្ពុជាអស់ ១៤ ថ្ងៃ ទៅថៃវិញ អស់ ១៤ ថ្ងៃ អ៊ីចឹងក្មួយៗកម្មករ-កម្មការិនីរបស់យើង ពលករ-ពលការិនីនៅថៃ គឺកុំមកកម្ពុជាចូលឆ្នាំនៅថៃទៅជាការល្អ»។ លោកបានបន្តថា៖ «ចំពោះអ្នកដែលត្រឡប់មកវិញយើងមិនទទួលពលរដ្ឋយើងមិនបានព្រោះជាពលរដ្ឋរបស់យើងធ្វើដំណើរត្រឡប់មកវិញ ហើយអ៊ីចឹងយើងត្រូវតែទទួល តែយើងត្រូវធ្វើចត្តាឡីស័ក ប៉ុន្តែឆ្លងដែនពីកម្ពុជាទៅថៃពី កម្ពុជាទៅវៀតណាម កម្ពុជាទៅឡាវ យើងមិនអនុញ្ញាតឱ្យទៅទេ អ៊ីចឹងកងកម្លាំងការពារព្រំដែនទាំងអស់ត្រូវបិទមិនឱ្យមានពលករចេញទេ»៕

## យុវជន ២នាក់ លួចឆ្លងដែនទាំងយប់ ត្រូវចាប់បញ្ជូនទៅធ្វើចត្តាឡីស័ក

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៤ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ២០:៣៦

បន្ទាយមានជ័យ៖ យុវជន២នាក់ វិលត្រឡប់ពីធ្វើកម្មករ នៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ បានឆ្លងដែនតាមច្រករបៀង ត្រូវបានកម្លាំងចម្រុះ រួមមាន នគរបាលការពារព្រំដែនគោកលេខ៩១១ និងយោធាកងពលតូចលេខ៥១ ឈរជើង នៅចំណុចបន្ទាត់ព្រំដែន ក្នុងភូមិសាមគ្គីមានជ័យ សង្កាត់ និងក្រុងប៉ោយប៉ែត ឃាត់សួរនាំ និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក នៅសាលាបឋមសិក្សាព្រហ្មនិមិត្ត ក្នុងក្រុងប៉ោយប៉ែត កាលពីយប់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១។ ពលរដ្ឋទាំង ២នាក់នេះ ម្នាក់ឈ្មោះ ឡាយ ហ៊ុន ភេទប្រុស អាយុ ១៨ឆ្នាំ មានទីលំនៅ ក្នុងភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត និងម្នាក់ ឈ្មោះ លី សុជា ភេទប្រុស អាយុ ២០ឆ្នាំ មានទីលំនៅ ក្នុងភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត។ ពេលសាកសួរពលរដ្ឋទាំង ២ នាក់ ប្រាប់សមត្ថកិច្ចថា ពួកគេជាកម្មករធ្វើស្បែកជើង នៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ ទើបវិលត្រឡប់មកផ្ទះវិញ។

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្ដិ៍បឹងសាគូនៃនគរបាលការពារព្រំដែនគោក លេខ៩១១ បានប្រាប់កោះសន្តិភាព តាមទូរស័ព្ទថា ពលរដ្ឋទាំង ២នាក់នេះ ក្រោយសាកសួរ ក្រុមការងារចម្រុះ បានបញ្ជូនតាមរថយន្តយោធា ទៅមណ្ឌលចត្តាឡីស័ក សាលាបឋមសិក្សាព្រហ្មនិមិត្ត ដើម្បីដាក់ឲ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ តាមវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការការឆ្លងជំងឺកូវីដ ពីប្រទេសជិតខាង ចូលសហគមន៍។

គួរបញ្ជាក់ថា មួយរយៈចុងក្រោយនេះ ពោលគឺខណៈប្រទេសថៃ មានករណីរីករាលដាលជំងឺកូវីដ១៩ ចូលសហគមន៍កាន់តែច្រើន កម្ពុជាក៏បានដាក់ពង្រាយកម្លាំងសមត្ថកិច្ចចម្រុះតាមព្រំដែនជាច្រើន ដើម្បីទប់ស្កាត់អ្នក

លួចឆ្លងដែនខុសច្បាប់ និងឃាត់បានពលករជាបន្តបន្ទាប់ បញ្ជូនទៅធ្វើចត្តាឡីស័ក តាមមណ្ឌលនានាផងដែរ។ ដោយៈ មុត សារុន

## ថៃបញ្ជូនប្រជាពលរដ្ឋខ្មែរម្នាក់មកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារ

https://www.rasmeinews.com/ 24 February, 2021

**ដោយ: បាយ័ន / ឧត្តរមានជ័យ:** *នៅវេលាម៉ោង១៣និង៣៥នាទី ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១នេះ នៅច្រកអន្តរជាតិជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ អាជ្ញាធរថៃបានធ្វើការបញ្ជូន ប្រជាពលរដ្ឋខ្មែរម្នាក់មកស្រុកកំណើតវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ។*

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថា ប្រជាពលរដ្ឋខ្មែរម្នាក់ដែលត្រូវបានថៃធ្វើការបញ្ជូនមកស្រុកកំណើតវិញនោះគឺមានឈ្មោះ ចេង សុខៈ ភេទប្រុស អាយុ២២ឆ្នាំរស់នៅភូមិកំពង់ក្តៅ ឃុំកោះខ្ញែ ស្រុកសំបូរខេត្តក្រចេះ ហើយត្រូវបានថៃចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ ដោយចូលតាមច្រកអានសេះ ខេត្តព្រះវិហារ ហើយត្រូវបានយកទៅដាក់ពន្ធនាគារនៅខេត្តអូប៊ុន។ បន្ទាប់ពីទទួលពីភាគីថៃរួចមក ក្រុមគ្រូពេទ្យប្រចាំការនៅច្រកអន្តរជាតិជាំ បានពិនិត្យនិងវាស់កំដៅ ហើយបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សាអន្លង់វែង៕

## ពលករខ្មែរ៧នាក់ដែលគេចវេះពីការធ្វើចត្តាឡីស័ក ត្រូវសមត្ថកិច្ចតាមខ្សែបន្ទាត់ព្រំដែនធ្វើការឃាត់ខ្លួន

https://www.rasmeinews.com/ 24 February, 20210

**ដោយ: គ្រញូង / បាត់ដំបង:** *កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងអន្តរាគមន៍ឈរជើងតាមខ្សែបន្ទាត់ព្រំដែន ក្នុងស្រុកសំពៅលូន ចំណុចប៉ុស្តិ៍នគរបាលការពារព្រំដែនគោកលេខ៨១៧ (គីឡូ៩) បានឃាត់ពលករខ្មែរឆ្លងដែនមកពីប្រទេសថៃចំនួន៧នាក់ (ស្រី២នាក់រួមទាំងក្មេងប្រុសម្នាក់ផង) ស្ថិតនៅភូមិរស្មី ឃុំជ្រៃសីម៉ា ស្រុកសំពៅលូន ដែលគេចវេះមិនព្រមចូលធ្វើចត្តាឡីស័ក ហើយដឹកតាមរថយន្តយកមកកាន់មណ្ឌលចត្តាឡីស័ក ស្រុកសំពៅលូន។*

កម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកលេខ៨១៧ (គីឡូ៩) បានឲ្យដឹងថា ការឃាត់ខ្លួនពលករខ្មែរឆ្លងដែនខុសច្បាប់ទាំង៧នាក់នេះ គឺដោយមានការណែនាំពីសំណាក់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្ត ស្រុកដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ចូលទៅក្នុងសហគមន៍។ ពលករទាំង៧នាក់ ត្រូវសមត្ថកិច្ចចម្រុះដឹកតាមរថយន្តតូយ៉ូតា១បាំង ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័កស្រុកសំពៅលូន៕

## អាជ្ញាធរ ចាប់មេខ្យល់៨៩នាក់ ដែលភាគច្រើន នាំពលករគេចពីការធ្វើចត្តាឡីស័ក

https://thmeythmey.com/ 24, Feb 2021 , 6:30 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ លោក ឆាយ គឹមខឿន អគ្គស្នងការរងនិងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ អះអាងថា មេខ្យល់៨៩ ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ចេញចូលប្រទេសកម្ពុជា និងថៃ ត្រូវបានចាប់ខ្លួន ហើយក្នុងចំណោមមេខ្យល់ទាំង៨៩នាក់នោះ ភាគច្រើនបាននាំពលករគេចវេះពីការធ្វើចត្តាឡីស័ក ពេលនាំពលករចូលមកកម្ពុជា។ ក្នុងកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានថ្មីៗ លោក ឆាយ គឹមខឿន បានមានប្រសាសន៍ថា ការចាប់មេខ្យល់៨៩ទាំងនាក់នោះ (ស្រី៧នាក់) គឺគិតពីថ្ងៃទី១៣ ដល់ថ្ងៃទី២៤កុម្ភៈ ឆ្នាំ២០២១។ លោក បន្តថា ភាគច្រើននៃមេខ្យល់ទាំងនោះ គឺនាំពលករចេញចូលប្រទេសកម្ពុជានិងថៃ ហើយក្នុងនោះមានមេខ្យល់តិចជាង១០នាក់ បាននាំ

ពលករចេញចូលកម្ពុជានិងវៀតណាម។ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិរូបនេះ ថ្លែងថា៖ «មេខ្យល់ដែលឃាត់ខ្លួនបាននឹងត្រូវចាត់ការតាមផ្លូវច្បាប់។ ពួកគេទាំងនោះ ខ្លះត្រូវបានបញ្ជូនទៅតុលាការ ហើយមួយចំនួនទៀតកំពុងធ្វើចត្តាឡីស័ក»។ លោក បន្ថែមថា៖«មេខ្យល់ទាំង៨៩នាក់ហ្នឹង ជាអ្នកនាំពលករឆ្លងដែនខុសច្បាប់និងគេចពីចត្តាឡីស័ក។ ប៉ុន្តែភាគច្រើនមេខ្យល់ទាំងនោះគឺនាំពលករគេចវេះពីចត្តាឡីស័ក តែខ្ញុំមិនច្បាស់ចំនួនជាក់លាក់នោះទេ»។ ជាមួយគ្នានេះ លោក អំពាវនាវដល់ពលករទាំងអស់បញ្ឈប់ការឆ្លងដែនខុសច្បាប់និងកុំព្យាយាមគេចវេះពីការធ្វើចត្តាឡីស័ក។

អនុក្រឹត្យថ្មី ពិន័យប្រាក់ពី១០លានរៀលដល់៥០លានរៀល លើអ្នកដែលនាំអ្នកដទៃ គេចវេះពីការធ្វើចត្តាឡីស័ក។ ចំពោះអ្នកដែលគេចវេះមិនចូលធ្វើចត្តាឡីស័ក និងអ្នក គេចចេញពីការធ្វើចត្តាឡីស័ក ក្នុងអំឡុងកំពុងធ្វើចត្តាឡីស័ក នឹងត្រូវពិន័យប្រាក់ពី១លានរៀលដល់៥លានរៀល។

គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ពលរដ្ឋខ្មែរដែលវិលត្រឡប់ពីប្រទេសថៃវិញមានជាង១,៦ម៉ឺននាក់ ក្នុងនោះមានស្រីជាង៦ពាន់នាក់។ រយៈពេលដូចគ្នានេះដែរ កម្ពុជាទទួលពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ពីអាជ្ញាធរថៃបានជាង៨០០នាក់។ នេះបើតាមរបាយការណ៍ដែលសារព័ត៌មានថ្មីៗ (Thmey Thmey) ទទួលបានពីលោក កែវ វណ្ណថន អគ្គនាយករងអន្តោប្រវេសន៍៕

## លោកឧត្តមសេនីយ៍ រ៉ែម វីរៈ បន្តចុះពិនិត្យកងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ ក្នុងភូមិសាស្រ្តស្រុកម៉ាឡៃ ឈរជើងការពារនៅតាមព្រំដែន

http://cambodiapolice.com/policekh/ 12:05 pm 24 កុម្ភៈ 2021

បន្ទាយមានជ័យ ៖ នៅរសៀលថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការស្តីទីបានបន្តចុះពិនិត្យ និងសួរសុខទុក្ខកងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកងកម្លាំងយោធាក្នុងប្រតិបត្តិការទប់ស្កាត់ ការលួចឆ្លងដែន និងបង្ក្រាបមេខ្យល់ និងអ្នកនាំផ្លូវឆ្លងដែនដោយមិនស្របច្បាប់ តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្រ្ត ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ក្នុងដំណើរការចុះពិនិត្យនោះដែរ លោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ បានជំរុញដល់កងកម្លាំងទាំង០២ប្រភេទ គឺនគរបាល និងយោធា ត្រូវបង្កើនការយកចិត្តទុកដាក់ ចំពោះការលួចឆ្លងដែន ចេញ-ចូល របស់ប្រជាពលរដ្ឋទៅប្រទេសថៃ ។ ជាងនេះទៀតសោត ត្រូវស្រាវជ្រាវចំពោះមេខ្យល់ ឬអ្នកនាំផ្លូវឆ្លងដែន ១/-គឺអ្នកមេខ្យល់ឬអ្នកនាំផ្លូវប្រជាជនឆ្លងដែនទៅប្រទេសថៃ, ២/-គឺមេខ្យល់ឬអ្នកនាំផ្លូវប្រជាជនមកពីថៃចូលខ្មែរគេចវេះពីសមត្ថកិច្ចរួចផុតពីការធ្វើចត្តាឡៃស័ក ។ លោកឧត្តមសេនីយ៍ស្នងការស្តីទី បានបញ្ជាក់ចំពោះមេខ្យល់ ឬអ្នកនាំផ្លូវ ឃាត់ខ្លួនបានមិនត្រូវមានការលើកលែងនោះឡើយ ត្រូវបបញ្ជូននខ្លួនទៅការិយាល័យជំនាញរៀបចំសំណុំរឿង ចាត់ការតាមនីតិវិធីច្បាប់ ។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១នេះដែរ មុខសញ្ញានាំផ្លូវឆ្លងដែនមិនស្របច្បាប់ម្នាក់ ឈ្មោះ នួន ទុំ ភេទប្រុស អាយុ២០ឆ្នាំ នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងប្រជាពលរដ្ឋប្រុស ស្រីចំនួន០៧នាក់ ក្នុងនោះក្មេងស្រី០១នាក់ មកក្រុងប៉ោយប៉ែត ដែលមានបំណងចូលទៅប្រទេសថៃ លក់អីវ៉ាន់នៅផ្សាររុងគ្លឿ ត្រូវបានចាញ់បោកមេខ្យល់គេយក០១នាក់៣ពាន់បាត ត្រូវបានកម្លាំងនគរបាលវរ៨១៥និងកម្លាំងយោធា ប្រចាំការនៅប៉ុស្តិ៍ការពារព្រំដែនសង្កែ សហការជាមួយសមត្ថកិច្ចថៃ ធ្វើការឃាត់ខ្លួន មកសួរនាំប៉ុស្តិ៍សង្កែ ។ ទន្ទឹមនោះផងដែរ ក៏មានប្រជាពលរដ្ឋខ្មែរវិលត្រឡប់មកពីប្រទេសថៃចូលតាមច្រករបៀងប៉ុស្តិ៍ចំបក់ ឃុំបឹងបេង សរុបចំនួន២៩នាក់ ស្រី១១នាក់ និងកុមារ០២នាក់ បានធ្វើការត្រួតពិនិត្យសុខភាពដោយមានគ្រូពេទ្យ សហការជាមួយកម្លាំងនគរបាលនៅប្រចាំការទីនោះ ។

នាឱកាសនោះ លោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការស្ដីទី ក៏បានអរគុណចំពោះកិច្ចសហការរបស់សមត្ថកិច្ចថៃ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ពិសេសគឺទប់ស្កាត់ប្រជាពលរដ្ឋរងគ្រោះដោយសារចាញ់បោកមេខ្យល់ឆ្លងដែនដោយខុសច្បាប់ទាំងចូលទៅថៃ និងត្រឡប់មកខ្មែរ និង សុំឲ្យជួយសហការក្នុងស្រាវជ្រាវរកមេខ្យល់ដែលកំពុងស្នាក់នៅទឹកដីថៃ ធ្វើសកម្មភាពអូសទាញប្រជាពលរដ្ឋខ្មែរឆ្លងដែនដោយមិនស្របច្បាប់នេះ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៨៤នាក់ ស្រី ៣២នាក់ ក្នុងនោះកុមារា នាក់ ៦កុមារី ៦នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣៣នាក់ ស្រី ១៤នាក់ កុមារា ៤នាក់ កុមារី ៥នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៩នាក់ ស្រី ៧នាក់ កុមារា ២នាក់ កុមារី ១នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣២នាក់ ស្រី ១១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៨៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥២នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៣២នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួល៖ ធូ កុសល

## ពលរដ្ឋខ្មែរ ២២ នាក់ មានទាំងកុមារ ៣ នាក់ផង វិលមកដល់កម្ពុជា តាមជើងយន្តហោះពិសេស

https://www.kampucheathmey.com/ on February 25, 2021By Dy Bunnara

ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីបន្តជួយសម្របសម្រួលឱ្យពលរដ្ឋកម្ពុជាដែលមករស់នៅ និងធ្វើការដោយខុសច្បាប់ចំនួន២២នាក់ និងកុមារ៣នាក់ បានវិលត្រឡប់ទៅកម្ពុជាវិញ និងបានទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះលេខ SQ5008 នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង០៥:៣៥នាទីល្ងាច។ ការវិលត្រឡប់របស់ពួកគាត់ គឺធ្វើឡើងតាមរយៈកម្មវិធី Undocumented Migrant Recalibration Plan របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី។ នេះបើតាមការបញ្ជាក់របស់ស្ថានទូតកម្ពុជា៕

## អាជ្ញាធរខេត្តបាត់ដំបង បញ្ជូនខ្លួនពួកមេខ្យល់ ៣៩នាក់ ទៅតុលាការ ពីបទនាំពលករឆ្លងដែនខុសច្បាប់

http://btv.com.kh/ 24/02/2021

បាត់ដំបង ៖ ពួកមេខ្យល់តែងនាំពលករលួចឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ តាមច្រករបៀងនានាជាប់ខេត្តបាត់ដំបង ហើយត្រូវសមត្ថកិច្ច អាជ្ញាធរស្រុកជាប់ព្រំដែនឃាត់ខ្លួន និងបានបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ១៩ រហូតមកដល់ពេលនេះមានចំនួន ៣៩នាក់ លើសំណុំរឿង ២១ករណី ។

លោកស្រី រស់ ជីវី ស្នងការរងខេត្តបាត់ដំបង ទទួលបន្ទុកការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ពួកមេខ្យល់ទាំងអស់នោះ ភាគច្រើនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបាន នៅពេលនាំពលករលួចឆ្លងដែនខុសច្បាប់ តាមបន្ទាត់ព្រំដែនជាក់ស្តែង និងកំពុងបន្តស្វែងរកពួកមេខ្យល់មួយចំនួនទៀត។ លោកស្រីបន្តថា ការកំណត់មុខសញ្ញា និងចាប់ខ្លួនពួកមេខ្យល់ទាំងនោះមានផលលំបាកមួយចំនួនព្រោះពួកនោះមានការបំលាស់ទីមិនច្បាស់លាស់ ខណៈការចាប់ខ្លួនពួកគេ តាមរយៈនគរបាលវរៈការពារព្រំដែន កងទ័ព និងកម្លាំងកងរាជអាវុធហត្ថជាដើម ។

ក្នុងឱកាសចុះចែកអំណោយពលរដ្ឋក្រីក្រ នៅឃុំព្រះផុស ស្រុកគាស់ក្រឡ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង និងជាអនុប្រធានកិត្តិយសសាខាកាកបាទក្រហមខេត្ត បានមានប្រសាសន៍ថា ក្នុងវិធានការទប់ស្កាត់នូវការនាំពលករឆ្លងដែនខុសច្បាប់ ពីសំណាក់ពួកមេខ្យល់ទាំងអស់នោះ អាជ្ញាធរខេត្តបានបង្កើនកម្លាំង និងពង្រាយនៅតាមបន្ទាត់ព្រំដែន ដើម្បីចាប់ខ្លួន និងស្វែងរកពួកមេខ្យល់ មកផ្តន្ទាទោសតាមច្បាប់ និងមិនមានការលើកលែង ។

យោងតាមរបាយការណ៍រដ្ឋបាលខេត្តបាត់ដំបង បានបង្ហាញថា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករឆ្លងដែនមកពីប្រទេសថៃ តាមច្រកព្រំដែននានា ជាប់ខេត្តបាត់ដំបង មានចំនួន ២២៣នាក់ និងចាប់ពីមានការឆ្លងរីករាលដាលក្នុងសហគមន៍ នៃជំងឺកូវីដ១៩ នៅខេត្តសាមុទសាខន មានជិត ៩០០០នាក់ បានបញ្ចប់ចត្តាឡីស័ក និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញជាង៤៧០០នាក់ ហើយអាជ្ញាធរខេត្ត នឹងរៀបចំមណ្ឌលចត្តាឡីស័ក ២ បន្ថែម និងពង្រីកការបោះតង់ ឬធ្វើរោងនៅតាមមណ្ឌលមួយចំនួននៅតាមស្រុកជាប់ព្រំដែន ខណៈកំណើនពលករកាន់តែច្រើនឆ្លងដែនមកពីថៃ ៕ អត្ថបទ ៖ បាន សុខរិទ្ធ

## ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

### គិតត្រឹមថ្ងៃទី២៤កុម្ភៈ ឃាត់ខ្លួនពលករ គេចវេះពីការធ្វើចត្តាឡីស័កជាង៦០០នាក់

https://www.kampucheathmey.com/ on February 25, 2021By Sorn Phanith

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនិងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រសាសន៍នៅព្រឹកថ្ងៃទី២៥ កុម្ភៈនេះថា ចាប់ពីថ្ងៃទី១៣រហូតមកដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១នេះ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនពលករខ្មែរ ដែលគេចវេះពីការធ្វើចត្តាឡីស័កបានជាង៦០០នាក់ និងបានបញ្ជូនទៅធ្វើចត្តាឡីស័កវិញនៅទូទាំងប្រទេស។ លោកឧត្តមសេនីយ៍ឯក បានបន្តថា ក្នុងចំណោមពលករគេចវេះពីការធ្វើចត្តាឡីស័កជាង៦០០នាក់នោះភាគច្រើនឆ្លងពីប្រទេសវៀតណាម ដោយសារពួកគាត់ស្គាល់ភូមិសាស្ត្រច្បាស់លាស់។ ជាក់ស្តែងគ្រាន់តែថ្ងៃទី២៣កុម្ភៈ មានពលករខ្មែរឆ្លងដែនតាមព្រំដែនវៀតណាមជិត៣០០នាក់។ ចំណែកព្រំដែនកម្ពុជាថៃវិញបានធ្លាក់ចុះជាបណ្តើរៗហើយបន្ទាប់ពីមានការបង្ក្រាបទៅលើពួកមេខ្យល់ដែលនាំពលករចូលកម្ពុជារួចមក។ លោក

ឧត្តមសេនីយ៍ឯក បានបន្តទៀតថា ចាប់ពីថ្ងៃទី១៣រហូតមកដល់ថ្ងៃទី២៤កុម្ភៈសមត្ថកិច្ច បានចាប់មេខ្យល់ ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ចេញចូលប្រទេសកម្ពុជាចំនួន៨៩នាក់ ទៅផ្តន្ទាទោសទៅតាមផ្លូវច្បាប់។ លោកឧត្តមសេនីយ៍ឯក បានបន្ថែមទៀតថា ការចាប់មេខ្យល់៨៩នាក់នោះ ភាគច្រើននាំពលករចេញចូលប្រទេសកម្ពុជានិងថៃ។ ចំណែកមេខ្យល់នាំពលករចេញចូលកម្ពុជានិងវៀតណាមវិញ មានតិចជាង១០នាក់ប៉ុណ្ណោះ។

យ៉ាងណាក៏ដោយ លោកឧត្តមសេនីយ៍ឯក ឆាយគឹមខឿន បានបញ្ជាក់ថា បន្ទាប់ពីរាជរដ្ឋាភិបាលចាត់វិធានការក្តៅទៅលើពួកមេខ្យល់រួចមកឃើញថា ការនាំពលករចូលមកកម្ពុជាតាមព្រំដែនកម្ពុជាថៃ ហាក់មានការថមថយច្រើន។ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានអំពាវនាវដល់ពលករទាំងអស់ សូមបញ្ឈប់ការឆ្លងដែនខុសច្បាប់និងកុំព្យាយាមគេចវេះពីការធ្វើចត្តាឡីស័ក ដើម្បីចៀសវាងការទទួលការផាកពិន័យនិងទោសទណ្ឌតាមផ្លូវច្បាប់។

គួរបញ្ជាក់ថា យោងតាមអនុក្រឹត្យថ្មីបានពិន័យប្រាក់ពី១០លានរៀលដល់៥០លានរៀល ចំពោះអ្នកដែលនាំអ្នកដទៃ គេចវេះពីការធ្វើចត្តាឡីស័ក។ ចំពោះអ្នកដែលគេចវេះមិនចូលធ្វើចត្តាឡីស័ក និងអ្នកគេចចេញពីការធ្វើចត្តាឡីស័ក ក្នុងអំឡុងកំពុងធ្វើចត្តាឡីស័ក នឹងត្រូវពិន័យប្រាក់ពី១លានរៀលដល់៥លានរៀល៕ **អត្ថបទ៖ សំអឿន**

## អភិបាលខេត្តកោះកុង បញ្ជាឱ្យមន្ត្រីតាមព្រំដែនស្វែងរកមេខ្យល់ ករណីនាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://www.freshnewsasia.com/ 2021-02-25 11:58am

(កោះកុង)៖ លោកស្រី មិថុនា ភូថង អភិបាលកោះកុង បានបញ្ជាឱ្យកងកម្លាំងនគរបាល ទាហាន និងមន្ត្រីពាក់ព័ន្ធដែលឈរជើងនៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីស្វែងរកនិងរកមុខក្រុមមេខ្យល់ទាំងឡាយណា ដែលបន្តសកម្មភាពលួចនាំពលករខ្មែរឆ្លងដែន ដោយខុសច្បាប់ចូលក្នុងប្រទេសថៃ។ ការចេញបទបញ្ជាយ៉ាងតឹងម៉ឹងម៉ាត់បែបនេះ របស់ស្រីអភិបាលខេត្តកោះកុង ធ្វើឡើងខណៈមានក្រុមមេខ្យល់នៅតែបន្តសកម្មភាពរបស់ខ្លួន ដើម្បីលួចនាំពលករខ្មែរឆ្លងដែនដោយប្រថុយប្រថានទៅប្រទេសថៃ ខណៈដែលប្រទេសថៃ កំពុងតែ្របរិបត្តិរាតត្បាតជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ជាដើម។ បទបញ្ជានេះបានធ្វើឡើងនារសៀលថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងឱកាសដែលលោកស្រី បានចុះពិនិត្យតាមប៉ុស្តិ៍រសេនាតូចការពារព្រំដែនគោក៨២៧ និង១៩៩ ដែលឈរជើងការពារខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងស្រុកមណ្ឌលសីមា។

លោកស្រីអភិបាលខេត្តកោះកុង បានបញ្ជាយ៉ាងដូច្នេះថា៖ «**កម្លាំងនគរបាលដែលឈរជើង នៅតាមច្រកធម្មជាតិត្រូវមានគោលជំហរឱ្យបានរឹងមាំចំពោះពលករចំណាកស្រុកដែលលួចឆ្លងដែនវិលចូលស្រុកវិញ តាមច្រកធម្មជាតិ ដើម្បីជៀលវាងការនាំជំងឺកូវីដ-១៩ ដែលជាជំងឺឆ្លងសកលឆ្លងចូលក្នុងសហគមន៍។ ដូច្នេះបើមានពលករចំណាកស្រុកឆ្លងកាត់តាមច្រកធម្មជាតិ ត្រូវឃាត់គាត់ទុកសួរនាំសិន ហើយត្រូវបញ្ជូនគាត់ឱ្យមន្ត្រីសុខាភិបាលដើម្បីធ្វើតេស្តចត្តាឡែស័ករយៈ១៤ថ្ងៃសិន**»។ លោកស្រីអភិបាលខេត្ត បានបន្តថា «**សមត្ថកិច្ចទាំងអស់ដែលឈរជើងតាមប៉ុស្តិ៍នីមួយៗ បើមានពលករឆ្លងដែនតាមច្រកប៉ុស្តិ៍របស់ខ្លួនត្រូវឃាត់ខ្លួនពលករចំណាកស្រុកដែលវិលចូលស្រុកវិញឬពលករលួចឆ្លងដែនចូលប្រទេសថៃ ត្រូវសួរនាំរកមេខ្យល់ដែលនាំពលករទាំងអស់នោះឱ្យឃើញ ដើម្បីសមត្ថកិច្ចមានចំណាត់ការតាមនីតិវិធីច្បាប់**»។ លោកស្រី មិថុនា ភូថង បានគូសបញ្ជាក់ថា «**សមត្ថកិច្ចទាំងអស់សូមកុំឱ្យមានការធ្វេសប្រហែសឱ្យសោះពីព្រោះយើងបានដឹងហើយថាជំងឺកូវីដ-១៩ កំពុងរីករាលដាលឆ្លងចូលក្នុង «សហគមន៍ ២០ កុម្ភៈ» នេះ ដែលធ្វើឲ្យរាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាលពិបាកក្នុងការគ្រប់គ្រង ដូច្នេះដើម្បីការពារកុំឱ្យកូវីដ-១៩ ឆ្លងចូលក្នុងសហគមន៍សមត្ថកិច្ចការពារខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃយើងនេះ ត្រូវធ្វើការត្រួតពិនិត្យឱ្យមុឹងម៉ាត**

ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយពីព្រោះជំងឺកូវីដ-១៩ ជាជំងឺឆ្លងសលកសម្លាប់មនុស្សហើយណាស់ហើយលើពិភពលោកពុំទាន់រកឃើញថ្នាំព្យាបាលនោះទេដូច្នេះ ត្រូវមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់»។

ក្នុងឱកាសចុះពិនិត្យស្ថានភាព និងពង្រឹងសមត្ថភាពកម្លាំងនគរបាលវរៈសេនាតូចនគរបាលព្រំដែនគោក ៨២៧ និងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកពយ (១៩៩) លោកស្រីបានពាំនាំនូវគ្រឿងឧបភោគ បរិភោគសម្ភារការពារជំងឺឆ្លងកូវីដ-១៩ ថ្នាំពេទ្យ និងថវិកាមួយចំនួនជូនដល់កម្លាំងសមត្ថកិច្ចផងដែរ។ បន្ថែមពីនេះ លោកស្រីបានអំពាវនាវដល់ប្រជាពលរដ្ឋទាំងក្នុងស្រុក និងក្រៅស្រុកទាំងអស់ត្រូវអនុវត្តន៍ តាមការណែនាំផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលឱ្យបានខ្ជាប់ខ្ជួនជានិច្ច ហើយបើបងប្អូនចង់វិលចូលស្រុកកំណើតវិញ សូមអញ្ជើញមកតាមច្រកទ្វារអន្តរជាតិចាំយាម និងសូមកុំគេចវេសឱ្យសោះ ដើម្បីការពារការឆ្លងកូវីដ-១៩ ចូលក្នុងសហគមន៍៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៤៩នាក់ ស្រី ២០នាក់ ក្នុងនោះកុមារនាក់ ១កុមារី ០០នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៥នាក់ ស្រី ៩នាក់ កុមារា ១នាក់ កុមារី ០០នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ២៨នាក់ ស្រី ១០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

5- ច្រកដូង ស្រុកកំរៀង៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់ ពួកគាត់ទាំង ៤៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ២១នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ២៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## កម្ពុជា-ហ្វីលីពីនមេ្តជា រួមគ្នាដោះស្រាយបញ្ហាផ្សេងៗដល់ពលករចំណាកស្រុក នៅក្រៅប្រទេស

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២១ វិទ្យុជាតិកម្ពុជា៖លោក ជួន បូណា

ភ្នំពេញ៖កម្ពុជា-ហ្វីលីពីន រួមគ្នាដោះស្រាយបញ្ហាដល់ពលករចំណាកស្រុកនៃប្រទេសទាំងពីរតាមរយៈការផ្តល់កិច្ចគាំពារផ្លូវច្បាប់ជូនពួកគាត់បានទាន់ពេវេលា។

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលោកជំទាវ ម៉ារៀ អាមេលីតាស៊ី អាគីណូ (MARIA AMELITA C.AQUINO) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋហ្វីលីពីនប្រចាំកម្ពុជា បានជួបពិភាក្សាការងារជាមួយគ្នានាព្រឹកថ្ងៃទី២៥ ខែកុម្ភៈ នៅទីស្តីការក្រសួង ដោយផ្តោតសំខាន់ទៅលើក្របខណ្ឌរបស់ប្រទេសទាំងពីរ ដើម្បីជួយគ្នាទៅវិញទៅមក ក្នុងការជួយដោះស្រាយ និងផ្តល់កិច្ចគាំពារទៅលើបញ្ហាពលរដ្ឋ ក៏ដូចជា ពល

ករទេសន្តរប្រវេសន៍ការងារ ។ ឯកឧត្តម អ៊ិត សំហេង បានបញ្ជាក់ថា តាមរយៈកិច្ចព្រមព្រៀង គឺមានការឯកភាពគ្នាជួយគ្នានៅពេលដែលពលរដ្ឋរបស់ហ្វីលីពីន ឬពលរដ្ឋកម្ពុជា ដែលមានបញ្ហាក្នុងបណ្តាប្រទេសផ្សេងៗ ដែលពុំមានស្ថានទូត និងមិនមានអនុព័ន្ធការងារសម្រាប់ជួយផ្តល់នូវការគាំពារទៅដល់ពួកគាត់ណាមួយ ពលរដ្ឋកម្ពុជាអាចស្វែងរកនូវជំនួយពីស្ថានទូតហ្វីលីពីននៅប្រទេសនោះបាន។

លោកជំទាវឯកអគ្គរដ្ឋទូតបានលើកឡើងថា ហ្វីលីពីន មានស្ថានទូតជាច្រើននៅទូទាំងពិភពលោក និងការិយាល័យអនុព័ន្ធការងារក៏ដូចជាការិយាល័យខាងផ្នែកផ្តល់កិច្ចគាំពារទៅដល់ពលករទេសន្តរ ប្រវេសន៍នៅស្ទើរគ្រប់ប្រទេសទូទាំងពិភពលោក។ ជាមួយគ្នានេះ លោកជំទាវក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលផ្តល់ការការពារ និងគាំពារយ៉ាងល្អដល់ពលរដ្ឋហ្វីលីពីនដែលកំពុងស្នាក់នៅ និងធ្វើការនៅកម្ពុជាប្រមាណជិត ៥០០០នាក់ ដែលពួកគេទទួលបាននូវការការពារសិទ្ធិ និងអត្ថប្រយោជន៍ដូចកម្មករនិយោជិតកម្ពុជាដែរ ជាពិសេសបានទទួលអត្ថប្រយោជន៍ពីសមាជិកភាពរបស់បេឡាជាតិសន្តិសុខសង្គម។ កន្លងទៅថ្មីៗនេះពលរដ្ឋហ្វីលីពីនប្រមាណ៨០០នាក់ ក៏ទទួលបានការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព ក្នុងស្ថានភាពនៃការរីករាតត្បាតនៃជំងឺកូវីដ ១៩។ លោកជំទាវឯកអគ្គរដ្ឋទូត បានប្តេជ្ញាថាក្នុងអាណត្តិការទូតរបស់លោកជំទាវ លោកជំទាវនឹងខិតខំពង្រីកនូវកិច្ចសហប្រតិបត្តិការបន្ថែមទៀត ព្រមទាំងបង្កើតនូវសមិទ្ធផលថ្មីៗជាច្រើនទៀត ដើម្បីផលប្រយោជន៍នៃប្រជាពលរដ្ឋនៃប្រទេសទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារក៏បានថ្លែងអំណរគុណចំពោះភាគីហ្វីលីពីន ដែលបានជួយចែករំលែកបទពិសោធន៍ និងចំណេះដឹងល្អៗដល់កម្ពុជា ក្នុងការរួមចំណែកជួយដល់ ការគាំពារកាន់តែប្រសើរឡើងដល់ពលរដ្ឋកម្ពុជាទាំងនៅក្នុង និងក្រៅប្រទេស។ សូមបញ្ជាក់ថា ប្រទេសកម្ពុជា និងហ្វីលីពិន ក៏មានកិច្ចសហប្រតិបត្តិការមួយទៀតទៅលើវិស័យសន្តិសុខសង្គម តាមរយៈអនុស្សរណៈយោគយល់គ្នាមួយ រវាងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) និងអង្គការធានារ៉ាប់រងសុខភាពរបស់ហ្វីលីពីន (Philhealth) ដែលជាក្របខណ្ឌកិច្ចប្រតិបត្តិការក្នុងការសហការគ្នាចែករំលែកនូវបទពិសោធន៍ ជាពិសេសទៅលើផ្នែកបច្ចេកទេសប្រតិបត្តិការ និងការគ្រប់គ្រងប្រព័ន្ធថវិកា ហិរញ្ញវត្ថុក្នុងការផ្តល់នូវកិច្ចគាំពារដល់កម្មករនិយោជិត៕